# ថ្ងៃទី០២ ខែ តុលា ឆ្នាំ២០២៣

## សម្តេចធិបតី ហ៊ុន ម៉ាណែត ណែនាំដល់ក្រសួងស្ថាប័នជំនាញ យកចិត្តទុកដាក់ខ្ពស់ចំពោះនារីរងគ្រោះ ដែលត្រូវបានជួយសង្គ្រោះ បាននាំបច់ត្រឡប់មកដល់ប្រទេសកម្ពុជា និងបានជួបជុំក្រុមគ្រួសារឪពុកម្តាយញាតិមិត្តរបស់ខ្លួនវិញ

https://www.tvk.gov.kh/?p=35207 *ចេញផ្សាយ ថ្ងៃទី 1 ខែ តុលា ឆ្នាំ 2023*

*(ភ្នំពេញ)៖ ក្រោមកិច្ចសហការដ៏ស្អិតរមួតជាមួយអាជ្ញាធរ នៃរដ្ឋាភិបាលឡាវ, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ បានធ្វើអន្តរាគមន៍ និងបានជួយសង្គ្រោះស្ត្រីខ្មែរ ៦រូប ដែលរងគ្រោះដោយការជួញដូរទៅធ្វើការនៅប្រទេសឡាវ និងកំពុងបន្តការសហការដើម្បីសង្គ្រោះ ១រូបទៀត។*

*សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានណែនាំដល់ ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអាជ្ញាធរពាក់ព័ន្ធ យកចិត្តទុកដាក់ខ្ពស់ ដើម្បីនារីរងគ្រោះ ដែលត្រូវបានជួយសង្គ្រោះ បានធាប់ត្រឡប់មកដល់ប្រទេសកម្ពុជា ដែលជាស្រុកកំណើតរបស់ខ្លួន និងបានជួបជុំក្រុមគ្រួសារឪពុកម្តាយញាតិមិត្តរបស់ខ្លួនវិញ។*

*សូមបញ្ជាក់ថា នៅព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ បានទទួលព័ត៌មានតាមបណ្តាញសង្គមហ្វេសប៊ុក ពាក់ព័ន្ធនឹងករណីស្ត្រីខ្មែរចំនួន ៧ រូប ដែលបានបង្ហោះសារអំពាវនាវតាមបណ្តាញសង្គមហ្វេសប៊ុកស្វែងរកការជួយសង្គ្រោះពួកគេ។ ស្ត្រីទាំង៧រូបនេះ ត្រូវបានជនខិលខូចបោកប្រាស់មកធ្វើការនៅខេត្តបរកែវ នៃប្រទេសឡាវ ហើយបានរត់ចេញពីកន្លែងធ្វើការបន្ទាប់ពីមានបញ្ហាជាមួយថៅកែ ដែលគ្រោងលក់ពួកគាត់ទៅប្រទេសទី៣។ ក្រោយពីបានទទួលពត៌មាននេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឡាវ បានសុំការសហការភ្លាមពីអាជ្ញាធរឡាវ ដើម្បីជួយសង្គ្រោះស្ត្រីខ្មែរទាំង ៧រូបនោះ។*

*ជាមួយគ្នានេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ក៏បានណែនាំឱ្យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំរុញស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវឱ្យផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ ដោយសហការជាមួយសមត្ថកិច្ចឡាវ។ រហូតមកដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ នេះ, នារីខ្មែរ ៦ រូបត្រូវបានជួយសង្គ្រោះ និងកំពុងស្ថិតនៅកន្លែងមានសុវត្ថិភាព និងមានការយកចិត្តទុកដាក់ខ្ពស់។ ដោយឡែក ស្ថានទូតបាន និងកំពុងបន្តសហការជាមួយកម្លាំងសមត្ថកិច្ចឡាវ បន្តខិតខំជួយសង្គ្រោះនារីខ្មែរ ១ រូបទៀត។*

ការជួយសង្គ្រោះនារីខ្មែរទាំង៧រូបនេះ បានបង្ហាញឱ្យឃើញពីចំណាត់ការដ៏រហ័សរហួន និងការយកចិត្តទុកដាក់របស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេចធិបតីនាយករដ្ឋមន្ត្រី ជាពិសេសមន្ត្រីនៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឡាវ និងអាជ្ញាធរពាក់ព័ន្ធ ដែលបានគិតគូរខ្ពស់អំពីសុវត្ថិភាព ទុក្ខលំបាក និងបញ្ហារបស់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង។ មិនថានៅបញ្ហាធំប៉ុណ្ណា លំបាកយ៉ាងណា ឬឆ្ងាយដល់ណានោះឡើយ ឱ្យតែរាជរដ្ឋាភិបាលបានដឹង គឺមិនព្រងើយកន្តើយទុកពលរដ្ឋចោលនោះទេ គឺប្រឹងប្រែងអស់លទ្ធភាព ដើម្បីជួយពួកគេ។

នារីរងគ្រោះទាំង៦រូបដែលបានសង្គ្រោះរួច បានបង្ហាញក្ដីរំភើបរីករាយជាពន់ពេកបានរួចផុតពីការជួញដូរ ជាពិសេសទទួលបានកិច្ចអន្តរាគមន៍យ៉ាងរហ័សពីសម្ដេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី និងអាជ្ញាធរកម្ពុជា។ ពួកគេបានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសម្ដេចធិបតី ហ៊ុន ម៉ាណែត ក៏ដូចជាអាជ្ញាធររបស់កម្ពុជា ក្នុងនោះរួមមានក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងមន្ត្រីនៃស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឡាវដែលបានខិតខំជួយសង្គ្រោះពួកគេឱ្យរួចផុតពីគ្រោះថ្នាក់ និងអាចបានត្រឡប់មកកាន់ប្រទេសកំណើតវិញ៕

## មន្ត្រីប្រឆាំងការជួញដូរមនុស្ស៖
## ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារជាអំពើមិនអាចអត់ឱនឱ្យបាន

https://www.postkhmer.com/national/2023-09-28-1808-254850.html ជា សុខនី | Publication date 28 September 2023 | 18:08 ICT

**ភ្នំពេញ៖** លោកស្រី ហ៊ុន កុសនី អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកណ្ដាលបានលើកឡើងថា ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញលើកុមារ គឺជាសកម្មភាពដែលមិនអាចអត់ឱនបាន ទោះក្នុងរូបភាពណាក៏ដោយ ព្រោះវាប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ សីលធម៌សង្គម សេចក្ដីថ្លៃថ្នូរ និងការអភិវឌ្ឍធនធានមនុស្សនាពេលអនាគតផងដែរ។

ការលើកឡើងរបស់លោកស្រី ហ៊ុន កុសនី ដូចនេះបានធ្វើឡើងនៅក្នុងអំឡុងពេលបើកវគ្គបណ្ដុះបណ្ដាលសេវាគាំទ្រកុមាររងគ្រោះ នៃការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញជូនដល់មន្ត្រីជួរមុខប្រមាណ៩៦នាក់ដែលមកពីមន្ទីរសង្គមកិច្ចខេត្ត ក្រុង និងស្រុកចំនួន៩ ក្នុងខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែកញ្ញា។ វគ្គបណ្ដុះបណ្ដាលនេះសហការរៀបចំដោយអាជ្ញាធរខេត្តកណ្ដាលនិងអង្គការ APLE ដើម្បីផ្ដល់ចំណេះដឹងដល់មន្ត្រីជួរមុខឱ្យយកចំណេះដឹងនេះទៅផ្សព្វផ្សាយជូនកុមារ និងពលរដ្ឋនៅតាមមូលដ្ឋាន។នេះបើតាមរដ្ឋបាលខេត្តកណ្ដាល។

លោកស្រី ហ៊ុន កុសនី ដែលជាអភិបាលរងខេត្តកណ្តាលផងនោះបានលើកឡើងថា ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញលើកុមារគឺជាបញ្ហាសកល ដែលបង្កផលវិបាកធ្ងន់ធ្ងរមិនត្រឹមតែប៉ះពាល់ស្ទើរពេញមួយជីវិតនៃជនរងគ្រោះនោះទេប៉ុន្តែដល់សង្គមជាតិទាំងមូលទៀតផង។ លោកស្រីបញ្ជាក់ថា៖«វគ្គនេះគឺមានសារៈសំខាន់ណាស់ក្នុងការជួយលើកកម្ពស់ការយល់ដឹងបន្ថែមអំពីហានិភ័យ ដែលអាចកើតមានឡើងចំពោះកុមារ ដូចជា ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញជាដើម។ ដូច្នេះហើយសិក្ខាកាមទាំងអស់ត្រូវយកចំណេះដឹង ដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះទៅផ្សព្វផ្សាយបន្តជូនកុមារ គ្រួសារ ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពប្រកបដោយការទទួលខុសត្រូវខ្ពស់»។

លោកស្រី បានបន្ថែមថា ស្ត្រីនិងកុមារនៅតែជាបញ្ហាអាទិភាពដែលក្រុមការងារកិច្ចការពារកុមារខេត្តកណ្តាលត្រូវយកចិត្តទុកដាក់និងគាំទ្រ ថ្វីបើនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះស្ថានភាពកិច្ចការពារកុមារនៅខេត្តនេះមានភាពល្អប្រសើរជាងមុនក៏ដោយ ប៉ុន្តែនៅតែមានកុមារមួយចំនួនប្រឈមនឹងបញ្ហាផ្សេងៗនៅឡើយ។ លោកស្រីបានបន្តថាដើម្បីឆ្លើយតបនិងចូលរួមដោះស្រាយបញ្ហានេះ គឺត្រូវប្តេជ្ញាចិត្តរួមគ្នាខិតខំផ្សព្វផ្សាយលើកកម្ពស់បង្កើនការយល់ដឹង និងបង្ការទប់ស្កាត់និងការឆ្លើយតបលើគ្រប់ទម្រង់ នៃការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញលើកុមារក្នុងខេត្តនេះ។

យោងតាមរបាយការណ៍ថ្មីមួយឈ្មោះថា ការបញ្ឈប់គ្រោះថ្នាក់ក្នុងប្រទេសកម្ពុជា(Disrupting Harm in Cambodia)ដែលចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២កន្លងមក បានរកឃើញថា ១៦ភាគរយនៃកុមារ ត្រូវបានទទួលរងការបញ្ចេញមតិទាក់ទងនឹងផ្លូវភេទរបស់ពួកគេ ដែលកើតឡើងជាចម្បងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម(Social Media)១៦ភាគរយទៀតនៃកុមារត្រូវបានផ្ញើសាររូបភាពផ្លូវភេទ និង៩ភាគរយនៃកុមារទទួលបានការស្នើសុំចែករំលែករូបភាពផ្លូវភេទរបស់កុមារទាំងនោះ។

ដោយឡែកនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំនេះ អាជ្ញាធរខេត្តកណ្តាលបានបន្តចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថានជូនដល់ប្រជាពលរដ្ឋនិងសិស្សានុសិស្សជាង៣០០នាក់ នៅឃុំព្រែកថ្មី ស្រុកកោះធំផងដែរ៕

# ឃាត់ខ្លួនបុរសជនជាតិស្វីសម្នាក់
# ករណីបៀតបៀនផ្លូវភេទ និងផលិតវីដេអូអាសអាភាសលើកុមារ

https://www.kampucheathmey.com/security/587990 ថ្ងៃសុក្រ ២៩ កញ្ញា ២០២៣ ដោយ Sokhom Khon

*បុរសជាជនជាតិស្វីសម្នាក់ ត្រូវបានកម្លាំងក្រុមការងារចម្រុះ FOXTROT23 ដែលបង្កើតឡើងដោយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ នាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងអង្គភាពការពារកុមារ (CPU) ធ្វើការឃាត់ខ្លួនក្នុងករណីបៀតបៀនផ្លូវភេទលើកុមារ និងផលិតវីដេអូអាសអាភាសនៅរាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការឃាត់នេះ បានធ្វើឡើងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣នេះ ដោយបានសង្គ្រោះកុមារចំនួន៣នាក់ពីស្ថានភាពគ្រោះថ្នាក់ បន្ទាប់ពីមានការឃ្លាំមើល និងស៊ើបអង្កេតអស់រយៈពេល២ខែ។*

*បើតាមក្រុមការងារចម្រុះ FOXTROT23 ករណីនេះ គឺស្ថិតក្នុងចំណោមករណីដែលធំបំផុតសម្រាប់អង្គភាពការពារកុមារ (CPU) ក្នុងរយៈពេល១០ឆ្នាំនៃកិច្ចប្រតិបត្តិការ។ កាលពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកញ្ញា កម្លាំងជំនាញបានអនុវត្តដីកាឆែកឆេរទីលំនៅផ្សេងគ្នាមួយចំនួន និងបានរកឃើញនូវភស្តុតាងជាច្រើនរួមមាន ទូរស័ព្ទដៃ កាមេរ៉ា កុំព្យូទ័រយួរដៃ ភ្លើងបញ្ចាំងផុនធូន់ ទឹករំអិល និងសារធាតុបំប៉នកម្លាំង។*

*លោក James McCabe នាយកប្រតិបត្តិអង្គភាពការពារកុមារ (CPU) បានលើកឡើងថា ភស្តុតាងដែលត្រូវបានរកឃើញ គឺគួរអោយបារម្ភ ហើយបង្ហាញថាជនសង្ស័យមានការពាក់ព័ន្ធនឹងសកម្មភាពថត ផលិតរូបភាព និងវីឌីអូអាសអាភាសលើកុមារ។ អំពើផលិត និងចែកចាយរូបភាព និងវីឌីអូអាសអាភាសលើកុមារ គឺជាបទល្មើសមួយដ៏គួរអោយស្អប់ខ្ពើម និងមានផលប៉ះពាល់យ៉ាងខ្លាំងទូទាំងពិភពលោក និងក្នុងតំបន់។ លោក James McCabe បន្ថែមថា ក្នុងរយៈពេល១០ឆ្នាំនៃកិច្ចប្រតិបត្តិការ នេះគឺជាលើកទី១ដែលអង្គភាពការពារកុមារ (CPU) ជួបប្រទះជាមួយការរៀបចំដោយមានជំនាញបែបនេះពីជនសង្ស័យ។ ហើយការស៊ើបអង្កេតនេះ នឹងបន្តរហូតដល់ដំណាក់កាលដែលយើងបានកំណត់មុខសញ្ញាបុគ្គលដែលពាក់ព័ន្ធគ្រប់ទាំងអស់។*

*ក្រុមការងារចម្រុះកំពុងតែប្រើប្រាស់ជំនាញ និងសេវាកម្មបន្ថែមរបស់ស្ថាប័នអនុវត្តច្បាប់អន្តរជាតិ ដែលជាដៃគូ ហើយយើងនឹងមិនឈប់តាមដានឡើយ រហូតដល់បុគ្គលពាក់ព័ន្ធគ្រប់គ្នាត្រូវបានកំណត់អត្តសញ្ញាណ មិនថាគេកំពុងនៅក្នុងប្រទេសណាឡើយ៕*

# ស្ត្រីថៃជាប់ពាក់ព័ន្ធនឹងករណីឆបោកដ៏គួរឱ្យរន្ធត់ត្រូវចាប់ខ្លួននៅព្រំដែនកម្ពុជា

https://www.khmertimeskh.com/501368811// Khmer Times September 29, 2023

ស្ត្រីអាយុ២២ឆ្នាំម្នាក់ត្រូវបានចាប់ខ្លួននៅច្រកទ្វារអន្តោប្រវេសន៍អារញ្ញប្រាថេត ក្នុងខេត្តស្រះកែវ ខណៈត្រឡប់មកពីប្រទេសកម្ពុជាវិញ ពាក់ព័ន្ធនឹងករណីឆបោកដ៏សាហាវ។ ការចាប់ខ្លួននេះធ្វើឡើងនៅថ្ងៃទី២៧ ខែកញ្ញា ភ្លាមៗបន្ទាប់ពីស្ត្រីឈ្មោះ Jirapinya Naeyued បានឆ្លងព្រំដែនតាមច្រកបានខ្លងលូក (Ban Khlong Luk) ពីក្រុងប៉ោយប៉ែតក្នុងប្រទេសកម្ពុជា។ ស្ត្រីរូបនេះត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ពីបទឃុបឃិតគ្នា ក្នុងការក្លែងបន្លំបញ្ចូលព័ត៌មានមិនត្រឹមត្រូវទៅក្នុងប្រព័ន្ធកុំព្យូទ័របណ្តាលឱ្យខូចខាត និងចូលរួមក្នុងសកម្មភាពឧក្រិដ្ឋកម្មអន្តរជាតិ។ ការចោទប្រកាន់នេះបានធ្វើឡើងបន្ទាប់ពីស្ត្រីនោះជាប់ពាក់ព័ន្ធជាមួយក្រុមឆបោកដែលនាំឱ្យមានសោកនាដកម្មមួយនៅខេត្តសាមុតប្រាកាន។ ការចាប់ខ្លួននេះ ធ្វើឡើងតាមព័ត៌មានអំពីជនសង្ស័យម្នាក់ ពាក់ព័ន្ធនឹងក្រុមឆបោកដែលធ្វើសកម្មភាពក្នុងក្រុងប៉ោយប៉ែត ត្រឡប់មកប្រទេសថៃវិញ តាមច្រកទ្វារបានខ្លងលូក។

ក្រុមឆបោក មានជាប់ពាក់ព័ន្ធជាមួយនឹងហេតុការណ៍ក្នុងគ្រួសារដ៏រន្ធត់មួយនៅខេត្តសាមុតប្រាកាន ដែលបុរសម្នាក់បានសម្លាប់ប្រពន្ធនិងកូនប្រុសពីរនាក់នៅក្នុងផ្ទះរបស់ពួកគេក្នុងសង្កាត់បាងភ្លី (Bang Phli) កាលពីថ្ងៃទី២៨ ខែសីហា។ បុរសរូបនេះបានធ្លាក់ក្នុងភាពអស់សង្ឃឹមបន្ទាប់ពីប្រពន្ធរបស់ខ្លួនបានធ្លាក់ខ្លួនជាជនរងគ្រោះ ដោយការឆបោករបស់ក្រុមឆបោកនោះ ហើយបានជំពាក់បំណុលគេយ៉ាងសន្ធឹកសន្ធាប់ដែលនាំឱ្យបុរសនោះព្យាយាមបញ្ចប់ជីវិតតែមិនបានជោគជ័យ។ ក្នុងពេលសាកសួរចម្លើយ Jirapinya បានសារភាពថាជាមនុស្សដែលមានឈ្មោះក្នុងដីកាចាប់ខ្លួន។ នាងត្រូវបានមន្ត្រីអន្តោប្រវេសន៍ឃាត់ខ្លួនដំបូងមុននឹងត្រូវបញ្ជូនទៅនគរបាលបាងកែវ (Bang Kaeo) ក្នុងខេត្តសាមុតប្រាកាន ដើម្បីចាត់ការបន្តតាមផ្លូវច្បាប់។

ការចាប់ខ្លួនស្ត្រីរូបនេះ មិនមែនជាករណីដាច់ដោយឡែកឡើយ។ កាលពីថ្ងៃទី២៩ ខែសីហា ស្ត្រីម្នាក់ទៀតដែលបានបើកគណនីធនាគារសម្រាប់ក្រុមឆបោកដូចគ្នាត្រូវបានចាប់ខ្លួននៅពេលនាងត្រឡប់មកប្រទេសថៃពីប្រទេសកម្ពុជាតាមច្រកព្រំដែនក្នុងខេត្តស្រះកែវ ដែលនាំទៅដល់ការស្វែងរកស៊ើបអង្កេតបន្ថែមទៀតនៅតាមបណ្តោយព្រំដែនរវាងប្រទេសទាំងពីរ នេះបើតាមសេចក្តីរាយការណ៍របស់កាសែតបាងកកប៉ុស្តិ៍។

ជាងនេះទៅទៀត កាលពីដើមខែនេះ ជនជាតិថៃ៤នាក់ ក្នុងនោះស្រី៣នាក់ ត្រូវបានចាប់ខ្លួននៅក្រុងប៉ោយប៉ែត។ ពួកគេត្រូវបានគេចោទថាជាប់ពាក់ព័ន្ធនឹងការហៅទូរស័ព្ទឆបោកដែលនាំឱ្យមានសោកនាដកម្មគ្រួសារដូចខាងលើនៅខេត្តសាមុតប្រាកាន។ ការចាប់ខ្លួនជាបន្តបន្ទាប់ទាំងនេះ

បង្ហាញពីការស៊ើបអង្កេតដែលកំពុងបន្ត និងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងក្រុមឆបោក ដែលពាក់ព័ន្ធនឹងហេតុការណ៍គ្រួសារដ៏គួរឱ្យរន្ធត់នៅខេត្តសាមុតប្រាកាន។ Thaiger

## មីយ៉ាន់ម៉ា ខឹង ចិន
## ដែលផលិតរឿង "No More Bets" បង្កើតឧក្រិដ្ឋកម្មបង្ខូចកេរ្តិ៍ឈ្មោះប្រទេសខ្លួន

https://www.kampucheathmey.com/global-news/588502 ថ្ងៃសៅរ៍ ៣០ កញ្ញា ២០២៣ Blue Sky

ប្រព័ន្ធផ្សព្វផ្សាយរដ្ឋបានរាយការណ៍កាលពីថ្ងៃសុក្រថា យោធារបស់មីយ៉ាន់ម៉ា បានរិះគន់សម្ព័ន្ធមិត្តជិតស្និទ្ធចិន ជុំវិញខ្សែភាពយន្ត ដែលផលិតឡើងលើការជួញដូរមនុស្ស និងសមាសធាតុឆបោក ដែលធ្វើឲ្យខូចកេរ្តិ៍ឈ្មោះរបស់ប្រទេសខ្លួនយ៉ាងខ្លាំងក្លា។ ភាពយន្តចិនរឿង "No More Bets" ប្រាប់ពីរឿងរ៉ាវរបស់អ្នកសរសេរកម្មវិធីកុំព្យូទ័រម្នាក់ ដែលត្រូវបានជួញដូរទៅប្រទេសអាស៊ីអាគ្នេយ៍ ដែលមិនបញ្ចេញឈ្មោះហើយត្រូវបានបង្ខំឲ្យធ្វើការជាអ្នកបោកប្រាស់តាមអ៊ីនធឺណិតសម្រាប់ក្រុម។ ត្បិតថាភាពយន្តមួយនេះ មិនបាននិយាយពីឈ្មោះមីយ៉ាន់ម៉ាក្តី ប៉ុន្តែការកំណត់របស់វាស្រដៀងទៅនឹងតំបន់ភាគខាងជើងដែលគ្មានច្បាប់របស់ប្រទេសនេះ ដែលក្រុងប៉េកាំងនិយាយថា ពលរដ្ឋរបស់ខ្លួនត្រូវបានគេបោកបញ្ឆោត ឬជួញដូរជាប្រចាំ និងបង្ខំឲ្យធ្វើការបោកប្រាស់ជនរួមជាតិតាមអ៊ីនធឺណិត។ ទោះយ៉ាងណាក៏ដោយ ការបោកប្រាស់បានធ្វើឲ្យទីក្រុងប៉េកាំងខឹងសម្បារ ដែលជាសម្ព័ន្ធមិត្តដ៏សំខាន់និងជាអ្នកផ្គត់ផ្គង់អាវុធសម្រាប់របបយោធាឯកោអន្តរជាតិ។

បើយោងតាមកាសែតរដ្ឋ Global New Light of Myanmar បានបញ្ជាក់ឲ្យដឹងថា អគ្គកុងស៊ុលរបស់យោធានៅទីក្រុងណាននីង ភាគនិរតីនៃប្រទេសចិនបានលើកឡើងពីការធ្វើឲ្យខូចមុខមាត់របស់មីយ៉ាន់ម៉ានៅក្នុងខ្សែភាពយន្ត ដែលត្រូវបានថតដោយចិន និងចេញផ្សាយនៅក្នុងប្រទេសព្រមទាំងជុំវិញពិភពលោកផងដែរ។ លោកបានប្រាប់មន្ត្រីរដ្ឋាភិបាលក្នុងតំបន់ Guangxi កាលពីដើមសប្តាហ៍នេះថា "ដំណើររឿងទាក់ទងនឹងមីយ៉ាន់ម៉ា អមដោយរបាយការណ៍ដែលថា ជនជាតិចិនមានការព្រួយបារម្ភអំពីការធ្វើដំណើរទៅកាន់ប្រទេសមីយ៉ាន់ម៉ា ក្រោយទស្សនាភាពយន្ត "No More Bets" ។

ទោះបីជាទើបតែចេញក្នុងខែសីហាក៏ដោយ "No More Bets" បានក្លាយជាភាពយន្តដែលពេញនិយមបំផុតទី ៣នៅក្នុងប្រទេសចិនក្នុងឆ្នាំនេះ ដោយទទួលបានប្រាក់ ៣.៨ពាន់លានយន់ (៥២១ លានដុល្លារ) និងការពិភាក្សាតាមអ៊ិនធរណេតដ៏ច្រើនបំផុតអំពីគ្រោះថ្នាក់នៃការមកទស្សនាអាស៊ីអាគ្នេយ៍។ ស្របពេលដែល ភាពយន្តនេះមិនត្រូវបានដាក់បញ្ចាំងនៅក្នុងរោងកុនមីយ៉ាន់ម៉ាទេ។ ទន្ទឹមនោះទៀតសោត មួយខែមុនពេលការចេញផ្សាយខ្សែភាពយន្តនេះ ប្រទេសចិនបានប្រាប់

យោធាមីយ៉ាន់ម៉ាឲ្យកម្ចាត់ចោលមជ្ឈមណ្ឌលបោកប្រាស់តាមអ៊ីនធឺណិតនៅតាមព្រំដែន ដែលគ្មានច្បាប់របស់ខ្លួន ដែលកំណត់គោលដៅពលរដ្ឋចិន។

## ស្ថាប័នពាក់ព័ន្ធ
## បន្តសកម្មភាពផ្សព្វផ្សាយពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅខេត្តបាត់ដំបង

https://www.postkhmer.com/national/2023-09-30-0806-254889.html សុខ រក្សា | Publication date 30 September 2023 | 15:06 ICT

ស្ថាប័នពាក់ព័ន្ធ បន្តសកម្មភាពផ្សព្វផ្សាយពីការចំណាកស្រុក ប្រកបដោយសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងខេត្តបាត់ដំបង ដើម្បីលើកកម្ពស់ការយល់ដឹងដល់ពលរដ្ឋ និងចូលរួមទប់ស្កាត់ការជួញដូរកម្លាំងមនុស្សដោយខុសច្បាប់។

កាកបាទក្រហមកម្ពុជា បានឱ្យដឹងថា ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣នេះ មន្ត្រីការិយាល័យអប់រំមីន និងស្តារទំនាក់ទំនង បានអមដំណើរ ប្រតិភូគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (អាយ.ស៊ី.អរ.ស៊ី)ប្រចាំទីក្រុងភ្នំពេញ និងប្រតិភូអាយ (អាយ.ស៊ី.អរ.ស៊ី) ប្រចាំទីក្រុងហាណូយ ចុះពិនិត្យការងារផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការជួញដូរមនុស្ស នៅស្រុកកំរៀង និងសេវាកម្មស្តារទំនាក់ទំនងគ្រួសារ នៅមូលដ្ឋានខេត្តបាត់ដំបង។ ទន្ទឹមនឹងនោះដែរ ប្រតិភូ អាយ.ស៊ី.អរ.ស៊ី ប្រចាំទីក្រុងភ្នំពេញ និងទីក្រុងហាណូយ បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការងារអប់រំផ្សព្វផ្សាយពីចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការងារស្តារទំនាក់ទំនងគ្រួសារ របស់មន្ត្រីស្តារទំនាក់ទំនងគ្រួសារ ដែលធ្វើបានយ៉ាងល្អប្រសើរ ដោយសង្កេតឃើញថាប្រជាពលរដ្ឋមានការយល់ដឹងខ្ពស់ពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

ជាមួយគ្នានោះដែរ ប្រតិភូ អាយ.ស៊ី.អរ.ស៊ី និងក្រុមការងារបានចុះពិនិត្យការចែកលិខិតដំណឹងគ្រួសាររបស់មន្ត្រីស្តារទំនាក់ទំនងគ្រួសារប្រចាំសាខាកាកបាទក្រហមកម្ពុជា ខេត្តបាត់ដំបង នៅតាមខ្នងផ្ទះដោយផ្ទាល់ និងបានវាយតម្លៃខ្ពស់ចំពោះការសហការរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅក្នុងមូលដ្ឋាន ដែលបានជួយសម្រួលការងាររហូតទទួលបានជោគជ័យ។ ក្នុងឱកាសនោះដែរ ប្រតិភូ អាយ.ស៊ី.អរ.ស៊ី បានពិនិត្យឃើញថា លិខិតដំណឹងគ្រួសាររបស់កាកបាទក្រហមកម្ពុជា ពិតជាមានសារៈសំខាន់ក្នុងការជួយផ្តល់ដំណឹងរវាងក្រុមគ្រួសារ និងជនជាប់ឃុំ។

ប្រភពខាងលើបញ្ជាក់ថា៖ «ជាក់ស្តែង ក្នុងនោះមានមួយករណី ដែលគ្រួសារបានបាត់ដំណឹងបងប្រុស អស់រយៈពេល ១០ ឆ្នាំ ស្មានតែបងប្រុសបានទទួលមរណភាពទៅហើយ មិននឹកស្មានថាបងប្រុសជាប់នៅពន្ធនាគារនោះទេ ។ ពេលដែលបានទទួលដំណឹងនេះក្រុមគ្រួសាររបស់គាត់ពិតជា

សប្បាយចិត្តជាខ្លាំង និងបានថ្លែងអំណរគុណចំពោះកាកបាទក្រហមកម្ពុជា ដែលបានផ្តល់ដំណឹងអំពីបងប្រុសរបស់គាត់ ដែលបាត់ដំណឹងអស់ជាច្រើនឆ្នាំ តាមរយៈលិខិតដំណឹងគ្រួសារកាកបាទក្រហមកម្ពុជា»។

គួសបញ្ជាក់បន្ថែមថា ការចុះពិនិត្យសកម្មភាពការងាររបស់មន្ត្រីនៅតាមសាខា គឺជាសកម្មភាពមួយដែលមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីជួយពង្រឹងការអនុវត្តសកម្មភាពការងារឱ្យកាន់តែល្អប្រសើរ និងទទួលបានលទ្ធផលតាមផែនការរំពឹងទុក។ លើសពីនេះទៀត ប្រតិភូ អាយ.ស៊ី.អរ.ស៊ី ប្រចាំទីក្រុងហាណូយ បានទទួលនូវសារគន្លឹះសំខាន់ៗពីកាកបាទក្រហមកម្ពុជា សម្រាប់យកទៅអនុវត្តសកម្មភាពស្តារទំនាក់ទំនងគ្រួសារនៅក្នុងប្រទេសវៀតណាម ឱ្យសម្រេចបានលទ្ធផលដូចកាកបាទក្រហមកម្ពុជា ធ្វើកន្លងមកផងដែរ។

# ថ្ងៃទី០៣ ខែ តុលា ឆ្នាំ២០២៣

## ជួញដូរមនុស្សនៅឡាវ៖ នារីរងគ្រោះ៦នាក់ត្រូវបានសង្គ្រោះត្រៀមបញ្ជូនមកកម្ពុជាវិញ

https://www.rfi.fr/km//20231002utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 02/10/2023 - 08:26 ដោយ៖អោ ស្រីពេជ្រ

កាលពីថ្ងៃសៅរ៍កន្លងទៅនេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ បានឱ្យដំណឹងអំពីករណីនារីខ្មែរ៧នាក់ ត្រូវបានជនខិលខូចបោកប្រាស់ទៅធ្វើការនៅតំបន់ត្រីកោណមាសប្រទេសឡាវ ហើយដែលត្រៀមលក់បន្តទៅប្រទេសទី៣។ បច្ចុប្បន្ននេះ នារីរងគ្រោះ៦នាក់ត្រូវបានជួយសង្គ្រោះនិងត្រៀមបញ្ជូនមកកម្ពុជាវិញ ខណៈ១នាក់ទៀត នៅមិនទាន់អាចរត់គេចចេញបាន។

ក្នុងទំព័រហ្វេសបុក ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ កាលពីថ្ងៃទី៣០ខែកញ្ញាកន្លងទៅ បានឱ្យដំណឹងអំពីករណីនារីខ្មែរ៧នាក់ ត្រូវបានជនខិលខូចបោកប្រាស់ទៅធ្វើការនៅខេត្តបូរកែវ តំបន់ត្រីកោណមាស ប្រទេសឡាវ ហើយដែលត្រៀមលក់បន្តទៅប្រទេសទី៣ បន្ទាប់ពីមានបញ្ហាជាមួយថៅកែ។ ដំណឹងនៃការជួញដូរមនុស្សឆ្លងដែននេះត្រូវបានស្ថានទូតកម្ពុជាដឹងតាមរយៈការបង្ហោះស្នើសុំជំនួយពីជនរងគ្រោះ នៅតាមបណ្តាញសង្គមហ្វេសបុករបស់ពួកគេ។ បន្ទាប់ពីអាចរត់គេចចេញពីកន្លែងធ្វើការបានដោយជោគជ័យ ជនរងគ្រោះ៦នាក់ ក្នុងចំណោម ៧នាក់ កំពុងត្រៀមបញ្ជូនមកកម្ពុជាវិញ ដោយមានការជួយសង្គ្រោះពីកងកម្លាំងប៉ូលីសឡាវ តាមរយៈការសម្របសម្រួលរបស់ស្ថានទូត។ ដោយឡែក ជនរងគ្រោះ១នាក់ទៀត ដែលនៅមិន

ទាន់អាចរត់គេចចេញបាន ដោយយកត្លាសុខភាព ស្ថានទូតកម្ពុជានិងអាជ្ញាធរឡាវនឹងបន្តជួយសង្គ្រោះ បញ្ជូនមកកម្ពុជាដូចគ្នាដែរ នៅពេលឆាប់ៗខាងមុខនេះ។ នេះបើតាមការបញ្ជាក់របស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ។

ទាក់ទងនឹងរឿងនេះដែរ ប្រធានរាជបណ្ឌិតសភាកម្ពុជា លោកបណ្ឌិត សុខ ទូច មើលឃើញថា ការបង្ហោះផ្សព្វផ្សាយតាមបណ្ដាញសង្គម របស់ស្ថាប័នពាក់ព័ន្ធ ជុំវិញការជួញដូរមនុស្ស តួយ៉ាងរឿងរ៉ាវ នៃការជួញដូរមនុស្សឆ្លងដែននៅឡាវនេះ នឹងអាចប៉ះពាល់ដល់ទេសចរណ៍កម្ពុជា។ ប៉ះពាល់ក៏ព្រោះថា រូបភាពអវិជ្ជមាននៅក្នុងបណ្ដាញសង្គមបែបនេះនឹងអាចត្រូវបានជនអគតិ យកទៅបំពុលពិភពលោក ធ្វើឱ្យគេលែងហ៊ានមកទស្សនាកម្ពុជាទៀត។ ជាយោបល់ លោកបណ្ឌិត សុខ ទូច យល់ថាហេតុការណ៍នេះគួរត្រូវដោះស្រាយនិងចាត់វិធានការពីក្រោយឆាក ដែលអាចមានប្រសិទ្ធភាពជាង។

## ចាប់ខ្លួនបុរសស្វីសម្នាក់ ខណៈកុមារ ៣ នាក់ ត្រូវបានសង្គ្រោះពីរំលោភបំពានផ្លូវភេទ

https://www.postkhmer.com/national/2023-10-02-1646-254930.html ហុង រស្មី। Publication date 02 October 2023 | 16:46 ICT

**ភ្នំពេញ**: បុរសជនជាតិស្វីសម្នាក់ត្រូវបានចាប់ខ្លួន ខណៈ កុមារ ៣ នាក់ ត្រូវបានជួយសង្គ្រោះក្នុងប្រតិបត្តិការ Task Force FOXTROT23 ដែលជាកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននិង អង្គភាពការពារកុមារ(CPU)បន្ទាប់ពីស៊ើបអង្កេតអស់ពេល៣ខែលើការរំលោភបំពានផ្លូវភេទកុមារនិងការផលិតរូបភាពអាសអាភាសកុមារនៅភ្នំពេញ។ ប្រតិបត្តិការនេះ ដើម្បីស៊ើបអង្កេតលើការចោទប្រកាន់ពីបទរំលោភបំពានផ្លូវភេទលើកុមារ និងការផលិតរូបភាពអាសអាភាសកុមារ គឺជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់បំផុតមួយរបស់ CPU ក្នុងប្រវត្តិសាស្ត្ររយៈពេល១ទសវត្សរ៍ ដែលជាការរួមចំណែកដល់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរលើកុមារនៅកម្ពុជា និងអាស៊ីអាគ្នេយ៍។ នៅចន្លោះថ្ងៃទី២៦ និងថ្ងៃទី ២៨ ខែកញ្ញា អ្នកស៊ើបអង្កេតបានអនុវត្តដីកាស្វែងរកនៅទីតាំងជាច្រើន ដោយបង្ហាញភស្តុតាងដ៏គួរឱ្យព្រួយបារម្ភរួមមាន ទូរស័ព្ទ កាមេរ៉ា កុំព្យូទ័រយួរដៃ ស្នូឱយោថត សារធាតុរំអិល និងថ្នាំបង្កើនប្រសិទ្ធភាពផ្លូវភេទជាដើម។

លោក James McCabe នាយក CPU បានថ្លែងថា ករណីនេះជា«ទង្វើដ៏រំខានបំផុត» និងបង្ហាញអំពីបុគ្គលដែលពាក់ព័ន្ធក្នុងការថត និងផលិតរឿងអាសអាភាសកុមារ ជាឧក្រិដ្ឋកម្មដែលមានផលវិបាកជាសកល និងក្នុងតំបន់។ លោក McCabe បានឱ្យដឹងថា៖ «ក្នុងរយៈពេល១០ឆ្នាំ នេះជាលើកដំបូងដែល CPU បានជួបប្រទះការរៀបចំប្រកបដោយវិជ្ជាជីវៈបែបនេះ។ ពិតជាគួរឱ្យកោត

សរសើរដល់នគរបាលជាតិកម្ពុជា ដែលពួកគេបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មបែបនេះ និងជួយសង្គ្រោះកុមារ»។

លោកបានថ្លែងអំណរគុណចំពោះអគ្គស្នងការនគរបាលជាតិលោក ស ថេត អគ្គស្នងការរងនគរបាលជាតិ លោក ជី ប៉ូលី និងស្នងការរាជធានីភ្នំពេញ លោក ជួន ណារិទ្ធ ដែលបានណែនាំ និងដឹកនាំការងារស៊ើបអង្កេត។ ការស៊ើបអង្កេតដែលកំពុងបន្តនេះមានការចូលរួមរបស់ប៉ូលិសសហព័ន្ធស៊ីសដែលកំពុងសហការជាមួយ Task Force FOXTROT23។ លោក James McCabe បានបន្តថា៖ « ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ថា ការស៊ើបអង្កេតនេះកំពុងបន្ត ហើយអ្នកពាក់ព័ន្ធទាំងអស់នឹងត្រូវកំណត់អត្តសញ្ញាណ។ Task Force សហការជាមួយប៉ូលិសអន្តរជាតិ ដែលនឹងមិនបញ្ឈប់ឡើយ រហូតទាល់តែមនុស្សទាំងអស់ដែលពាក់ព័ន្ធមិនថាពួកគេស្ថិតនៅក្នុងប្រទេសណានោះទេត្រូវបានកំណត់អត្តសញ្ញាណ»។

ក្នុងរយៈពេល១ទសវត្សរ៍កន្លងមក ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៣ អង្គភាព CPU ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ដែលនេះរួមបញ្ចូលទាំងការដោះស្រាយបញ្ហារំលោភបំពានលើកុមារ ២៦៩ករណីក្នុងឆ្នាំ២០២៣ ដែលកើនឡើងពី២៤២ករណី ក្នុងឆ្នាំ២០២២ នៅទូទាំង២៥ ខេត្ត-ក្រុង និងរាជធានី។ អង្គភាពនេះក៏បានរួមចំណែកយ៉ាងសំខាន់ ចំពោះការជំរុញឱ្យមានអត្រាការផ្តន្ទាទោសលើករណីជាប់ពាក់ព័ន្ធនឹងកុមារ ៦ដងផងដែរ ។ ក្នុងអំឡុងពេលនេះ CPU បានស៊ើបអង្កេតលើករណីឃាតកម្មលើអនីតិជនជាង៣០០ករណី ហើយបានបើកការស៊ើបអង្កេតចំនួន១១៨ករណីទៅលើការគំរាមកំហែងតាមអ៊ីនធឺណិត ដូចជា ការមើលកូនកំលោះ និងការចែកចាយរូបភាពអាសអាភាសរបស់កុមារ។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេបាននាំឱ្យមានការចាប់ខ្លួនចំនួន១ ៩៩៨ នាក់ ដែលបណ្តាលឱ្យមានការកាត់ទោសជាប់ពន្ធនាគារសរុបចំនួន ៥ ៨៩៦នាក់ ដែលរាប់បញ្ចូលទាំងទោស១ជីវិត ២០ករណី។

លើសពីនេះទៅទៀត CPU បានផ្តល់ការគាំទ្រដល់សមាជិកគ្រួសារជាង១ម៉ឺននាក់ និងជួយលើផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះចំនួន១ ១០១នាក់ ដោយបញ្ជាក់ពីការប្តេជ្ញាចិត្តឥតងាករេរបស់ពួកគេចំពោះយុត្តិធម៌ និងសុខុមាលភាពរបស់ជនរងគ្រោះ ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេ។ ខណៈការស៊ើបអង្កេតកំពុងបន្តកំណត់មុខសញ្ញានៃបទល្មើសដែលបានរកឃើញនៅក្នុងរាជធានីភ្នំពេញ ពិភពលោកកំពុងឃ្លាំមើលដោយរំពឹងថា Task Force FOXTROT23 និងអង្គភាពការពារកុមារ(CPU) នៅតែប្តេជ្ញាការពារកុមារ និងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ៕

**អភិបាលរងខេត្តព្រះវិហារ**
**អំពាវនាវឱ្យរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស និងប្រយុទ្ធប្រឆាំងរាល់ទំរង់**
**នៃអំពើការជួញដូរមនុស្សដើម្បីការពារ និងលើកកម្ពស់សិទ្ធិសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ**

https://m.freshnewsasia.com/index.php/en/localnews/312441-2023-10-02-10-23-59.html 2023-10-02 05:23pm

*(ព្រះវិហារ)៖ លោកស្រី ប៉ាង រ៉ាវី អភិបាលរងខេត្តព្រះវិហារ និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានអំពាវនាវឱ្យរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសំរេចគោលដៅ អភិវឌ្ឍជាតិ ប្រកបដោយចីរភាព យើងរួមគ្នាប្រយុទ្ធប្រឆាំងរាល់ទំរង់នៃអំពើការជួញដូរមនុស្ស ដើម្បីការពារ និងលើកកម្ពស់សិទ្ធិសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។*

*ការថ្លែងរបស់លោកស្រី ប៉ាង រ៉ាវី ក្នុងឱកាសដែលលោកស្រី តំណាងលោក គីម រិទ្ធី អភិបាលខេត្តព្រះវិហារ ចូលរួមផ្សព្វផ្សាយស្តីពីវិធានការទប់ស្កាត់អំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយ សុវត្ថិភាព នៅស្រុកគូលេន នៅព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ ដោយមានការចូលរួមពីអាជ្ញាធរស្រុក មន្ត្រីរាជការ កងកម្លាំងទាំង៣ លោកមេឃុំ មេភូមិ ជាច្រើនរូបទៀត។*

*នាឱកាសនោះ លោកស្រី ប៉ាង រ៉ាវី បានថ្លែងអំណរគុណក្រុមការងារលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ ចូលរួមគាំទ្រដល់សកម្មភាពការងារជួញដូរមនុស្ស យកស្មារតីទទួលខុសត្រូវខ្ពស់ចំពោះតួនាទី ភារកិច្ច របស់ខ្លួនដែលថ្នាក់ដឹកនាំបានប្រគល់ជូន ហើយក៏សូមបន្តរក្សាភាពថ្លៃថ្នូរក្នុងនាមជាមន្ត្រីរាជការ ជាអ្នកដឹកនិងការអនុវត្តការងារមានភាពទទួលខុសត្រូវខ្ពស់ ដើម្បីទទួលបានលទ្ធផលល្អនិងមានប្រសិទ្ធភាពខ្ពស់ ។*

*លោកស្រីអភិបាលរងខេត្ត ក៏បានថ្លែងណែនាំដល់ក្រុមការងារលេខាធិការដ្ឋានរបស់យើងទាំងអស់ ជាពិសេសក្រុមដែលទទួលបន្ទុកវិស័យអប់រំ ទេសចរណ៍ បន្តធ្វើយ៉ាងណាជំរុញដល់គ្រឹះស្ថានសិក្សាដើម្បីបញ្ជ្រាបការអប់រំ ផ្សព្វផ្សាយ ឱ្យបានទូលំទូលាយដល់ក្មួយៗសិស្សានុសិស្សតាមគ្រឹះស្ថាននានា តាមសាលារៀន ដើម្បីឱ្យពួកគាត់យល់ច្បាស់អំពីកលល្បិចជនខិលខូចដែលតែងតែឃោសនា អូសទាញ តាមគ្រប់ទំរង់រូបភាពលួងលោមឱ្យក្មួយៗ បងប្អូនប្រជាពលរដ្ឋដែលស្វែងរកការងារធ្វើក្នុងប្រទេសនិក្រៅប្រទេសទាំងប្រថុយប្រថានផងដែរ។*

*លោកស្រី ប៉ាង រ៉ាវី ក៏បានថ្លែងណែនាំដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តជម្រុញនិងពង្រឹងអប់រំផ្សព្វផ្សាយណែនាំ ដល់បងប្អូនប្រជាពលរដ្ឋឱ្យពួកគាត់យល់ច្បាស់ពីមុខរបរការងារដែលពួកគាត់ ចង់ធ្វើ។ ជាពិសេសផ្សព្វផ្សាយនូវគោល នយោបាយភូមិ ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ដើម្បីធ្វើយ៉ាងណាធ្វើឱ្យ ភូមិ ឃុំ របស់យើងមានសុវត្ថិភាពផងដែរ។បន្តពង្រឹងសកម្មភាពការងារ*

ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ពីគ្រប់មជ្ឈដ្ឋាន និងគំនិតថ្មីៗដើម្បីឱ្យពួកគាត់យល់ ដឹង និងរក្សាភាពរឹងមាំ មានសកមត្ថភាពក្នុងការប្រកួតប្រជែង រវាង ឃុំនិងឃុំ ភូមិនិងភូមិ ខ្នងផ្ទះនិងខ្នងផ្ទះ នេះជាគំរូល្អ សំរាប់ភូមិឃុំមានសុវត្ថិភាព។

អនុវត្តអនុសាសន៍លោកអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ណែនាំឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ត្រូវបន្តយកចិត្តទុកដាក់លើការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងពង្រឹងការទប់ស្កាត់ការជួញដូរមនុស្ស ការចែកចាយនិងការប្រើប្រាស់គ្រឿងញៀន នៅតាមមូលដ្ឋាន រួមទាំងចាត់វិធានការបង្ក្រាបល្បែងសីុសងខុសច្បាប់គ្រប់ប្រភេទឱ្យមានប្រសិទ្ធិភាព។

លោកស្រី ប៉ាង រ៉ាវី បានថ្លែងយ៉ាងដូច្នេះទៀតថា ពុកម៉ែ បងប្អូន ក្មួយៗទាំងអស់បានដឹងហើយថា ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តែងតែប្រើឧបបាយកលគ្រប់រូបភាពជាច្រើន ដូចនេះយើងទាំងអស់គ្នាត្រូវបង្កើន ការសើបអង្កេតតាមដានបង្ក្រាប ពង្រឹកការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់លើការជួញដូរចែកចាយប្រើប្រាស់គ្រឿងញៀន ល្បែងសីសងខុសច្បាប់គ្រប់ប្រភេទ ដែលបង្កឱ្យមានអំពើហិង្សា និងការលួចឆក់ប្លន់ដែលនាំឱ្យមានអសន្តិសុខ ដល់សហគមន៍ និងជាកត្តារួមផ្សំបណ្តាលអោយមានអំពើជួញដូរមនុស្ស។

ជាមួយគ្នានេះដែរ ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំង និងបង្ក្រាបឧក្រិដ្ឋកម្មគ្រឿងញៀន ការជួញដូរនិងរត់ពន្ធមនុស្ស ពលកម្មដោយបង្ខំ និង អជីវកម្មផ្លូវភេទឱ្យមានប្រសិទ្ធភាព។ទាំងអស់គ្នាត្រូវធ្វើសកម្មភាពព្រមៗគ្នា ដើម្បីរួមគ្នាលុប់បំបាត់ គ្រឿងញៀន ល្បែងស៊ីសងដែលជាអបាយមុខខុសច្បាប់គ្រប់ប្រភេទ និងគ្រប់ទំរង់នៃការជួញដូរមនុស្ស ដោយត្រូវស៊ើបអង្កេតស្រាវជ្រាវរកជនប្រព្រឹត្តបទល្មើសនិងបណ្តាញបក្សពួកមកផ្តន្ទាទោសតាមច្បាប់។ ត្រូវបង្ការទប់ស្កាត់បញ្ហាទាំងអស់នេះតាមរយៈវិធានការផ្សព្វផ្សាយ អប់រំវិធានការច្បាប់កុំឱ្យកូនចៅរបស់យើងក្លាយជាអ្នករងគ្រោះដោយសាតែអំពើខុសច្បាប់ទាំងអស់នេះ និងកុំឱ្យប្រទេសរបស់យើងក្លាយជាជំរក នៃអំពើអាជីវកម្ម និងធ្វើការគ្រប់គ្រងអាវុធឱ្យបានត្រឹមត្រូវ។

អាជ្ញាធរសមត្ថកិច្ចថ្នាក់ក្រោមជាតិ ត្រូវធ្វើសកម្មភាពបង្ក្រាបល្បែងសីសងខុសច្បាប់ជាប្រចាំដូចភ្លៀងរលឹមដើម្បីរួមចំណែកកាត់បន្ថយអំពើជួញដូរមនុស្ស និងបង្កើនសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម។សហការគ្នាដើម្បីលុប់បំបាត់អំពើជួញដូរមនុស្ស ដែលចាប់ផ្តើមពីការផ្សព្វផ្សាយអប់រំបង្ការទប់ស្កាត់ការពារជនរងគ្រោះ ធ្វើការស្ទើបអង្កេតស្រាវជ្រាវ បង្ក្រាបនិងផ្តន្ទាទោសជនល្មើសឱ្យបានមឹងម៉ាត់។ យើងរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសំរេចគោលដៅអភិវឌ្ឍជាតិ

ប្រកបដោយចីរភាព យើងរួមគ្នាប្រយុទ្ធប្រឆាំងរាល់ទំរង់ នៃអំពើការជួញដូរមនុស្សដើម្បីការពារនិង លើកកម្ពស់សិទ្ធិសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិយើង។

## ស្ត្រីខ្មែរដែលរងគ្រោះពីការជួញដូរនៅឡាវស្នើអាជ្ញាធរចាប់មេខ្យល់យកមកផ្តន្ទាទោស

https://www.rfa.org/khmer/news/human-rights/a-group-of-cambodian-women-victims-of-trafficking-in-laos-ask-authorities-to-arrest-brokers-and-punish-them-according-to-law-10022023073312.html 2023.10.02ដោយ ជីវិតា

ស្ត្រីខ្មែរមួយក្រុម ដែលរងគ្រោះពីការជួញដូរនៅប្រទេសឡាវ (Laos) ស្នើឱ្យអាជ្ញាធរកម្ពុជា ចាប់មេខ្យល់យកមកផ្តន្ទាទោសតាមច្បាប់។ មន្ត្រីសិទ្ធិមនុស្សជំរុញឱ្យរឹតបន្តឹងការអនុវត្តច្បាប់ និង ផ្សព្វផ្សាយការយល់ដឹងរស់ពលរដ្ឋឱ្យបានទូលំទូលាយ ជាពិសេសស្ត្រីត្រូវប្រយ័ត្នប្រយែងក្នុងការ ស្វែងរកការងារនៅក្រៅប្រទេស។

ស្ត្រីខ្មែរមួយក្រុម ដែលមេខ្យល់បោកបញ្ឆោតយកទៅលក់នៅប្រទេសឡាវ កំពុងស្នាក់នៅ កន្លែងមានសុវត្ថិភាពហើយ ក្រោយពេលពួកគេស្វែងការជួយសង្គ្រោះពីប៉ូលិសឡាវ និងមន្ត្រីស្ថាន ទូតកម្ពុជា។ ទោះយ៉ាងណាពួកគេស្នើដល់អាជ្ញាធរពាក់ព័ន្ធតាមចាប់មេខ្យល់យកមកអនុវត្តច្បាប់ឱ្យ បានត្រឹមត្រូវ ដើម្បីផ្តល់យុត្តិធម៌ និងកុំឱ្យពលរដ្ឋខ្មែរទទួលរងគ្រោះតទៅទៀត។

ស្ត្រីរងគ្រោះដែលមានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ អះអាងប្រាប់វិទ្យុអាស៊ីសេរីថា នាងត្រូវ មេខ្យល់ជួញដូរឱ្យទៅថៅកែចិន នៅតំបន់ត្រីកោណមាសក្នុងទឹកដីប្រទេសឡាវ តាមរយៈមេខ្យល់ ឈ្មោះចេត និងប្រពន្ធឈ្មោះ លីលី ដែលបង្ហោះសារនៅលើហ្វេសប៊ុកស្វែងរកនារីខ្មែរ ដើម្បីទៅធ្វើ ការនៅប្រទេសឡាវ ដោយប្រាប់ថា នឹងទទួលបានប្រាក់ឈ្នួល ៣រយដុល្លារក្នុងមួយខែ។ កញ្ញាបន្ត ថា ពេលទៅដល់ទីនោះភ្លាម ថៅកែបានដកហូតយកលិខិតឆ្លងដែនទុក ហើយបង្ខំឱ្យពួកនាងអង្គុយ ចាំដេកជាមួយភ្ញៀវ ឬបម្រើផ្លូវភេទដោយមិនហ៊ានប្រកែកនោះទេ ព្រោះខ្លាចគេធ្វើបាប។ កញ្ញាចង់ ឱ្យមេខ្យល់ទទួលខុសត្រូវចំពោះមុខច្បាប់។ នារីរងគ្រោះ៖ «ខ្ញុំចង់ប្តឹងគាត់(មេខ្យល់) ទាមទារជំងឺចិត្ត ខ្លះ ខ្ញុំចង់ឱ្យប៉ូលិសចាប់ឃាត់ខ្លួនមួយរយៈដើម្បីឱ្យគាត់ដឹងខ្លួន។ បងប្អូនសូមប្រយ័ត្នប្រយែង ប្រយ័ត្ន ដូចខ្ញុំ សូមកុំជឿសម្តីគេ ចាញ់បោកគេអ៊ីចឹងភ័យខ្លួន»។

ស្រដៀងគ្នានេះដែរ ស្ត្រីរងគ្រោះម្នាក់ទៀត ដែលមានស្រុកកំណើតនៅរាជធានីភ្នំពេញ បញ្ជាក់ប្រាប់ថា រយៈពេលជាង១ខែ ដែលមេខ្យល់បោកប្រាស់នាង ឱ្យទៅធ្វើការនៅប្រទេសឡាវ នោះ ថៅកែបានបង្ខាំងឱ្យពួកនាងនៅតែក្នុងបន្ទប់ និងអង្គុយទទួលភ្ញៀវដោយមិនអនុញ្ញាតឱ្យចេញ ក្រៅនោះទេ។ ស្ត្រីរូបនេះឱ្យដឹងថា នាងចង់រត់គេចមកស្រុកខ្មែរវិញដែរ តែថៅកែមិនព្រមប្រគល់

លិខិតឆ្លងដែនឱ្យនោះទេ បើទោះជាគ្រួសាររបស់កញ្ញាបានវេរលុយឱ្យថៅកែជាង១ពាន់ដុល្លារក្តី។ មិនតែប៉ុណ្ណោះ ពួកនាងរងការគំរាមយកទៅលក់ឱ្យថៅកែផ្សេងទៀតផង។

នារីរងគ្រោះផ្សេងទៀត៖ «មេខ្យល់ប្រាប់មកឡាវធ្វើការខេធីវី (KTV) គេប្រាប់ថា កន្លែងហ្នឹងជ្រើសរើសបុគ្គលិកច្រើន ឬរត់តុជាដើម ប៉ុន្តែពេលមកដល់អត់មានអ៊ីចឹងទេ គឺគាត់(ថៅកែ)ដាក់ឱ្យអង្គុយនៅមួយកន្លែងសម្រាប់បុរសមកយកទៅគេង ហើយពួកខ្ញុំអត់មានអ្វីត្រូវនិយាយទេ គឺពេលហ្នឹងបានពិភាក្សាគ្នាថា ត្រូវធ្វើបែបណា ហើយសម្រាប់ពួកខ្ញុំនិយាយទៅកាន់ថៅកែចាំៗសិន»។

ស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវបានប្រកាសថា មន្ត្រីស្ថានទូតបានសហការជាមួយមន្ត្រីប៉ូលិសឡាវនៅតំបន់ត្រីកោណមាស រកឃើញទីតាំង និងជួយសង្គ្រោះស្ត្រីខ្មែរបានចំនួន ៦នាក់ ហើយបញ្ជូនទៅកន្លែងសុវត្ថិភាព កាលពីថ្ងៃទី៣០ ខែកញ្ញា។ មន្ត្រីស្ថានទូតបន្តថា ស្ត្រីខ្មែរម្នាក់ទៀតដែលមិនអាចរត់ចេញពីកន្លែងនោះ ដោយសារមានបញ្ហាសុខភាព ប៉ូលិសឡាវនឹងខិតខំជួយសង្គ្រោះនៅពេលខាងមុខ។ ការអន្តរាគមន៍នេះគឺកើតឡើងបន្ទាប់ពីក្រុមស្ត្រីរងគ្រោះទាំងនោះ បាននិយាយសារជាវីដេអូផ្សាយផ្ទាល់បង្ហោះនៅលើហ្វេសប៊ុក ស្នើឱ្យសុំអាជ្ញាធរកម្ពុជាជួយសង្គ្រោះជាបន្ទាន់ កាលពីព្រឹកថ្ងៃទី៣០ ខែកញ្ញា ដោយសារថៅកែបម្រុងយកពួកនាងទៅលក់នៅប្រទេសផ្សេងទៀត។

វិទ្យុអាស៊ីសេរីនៅពុំទាន់អាចទាក់ទងមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ និងអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ដើម្បីសុំការបញ្ជាក់បន្ថែមចំពោះបញ្ហានេះបាននៅឡើយទេ នៅថ្ងៃទី១ ខែតុលា។

ជុំវិញរឿងនេះ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា រហូតមកដល់ពេលនេះ បញ្ហាការជួញដូរមនុស្សក្រោមទម្រង់នៃការជួញដូរស្ត្រីឱ្យបម្រើសេវាផ្លូវនៅតែបន្តកើតមាន និងកើនឡើងច្រើនជាងមុន។ លោកថា បញ្ហានេះដោយសារជីវភាពក្រីក្រ ហើយសមត្ថកិច្ចអនុវត្តច្បាប់លើបណ្តាញឧក្រិដ្ឋជននៅធូររលុង។ មន្ត្រីសង្គមស៊ីវិលរូបនេះជំរុញដល់រដ្ឋាភិបាលត្រូវផ្សព្វផ្សាយអប់រំដល់ពលរដ្ឋខ្មែរឲ្យបានទូលំទូលាយអំពីបញ្ហាធ្វើចំណាកស្រុកទាក់ទងការបញ្ចុះបញ្ចូលពីមេខ្យល់ ដើម្បីទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែន។

លោក ឌី ថេហូយ៉ា៖ «អ្នកតូចតាចធម្មតា អ្នកស្រុកអ្នកភូមិគឺគ្មានសមត្ថភាពអ្វីទៅជួញដូរឆ្លងដែនលំដាប់ប្រទេសនោះទេ អានេះហើយជាបញ្ហា កាលណាមិនអាចស្រាវស្វែងរកជនល្មើសបានកាត់ទោស និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពទេ គឺមិនអាចដោះស្រាយទេ បញ្ហាធំៗមានបីហ្នឹងមានកត្តាជីវភាពរបស់ពលរដ្ឋ ការផ្សព្វផ្សាយឱ្យពលរដ្ឋបានយល់ដឹង ការចាត់វិធានការទប់ស្កាត់បទ

ល្មើស ហើយបើយើងមិនអាចធ្វើកិច្ចការងារហ្នឹងបានទេបញ្ហាហ្នឹងនៅតែកើតឡើងដដែលៗ អាចកើនឡើងជាងមុនទៀតដោយសារតែអ្នកប្រព្រឹត្តបទល្មើសទៅអត់មានប្រឈមបញ្ហាផ្លូវច្បាប់»។

មន្ត្រីសង្គមស៊ីវិលជំរុញឱ្យអាជ្ញាធរ នៃប្រទេសទាំងពីរ គឺឡាវ និងកម្ពុជាគួររឹតបន្តឹងការនាំចេញ និងការទទួលយកស្ត្រីខ្មែរ ព្រមទាំងចាត់វិធានការឲ្យបានតឹងរ៉ឹងបំផុតចំពោះមេខ្យល់ដែលជាអ្នកទទួលស្ត្រីខ្មែរទៅលក់នោះ៕

## ក្រសួងមហាផ្ទៃ រៀបចំកិច្ចប្រជុំកែសម្រួលអនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

http://nokorwatnews.com/archives/1049301 02/10/2023

ភ្នំពេញ៖ យោងតាមអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ បានឱ្យដឹងថា ក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃចន្ទ ទី០២ ខែតុលា ឆ្នាំ២០២៣នេះ បានរៀបចំកិច្ចប្រជុំកែសម្រួលអនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រោមអធិបតីភាព លោកស្រី ជួ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ក្នុងកិច្ចប្រជុំនេះដែរ ដោយមានការអញ្ជើញចូលរួមពី លោកស្រី អគ្គលេខាធិការ, លោក លោកស្រី ជាអគ្គលេខាធិការរង នៃ គ.ជ.ប.ជ និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត ពិធីនេះធ្វើឡើងនៅទីស្ដីការក្រសួងមហាផ្ទៃ។

សូមជម្រាបជូនដែរថា អនុក្រឹត្យនេះ មានគោលបំណងកែសម្រួលតួនាទី ភារកិច្ចរបស់ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការពង្រឹងទំនាក់ទំនង សម្របសម្រួលកិច្ចសហប្រតិបត្តិការ រវាង ក្រសួង ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិ ព្រមទាំងអង្គការ ដៃគូជាតិ អន្តរជាតិ និងវិស័យឯកជនដែលពាក់ព័ន្ធ ក្នុងការងារប្រយុទ្ធប្រឆាំងរាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសស្ត្រី កុមារ ជនមានពិការភាព និងក្រុមជនងាយរងគ្រោះដទៃទៀត ក៏ដូចជា ទម្រង់ នៃទាសភាពសម័យទំនើប ដែលកើតមាននៅក្នុងដែនដី និងនៅក្រៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា៕

# ថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០២៣

## ឧបនាយករដ្ឋមន្ត្រី ស សុខា
## អំពាវនាវអាជ្ញាធរជាប់ព្រំដែនរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស

https://dap-news.com/national/2023/10/03/363334/ BySKK106Posted on October 3, 2023 4:44 pm

*ភ្នំពេញ ៖ លោកឧបនាយករដ្ឋមន្ត្រី ស សុខា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានធ្វើការអំពាវនាវដល់អាជ្ញាធរខេត្តជាប់ព្រំដែនទាំងអស់ ត្រូវរួបរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស ខណៈការជួញដូរមនុស្សភាគច្រើនកើតឡើងលើនារីវ័យក្មេង។ លោក ឧបនាយករដ្ឋមន្ត្រី ស សុខា លើកឡើងបែបនេះ ក្រោយពី កិច្ចសហការដ៏ស្អិតរមួតជាមួយអាជ្ញាធរ នៃរដ្ឋាភិបាលឡាវ, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ បានធ្វើអន្តរាគមន៍ជួយសង្គ្រោះស្ត្រីខ្មែរ ៦រូប ដែលរងគ្រោះដោយការជួញដូរទៅធ្វើការនៅប្រទេសឡាវ និងកំពុងបន្តការសហការដើម្បីសង្គ្រោះ ១រូបទៀត។*

*នាឱកាសអញ្ជើញបិទសន្និបាតបូកសរុបលទ្ធផលការងារ អាណត្តិទី១ និងលើកទិសដៅការងារបន្តរបស់ គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម (គ.ជ.ប.ទ) នារសៀលថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣នេះ នៅទីស្តីការក្រសួងមហាផ្ទៃ លោកឧបនាយករដ្ឋមន្ត្រី ស សុខា បានថ្លែងថា «ខ្ញុំ អំពាវនាវទៅដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសខេត្តជាប់ព្រំប្រទល់ប្រទេសទាំងបី វៀតណាម ថៃ ឡាវ មេត្តាពិនិត្យ ជាពិសេសជនរងគ្រោះទាំងអស់នោះ ភាគច្រើនប៉ះពាល់ដល់នារីវ័យក្មេងៗ ក្រោមអាយុ ១៨ឆ្នាំ។ អញ្ចឹងហើយបើមានការនាំតាមរយៈមេខ្យល់ ទៅជាក្រុម ទៅព្រំប្រទល់អន្តរជាតិ សូមមេត្តាពិនិត្យ»។*

*ជាមួយគ្នានេះ លោក ឧបនាយករដ្ឋមន្ត្រី បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ អង្គការជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ បានខិតខំប្រឹងប្រែងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគោរពសិទ្ធិមនុស្ស ការប្រយុទ្ធប្រឆាំង ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ និងការលើកស្ទួយក្របសីលធម៌ ក្នុងសង្គមជាដើម៕*

# ក្រសួងមហាផ្ទៃ
# បញ្ជាអាជ្ញាធរ បិទច្រករបៀងខុសច្បាប់ និងចាត់វិធានម៉ឺងម៉ាត់ ចំពោះមេខ្យល់

https://dap-news.com/national/2023/10/04/363410/ ByPH104Posted on October 4,2023 8:57 am

ភ្នំពេញ ៖ ក្រសួងមហាផ្ទៃ បានបញ្ជាឲ្យអាជ្ញាធរខេត្តជាប់ព្រំដែន ត្រូវបិទច្រករបៀង ខុសច្បាប់ទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងចាត់វិធានការផ្លូវច្បាប់ ម៉ឺងម៉ាត់ចំពោះមេខ្យល់ និងអ្នកសមគំនិត អូសទាញប្រជាពលរដ្ឋ ឲ្យឆ្លងដែនខុសច្បាប់។

តាមរយៈលិខិតរបស់ ក្រសួងមហាផ្ទៃ នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បានបញ្ជាក់ថា «សូមធ្វើការក្រើនរំលឹកដល់ អភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាល ខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ ត្រូវបិទច្រករបៀងខុសច្បាប់ទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីចាំបាច់ ត្រូវ ធ្វើការសិក្សា ស្រាវជ្រាវ និងវាយតម្លៃលើ សក្តានុពលសេដ្ឋកិច្ច និង សង្គមរបស់ច្រកដែល មានស្រាប់ រួចលើកសំណើមកក្រសួងមហាផ្ទៃ ដើម្បីមានមូលដ្ឋានសិក្សា និងលើកយោបល់ ជូនថ្នាក់ដឹកនាំ ពិនិត្យ សម្រេច ក្នុងការបង្កើតជាច្រកទ្វារព្រំដែនផ្លូវការ»។

ក្រសួងបន្តថា ត្រូវចាត់វិធានការ ដើម្បីពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យអ្នកដំណើរ ទំនិញ និងមធ្យោបាយ ចេញចូលឆ្លងកាត់ព្រំដែន សំដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបពល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសត្រូវពង្រឹងការទទួលខុសត្រូវលើសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅតាមបណ្តាច្រកទ្វារព្រំដែនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង បន្ថែមថា ត្រូវក្រើនរំលឹកដល់អាជ្ញាធរ មានសមត្ថកិច្ចឈរជើង នៅតាមបណ្តាច្រកទ្វារព្រំដែនទាំងអស់ ឱ្យបញ្ឈប់ជាបន្ទាន់នូវការចេញ ឯកសារឆ្លងដែនមិនប្រក្រតី និងការយកកម្រៃក្រៅផ្លូវការពី ពលករ និងប្រជាពលរដ្ឋទូទៅនៅពេលពួកគាត់ឆ្លង កាត់ចេញចូលតាមបណ្តាច្រកទ្វារព្រំដែន ដែលផ្ទុយពីស្មារតីនៃ កិច្ចព្រមព្រៀងជាមួយប្រទេសជិតខាង ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួង បន្ថែមថា ត្រូវបន្តផ្តល់សេវាសាធារណៈ និងសេវាប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋដោយគ្មានការ រើសអើង ដើរទន្ទឹមនឹងការគ្រប់គ្រងស្ថិតិនិងលំហូរប្រជាពលរដ្ឋ ចេញចូលឆ្លងកាត់ព្រំដែន ឲ្យបានច្បាស់លាស់ ព្រមទាំងខិតខំដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមានឡើង នៅតាមបណ្តាច្រកទ្វារព្រំដែន ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យបានល្អប្រសើរ។

លើសពីនេះ ក្រសួងមហាផ្ទៃ បានគូសបញ្ជាក់ថា «ត្រូវចាត់វិធានការផ្លូវច្បាប់ឲ្យ បានម៉ឺងម៉ាត់ ក្នុងការបង្ក្រាបសកម្មភាព មេខ្យល់ និងអ្នកសមគំនិត ដែលអូសទាញប្រជាពលរដ្ឋ ឱ្យឆ្លងដែនខុសច្បាប់តាមគ្រប់រូបភាព។ ស្របគ្នានេះដែរ ត្រូវធ្វើ ការអប់រំ ណែនាំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាប់ជាប្រចាំដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅពេលចេញចូលឆ្លង កាត់ព្រំដែន ត្រូវមានឯកសារ

ឆ្លងដែនស្របច្បាប់ ដែលចេញដោយ ក្រសួងស្ថាប័ននិង អាជ្ញាធរមានសមត្ថកិច្ច ដើម្បីចៀសវាងការជួញដូរមនុស្ស ការកេងប្រវ័ញ្ច កម្លាំងពលកម្ម ការប្រព្រឹត្តបទល្មើស និងផលវិបាកផ្សេងៗ នៃការឆ្លងដែនខុសច្បាប់»៕

## ចាប់ខ្លួនប្តីប្រពន្ធ២នាក់ នាំនារីខ្មែរ៧នាក់ទៅឡាវ ក្រោយនាងបង្ហោះហ្វេសប៊ុកស្វែងរកការជួយសង្គ្រោះ

https://kohsantepheapdaily.com.kh/article/1813726.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ០៣ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ១៦:២៨

រាជធានីភ្នំពេញ ៖ ប្តីប្រពន្ធ២នាក់ ជាមេខ្យល់រៀបចំនាំនារីខ្មែរចំនួន៧នាក់ ឲ្យទៅបម្រើការងារដោយខុសច្បាប់នៅប្រទេសឡាវ ត្រូវបានកម្លាំងសមត្ថកិច្ចជំនាញ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ ធ្វើការឃាត់ខ្លួនបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នារសៀលថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ នេះ ពាក់ព័ន្ធករណី «លក់ដូរមនុស្សសម្រាប់ឆ្លងដែន ដោយមិនស្របច្បាប់»។ ប្តីប្រពន្ធទាំង២នាក់ ជាមេខ្យល់ខាងលើនេះ រួមមាន ៖ ១- បុរសជាប្តីឈ្មោះ ហង្ស វិចេន ហៅ ចេម អាយុ២១ឆ្នាំ និងប្រពន្ធមានឈ្មោះ ឌុច ទូច អាយុ៣០ឆ្នាំ ទីលំនៅមិនពិប្រាកដ។

បើតាមមន្ត្រីនគរបាល បានបង្ហើបប្រាប់ឲ្យដឹងថា ២នាក់ប្តីប្រពន្ធខាងលើនេះ គឺជាមេខ្យល់អ្នករៀបចំនាំយកមនុស្សចេញទៅប្រទេសឡាវ តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រួចបន្តទៅបាងកក និងឆ្លងកាត់ខេត្តឈៀងរ៉ៃ ប្រទេសថៃ ហើយក៏បានបន្តចូលទៅប្រទេសឡាវទៀត។ រីឯថៅកែ ដែលរង់ចាំទទួលនៅប្រទេសឡាវ ក្នុងតំបន់ត្រីកោណនោះ គឺជាជនជាតិចិនទៀតផង។ បើតាមមន្ត្រីនគរបាល ប្រាប់បន្តថា ជនសង្ស័យ២នាក់ប្តីប្រពន្ធជាប់ពាក់ព័ន្ធពីបទ «អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន» ខាងលើនេះ ជនណាដែលលក់ដូរជនដទៃ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជានោះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី៧ឆ្នាំ រហូតទៅ១៥ឆ្នាំ ។

ជនណាដែលលក់ដូរជនដទៃ ក្នុងប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬនាំជនរងគ្រោះនោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានិងកថាខណ្ឌទី ១ ខាងលើ។ ដោយផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី១៥ឆ្នាំ ដល់២០ឆ្នាំ ក្នុងករណីដែល ៖ ១- ជនរងគ្រោះជាអនិតិជន។ ២- អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពា.នដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។ ៣- អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង ។

សូមជម្រាបថា កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលព័ត៌មានតាមបណ្តាញសង្គមថា «ដោយមាននារីខ្មែរចំនួន៧នាក់នៅ

ធ្វើការងារក្នុងប្រទេសឡាវ កំពុងដង្ហើយរកសមត្ថកិច្ចឲ្យជួយសង្គ្រោះ»។ ក្រោយពីទទួលបានព័ត៌មានខាងលើនោះភ្លាម កម្លាំងជំនាញបានធ្វើការស៊ើបអង្កេត និងស្រាវជ្រាវ ក្រោមការដឹកនាំបញ្ជាផ្ទាល់ពីលោកជំទាវ ឧត្តមសេនីយ៍ទោ ស៊ឹម ផាណុំ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដោយសហការជាមួយស្ថានទូតកម្ពុជាប្រចាំនៅប្រទេសឡាវ អន្តរាគមន៍ ជួយសង្គ្រោះជនរងគ្រោះបាន៦នាក់ ក្នុងនោះអនីតិជនចំនួន៤នាក់ និងបានធ្វើការឃាត់ខ្លួនជនប្រព្រឹត្តិល្មើសចំនួន២នាក់ប្តីប្រពន្ធ នៅខេត្តបន្ទាយមានជ័យ។ ហើយជនរងគ្រោះ ពេលនេះកំពុងស្ថិតនៅប្រទេសឡាវនៅឡើយទេ ដោយអគ្គកុងស៊ុលនឹងសម្របសម្រួលត្រៀមបញ្ជូនមកកម្ពុជាវិញ ក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើបាន។

សូមបញ្ជាក់ថា នៅថ្ងៃខាងលើនេះដែរ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ ក៏បានទទួលព័ត៌មានតាមបណ្តាញសង្គមហ្វេសប៊ុក ពាក់ព័ន្ធនឹងករណីស្ត្រីខ្មែរចំនួន៧នាក់ ដែលបានបង្ហោះសារអំពាវនាវតាមបណ្តាញសង្គមហ្វេសប៊ុក ស្វែងរកការជួយសង្គ្រោះពួកគេ។ ស្ត្រីទាំង៧នាក់នេះ ត្រូវបានជនខិលខូចបោកប្រាស់ឲ្យទៅធ្វើការនៅខេត្តបរកែវ នៃប្រទេសឡាវ ហើយបានរត់ចេញពីកន្លែងធ្វើការ បន្ទាប់ពីមានបញ្ហាជាមួយថៅកែ ដែលគ្រោងនឹងលក់ពួកគេឲ្យទៅប្រទេសទី៣ ។ ក្រោយពីបានទទួលព័ត៌មាននេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឡាវ បានសុំការសហការភ្លាមៗពីអាជ្ញាធរឡាវ ដើម្បីជួយសង្គ្រោះស្ត្រីខ្មែរទាំង៧រូបនោះ ។

ជាមួយគ្នានោះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ក៏បានណែនាំឱ្យឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំរុញស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ ឱ្យផ្តល់នូវការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ ដោយសហការជាមួយសមត្ថកិច្ចឡាវ ។ លុះរហូតមកដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ មាននារីខ្មែរ៦នាក់ត្រូវបានជួយសង្គ្រោះ និងកំពុងស្ថិតនៅកន្លែងមានសុវត្ថិភាព ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាបាល នៃប្រទេសទាំងពីរ ។ ចំណែកស្ថានទូត ក៏បាននិងកំពុងបន្តសហការជាមួយកម្លាំងសមត្ថកិច្ចឡាវ ដើម្បីបន្តខិតខំប្រឹងប្រែងជួយសង្គ្រោះនារីខ្មែរម្នាក់ទៀតផងដែរ។

ការជួយសង្គ្រោះនារីខ្មែរទាំង៧រូបនេះខាងលើនេះ បានបង្ហាញឱ្យឃើញពីចំណាត់ការដ៏រហ័សរហួន និងការយកចិត្តទុកដាក់របស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី ជាពិសេសមន្ត្រីនៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសឡាវ និងអាជ្ញាធរពាក់ព័ន្ធ ដែលបានគិតគូរខ្ពស់អំពីសុវត្ថិភាព ទុក្ខលំបាក និងបញ្ហារបស់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង មិនថាបញ្ហាធំប៉ុណ្ណា លំបាកយ៉ាងណា ឬឆ្ងាយដល់ទីណានោះឡើយ ឱ្យតែ

រាជរដ្ឋាភិបាលបានដឹង គឺមិនព្រងើយកន្តើយទុកប្រជាពលរដ្ឋចោលនោះទេ គឺប្រឹងប្រែងអស់លទ្ធភាព ដើម្បីជួយពួកគេ។

ចំណែកនារីរងគ្រោះទាំង៦រូប ដែលបានជួយសង្គ្រោះរួចនោះ បានបង្ហាញក្តីរំភើបរីករាយជាពន់ពេក ដែលរួចផុតពីការជួញដូរ ជាពិសេសទទួលបានកិច្ចអន្តរាគមន៍យ៉ាងរហ័សពីសម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី និងអាជ្ញាធរកម្ពុជា ។ ពួកគេបានគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសម្តេចធិបតី ហ៊ុន ម៉ា ណែត ក៏ដូចជា អាជ្ញាធររបស់កម្ពុជា ក្នុងនោះរួមមាន ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមន្ត្រីនៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសឡាវ ដែលបានខិតខំខ្នែងជួយសង្គ្រោះពួកគេឱ្យរួចផុតពីគ្រោះថ្នាក់ និងអាចបានត្រឡប់មកកាន់ប្រទេសកំណើតវិញ៕

## UNODC៖ កម្ពុជាកំពុងពេញនិយមខ្លាំង នៃការជួញដូរមនុស្ស បង្ខំឱ្យធ្វើឧក្រិដ្ឋកម្មបោកប្រាស់អនឡាញ

https://www.rfi.fr/km//20231003-unodc?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ 03/10/2023 - 09:49

របាយការណ៍ថ្មីរបស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម ហៅថា UNODC បង្ហាញថា នៅតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាកំពុងពេញនិយមខ្លាំងនៃការជួញដូរមនុស្ស ដើម្បីបង្ខំឱ្យធ្វើឧក្រិដ្ឋកម្មបោកប្រាស់អនឡាញ។ តាមរបាយការណ៍ដែលទើបចេញផ្សាយរបាយការណ៍នៅចុងខែកញ្ញា ឆ្នាំ២០២៣កន្លងទៅ ឧក្រិដ្ឋជនមានប្រតិបត្តិការយ៉ាងបើកចំហរ តាមរយៈការផ្សារភ្ជាប់ទៅនឹងកន្លែងកម្សាន្តនានាដូចជា បនល្បែង សណ្ឋាគារធំៗ និងក្រុមហ៊ុនអាជីវកម្មចុះបញ្ជីជាដើម។

របាយការណ៍ថ្មីរបស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម ហៅថា UNODC បង្ហាញថា ប្រទេសកម្ពុជា ស្ថិតក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍រួមមាន ឡាវ និងភូមា កំពុងពេញនិយមខ្លាំង សម្រាប់ការជួញដូរមនុស្ស បង្ខំឱ្យធ្វើឧក្រិដ្ឋកម្ម បោកប្រាស់អនឡាញនិងក្លែងបន្លំហិរញ្ញវត្ថុ។ ជាប្រតិបត្តិការយ៉ាងបើកចំហរ តាមរយៈការផ្សារភ្ជាប់ទៅនឹងកន្លែងកម្សាន្តនានាដូចជា បនល្បែង សណ្ឋាគារធំៗ និងក្រុមហ៊ុនអាជីវកម្មចុះបញ្ជីជាដើម។ និងដែលជាពិសេសកើតឡើង នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZs) និងតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសភូមាក៏ដូចជាប្រទេសគោលដៅផ្សេងទៀត( រួមទាំងម៉ាឡេស៊ី និងហ្វីលីពីន)។

តាមរបាយការណ៍ដដែល នៅកម្ពុជា ទីតាំងនៃការប្រព្រឹត្តបទល្មើសឆបោកតាមអនឡាញច្រើនបំផុត គឺនៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ ក៏មានដែរ ទីតាំងផ្សេងទៀត នៅខេត្តកណ្ដាល កោះកុង ប៉ោយប៉ែត ពោធិ៍សាត់ កំពត និងនៅតំបន់ទន្លេបាសាក់ ក្បែរព្រំដែនកម្ពុជា-វៀតណាម នៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង។ ហើយទីតាំង ដែលល្បីល្បាញជាងគេនោះគឺ អគារខ្ពស់កប់ពពកមួយកន្លែងនៅឆ្នេរអូរត្រេះ ក្នុងខេត្តព្រះសីហនុ។

ទម្រង់នៃឧក្រិដ្ឋកម្មទាំងនេះ ក្នុងរបាយការណ៍ គឺធ្វើឡើងតាមរយៈការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក ដោយសន្យាទទួលបានប្រាក់ខែខ្ពស់ខ្ទង់ពាន់ដុល្លារ ជាមួយនឹងការងារតាមបនល្បែងសណ្ឋាគារ និងទីតាំងមិនច្បាស់លាស់ផ្សេងទៀត។ ចំណែកវិធីសាស្ត្រគ្រប់គ្រងជនរងគ្រោះវិញមានដូចជា ការឃុំខ្លួន បំបិទសិទ្ធិសេរីភាពមិនអោយមានទំនាក់ទំនងទៅខាងក្រៅ ការដកហូតឯកសារបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ការរំលោភបំពានរាងកាយ និងការផ្ទេរជនរងគ្រោះពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតជាដើម។

ពីខាងក្រសួងមហាផ្ទៃថ្មីៗនេះ ធ្លាប់ទទួលស្គាល់ថា ករណីជួញដូរមនុស្ស និងករណីចាញ់បោកបញ្ឆោតតាមប្រព័ន្ធអនឡាញនៅតែបន្តកើតមានដដែលក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ស្ថិតក្នុងកម្រិតតិចតួចជាងពេលមុន។ តិចតួចដោយសារតែ ពាក្យបណ្ដឹងស្នើឱ្យអាជ្ញាធរកម្ពុជាជួយអន្តរាគមន៍សង្គ្រោះជនបរទេសដែលរងគ្រោះ គឺមានតិចជាង៣បណ្ដឹងក្នុងមួយថ្ងៃ បើធៀបនឹងឆ្នាំកន្លងមក មានប្រមាណជិត២០បណ្ដឹង។

គួរជម្រាបជូនដែរថា យោងតាមរបាយការណ៍ស្ដីពីលទ្ធផលជួយសង្គ្រោះជនបរទេសរងគ្រោះករណីជួញដូរមនុស្ស និងករណីចាញ់បោកបញ្ឆោតតាមប្រព័ន្ធកាលពីខែមិថុនាកន្លងទៅ អាជ្ញាធរកម្ពុជាទទួលបានពាក្យបណ្ដឹងសរុបចំនួន៩៣៦ករណី ដែលមានមនុស្សចំនួន២,២៨២នាក់ ឬ១៦សញ្ជាតិ។ ក្នុងនោះ អាជ្ញាធរបានចុះស៊ើបអង្កេតចំនួន៨៩៨បណ្ដឹង និងបានរកឃើញមនុស្សចំនួន១,៣៧៣នាក់ដែលមាន១៤សញ្ជាតិ។ ក្នុងចំណោមអ្នកដែលបានរកឃើញ អាជ្ញាធរឃាត់ខ្លួនចំនួន១៣៧នាក់ ភាគច្រើនជាជនជាតិចិន (ចិន៖ ១០៥នាក់ ខ្មែរ៖ ១៧នាក់ វៀតណាម១២ និងថៃ០៣នាក់)។

ដោយឡែកបណ្ដឹងចំនួន៣៨ផ្សេងទៀត អាជ្ញាធរកំពុងបន្តចុះប្រតិបត្តិការស្រាវជ្រាវ ខណៈបណ្ដឹងចំនួន៣០៣ករណីដែលមានមនុស្សចំនួន៧៤២នាក់បានបិទបញ្ចប់ដោយមូលហេតុរកពុំឃើញ។ នេះបើតាមរបាយការណ៍ដដែលខាងលើ។

## ប៉ូលិសប៉ាគីស្ថាន ចាប់បានអ្នកជួញដូរក្រលៀនមនុស្សជាង ៣០០ នាក់

https://www.kampucheathmey.com/global-news/590007 ថ្ងៃអង្គារ ៣ តុលា ២០២៣ដោយ Boa Sokunveary

ប៉ូលិសប៉ាគីស្ថានចាប់បានអ្នកជួញដូរក្រលៀន ៨ នាក់ ដែលធ្លាប់យកក្រលៀនរបស់មនុស្សជាង ៣០០ នាក់មកហើយ ។ មេរបស់ពួកគេមានឈ្មោះថា Fawad Mukhtar ដែលតែងតែលក់ក្រលៀនឲ្យអតិថិជនភាគច្រើនដែលជាអ្នកមាន ។ មែនទែនទៅ Fawad ធ្លាប់ត្រូវប៉ូលិសចាប់ខ្លួន ៥ ដងហើយ ប៉ុន្តែគាត់អាចធានាឲ្យនៅក្រៅឃុំរហូត ។ អាជ្ញាធរបានឲ្យដឹងថា យ៉ាងហោចណាស់មនុស្ស ៣ នាក់បានស្លាប់ដោយសារការវះយកគ្រឿងក្នុង ។

ក្រុមសង្គមងងឹតខាងលើតែងតែធ្វើប្រតិបត្តិការនៅទូទាំងខេត្ត Punjab ភាគខាងកើត ក៏ដូចជាតំបន់ Kashmir ដែលគ្រប់គ្រងដោយប៉ាគីស្ថានផងដែរ ។ ពួកគេចូលចិត្តលួងលោមអ្នកជំងឺឲ្យចេញពីមន្ទីរពេទ្យមក ដើម្បីវះកាត់យកគ្រឿងក្នុងនៅកន្លែងឯកជន ខណៈក្រលៀនមួយអាចលក់បានដល់ទៅ ១២០ ០០០ ដុល្លារឯណោះ ។ តាមពិត ការលក់ដូរគ្រឿងក្នុងមនុស្ស ត្រូវបានហាមឃាត់នៅប្រទេសប៉ាគីស្ថានតាំងពីឆ្នាំ ២០១០ មកម្ល៉េះ ។ សម្រាប់អ្នកបំពានច្បាប់នឹងត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារ ១០ ឆ្នាំ និងការផាកពិន័យជាទឹកប្រាក់មួយចំនួនធំ ៕ **ប្រែសម្រួល៖ វារី** ប្រភព៖ BBC

# ថ្ងៃទី០៥ ខែ តុលា ឆ្នាំ២០២៣

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រួយបារម្ភពីពលករដែលចាញ់បោកមេខ្យល់ទៅធ្វើការនៅក្រៅប្រទេសខុសច្បាប់ និងជំរុញអាជ្ញាធរពាក់ព័ន្ធតាមព្រំដែនពង្រឹងការទប់ស្កាត់

https://freshnewsasia.com/index.php/en/localnews/312594-2023-10-04-01-36-39.html 2023-10-04 08:36am

**(ភ្នំពេញ)៖** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកអភិសន្តិបណ្ឌិត ស សុខា បានបង្ហាញពីការព្រួយបារម្ភចំពោះពលករខ្មែរ ដែលចាញ់បោកមេខ្យល់ទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់ ហើយអាចធ្លាក់ចូលក្នុងអំពើជួញដូរមនុស្ស ឬការរំលោភបំពានតាមគ្រប់រូបភាព។

ក្នុងឱកាសអញ្ជើញបិទសន្និបាតបូកសរុបលទ្ធផលការងារអាណត្តិទី១ និងលើកទិសដៅបន្តរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើទារុណកម្ម នៅរសៀលថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣នេះ លោកអភិសន្តិបណ្ឌិត ស សុខា បានណែនាំអាជ្ញាធរតាមព្រំដែនទាំងអស់ ត្រូវបន្តទប់ស្កាត់ការលួចនាំមនុស្សចេញពីក្នុងប្រទេស ដើម្បីទៅធ្វើការដោយខុសច្បាប់នៅក្រៅប្រទេស។ ជាមួយគ្នានេះ លោកអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ក៏បានជំរុញផងដែរឲ្យយកចិត្តទុកដាក់ស្រាវជ្រាវជួយអន្ត

*រាគមន៍ដល់អ្នកដែលបានរងគ្រោះ នៅពេលទទួលបានព័ត៌មានថា ពួកគាត់ទាំងអស់កំពុងចាញ់បោកគេនៅក្រៅប្រទេស។*

*រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរូបនេះ បានថ្លែងយ៉ាងដូច្នេះថា* ***«ខ្ញុំសូមអំពាវនាវទៅដល់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសខេត្តជាប់ព្រំដែនប្រទេសទាំងបី ថៃ វៀតណាម និងឡាវ មេត្តាពិនិត្យ ហើយជាពិសេសជនរងគ្រោះទាំងអស់នោះភាគច្រើន ជានារីក្មេងក្រោមអាយុ១៨ឆ្នាំ។ អញ្ចឹងហើយបើមានការលួចនាំតាមរយៈមេខ្យល់ ឬមួយនាំជាក្រុម ទៅតាមព្រំប្រទល់អន្តរជាតិមួយចំនួន ឬច្រកទ្វារភាគីមួយចំនួនសូមពិនិត្យ»*** *។*

*លោកអភិសន្តិបណ្ឌិត ស សុខា បានអះអាងថា ករណីនេះជារបៀបរបបជួញដូរមនុស្សនេះធ្លាប់កើតមាននៅប្រទេសអឺរ៉ុបមួយចំនួនដែលជាបទពិសោធន៍រួចទៅហើយ ប៉ុន្តែឥលូវរឿងនេះចាប់ផ្តើមសាយភាយសារជាថ្មី។ តែទោះជាយ៉ាងណា ក្នុងករណីរកឃើញថា ពលរដ្ឋខ្មែរនៅក្រៅប្រទេសកំពុងធ្លាក់ចូលអន្ទាន់នេះ សមត្ថកិច្ចកម្ពុជាក៏បានជួយអន្តរាគមន៍បានដោយជោគជ័យជាបន្តបន្ទាប់ផងដែរ ជាក់ស្តែងប៉ុន្មានថ្ងៃមុននេះបានជួយពលករខ្មែរ៦នាក់ នៅប្រទេសឡាវ។*

*សូមរំលឹកថា នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឡាវ បានទទួលព័ត៌មានតាមបណ្តាញសង្គមហ្វេសប៊ុក ពាក់ព័ន្ធនឹងករណីស្ត្រីខ្មែរចំនួន៧រូប ដែលបានបង្ហោះសារអំពាវនាវតាមបណ្តាញសង្គមហ្វេសប៊ុកស្វែងរកការជួយសង្គ្រោះពួកគេ។ ស្ត្រីទាំង៧រូបនេះ ត្រូវបានជនខិលខូចបោកប្រាស់មកធ្វើការនៅខេត្តបរកែវ នៃប្រទេសឡាវ ហើយបានរត់ចេញពីកន្លែងធ្វើការបន្ទាប់ពីមានបញ្ហាជាមួយថៅកែ ដែលគ្រោងលក់ពួកគាត់ទៅប្រទេសទី៣។*

*ក្រោយពីបានទទួលពត៌មាននេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឡាវ បានសុំការសហការភ្លាមពីអជ្ញាធរឡាវ ដើម្បីជួយសង្គ្រោះស្ត្រីខ្មែរទាំង ៧រូបនោះ។ ជាមួយគ្នានេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ក៏បានណែនាំឲ្យឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំរុញស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ ឲ្យផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ ដោយសហការជាមួយសមត្ថកិច្ចឡាវ។*

*រហូតមកដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣នេះ, នារីខ្មែរ៦រូប ត្រូវបានជួយសង្គ្រោះនិងកំពុងស្ថិតនៅកន្លែងមានសុវត្ថិភាព និងមានការយកចិត្តទុកដាក់ខ្ពស់។ ដោយឡែក ស្ថានទូតបាន និងកំពុងបន្តសហការជាមួយកម្លាំងសមត្ថកិច្ចឡាវ បន្តខិតខំជួយសង្គ្រោះនារីខ្មែរ១រូបទៀត៕*

## រដ្ឋលេខាធិការក្រសួងមហាផ្ទៃណែនាំដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនត្រូវពង្រឹង ការពារបន្ទាត់ព្រំដែននិងបទល្មើសឆ្លងដែន

http://nokorwatnews.com/archives/1049790 04/10/2023

ខេត្តបន្ទាយមានជ័យ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃណែនាំដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនត្រូវពង្រឹងការពារបន្ទាត់ព្រំដែន និងបទល្មើសឆ្លងដែនក្នុងឱកាសចុះសួរសុខទុកនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣នៅទីបញ្ជាការប្រចាំទិសទី៥ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ពិធីជួបជួបសំណេះសំណាល និងសួរសុខទុក្ខកងកម្លាំងនគរបាលទិសភូមិភាគទី៥ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌឆ្នាំ២០២៣ ឯកឧត្តម សំរិទ្ធិ ឌី រដ្ឋលេខាធិការក្រសួងមហាផ្ទៃបានមានប្រសាសន៍ណែនាំដល់កងកម្លាំងនគរបាលការពារព្រំដែនគោកទិសភូមិភាគទី៥ ត្រូវពង្រឹងការពារបន្ទាត់ព្រំដែន និងទប់ស្កាត់បទល្មើសឆ្លងដែន និងការពារសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋដែលរស់នៅតាមបន្ទាត់ព្រំដែនអោយមានសុខសន្តិភាព។ ឯកឧត្តមបានផ្តាំផ្ញើដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា.ថៃត្រូវបង្កើនការទំនាក់ទំនងល្អនិងពង្រឹងកិច្ចសហប្រតិបត្តិការល្អ ជាមួយកងកម្លាំងប្រទេសជិតខាង គោលដៅកសាងព្រំដែនសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍន៍រីកចម្រើនតាមបន្ទាត់ព្រំដែន។

ឯកឧត្តម សំរិទ្ធិ ឌី បានមានប្រសាសន៍ថា៖ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌបានចុះសួរសុខទុក្ខនិងនាំយកអំណោយឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានអំណោយគ្រឿងបរិភោគមានមី១១១កេស ត្រី៥៤កេស ទឹកក្រូច១៣១កេស ភេជ្ជៈ២៦៧កេសនិងថវិកាចំនួន៥៤លានរៀល បានចែកជូនដល់កងកម្លាំងនគរបាលការពារព្រំដែនគោកទិសភូមិភាគទី៥ចំនួន១០វរសេនាតូចនិង៦៤ប៉ុស្តិ៍ ដែលមានកម្លាំងសរុបចំនួន១,៥៩១នាក់ ដែលកំពុងការពារបូរណៈភាពទឹកដីភូមិសាស្ត្រ៤ខេត្តមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់ តាមបន្ទាត់ព្រំដែនប្រវែង៣៥៧គីឡូម៉ែត្រ៕

## អភិបាលរាជធានីជំរុញអាជ្ញាធរ ចុះត្រួតពិនិត្យទីតាំងស្នាក់នៅនិងក្លឹបកំសាន្តនៅក្នុងរាជធានីដើម្បីទប់ស្កាត់គ្រឿងញៀននិងជួញដូរមនុស្ស

https://www.kampucheathmey.com/local-news/591377 ថ្ងៃពុធ ៤ តុលា ២០២៣ដោយ Kang Tola

ភ្នំពេញ ៖ ប្រធានគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ លោកឃួង ស្រេង បានជំរុញឱ្យកងកម្លាំងមានសមត្ថកិច្ចទាំងអស់និងអាជ្ញាធរខណ្ឌទាំង១៤ បង្កើតគណៈកម្មការមួយ ចុះត្រួតពិនិត្យទីតាំងស្នាក់នៅរួមនឹងក្លឹបកំសាន្តទាំងអស់នៅក្នុងរាជធានីភ្នំពេញ ដើម្បីពង្រឹងសន្តិសុខឱ្យបានរឹងមាំទប់ស្កាត់បទល្មើសផ្សេងៗ ពិសេសគ្រឿងញៀននិងការជួញដូរមនុស្សគ្រប់ទម្រង់។ ការជំរុញបែប

នេះរបស់លោកឃួង ស្រេង បានធ្វើឡើងក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ នារសៀលថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣នេះ នៅសាលារាជធានីភ្នំពេញ។

លោក ឃួង ស្រេង បានមានប្រសាសន៍លើកឡើងថា៖ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងអាជ្ញាធរខណ្ឌទាំង១៤ ត្រូវបង្កើតគណៈកម្មការចុះត្រួតពិនិត្យទីតាំងស្នាក់នៅរួមនឹងក្លឹបកំសាន្តទាំងអស់នៅក្នុងរាជធានីភ្នំពេញ ដើម្បីពង្រឹងសន្តិសុខឱ្យបានរឹងមាំ ទប់ស្កាត់បទល្មើសផ្សេងៗពិសេស ទប់ស្កាត់ ការជួញដូរគ្រឿងញៀននិងការជួញដូរមនុស្សគ្រប់ទម្រង់។ គណៈកម្មការនេះត្រូវតែចេញដំណើរជាបន្ទាន់ ហើយការចុះត្រួតពិនិត្យនោះ ដាច់ខាតត្រូវធ្វើកំណត់ហេតុនិងចុះហត្ថលេខាពីម្ចាស់ទីតាំងដែលមានភាគហ៊ុនធំជាងគេ មិនអនុញ្ញាតឱ្យមេការគ្រប់គ្រងមកទទួលខុសត្រូវចុះហត្ថលេខាជំនួសនោះទេ។

ការងារនេះត្រូវតែក្តាប់ឱ្យបាន បើយើងក្តាប់ស្ថិតិនេះមិនបាន តើយើងធ្វើអីកើត។ លោកបន្តថា ចំពោះការគ្រប់គ្រងអាវុធជាតិផ្ទុះជារឿងសំខាន់ ដែលយើងត្រូវពង្រឹងនិងគ្រប់គ្រងឱ្យបាន ដើម្បីកុំឱ្យក្រុមសង្គមងឹតធ្វើសកម្មភាពបាន។ គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ ត្រូវតែគ្រប់គ្រងមនុស្សចេញ-ចូលរាជធានីភ្នំពេញឱ្យបាន ។ ការរឹតបណ្តឹងខ្លាំង វាមិនប៉ះពាល់ដល់វិស័យទេសចរណ៍ទេ បើរាជធានីភ្នំពេញយើងមានសន្តិសុខល្អប្រសើរ នោះអ្នកទេសចរណ៍បរទេសគេនឹងមកលេងរាជធានីភ្នំពេញរបស់យើងកាន់តែច្រើនហើយ។ ការរឹតបណ្តឹងខាងលើនេះត្រូវអនុវត្តចាប់ពីពេលនេះតទៅ រហូតដល់បុណ្យភ្ជុំបិណ្ឌ បន្តដល់បុណ្យអុំទូកនិងបន្តរហូតទៅ។

លោក ឃួង ស្រេង បានបន្ថែមទៀតថា ក្រៅពីវិធានការខាងលើហើយនោះ ការដាក់កម្លាំង ពិនិត្យអាវុធជាតិផ្ទុះ ការទប់ស្កាត់ក្មេងទំនើងនៅតាមសាលារៀន ការបង្ក្រាបល្បែងស៊ីសងនៅតាមមូលដ្ឋាន ក៏រឿងសំខាន់ ដែលត្រូវតែអនុវត្តឱ្យមានប្រសិទ្ធភាព ជាមួយនិង ការចុះពង្រឹងសន្តិសុខ បង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទនៅតំបន់ស្មុកស្មាញឱ្យបាន២៤ម៉ោងលើ២៤ម៉ោង ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានភាពកក់ក្តៅ៕ ដោយ ៖ ស្រីរ័ត្ន

# ថ្ងៃទី០៦ ខែ តុលា ឆ្នាំ២០២៣

## ជនរងគ្រោះឥណ្ឌូនេស៊ី២៨នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍

https://www.khmertimeskh.com/501371419// តាំង វីនិត្យ / Khmer Times October 5, 2023

ស្ថានទូតឥណ្ឌូនេស៊ីប្រចាំនៅកម្ពុជាកាលពីម្សិលមិញ បានធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្លួនចំនួន ២៨ នាក់ ដែលត្រូវបានជួយសង្គ្រោះពីប្រតិបត្តិការជួញដូរមនុស្សនៅកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរកម្ពុជា។

យោងតាមសេចក្តីថ្លែងការណ៍ ដែលចេញផ្សាយដោយស្ថានទូតឥណ្ឌូនេស៊ី ពួកគេទាំងអស់បានធ្វើការនៅក្នុងក្រុមហ៊ុនបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណែត មុនពេលត្រូវបានជួយសង្គ្រោះដោយនគរបាលកម្ពុជា និងដាក់ក្រោមការត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ដំណើរការធ្វើមាតុភូមិនិវត្តន៍សម្រាប់ជនជាតិឥណ្ឌូនេស៊ីទាំង ២៨ នាក់នេះ គឺជាដំណើរការដ៏យូរមួយក្នុងការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា រួមមាន នគរបាលជាតិកម្ពុជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងសង្គមកិច្ច អង្គការអន្តរជាតិសម្រាប់ការធ្វើចំណាកស្រុក (IOM) និងបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។

ករណីនេះបានកើតឡើងនៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៣ នៅពេល ដែលស្ថានទូតបានទទួលព័ត៌មានមួយទាក់ទងនឹងពលរដ្ឋឥណ្ឌូនេស៊ីមួយក្រុម ដែលត្រូវបានបង្ខំឱ្យធ្វើការបោកប្រាស់តាមប្រព័ន្ធអនឡាញ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ គេបានលើកឡើងថា ពួកគេទាំងអស់ត្រូវបានគេជួញដូរដោយខុសច្បាប់ចូលប្រទេសកម្ពុជា។ នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៣ បន្ទាប់ពីការស្វែងរកដ៏យូរ ដែលបង្កឡើងដោយការផ្លាស់ទីលំនៅឥតឈប់ឈររបស់ជនរងគ្រោះ នគរបាលបានទទួលជោគជ័យក្នុងការស្វែងរកកន្លែងលាក់ខ្លួនរបស់ពួកគេ ហើយបានបន្តផ្ទេរពួកគេទាំងអស់ទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ២ ថ្ងៃក្រោយមក។

បន្ទាប់មក ពលរដ្ឋឥណ្ឌូនេស៊ីត្រូវបានសម្ភាសជាបន្តបន្ទាប់ដោយនគរបាល និង ក្រសួងសង្គមកិច្ច មុនពេលអាជ្ញាធរកម្ពុជាកំណត់អត្តសញ្ញាណពួកគេយ៉ាងទូលំទូលាយថាជាជនរងគ្រោះ នៃការជួញដូរមនុស្សនៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២៣។ ស្ថានទូតបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនថា៖ «ពេញមួយដំណើរការ ស្ថានទូតបានផ្តល់ការសម្របសម្រួល និងការគាំទ្រសម្រាប់ពលរដ្ឋឥណ្ឌូនេស៊ីទាំងនេះ រួមទាំងការប្រឹក្សា ក៏ដូចជាអាហារ និងគ្រឿងបរិក្ខារនានា»។ សេចក្តីថ្លែងការណ៍បន្តថា៖ «ដំណើរការនេះក៏មានការចូលរួមពីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតរបស់កម្ពុជា និង

ឥណ្ឌូនេស៊ី ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ ដូចជាអង្គការអន្តរជាតិសម្រាប់ជនចំណាកស្រុក (IOM) និងបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)»។

ក្រោយពីបានបញ្ជាក់ពីស្ថានភាពពលរដ្ឋឥណ្ឌូណេស៊ីទាំង ២៨ នាក់ ជាជនរងគ្រោះ នៃការជួញដូរមនុស្សនោះ ស្ថានទូតបានបន្តរៀបចំធ្វើមាតុភូមិនិវត្តន៍របស់ពួកគេទៅប្រទេសឥណ្ឌូនេស៊ី។ ករណីនេះនឹងត្រូវតាមដានបន្ថែមទៀត ដោយភ្នាក់ងារពាក់ព័ន្ធក្នុងប្រទេសឥណ្ឌូណេស៊ីដើម្បីធានាយ៉ាងពេញលេញថា ឧក្រិដ្ឋជន ដែលពាក់ព័ន្ធ ត្រូវបានកាត់ទោស និងករណីបន្ទាប់ត្រូវចៀសវាង។

ថ្ងៃងប្រាប់កាសែតខ្មែរថាមស៍ក្នុងបទសម្ភាសន៍ផ្ទាល់មុខជាមួយ ឯកអគ្គរដ្ឋទូតរបស់ឥណ្ឌូណេស៊ីដែលទើបនឹងមកដល់កម្ពុជា លោក Santo Darmosumarto បានសម្តែងការជឿជាក់លើអាជ្ញាធរកម្ពុជាក្នុងប្រតិបត្តិការបង្រ្កាប និងជួយសង្រ្គោះទៅដល់ជនរងគ្រោះ។ លោកបានមានប្រសាសន៍ថា៖ «ជាពិសេសកាលពីឆ្នាំមុន ចំនួនជនជាតិឥណ្ឌូនេស៊ី ដែលមានបញ្ហាអន្តោប្រវេសន៍ ឬជាជនរងគ្រោះ នៃការជួញដូរមនុស្សបានកើនឡើង ប៉ុន្តែខ្ញុំគិតថា នេះកើតឡើងជាមួយនឹងការពិតដែលថាមានជនជាតិឥណ្ឌូនេស៊ីជាច្រើនរស់នៅក្នុងប្រទេសកម្ពុជា»។

លោកបានបន្តថា៖ «ប៉ុន្តែខ្ញុំក៏មានសេចក្តីសោមនស្សរីករាយផងដែរ ដែលកិច្ចសហប្រតិបត្តិការរបស់យើងជាមួយទីភ្នាក់ងាររដ្ឋាភិបាល ដែលពាក់ព័ន្ធគឺល្អណាស់ ហើយយើងបានគាំទ្រក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថាប្រជាជនឥណ្ឌូនេស៊ីនៅតែមានសុវត្ថិភាព និងសិទ្ធិស្របច្បាប់របស់ពួកគេត្រូវបានការពារ។ ខ្ញុំប្រាកដថា រដ្ឋាភិបាលកម្ពុជាមានចេតនាបរិសុទ្ធបំផុតក្នុងការកែលម្អទិដ្ឋភាពនៃកិច្ចសហប្រតិបត្តិការរបស់យើង»។ មានជនជាតិឥណ្ឌូនេស៊ីជាង ១៥,០០០ នាក់ដែលកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសកម្ពុជា ហើយលោក Darmosumarto បាននិយាយថា លោក និងក្រុមការងាររបស់លោកប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការការពារសុវត្ថិភាព និងសុខុមាលភាពរបស់បងប្អូនជនរួមជាតិរបស់ពួកគេ។

លោកថា៖ «ក្នុងនាមជាស្ថានទូតតូចមួយ យើងត្រូវខិតខំបន្ថែមទៀត ដើម្បីធានាថា ពលរដ្ឋឥណ្ឌូនេស៊ី នៅកម្ពុជា ទទួលបានការមើលថែ ហើយធ្វើការតាមវិធីដែលយើង និងរដ្ឋាភិបាលកម្ពុជា អាចបន្តសម្របសម្រួល និងធានាសុវត្ថិភាព និងសន្តិសុខរបស់ពលរដ្ឋឥណ្ឌូនេស៊ី នៅទីនេះ នៅតែជាអាទិភាពរបស់យើង»។Ⅷ

# ពលករ២នាក់ប្ដីប្រពន្ធមកពីថៃ
# ដល់អូរព្រំដែនកំពុងមានទឹកជំនន់ ស្រាប់តែឈឺពោះសម្រាលកូន

https://kohsantepheapdaily.com.kh/article/1814465.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram *បន្ទាយមានជ័យ០៥ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ០៩:២៦*

*ខេត្តបន្ទាយមានជ័យ ៖ ពលករ២នាក់ប្ដីប្រពន្ធត្រឡប់ពីធ្វើការនៅប្រទេសថៃ មកដល់អូរព្រំដែនបានសម្រាលកូន ត្រូវបានកម្លាំងជួយអន្តរាគមន៍ជួយសង្គ្រោះឆ្លងទឹកជំនន់កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ នៅចំណុចភូមិបឹងបេង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។*

*លោកវរៈសេនីយ៍ត្រី សុខ ចន្ថា ជំនួយការសេនាធិការវរៈសេនាតូចថ្មើជើងលេខ៥១១បានឱ្យដឹងថាពលករដែលត្រឡប់ពីថៃ២នាក់ប្ដីប្រពន្ធខាងលើ ប្ដីឈ្មោះ វ៉ាន់ ដេត អាយុ២៨ឆ្នាំ និងប្រពន្ធឈ្មោះ ណា វិន អាយុ២៤ឆ្នាំ មានស្រុកកំណើតនៅភូមិទួលឃ្លាំង ឃុំព្រះជាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ។ លោកបានបញ្ជាក់ថា ពលករខ្មែរ២នាក់ប្ដីប្រពន្ធនិងកូនប្រុសម្នាក់ត្រឡប់ពីធ្វើការនៅប្រទេសថៃវិញតាមច្រករបៀងខុសច្បាប់ ស្រាប់តែប្រពន្ធឈឺពោះសម្រាលកូនក្នុងទឹកដីថៃជាប់ព្រំដែន ត្រូវបានកម្លាំងជួយអន្តរាគមន៍យកធុងលាយស៊ីម៉ងដាក់ឆ្លងអូរព្រំដែន ខណៈទឹកកំពុងជន់ និងហូរខ្លាំង។ បន្ទាប់មកកូនប្រុសម្នាក់ និងស្ត្រីសម្រាលកូនត្រូវបានដឹកតាមម៉ូតូកង់បីទៅកាន់មណ្ឌលសុខភាពបឹងបេង ស្រុកម៉ាឡៃ ។*

*លោកវរៈសេនីយ៍ត្រី សុខ ចន្ថា បានបញ្ជាក់ថា ក្រោយពេលដែលជួយសង្គ្រោះពលករខ្មែរ១គ្រួសារដែលមានប្រពន្ធមានផ្ទៃពោះហើយសម្រាលកូននៅក្បែរអូរព្រំដែនថៃ-កម្ពុជានោះត្រូវបានជួយអន្តរាគមន៍ទាន់ពេលវេលា និងមានសុវត្ថិភាព ៕*

# អង្គភាពប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំង
# របស់អង់គ្លេស សន្យាបន្តពង្រឹងកិច្ចសហប្រតិបត្តិការ
# ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ សំដៅបង្ការ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ

https://freshnewsasia.com/index.php/en/localnews/312864-2023-10-05-13-47-37.html 2023-10-05 08:47pm

***(ភ្នំពេញ)៖*** *នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ នៅព្រឹកថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣នេះ អញ្ជើញទទួលជួបលោក* PETER VERNON *មន្ត្រីទំនាក់ទំនងរបស់ទីភ្នាក់ជាតិ នៃចក្រភពអង់គ្លេស ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំង* (NCA) *ប្រចាំវៀតណាម កម្ពុជា ឡាវ និងប្រ៊ុយណេ និងលោក* MARC THAYRE *អនុប្រធានបេសកកម្ម នៃស្ថានទូត*

ចក្រភពអង់គ្លេស ប្រចាំកម្ពុជា ព្រមទាំងសហការី ដើម្បីសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងមហាផ្ទៃ។

ជាកិច្ចចាប់ផ្តើម លោក PETER VERNON មន្ត្រីទំនាក់ទំនងរបស់ទីភ្នាក់ងារជាតិ នៃចក្រភពអង់គ្លេស ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំង (NCA) ប្រចាំវៀតណាម កម្ពុជា ឡាវ និងប្រ៊ុយណេ បានឧទ្ទេសនាមខ្លួនជូននាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ និងបានសម្តែងនូវការចូលរួមអបអរសាទរចំពោះនាយឧត្តមសេនីយ៍ ដែលត្រូវបានតែងតាំងជាអគ្គស្នងការនគរបាលជាតិ និងបានស្នើសុំបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រុមការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំង(NCA) ជាមួយនគរបាលជាតិកម្ពុជា ដែលមានពីមុនមកតាមរយៈយន្តការដែលមានស្រាប់។

ជាមួយគ្នានេះ លោក MARC THAYRE អនុប្រធានបេសកកម្ម នៃស្ថានទូតចក្រភពអង់គ្លេសប្រចាំកម្ពុជា ក៏បានលើកឡើងពីការផ្តល់ជូននូវការបណ្តុះបណ្តាលដល់នគរបាលជាតិកម្ពុជា ពាក់ព័ន្ធភាសាអង់គ្លេស ក៏ដូចជាមុខជំនាញបច្ចេកវិទ្យា និងការប្រយុទ្ធប្រឆាំងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងបានថ្លែងអំណរគុណដល់នគរបាលជាតិកម្ពុជា ចំពោះកិច្ចអន្តរាគមន៍ជួយដល់ពលរដ្ឋអង់គ្លេសរស់នៅកម្ពុជាពេលជួបបញ្ហា។

ជាការឆ្លើយតប នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិ បានគាំទ្រ និងរីករាយស្វាគមន៍ក្នុងការបង្កើនកិច្ចសហការប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទ ពិសេសបទល្មើសឧក្រិដ្ឋឆ្លងដែន ជាមួយក្រុមការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានការចាត់តាំង (NCA) ក្នុងគោលបំណងថែរក្សាសន្តិសុខ សុវត្ថិភាព ជូនពលរដ្ឋប្រទេសទាំងពីរ ក៏ដូចជាក្នុងតំបន់ផងដែរ។

## ក្រសួងមហាផ្ទៃនឹងមិនអាចលុប
## «បំបាត់ការយកប្រាក់ក្រៅផ្លូវការ» នៅច្រកព្រំដែនបានឡើយ

https://www.rfa.org/khmer/news/social-economy/due-to-systemic-corruption-the-ministry-of-interior-will-not-be-able-to-eliminate-informal-collection-of-money-at-border-crossings-say-analysts-10052023055109.html ដោយ សុជីវ 2023.10.05

អ្នកវិភាគនយោបាយលើកឡើងថា ដរាបណាអំពើពុករលួយជាប្រព័ន្ធនៅតែបន្តកើតមាន នោះក្រសួងមហាផ្ទៃនឹងមិនអាចលុបបំបាត់ ការយកប្រាក់ក្រៅផ្លូវការពីប្រជាពលរដ្ឋធ្វើដំណើរចេញចូលតាមច្រកព្រំដែនបានឡើយ។ មន្ត្រីអង្គការសង្គមស៊ីវិលយល់ឃើញថា ដោយសារប្រជាពលរដ្ឋភាគច្រើនឆ្លងដែនទៅធ្វើការ នៅប្រទេសថៃដោយខុសច្បាប់ ដូច្នេះក្រសួងមហាផ្ទៃត្រូវមានដំណោះ

ស្រាយជាប្រព័ន្ធទើបអាចដោះស្រាយបញ្ហាបង់ប្រាក់ក្រៅផ្លូវការនៅតាមច្រកព្រំដែនបានជោគជ័យ។ អ្នកវិភាគនយោបាយអះអាងថា ក្រសួងមហាផ្ទៃនឹងមិនអាចលុបបំបាត់ ការយកប្រាក់ក្រៅផ្លូវការពីប្រជាពលរដ្ឋចេញចូលតាមច្រកព្រំដែនបានឡើយ ប្រសិនបើក្រសួងមួយនេះមិនមានវិធានការច្បាប់ឱ្យបានតឹងរ៉ឹងទៅលើអាជ្ញាធរ ដែលឃុបឃិតប្រព្រឹត្តិអំពើពុករលួយជាប្រព័ន្ធជាមួយមេខ្យល់។

អ្នកវិភាគនយោបាយ លោកបណ្ឌិត រ៉ូ វណ្ណៈ មានប្រសាសន៍ថា ការចេញលិខិតព្រមានថានឹងវិធានការណ៍ផ្លូវច្បាប់ទៅលើមន្ត្រីតាមច្រកព្រំដែន ដែលយកប្រាក់ក្រៅផ្លូវការ នឹងមិនមានប្រសិទ្ធភាពនោះឡើយ។ លោកបន្ថែមថា ក្រសួងមហាផ្ទៃគួរតែបង្ហាញសកម្មភាពជាក់ស្តែង តាមរយៈការចាប់មន្ត្រីខិលខូចឱ្យប្រឈមនឹងផ្លូវច្បាប់ ជាជាងគ្រាន់តែចេញលិខិតព្រមាន។ ទោះជាយ៉ាងណា បណ្ឌិត រ៉ូ វណ្ណៈ គាំទ្រចំពោះវិធានការរបស់ក្រសួងមហាផ្ទៃដែលជំរុញឱ្យអាជ្ញាធរនៅតាមព្រំដែនរៀបចំឯកសារស្នើឱ្យមានច្រកចេញចូលតាមព្រំដែនបន្ថែមក្នុងករណីមានតម្រូវការចាំបាច់។ បណ្ឌិត រ៉ូ វណ្ណៈ៖ «ដំណាក់កាលនេះ ជាដំណាក់កាលដែលត្រូវវះកាត់គឺមានន័យថា ការបោសសម្អាត ឬការកាត់បន្ថយអំពើពុករលួយហ្នឹងត្រូវតែធ្វើ ដោយសាររដ្ឋាភិបាលមួយដែលស្អាតស្អំ អ៊ីចឹងទាមទារនូវការអនុវត្តប្រព័ន្ធច្បាប់ ការអនុវត្តប្រសិទ្ធភាពការងារ ជាជាងការដែលគ្រាន់តែព្រមាន គឺមានន័យថា យើងមានសិទ្ធិអំណាចក្នុងការចាត់ការ»។

ប្រតិកម្មរបស់អ្នកវិភាគនយោបាយបែបនេះ ធ្វើឡើងបន្ទាប់ពីក្រសួងមហាផ្ទៃ បានចេញលិខិតមួយ កាលពីថ្ងៃទី៣ តុលា ដោយបានផ្តល់ដំណឹងដល់អាជ្ញាធរតាមច្រកព្រំដែន រឹតបន្តឹងចំពោះការបើកច្រករបៀង និងយកប្រាក់ក្រៅផ្លូវការពីប្រជាពលរដ្ឋនៅពេលធ្វើដំណើរឆ្លងកាត់តាមច្រកព្រំដែន។ បើទោះបីជាលិខិតបានលើកឡើងថា ក្រសួងមហាផ្ទៃបានរកឃើញមានករណីយកប្រាក់ក្រៅផ្លូវការ និងមានមន្ត្រីឃុបឃិតលួចបើកច្រករបៀង ដើម្បីយកប្រាក់ក្រៅផ្លូវការក្តី ប៉ុន្តែក្រសួងមហាផ្ទៃមិនមានវិធានការច្បាប់អ្វីទៅលើមន្ត្រីណាម្នាក់នោះឡើយ ដោយគ្រាន់តែព្រមានថា នឹងមានវិធានការច្បាប់ទៅលើមន្ត្រីខិលខូចទាំងនោះនៅក្រោយពេលអគ្គស្នងការនគរបាលជាតិចុះត្រួតពិនិត្យទៅវិញ។

ជុំវិញរឿងនេះ មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស អង្គការសង់ត្រាល់(CENTRAL) លោក លឹង សុផុន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៤ តុលា ថា បញ្ហាមន្ត្រីខិលខូចសហការជាមួយមេខ្យល់ ដើម្បីនាំពលករខ្មែរចូលធ្វើការនៅប្រទេសថៃដោយខុសច្បាប់ នៅតែបន្តកើតមាន និងមិនងាយលុបបំបាត់បាននោះឡើយ។ លោកបន្ថែមថា ដើម្បីដោះស្រាយបញ្ហានេះបាន លុះត្រាតែរដ្ឋាភិបាលដោះស្រាយបញ្ហាអាទិភាពផ្សេងៗជាប្រព័ន្ធតែម្តង បញ្ហាទាំងនោះរួមមាន ការបញ្ចុះតម្លៃលិខិតឆ្លងដែន បង្កើនចំនួនកូតាពលករជាមួយក្រុមហ៊ុនថៃ តាមរយៈការចុះអនុស្សរណៈ

យោគយល់គ្នា ឬ MOU និងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ពីហានិភ័យនៃការធ្វើចំណាកស្រុកដោយខុសច្បាប់ឱ្យបានទូលំទូលាយជាដើម។

លោក លឹង សុផុនះ «បើសិនជាយើងធ្វើតែពីខាងលើហើយ មិនចុះអនុវត្តជាក់ស្តែង ខ្ញុំគិតថាវាជារឿងដែលមិនល្អប្រសើរទេ ហើយយើងដឹងស្រាប់ហើយថា ស្រុកខ្មែរពុកសឹងដល់ឆ្អឹងហើយ គ្រាន់តែថា ការចេញវិធានការមកប៉ុណ្ណឹង ប៉ុន្តែការចេញលទ្ធផលបង្ហាញឱ្យប្រជាពលរដ្ឋបានឃើញវាអត់ទាន់ឃើញមាន»។ មន្ត្រីអង្គការសង្គមស៊ីវិលអះអាងថា ក្នុងចំណោមពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណ២លាននាក់ (២.០០០.០០០) មានតែពលករប្រមាណ២សែននាក់(២០០.០០០) ឬស្មើនឹង១០ភាគរយតែប៉ុណ្ណោះ ដែលមានឯកសារស្របច្បាប់ធ្វើការនៅប្រទេសថៃ។ អ្នកវិភាគនយោបាយលើកឡើងថា បញ្ហាបង់ប្រាក់ក្រៅផ្លូវការនេះ កើតមានរាប់សិបឆ្នាំមកហើយ ដូច្នេះក្រសួងមហាផ្ទៃ គួរចាត់វិធានការច្បាប់ជាក់ស្តែងទៅលើមន្ត្រីខិលខូចទាំងនោះ ដើម្បីបង្កើនប្រាក់ចំណូលជាតិ ជាជាងគ្រាន់តែចេញលិខិតព្រមាន ដែលបង្ហាញពីភាពទន់ខ្សោយក្នុងការដឹកនាំរបស់ក្រសួងមួយនេះ។//

# ថ្ងៃទី០៩ ខែ តុលា ឆ្នាំ២០២៣

## ជនរងគ្រោះពីការជួញដូរដែលធ្វើដំណើរទៅកម្ពុជា២នាក់ ត្រូវបានជួយសង្គ្រោះ

https://www.khmertimeskh.com/501372445// October 6, 2023

ការិយាល័យអន្តោប្រវេសន៍ បានរាយការណ៍កាលពីថ្ងៃព្រហស្បតិ៍ថា ជនរងគ្រោះពីរនាក់នៃការជ្រើសរើសការងារខុសច្បាប់ត្រូវបានជួយសង្គ្រោះនៅឯអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino។

ស្នងការអន្តោប្រវេសន៍ លោក Norman Tansingco បាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា "ប្រសិនបើមិនមានការតាមដានអោយបានហ្មត់ចត់ពីមន្ត្រីអន្តោប្រវេសន៍ នៅព្រលានយន្តហោះទេពេលនេះ ពួកគេប្រហែលជាទៅដល់ប្រទេសកម្ពុជាធ្វើការឱ្យថៅកែ ដែលអាចធ្វើបាបពួកគេដូចដែលអ្នកមុនៗជួបប្រទះកន្លងមក" ។ លោក Tansingco បាននិយាយថា ពលរដ្ឋហ្វីលីពីនទាំងពីរនាក់ត្រូវបានរារាំងកាលពីថ្ងៃទី២៧ ខែកញ្ញា។ ផ្នែកការពារអន្តោប្រវេសន៍ និងការអនុវត្តព្រំដែនរបស់ការិយាល័យអន្តោប្រវេសន៍ បានរាយការណ៍ថា អ្នកទាំងពីរបានអះអាងថា មានគេផ្តល់ការងារនៅក្នុងប្រទេសហ្វីលីពីន ប៉ុន្តែបានបង្ហាញឯកសារគួរឱ្យសង្ស័យ។

ការិយាល័យក៏បានកត់សម្គាល់ផងដែរថា ជនរងគ្រោះធ្វើដំណើរជាភ្ញៀវទេសចរទៅប្រទេសថៃ ប៉ុន្តែមិនអាចលម្អិតអំពីការធ្វើដំណើររបស់ពួកគេបានទេ។ ការិយាល័យអន្តោប្រវេសន៍ បានឱ្យ

ដឹងថា នៅទីបំផុត អ្នកទាំងពីរបានសារភាពថា ពួកគេពិតជាកំពុងធ្វើដំណើរទៅធ្វើការជា "អ្នកសរសេរកូដ" នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេសន្យាថានឹងផ្តល់ប្រាក់ឈ្នួលប្រចាំខែចំនួន៤០,០០០ប៉េសូ។

កាលពីដើមឆ្នាំនេះ ពលរដ្ឋហ្វីលីពីនជាច្រើននាក់ត្រូវបានជួយសង្គ្រោះនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីពួកគេត្រូវបានរាយការណ៍ថាត្រូវបានរំលោភបំពានរាងកាយ និងផ្លូវចិត្តដោយក្រុមឆបោករូបិយបណ្ណអេឡិចត្រូនិច (crypto scammers)។

## ជប៉ុនផ្អាកទទួលសិក្ខាកាមបច្ចេកទេសដែលត្រូវបានបញ្ជូនដោយអង្គភាពកម្ពុជាចំនួន៣

https://www.khmertimeskh.com/501372672//?p=1372672 October 7, 2023

អាជ្ញាធរអន្តោប្រវេសន៍ជប៉ុន បានសម្រេចផ្អាកការទទួលយកសិក្ខាកាមបច្ចេកទេសដែលត្រូវបានបញ្ជូនដោយអង្គការចំនួនបីក្នុងប្រទេសកម្ពុជា បន្ទាប់ពីសិក្ខាកាមជាច្រើននាក់នេះបានគេចខ្លួនចេញពីកន្លែងធ្វើការ។ ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍និយាយថាសិក្ខាកាមថ្មីមកពីអង្គការទាំងបីនឹងមិនត្រូវបានទទួលយកយ៉ាងហោចណាស់៦ខែចាប់ពីចុងខែវិច្ឆិកា។

គេបានឱ្យដឹងថា នៅឆ្នាំ២០២២ ចំនួនសិក្ខាកាមបរទេសដែលបានបាត់ខ្លួនមានចំនួនសរុប៩០០៦នាក់ ដែលជាចំនួនច្រើនបំផុតទីពីរនៅក្នុងកំណត់ត្រា។ ទីភ្នាក់ងារនេះបាននិយាយថា ខ្លួនបានដោះស្រាយបញ្ហាដោយការដកសិទ្ធិអង្គការទាំងនោះជាបណ្តោះអាសន្ន នៅក្នុងប្រទេសជប៉ុន ដែលសិក្ខាកាមថ្មីបានរត់គេចខ្លួនយ៉ាងច្រើន។ ខ្លួនក៏បានផ្អាកការទទួលយកសិក្ខាកាមពីអង្គការវៀតណាមមួយចំនួននៅឆ្នាំ២០២១។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កូអ៊ីហ្សុមី រ្យូជី បាននិយាយថា ក្រសួងបានចាត់វិធានការជាមួយអង្គការកម្ពុជា ដើម្បីកាត់បន្ថយចំនួនអ្នករត់គេចខ្លួន។ លោកបានបន្ថែមថា បញ្ហាធំមួយគំរាមកំហែងដល់អត្ថិភាពរបស់កម្មវិធី។ NHK World

## អង្គការ APLE និងសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី «កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ»

https://freshnewsasia.com/index.php/en/localnews/312980-2023-10-06-14-00-57.html 2023-10-06 09:00pm

នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣នេះ ដោយទទួលបានជំនួយឧបត្ថម្ភថវិកាពីអង្គការដែនដីមនុស្សហូឡង់ដ៍ (Terre des Homes Netherlands) អង្គការ APLE និងសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី «កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ» ដល់មន្ត្រីមូលដ្ឋានក្នុងសង្កាត់ទាំង១០ នៃខណ្ឌទួលគោកចំនួន៤៤នាក់។

លោក ជិន ប៊ុនធឿន នាយកប្រតិបត្តិ នៃសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ដែលធ្វើជាអធិបតី និងបើកកម្មវិធី មានប្រសាសន៍ថា «ប្រទេសកម្ពុជាបានកំពុងតែយកចិត្តទុកដាក់និងរួមគ្នាដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការរំលោភបំពានក្នុងបរិបទប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលក្នុងនោះប្រទេសកម្ពុជាបានបោះជំហានទៅមុខក្នុងការចូលរួមចំណែក សំដៅធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការលើកកម្ពស់កិច្ចការពារកុមារ និងឧត្តមប្រយោជន៍របស់កុមារទាំងនៅកម្ពុជាក៏ដូចជាក្នុងពិភពលោកផងដែរ។ មន្ត្រីមូលដ្ឋាននៅតែមានតួនាទីសំខាន់ណាស់ក្នុងការចូលរួមបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះករណីនេះ ពីព្រោះកុមារនិងក្រុមគ្រួសាររស់នៅក្នុងមូលដ្ឋាននោះដោយផ្ទាល់»។

លោក សំលៀង សីលា នាយកប្រតិបត្តិអង្គការ APLE បានថ្លែងថា កម្មវិធីលើកកម្ពស់ការយល់ដឹងនេះ មានគោលបំណងពង្រឹងចំណេះដឹងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ធ្វើការឆ្លុះបញ្ចាំងឈ្វេងយល់លើការប្រើប្រាស់អ៊ីនធឺណិត និងការទំនាក់ទំនងតាមបច្ចេកវិទ្យា របស់ កុមារ និងយុវជននៅប្រទេសកម្ពុជា ឈ្វេងយល់ពីហានិភ័យនៃការប្រើប្រាស់អ៊ីធឺណិត និងទម្រង់នៃការកេងប្រវ័ញ្ច ផ្លូវ ភេទ លើ កុមារ តាមប្រព័ន្ធអនឡាញ និងការឆ្លើយតបចំពោះបញ្ហានេះ។ លោក ក៏បានលើកទឹកចិត្តឲ្យសិក្ខាកាមទាំងអស់មេត្តាចូលរួមយ៉ាងសកម្មក្នុងការទទួលយក និងចែករំលែកចំណេះដឹង បញ្ចេញជាយោបល់ និងបន្តចែករំលែកចំណេះដឹងដែលទទួលបានដល់ក្រុមគោលដៅនានាក្នុងមូលដ្ឋានដែលអ្នកចូលរួមកំពុងបំពេញការងារ។

តាមការសិក្សាស្រាវជ្រាវ អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញបានក្លាយជាបញ្ហាសកល និងនៅក្នុងប្រទេសកម្ពុជា ហើយវាក៏បានក្លាយជាក្តីបារម្ភថ្មីមួយទៀតដែលទាមទារអោយភាគីពាក់ព័ន្ធទាំងសាធារណជន អាណាព្យាបាល អាជ្ញាធរ សង្គមស៊ីវិល មន្ត្រីអនុវត្តច្បាប់ ចាំបាច់ធ្វើការរួមគ្នាដើម្បីទប់ស្កាត់ និងការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញនេះ។

តំណភ្ជាប់អ៊ីនធឺណិតនៅកម្ពុជាបានកើនឡើងជាលំដាប់ ហើយមនុស្សកាន់តែច្រើនឡើងៗរួមទាំងកុមារមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ការសិក្សាថ្មីលើការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disruptiong Harm Study in Cambodia) បានបង្ហាញថា កុមារ ជាង៨០%ដែលមានអាយុចន្លោះពី ១២ឆ្នាំ ទៅ ១៧ឆ្នាំ បានប្រើប្រាស់ និងភ្ជាប់អ៊ីនធឺណិតច្រើនជាងមនុស្សពេញវ័យ។ ខណៈពេលដែលកុមារ និងក្មេងវ័យជំទង់ បានចំណាយពេលវេលាច្រើនលើការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ពួកគេភាគច្រើនមិនបានដឹងពីហានិភ័យ និងគ្រោះថ្នាក់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញនោះទេ។

ល្បិចកលរបស់ជនល្មើសកាន់តែស្មុគស្មាញ និងកាន់តែអាក្រក់ទៅៗដែលទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធចាំបាច់រួមគ្នាដោះស្រាយ។ កុមាររងគ្រោះ ពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទបានទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរ ទាំងផ្លូវកាយ និងផ្លូវចិត្ត និងពេញមួយជីវិតរបស់ពួកគេ។ កុមាររងគ្រោះភាគច្រើនមានអារម្មណ៍អាម៉ាស ពិបាកក្នុងការទុកចិត្តអ្នកដទៃ អស់សង្ឃឹម បាក់ទឹកចិត្ត ខកចិត្ត ស្ដីបន្ទោសខ្លួនឯង ឆាប់ភ័យខ្លាច និងមានតម្រូវការដោះស្រាយបញ្ហាបន្ទាន់។ ទំហំនៃផលប៉ះពាល់ នៃដំណើរការស្តារនីតិសម្បទារបស់កុមាររងគ្រោះ ត្រូវការគាំទ្រទាំងផ្លូវចិត្ត និងផ្លូវកាយពីសំណាក់ឪពុកម្ដាយ អាណាព្យាបាល អ្នកជំនាញ និងសហគមន៍ផងដែរ។

គោលនយោបាយជាតិ ស្ដីពីប្រព័ន្ធកិច្ចការពារកុមារ (២០១៩-២០២៩) របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានលើកឡើងថា កង្វះការរៀបចំ និងការទទួលបានសេវាទប់ស្កាត់សម្រាប់កុមារងាយរងគ្រោះមកពីអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់ ការមិនអើពើ និងការធ្វើអាជីវកម្ម ត្រូវបានផ្តល់ដោយអ្នកពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ដែលជាបញ្ហាប្រឈមដ៏ធំដល់ដំណើរការនៃការអនុវត្តកិច្ចការពារកុមារដែលមានលក្ខណៈជាប្រព័ន្ធ។

ជាការពិត គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គ.ក.ន.ក) និងអង្គការសង្គមស៊ីវិល មួយចំនួនបានត្រឹមតែអនុវត្តវិធានការផ្លូវច្បាប់ ដែលរួមមានការបញ្ជូនទៅមណ្ឌលសុខភាព ការរាយការណ៍អំពីករណី និងការដោះស្រាយសម្រុះសម្រួលជាមួយជនល្មើស និងកុមាររងគ្រោះត្រឹមតែថ្នាក់មូលដ្ឋានប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ យុទ្ធនាការនៃការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ ការផ្តល់ប្រឹក្សាយោបល់ទាំងផ្នែកច្បាប់និងសង្គម ការគាំទ្រ និងការថែទាំ កុមារនៅក្នុងគ្រួសារ និងសហគមន៍នៅមានកម្រិត និងមិនទាន់ដោះស្រាយបានចំគោលដៅនៅឡើយ។

ការបំពេញតួនាទីភារកិច្ចជាពហុវិស័យរបស់អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងអ្នកពាក់ព័ន្ធបាននឹងកំពុងប្រឈមបញ្ហាជាច្រើនដូចជាអណត្តិ តួនាទីភារកិច្ច និងការទទួលខុសត្រូវ កង្វះ

ធនធាន កង្វះបទពិសោធន៍ និងសមត្ថភាពបច្ចេកទេសសម្របសម្រួលដោះស្រាយបញ្ហាកិច្ចការពារកុមារ ជាពិសេសវិធីសាស្ត្រក្នុងការបង្ការទប់ស្កាត់ជាដើម។

ដោយឡែក យោងតាមរបាយការណ៍របស់អង្គការ APLE ក្នុងរយៈពេល៩ខែឆ្នាំ២០២៣ មានការរាយការណ៍ចំនួនជាង១៨០ករណីដែលពាក់ព័ន្ធនឹងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ហើយមាន១៣០ករណីដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៕

## នារីរងគ្រោះចាញ់បោកគេទៅបម្រើការនៅឡាវបានបញ្ជូនដល់ច្រកព្រំដែនកម្ពុជាហើយ

https://kohsantepheapdaily.com.kh/article/1815769.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៧ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ០៩:៣៤

ខេត្តស្ទឹងត្រែង ៖ កាលពីវេលាម៉ោង១រសៀលថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៣ លោក គី មុន្នីរ័ត្ន អគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងប៉ាសេ ខេត្តចំប៉ាសាក់ បាននាំស្ត្រីរងគ្រោះ៦នាក់ ពីប្រទេសឡាវចូលមកកម្ពុជាវិញ នៅច្រកអន្តរជាតិត្រពាំងក្រៀល ខណៈអាជ្ញាធរខេត្តស្ទឹងត្រែងដឹកនាំដោយលោកស្រី កែវ សារឿន អភិបាលរងខេត្តតំណាង លោក ស្វាយ សំអ៊ាង ស្វាគមន៍ទទួលស្ត្រីរងគ្រោះ ។

លោកអគ្គកុងស៊ុលបានឱ្យដឹងថា ស្ត្រីរងគ្រោះទាំង៦នាក់ គឺមកពីខេត្តព្រះសីហនុ១នាក់ ខេត្តកំពត២នាក់ ខេត្តកំពង់ស្ពឺ២នាក់ និងរាជធានីភ្នំពេញ១នាក់ ត្រូវបានស្ថានទូតកម្ពុជាប្រចាំរដ្ឋធានីវៀងចន្ទន៍ ទំនាក់ទំនងជាមួយមន្ត្រីប៉ូលិសឡាវជួយសង្គ្រោះពីខេត្តបរកែវ តំបន់ត្រីកោណកាលពីវេលាម៉ោង៣ និង៣០នាទីរសៀលថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០២៣។ បន្ទាប់ពីមានការសង្គ្រោះរួចហើយ បានទំនាក់ទំនងមកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិត្រពាំង ក្រៀលដើម្បីជួយសម្រួលធ្វើបែបបទប្រគល់ទទួលស្ត្រីរងគ្រោះ៦នាក់ត្រឡប់ចូលប្រទេសកម្ពុជាវិញ។

ស្ត្រីរងគ្រោះក្នុងចំណោម៦នាក់បានឱ្យដឹងថា៖ ពួកគេបានចាញ់បោកមេខ្យល់យកទៅធ្វើការនៅប្រទេសឡាវតំបន់ត្រីកោណ តាំងពីខែសីហា ឆ្នាំ២០២៣ គឺមានរយៈពេល១ខែ១០ថ្ងៃគត់ ដោយដំបូងគឺការនៅផ្នែកKTVបម្រើសេវា24ម៉ោង ហើយបាន៣ថ្ងៃ ថៅកែនៅទីនោះឱ្យធ្វើជាស្ត្រីបំរើផ្លូវភេទ ២៤ម៉ោង លើ២៤ម៉ោងវិញ ដោយមានសកម្មភាពបែបនោះទើបពួកគេដែលរងគ្រោះបានបង្ហោះសារ តាមបណ្តាញសង្គមហ្វេសប៊ុក អំពាវនាវឱ្យ សមត្ថកិច្ច ជួយកាលពីព្រឹកថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៣។

លោកស្រី កែវ សារឿន អភិបាលរង នៃគណៈអភិបាលខេត្តស្ទឹងត្រែង រួមនិងមន្ទីរកិច្ចការនារីខេត្ត មន្ទីរសង្គមកិច្ចខេត្ត និងមន្ទីរព័ត៌មានខេត្ត បានទទួលស្ត្រីរងគ្រោះទាំង៦នាក់ដោយក្តីរីករាយ

បំផុត ខណៈពេលស្ត្រីទាំងនោះបានបង្ហោះសារឱ្យជួយសង្គ្រោះ និងអន្តរាគមន៍ពីសំណាក់ស្ថានទូតកម្ពុជា ។ លោកស្រីអភិបាលរងខេត្តបានផ្តល់នូវប្រសាសន៍ថា រាជរដ្ឋាភិបាលមិនប្រងើយកន្តើយទេ គឺតែងតែមានការយកចិត្តទុកដាក់ជានិច្ច ក្នុងកិច្ចអន្តរាគមន៍ដើម្បីជួយសង្គ្រោះផ្តល់នៅភាពកក់ក្តៅជានិច្ចចំពោះប្រជាជនកម្ពុជា ជាក់ស្តែង ដូចស្ត្រីរងគ្រោះទាំង៦នាក់នេះ គឺបានជួយរួចផុតពីការចាញ់បោកមេខ្យល់យកទៅលក់បំរើផ្លូវភេទនៅតំបន់ត្រីកោណ។ លោកជំទាវអភិបាលរងខេត្តបានថ្លែងអំណរគុណដល់អាជ្ញាធរឡាវ មានកិច្ចសហការប្រសើរ បំផុតជាមួយស្ថានទូតកម្ពុជា រំដោះស្ត្រីរងគ្រោះកម្ពុជាឱ្យរួចផុតពីជនខិលខូចនាំយកទៅលក់បំរើផ្លូវ ភេទ។

គួសបញ្ជាក់ថា ស្ត្រីរងគ្រោះចាញ់បោកជនខិលខូចនាំទៅបម្រើការនៅប្រទេសឡាវ(ផ្នែកKTV បម្រើសេវ៉ា24h)ពេលនេះត្រូវបានអគ្គកុងសុលខ្មែរប្រចាំនៅក្រុងប៉ាក់សេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ បានធ្វើការប្រគល់ ជូនរដ្ឋបាលខេត្តស្ទឹងត្រែង និងរដ្ឋបាលខេត្តស្ទឹងត្រែង បានទទួល និងប្រគល់ភ្លាមៗនៅអាគារប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងគ្រៀល ជូនអង្គការ ការីតាស កម្ពុជា (Caritas Cambodia) ដែលមានទីស្នាក់ការនៅខេត្តកណ្តាល តាមរយៈ អគ្គនាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនិតិសម្បទា ដើម្បីទទួលយកទៅស្នាក់នៅបស្ត្រីរងគ្រោះចាញ់បោកជនខិលខូចនាំទៅបម្រើការនៅប្រទេសឡាវបានបញ្ជូនមកដល់ច្រក់អន្តរជាតិ ត្រពាំងក្រៀលព្រំដែនកម្ពុជាឡាវ ។

# ថ្ងៃទី១០ ខែ តុលា ឆ្នាំ២០២៣

## មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវបញ្ជូននារីរងគ្រោះពីការជួញដូរមកកម្ពុជាវិញ

https://www.rfa.org/khmer/news/human-rights/cambodian-women-who-were-trafficking-in-lao-were-repatriated-to-cambodia-10072023113709.html ដោយ ថា ថៃ2023.10.07

មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ (Laos) បញ្ជូននារីរងគ្រោះពីការជួញដូរ ៦នាក់ មកកម្ពុជាវិញ ខណៈស្ត្រីរងគ្រោះម្នាក់ទៀតសមត្ថកិច្ចឡាវ និងកម្ពុជា មិនទាន់ស្វែងរកឃើញនៅឡើយ។ មន្ត្រីផ្នែកសិទ្ធិមនុស្សលើកឡើងថា ប្រសិនបើរដ្ឋាភិបាលមានចំណាត់ការត្រឹមការជួយសង្គ្រោះជនរងគ្រោះ ដោយគ្មានការស៊ើបអង្កេតស្វែងរកមេខ្លោងយកមកផ្តន្ទាទោសនោះបញ្ហាស្ត្រីខ្មែររងគ្រោះពីការជួញដូរនឹងនៅតែបន្តកើតមានដដែល។

ស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវប្រកាសនៅថ្ងៃទី៦ ខែតុលា ថា នារីរងគ្រោះពីការជួញដូរចំនួន ៦នាក់ពួកគាត់បានចាកចេញពីទីក្រុងវៀងចន្ទន៍ (Vientiane) មកកាន់ទីក្រុងបាកសេ (Bakse)

ហើយ និងវង់ចាំអគ្គកុងស៊ុលកម្ពុជាប្រចាំតំបន់នោះសម្របសម្រួលឱ្យពួកគាត់បន្តធ្វើដំណើរតាមច្រកទ្វារអន្តរជាតិត្រពាំងគ្រៀល ខេត្តស្ទឹងត្រែង ដើម្បីត្រឡប់មកកម្ពុជាវិញ។ ទោះបីជាយ៉ាងណាស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ និងអាជ្ញាធរឡាវមិនទាន់ស្វែងរកឃើញនារីខ្មែរម្នាក់ទៀតដែលរងគ្រោះពីការជួញដូរ និងបង្ហាញលទ្ធផលស៊ើបអង្កេតចុងនៅឡើយទេ។

វិទ្យុអាស៊ីសេរីមិនទាន់អាចទាក់ទងស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ ដើម្បីសាកសួរជុំវិញរឿងនេះបានទេនៅថ្ងៃទី៦ ខែតុលា។

ស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវ កាលពីថ្ងៃទី៣០ ខែកញ្ញា ប្រកាសថា សមត្ថកិច្ចឡាវនៅតំបន់ត្រីកោណមាស បានជួយសង្គ្រោះស្ត្រីខ្មែរបានចំនួន ៦នាក់ បន្ទាប់ពីក្រុមនារីរងគ្រោះទាំងនោះផ្សព្វផ្សាយជាវីដេអូលើបណ្ដាញសង្គម ដោយស្នើឱ្យអាជ្ញាធរកម្ពុជាជួយសង្គ្រោះជាបន្ទាន់ ក្រោយពីពួកគាត់ដឹងថា មេខ្យល់ និងថៅកែជនជាតិចិនបម្រុងនាំពួកគាត់ទៅលក់នៅប្រទេសផ្សេងទៀត។ ក្នុងចំណោមនារីរងគ្រោះទាំង ៦នាក់ ក្នុងនោះមាន ២នាក់ អះអាងប្រាប់វិទ្យុអាស៊ីសេរីថា ពួកគេសុទ្ធតែចាញ់បោកការល្បួងលោមលួងពីមេខ្យល់ដោយកុហកថា មានការងារទទួលបានចំណូលខ្ពស់នៅប្រទេសឡាវ ប៉ុន្តែពេលពួកគាត់ទៅដល់កន្លែងការងារថៅកែជនជាតិចិន និងមេខ្យល់បែរជាបង្ខំឱ្យអង្គុយចាំដេកជាមួយភ្ញៀវ ឬបម្រើផ្លូវភេទទៅវិញ។

អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ប្រាប់វិទ្យុអាស៊ីសេរីថា សមត្ថកិច្ចកម្ពុជា និងឡាវ នៅតែបន្តសហការស្វែងរកនារីខ្មែរម្នាក់ទៀតដែលរងគ្រោះពីការជួញដូរ។ អ្នកស្រីអះអាងទៀតថា សមត្ថកិច្ចនៃប្រទេសទាំងពីរក៏កំពុងស្រាវជ្រាវស្វែងរកមេខ្យល់ និងមេខ្លោងពាក់ព័ន្ធនឹងការជួញដូរមនុស្សយកមកផ្ដន្ទាទោសតាមច្បាប់ដែរ។ អ្នកស្រីអំពាវនាវឱ្យពលរដ្ឋខ្មែរបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះបុគ្គល ឬប្រភពមិនច្បាស់លាស់ដែលឃោសនាក្នុងគោលបំណងឱ្យបង់ប្រាក់ដល់ពួកគេបន្តិចបន្តួច ហើយទទួលបានការងារធ្វើនៅក្រៅប្រទេសទទួលបានប្រាក់ចំណូលខ្ពស់។

អ្នកស្រី ជូ ប៊ុនអេង៖ «ដូចពួកគាត់អ៊ីចឹងពេលដែលទៅ គេប្រាប់ឱ្យធ្វើការនៅទីនោះ [ប្រទេសឡាវ] មួយខែក្នុងម្នាក់ទទួលបាន ៥ពាន់ដុល្លារ។ គិតថា គាត់អាចទៅរួចទេ? នៅពេលដែលរបស់ងាយពេកដោយយើងអត់មានសមត្ថភាព ហើយយើងជាអ្នកនៅវ័យក្មេងទៅទៀត ប៉ុន្តែនេះគឺជាការអូសទាញរបស់មេខ្យល់ ឬមួយរបស់ជនល្មើស។ បណ្ដាញមេខ្យល់មិនមែននៅក្នុងប្រទេសណាមួយទេ គឺវេបណ្ដាញរហូតដល់ប្រទេសធំៗក៏មានជនល្មើសនៅទីនោះដែរ ពីព្រោះគេបានប្រើវិធីសាស្ត្រអូសទាញតាមប្រព័ន្ធអនឡាញ»។

ជុំវិញរឿងនេះ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា បញ្ហាពលរដ្ឋខ្មែររងគ្រោះព្រោះការជួញដូរនៅក្រៅប្រទេសនៅតែក្តីព្រួយបារម្ភ ព្រោះលោកថា អាជ្ញាធរពាក់ព័ន្ធមិនទាន់ចាត់វិធានការលើក្រុមមេខ្យល់ និងមេខ្លោងជួញដូរមនុស្សឱ្យមានប្រសិទ្ធភាពនៅឡើយ។ ក្រៅពីនេះ លោកជំរុញដល់រដ្ឋាភិបាលបង្កើនការផ្តល់កិច្ចគាំពារដល់ស្ត្រីខ្មែររងគ្រោះ និងវាយតម្លៃផលប៉ះពាល់ផ្នែកស្មារតី និងរាងកាយ ដើម្បីបញ្ជូនពួកគាត់ទៅប្រឹក្សាជាមួយអ្នកជំនាញបានទាន់ពេល។

លោក ឌី ថេហូយ៉ា៖ «ទាំងបញ្ហាផ្លូវកាយ ផ្លូវចិត្ត ធម្មតាជនរងគ្រោះគាត់រងគ្រោះទាំងពីរ ការជួយសង្គ្រោះជនរងគ្រោះយើងត្រូវធ្វើការវាយតម្លៃថា តើគាត់រងគ្រោះទៅលើអ្វីខ្លះ? អ៊ីចឹងរដ្ឋាភិបាលក៏គួរពិចារណា ទៅលើការគាំពារ ផ្នែកសេដ្ឋកិច្ច ហើយមួយទៀតពាក់ព័ន្ធផ្នែកវិជ្ជាជីវៈ។ ធម្មតាមនុស្ស ឬប្រជាពលរដ្ឋនៅក្នុងសង្គមមួយដែលគាត់អត់វិជ្ជាជីវៈដែលអត់អាចរកការងារធ្វើបាន ថ្ងៃមុខថ្ងៃក្រោយគាត់លំបាក គាត់គង់តែអាចភ្ញាត់ស្នៀតចាញ់បោកគេដដែលទេ អ៊ីចឹងរបៀបនៃការធ្វើការរបស់រដ្ឋត្រូវសិក្សាពិចារណាឱ្យបានល្អិតទៅចំណុចទាំងអស់ហ្នឹង»។

លោក ឌី ថេហូយ៉ា ព្រួយបារម្ភអំពីស្ថានភាពនៃមន្ត្រីអាជ្ញាធរប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធដែលជាហេតុនាំឱ្យក្រុមមេខ្យល់នៅតែហ៊ានប្រព្រឹត្តអំពើជួញដូរមនុស្ស។ លោកបន្ថែមថា បើរដ្ឋាភិបាលចាត់វិធានការត្រឹមការជួយសង្គ្រោះជនរងគ្រោះ ហើយគ្មានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងគ្មានការស្វែងរកជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សយកផ្តន្ទាទោសទេនោះ ពលរដ្ឋ ជាពិសេសស្ត្រីខ្មែរនៅតែប្រឈមរងគ្រោះពីការជួញដូរតាមរយៈមេខ្យល់យកទៅលក់នៅក្រៅប្រទេសដដែល៕

## អាជ្ញាធរគ្រោងបណ្តេញជនជាតិជប៉ុន
## ២៥នាក់ចេញពីកម្ពុជាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស

https://www.rfa.org/khmer/news/human-rights/cambodian-expelled-25-japanese-who-were-involved-with-human-trafficking-10072023102701.html 2023.10.07

អាជ្ញាធរកម្ពុជាគ្រោងបណ្តេញជនជាតិជប៉ុន (Japan) ២៥នាក់ ចេញពីប្រទេសកម្ពុជា និងដាក់ចូលក្នុងបញ្ជីខ្មៅមិនឲ្យពួកគេជាន់ទឹកដីកម្ពុជាឡើយ ដោយសារតែពួកគេជាប់ពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស។

អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍លោក កែវ វណ្ណថន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៦ ខែ តុលា ថា សមត្ថកិច្ចបានបញ្ជូនជនជាតិជប៉ុនទាំងនោះមកដល់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ហើយលោកក៏បានរៀបចំឯកសារត្រៀមបញ្ជូនពួកគេចេញពីប្រទេសកម្ពុជាដែរ។

អ្នកនាំពាក្យរងនៃក្រសួងមហាផ្ទៃ លោក ទូច សុខៈ ប្រាប់កាសែតក្នុងស្រុកថា សមត្ថកិច្ចបានចុះបង្ក្រាបជនជាតិជប៉ុនមួយក្រុមនៅចំណុចអគារស្កាយឡាញ (Skyline) ក្នុងរាជធានីភ្នំពេញ កាលពីខែកញ្ញា បន្ទាប់ពីស្ថានទូតជប៉ុនស្នើឱ្យសមត្ថកិច្ចអន្តរាគមន៍ជួយជនរងគ្រោះម្នាក់រងការបង្ខាំង និងអំពើហិង្សា។ ក្រៅពីការឃាត់ខ្លួនជនសង្ស័យជនជាតិជប៉ុន ២៥នាក់ ក្រសួងមហាផ្ទៃកាលពីដើមខែកញ្ញា ប្រកាសតាមចាប់ខ្លួនជនបរទេស ៣នាក់ទៀត ដែលពាក់ព័ន្ធនឹងការបង្ខាំងមនុស្សនេះ។ ប៉ុន្តែមកទល់ពេលនេះសមត្ថកិច្ចមិនទាន់ចាប់ខ្លួនពួកគេបាននៅឡើយ។

កាលពីឆ្នាំ២០២២ សមត្ថកិច្ចបានបណ្តេញបរទេសជាង ៣ពាន់នាក់ ក្នុងនោះជនជាតិចិនជាង ១ពាន់ ៣រយនាក់ (១.៣០៨) ឱ្យត្រឡប់ទៅប្រទេសពួកគេវិញ ដោយសារតែពួកគេភាគច្រើនជាប់ពាក់ព័ន្ធឧក្រិដ្ឋកម្មឆ្លងដែន កាន់កាប់អាវុធខុសច្បាប់ ជួញដូរគ្រឿងញៀន និងជួញដូរមនុស្សជាដើម។

អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សថ្មីៗនេះ រកឃើញថា មានមនុស្សប្រមាណ ១សែននាក់ត្រូវបានបង្ខំឱ្យធ្វើការបោកប្រាស់តាមអនឡាញ (Online) នៅកម្ពុជា ហើយជនរងគ្រោះប្រឈមមុខនឹងការរំលោភបំពាន គំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខ។ ក្រៅពីនេះ មនុស្សជាច្រើនបានទទួលរងការធ្វើទារុណកម្ម និងប្រព្រឹត្តិដោយឃោរឃៅ អមនុស្សធម៌ ការឃុំខ្លួនដោយបំពាន និងអំពើហិង្សាផ្លូវភេទជាដើម។

## បង្ក្រាបទីតាំងម៉ាស្សាមួយកន្លែង ឃាត់ខ្លួននារីៗ៧នាក់ ចំណែកថៅកែប្រុសរត់គេចខ្លួនបាត់

https://kohsantepheapdaily.com.kh/article/1817231.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ១០ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ០៩:២៣

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា ផ្ទះម៉ាស្សាមួយកន្លែងឃីហោ «ពន្លៃជក់ចិត្ត» ត្រូវបាននាយកដ្ឋានជួញដូរមនុស្ស និងការពារអនីតិជន ចុះឃាត់ខ្លួនបានមនុស្សចំនួន ៧នាក់ ចំណែកឯថៅកែប្រុសវិញរត់គេចខ្លួនបាត់ស្រមោល បង្កឱ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៩និង៣០នាទីយប់ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ស្ថិតនៅក្នុងភូមិក្បាលដំរីទី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

តាមប្រភពព័ត៌មានពីនគរបាលនាយកដ្ឋានជួញដូរមនុស្ស និងការពារអនីតិជន បានប្រាប់ឱ្យដឹងថា ទីតាំងខាងលើនេះ មានបងប្អូនប្រជាពលរដ្ឋបានរាយការណ៍ទៅកម្លាំងសមត្ថកិច្ចថា «មានក្មេងស្រីៗខ្លះក្រោមអាយុ១៧ឆ្នាំ បានមកធ្វើជានារីម៉ាស្សា និងមានចបង្កប់សេវាបម្រើកម្សាន្ត ដោយលួចលាក់»។ បន្ទាប់មកកម្លាំងនគរបាលនាយកដ្ឋានជួញដូរមនុស្ស និងការពារអនីតិជន សហការ

ជាមួយកម្លាំងនគរបាលប៉ុស្តិ៍ រួមទាំងសមត្ថកិច្ចនគរបាលខណ្ឌពោធិ៍សែនជ័យ និងអាជ្ញាធរខណ្ឌ ដើម្បីចុះបង្ក្រាបទីតាំងម៉ាស្សាខាងលើភ្លាមៗតែម្តង។

សមត្ថកិច្ចបានបញ្ជាក់ប្រាប់ថាខណៈពេលកម្លាំងនគរបាលចុះមកដល់កន្លែងកើតហេតុភ្លាមៗ ថៅកែប្រុសម្នាក់ក៏រត់គេចខ្លួនបាត់ស្រមោលតែម្តង នៅសល់តែនារីចំនួនចំនួន៧នាក់នៅក្នុងហាងម៉ាស្សាឃីហោ «៣ន្ទៃជក់ចិត្ត» បន្ទាប់មកកម្លាំងនគរបាលក៏បានឃាត់នារីៗទាំងនោះយកមកសាកសួរភ្លាមៗផងដែរ។ ក្រោយពេលកើតហេតុ កម្លាំងនគរបាលនាយកដ្ឋានជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូននារីម៉ាស្សាទាំង៧នាក់ទៅផ្នែកជំនាញ ដើម្បីចាត់ការតាមនីតិវិធីនៃច្បាប់បន្តទៀត៕

## អង្គការ ២ ផ្សព្វផ្សាយការយល់ដឹងពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញដល់កុមារ

https://www.postkhmer.com/national/2023-10-09-1018-255104.html សំបាន ច័ន្ទដារ៉ា | Publication date 09 October 2023 | 10:18 ICT

**ភ្នំពេញៈ** អង្គការសេរីភាពកម្ពុជា-អូស្ត្រាលី និងអង្គការដែនដីមនុស្សហូឡង់ដ៍ប្រចាំកម្ពុជាធ្វើយុទ្ធនាការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹង ពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញសម្រាប់កុមារ ជាពិសេសសម្រាប់កុមារី និងយុវតីរយៈពេល ១ ខែ។ យុទ្ធនាការនេះ ធ្វើឡើងក្នុងគោលដៅលើកកម្ពស់ការយល់ដឹងពីសុវត្ថិភាពនៃការប្រើប្រាស់បណ្តាញសង្គម និងជំរុញការចូលរួមពីតួអង្គកុមារផ្ទាល់ ដើម្បីបញ្ឈប់ការរំលោភបំពាននៅលើប្រព័ន្ធអ៊ីនធឺណិត លើកុមារ ខណៈគេរកឃើញថា ក្មេងស្រី ១ នាក់ ក្នុងចំណោម ១០ នាក់រងហានិភ័យពីការបំពានលើប្រព័ន្ធអនឡាញ។

យោងតាមសេចក្តីប្រកាសព័ត៌មានអង្គការដែនដីមនុស្សហូឡង់ដ៍ប្រចាំកម្ពុជា នៅថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០២៣ បានឱ្យដឹងថា យុទ្ធនាការនេះធ្វើនៅតាមសាលារៀនរយៈពេល ១ ខែ ចាប់ផ្តើមពីថ្ងៃទី ៧ ខែតុលា តាមរយៈគម្រោង «សុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ» ហៅកាត់ថា «ស្ក្រូល SCROL» ដែលគាំទ្រថវិកាដោយក្រុមហ៊ុនឆ្នោតហូឡង់ (Dutch Postcode Lottery NPL)។

នៅថ្ងៃដំបូង នៃយុទ្ធនាការនេះបានប្រារព្ធឡើងនៅវិទ្យាល័យចំរើនផល ដែលរៀបចំឡើងដោយយុវតីនាវិទ្យាល័យនេះផ្ទាល់ដែលបានជជែកក្នុងប្រធានបទ «តើប្រើប្រាស់បណ្តាញសង្គម ជាមូលហេតុនាំឱ្យមានការរំលោភបំពានកុមារ ឬយ៉ាងណា? ដោយមានអ្នកចូលរួមប្រមាណ ៣៥០ នាក់ និងវត្តមាននាយកសាលា លោកគ្រូ-អ្នកគ្រូ និងអាណាព្យាបាលសិស្ស និងមន្ត្រីជំនាញជាច្រើនទៀត។

លោកស្រី Zoe De Melo ប្រធានគម្រោងការពារកុមារពីការរំលោភបំពានតាមប្រព័ន្ធអនឡាញ នៃអង្គការដែនដីមនុស្សហូឡង់ដ៍ប្រចាំកម្ពុជាថ្លែងតាមរយៈសេចក្តីប្រកាសព័ត៌មានថាៈ « យើងជំរុញឱ្យមាន ការចូលរួមយ៉ាងសកម្មពីកុមារដើម្បីបង្កើតឱ្យមានទម្លាប់សុវត្ថិភាពតាមប្រព័ន្ធអន

ឡាញ ជាពិសេសការប្រើប្រាស់បណ្ដាញសង្គមប្រកបដោយសុវត្ថិភាព»។ លោកស្រីបន្តថា៖ «វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពួកយើង ក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយនេះឡើងនៅតាមសាលារៀន ដើម្បីឱ្យកុមារជាច្រើនបានយល់ដឹងពីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ»។

លោក សេក សុជាតិ នាយកប្រតិបត្តិអង្គការអភិវឌ្ឍន៍ផ្នត់គំនិត និងជាអ្នកជំនាញផ្នែកព័ត៌មានវិទ្យា បានប្រាប់ឱ្យដឹងថា យុទ្ធនាការនេះ ជារឿងល្អ ខណៈសង្គមកម្ពុជាកំពុងបើកទូលាយឱ្យមានការប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់មនុស្សគ្រប់វ័យ ជាពិសេសប្រព័ន្ធទំនាក់ទំនងសង្គមនានា។ លោកបន្តថា មានជនឆ្លៀតឱកាស និងជនខិលខូចមួយចំនួនកំពុងប្រើប្រាស់ដើម្បីរំលោភបំពានសិទ្ធិអ្នកដទៃ ក៏ដូចជារំលោភបំពានលើកុមារ ជាពិសេសក្រុមសិស្សានុសិស្ស ដែលក្រុមឧក្រិដ្ឋជនយកជាមុខសញ្ញាដើម្បីប្រព្រឹត្តអំពើល្មើសច្បាប់ ឬយកទៅបង្កើតលាភសក្ការៈនានាក្នុងផ្លូវទុច្ចរិត។

លោក សេក សុជាតិ ថា៖ «យុទ្ធនាការនេះ ជាយុទ្ធនាការល្អ ដែលខ្ញុំគាំទ្រ ហើយសុំឱ្យមានការធ្វើជាប់ជាប្រចាំ និងបានទូលំទូលាយ ដើម្បីផ្ដល់ការយល់ដឹងដល់យុវជន ជាពិសេសរង្វង់កុមារយុវតីនានា បានជ្រាបពីបញ្ហាប្រឈម និងអាចចេះការពារខ្លួន ដើម្បីបញ្ចៀសបញ្ហានៅថ្ងៃអនាគត»។ លោកថ្លែងថា រដ្ឋាភិបាល និងផ្នែកពាក់ព័ន្ធគួរបន្ថែមការយកចិត្តទុកដាក់ទៅលើសុវត្ថិភាពតាមប្រព័ន្ធអនឡាញរបស់កុមារ ជាពិសេសកុមារី និងយុវតី ដែលជាទំពាំងស្នងឫស្សីដែលជារឿងចាំបាច់សម្រាប់អនាគតប្រទេសជាតិ ឱ្យពួកគេយល់ដឹង ចេះការពារខ្លួន ចេះពិចារណាវែងឆ្ងាយ ចេះដោះស្រាយបញ្ហាដែលជួបប្រទះ។

«ស្រួល» ជាគម្រោងមានរយៈពេល ៣ ឆ្នាំ បានបង្កើត និងអនុវត្តដោយ អង្គការដែនដីមនុស្សហូឡង់ប្រចាំនៅកម្ពុជា ដោយមានការសហការ ជាមួយអង្គការដៃគូដូចជាអង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គការសេរីភាពកម្ពុជា-អូស្ត្រាលី (AusCam Freedom Project)៕

# ថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០២៣

## មន្ត្រីជាន់ខ្ពស់កម្ពុជា អំពាវនាវដល់គ្រប់ភាគីចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស

https://www.cnc.com.kh/detail/news/45789 ១១-តុលា-២០២៣ ០២:៣៥ ល្ងាច អត្ថបទ៖ ជា ស្រស់

សៀមរាប៖ មន្ត្រីជាន់ខ្ពស់កម្ពុជា បានលើកឡើងថា បើទោះបីជាកម្ពុជានៅមានសុវត្ថិភាពក្តី ប៉ុន្តែអំពើជួយញដូរមនុស្សនៅលើពិភពលោក នៅមិនទាន់មានសភាពស្ងប់ស្ងាត់ទៅឡើយនោះទេ។ ដូច្នេះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវរួមគ្នាទប់ស្កាត់ឲ្យខានតែបាន។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍លើកឡើងបែបនេះ ប្រាប់ CNC នៅក្នុងឱកាសដែលលោកស្រីអញ្ជើញចូលរួមនៅក្នុងពិធីដង្ហែក្បួនព្យុហយាត្រា "ដំណើរឆ្ពោះទៅបញ្ឈប់អំពើជួញដូរមនុស្ស" នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ នាក្រុងសៀមរាប។

លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍ថា សកម្មភាពជួញដូរមនុស្សនៅលើពិភពលោក នៅមិនទាន់ស្ងប់ស្ងាត់នៅឡើយទេ ជាពិសេសនៅក្នុងកាលៈទេសៈដែលពិភពលោកកំពុងជួបនូវវិបត្តិដូចបច្ចុប្បន្ននេះ ឧក្រិដ្ឋជនបានឆ្លៀតឱកាសប្រើគ្រប់មធ្យោបាយក្នុងការអូសទាញប្រជាពលរដ្ឋឲ្យធ្លាក់ចូលក្នុងការកេងប្រវ័ញ្ចរបស់ពួកគេ។ លោកស្រីបន្តថា ដូច្នេះកម្មវិធីដែលធ្វើឡើងនៅក្រុងសៀមរាបនាថ្ងៃនេះ ត្បិតតែមានអ្នកចូលរួមតែជា៦០០នាក់ ប៉ុន្តែវាជានិមិត្តរូបនៃការចូលរួមរបស់ប្រជាជននៅលើពិភពលោកនៅក្នុងការរួមគ្នាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ហើយក៏ចង់បង្ហាញថា កម្ពុជា នៅមានសុវត្ថិភាពនៅឡើយទេ។

ក្រុមយុវជន ដែលជាអ្នកផលិតមាតិកាតាមបណ្តាញសង្គម កញ្ញាយូប៊ី កញ្ញា អេមីកា និងលីនចាស្ទីន បានលើកឡើងថា អំពើជួញដូរមនុស្សមានច្រើនទម្រង់ និងបង្កផលប៉ះពាល់ដល់មនុស្សគ្រប់វ័យ និងជំរុញនិងលើកទឹកចិត្តដល់ជនរងគ្រោះ ត្រូវក្លាហាននៅក្នុងការស្វែងរកការជួយអន្តរាគមន៍ ពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលេខទូរស័ព្ទ១២៨៨ ។ កញ្ញា គ្រីស្ទីន ស្កាហ្វ នាយិកាមូលនិធិ អេ២១ បានលើកឡើងថា អំពើជួញដូរមនុស្ស បានបង្កផលវិបាកជាច្រើនជាពិសេសបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរជនរងគ្រោះទាំងផ្លូវកាយ ផ្លូវចិត្ត និងបង្កការឈឺចាប់អស់ពេញមួយជីវិតរបស់ពួកគាត់។ កញ្ញាបន្តថា ការដែលយើងអនុញ្ញាតឲ្យបទល្មើសមួយនេះកើតឡើង វាស្មើនឹងយើងចូលរួមធ្វើឲ្យជនរួមជាតិរបស់យើងក្លាយជាជនរងគ្រោះ។ កញ្ញា បានបន្តថា ការជួញដូរមនុស្ស ហៅថា ទាសភាពសម័យទំនើប នៅតែមានអទិភាព ប៉ុន្តែ យើងទាំងអស់គ្នាអាចធ្វើកិច្ចការមួយចំនួនដើម្បីជួយបញ្ឈប់វាបាន។

កញ្ញា គ្រីស្ទីន បានលើកឡើងថា វាមិនមែនជារឿងសម្ងាត់នោះទេ ដែលថា អំពើជួញដូរមនុស្សគឺជា បទល្មើសដ៏លំបាក និងស្មុគស្មាញមួយក្នុងការប្រយុទ្ធប្រឆាំង។ ភាពអយុត្តិធម៌ជាសកលនេះ គ្មានព្រំដែននោះទេ វាមានផលប៉ះពាល់ដល់គ្រប់ប្រទេស គ្រប់ពូជសាសន៍ ភេទ និងសាវតាផ្នែកសេដ្ឋកិច្ចសង្គម។ កុមារ មនុស្សពេញវ័យ ស្ត្រី បុរស អ្នកស្រលាញ់ភេទដូចគ្នា ជនពិការ និងបុគ្គលស្លូតត្រង់ កំពុងត្រូវគេឆបោក លក់ ជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវកាយ និងផ្លូវភេទ ដើម្បីប្រាក់ចំណេញ និងអត្ថប្រយោជន៍របស់ចារី និង ជនជួញដូរនៅទូទាំងពិភពលោក។ វាប្លន់សិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងសេរីភាពរបស់បុគ្គលទាំងឡាយ។ជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្ត ដែលជាញឹកញាប់ ទទួលរងការឈឺចាប់ដែលនឹងស្មាន មិនដល់ តាមរយៈការអនុញ្ញាតឱ្យបទល្មើសនេះនៅតែបន្តកើតមាន យើងកំពុងចូលរួមធ្វើឲ្យមនុស្សជាតិ របស់យើងក្លាយជាជនរងគ្រោះ។

កញ្ញា បន្តថា មនុស្សមួយចំនួនប្រហែលជាពិបាកយល់អំពីការពិតនៃអំពើជួញដូរមនុស្ស ពីព្រោះ ប្រសិនបើអ្នកមិនធ្លាប់ជួប ប្រទះ ឬមិនស្គាល់នរណាម្នាក់ដែលធ្លាប់ជួបប្រទះដោយផ្ទាល់ទេនោះ អ្នកប្រហែលជាគិតថា វាគឺជាបញ្ហាឆ្ងាយ ដែលកើតឡើងតែនៅកន្លែងឆ្ងាយៗ ឬនៅក្នុងខ្សែភាពយន្តប៉ុណ្ណោះ។ ប៉ុន្តែវាកើតឡើងនៅក្នុងសហគមន៍របស់ យើងផ្ទាល់។ បច្ចេកវិទ្យាមានភាពជឿនលឿនយ៉ាងខ្លាំង ដែលធ្វើឲ្យជនជួញដូរ និងអ្នកសមគំនិត អាចចូលទៅជិត ប្រជាជនបានកាន់តែងាយស្រួល តាមរយៈឧបករណ៍ដែលយើងកាន់ជារៀងរាល់ថ្ងៃ ដូចជាទូរស័ព្ទដៃជាដើម ។ នៅពេលដែលយើងព្រងើយកន្តើយនឹងបញ្ហានេះ យើងបង្កើតវប្បធម៌មួយ ដែលអនុញ្ញាតឱ្យជនជួញដូរអាច ដំណើរការបានដោយសេរី។

អភិបាលរងនៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តសៀមរាប លោកស្រី យូ សុភា បានបញ្ជាក់ថា ខេត្តសៀមរាប ជាប៉ូលទេសចរណ៍មួយដ៏សំខាន់ របស់ព្រះរាជាណាចក្រកម្ពុជា ដែលមានប្រាសាទអង្គរវត្ត ជាសម្បត្តិបេតិកភណ្ឌពិភពលោក និងមានតំបន់ទេសភាពធម្មជាតិអេកូទេសចរណ៍ជាច្រើនកន្លែងផ្សេងទៀតសម្រាប់ភ្ញៀវទេសចរទេស្សនាកម្សាន្ត ។ ទន្ទឹមនឹងផលវិជ្ជមានពីសេវាកម្មទេសចរណ៍ ក៏យើងបានទទួលរងផលជាអវិជ្ជមានផងដែរ ពីអ្នកទេសចរមួយចំនួន ដែលមានបំណងទុច្ចរិត បានប្រព្រឹត្តបទល្មើសរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ តាមរូបភាពផ្សេងៗ និងការយកខេត្តសៀមរាប ជាខេត្តសម្រាប់ឆ្លងកាត់ការនាំចេញមនុស្សដោយខុសច្បាប់ និងកន្លែងសម្រាប់ប្រព្រឹត្តបទល្មើសផងដែរ ។

លោកស្រីបន្តថា អំពើជួញដូរមនុស្សគឺជាវិបត្តិសកលមួយដែលបណ្ដាប្រទេសជាច្រើនបានជួបប្រទះហើយកម្ពុជាយើងក៏ទទួលរងពីវិបត្តិនេះផងដែរ ដែលធ្វើឲ្យរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដីរាជរដ្ឋាភិបាល និងអង្គការដៃគូ បានខិតខំរិះរកគ្រប់វិធានការ ក្នុងន័យរួមគ្នាដោះស្រាយលើបញ្ហានេះ ឆ្ពោះទៅការសម្រេចឲ្យបានក្នុងការលុបបំបាត់គ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស។

## ពលករខ្មែរ
## ចាប់ផ្ដើមចាកចេញពីប្រទេសថៃវិលត្រឡប់ មកស្រុកកំណើតចូលរួមពិធីបុណ្យភ្ជុំបិណ្ឌ

https://www.kampucheathmey.com/local-news/594054 ថ្ងៃអង្គារ ១០ តុលា ២០២៣ deth leng

ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ បានចាប់ផ្ដើមវិលត្រឡប់មកស្រុកកំណើតរៀងៗខ្លួនដើម្បីចូលរួមពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌដើម្បីជួបជុំសាច់ញាតិ និងធ្វើបុណ្យឧទ្ទិសកុសលដល់បុព្វការីជនដែលបានចែកឋានទៅបរមលោក។

លោក កត្តា អ៊ន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍នៅរសៀលថ្ងៃទី ១០ ខែតុលានេះថា ពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌឆ្នាំនេះមានបងប្អូនប្រជាពលរដ្ឋរួមទាំងពលករខ្មែរធ្វើការនៅថៃ បាននាំគ្នាវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីធ្វើដំណើរទៅតាមស្រុកកំណើតរបស់ខ្លួនជួបជុំឪពុកម្ដាយសាច់ញាតបងប្អូន និងធ្វើបុណ្យឧទ្ទិសកុសល្យជូនដូនតាដែលបានចែកឋាននាពេលកន្លងទៅ។

លោកបានបន្តថា ប្រជាពលរដ្ឋ រួមទាំងពលករធ្វើដំណើរពីប្រទេសថៃចូលមកតាមច្រកព្រំដែនខេត្តបាត់ដំបង និងបន្ទាយមានជ័យ ក្នុងនោះនៅខែកញ្ញាតាមច្រកព្រំដែនប៉ោយប៉ែតខេត្តបន្ទាយមានជ័យមានចំនួនសរុប ៤៨៩ នាក់ស្រី ១៩៥នាក់ និងច្រកដូងខេត្តបាត់ដំបង សរុបចំនួន ៥ ៨៧៧ ស្រី ២ ៨០៦ នាក់ សរុបរួមខែកញ្ញាមានចំនួន ៦ ៣៦៦ ស្រី ៣ ០០១នាក់។

ចំណែកខែតុលាវិញ តាមច្រកព្រំដែនប៉ោយប៉ែត មានចំនួន ៤៦៩ នាក់ ស្រី ១៨៨ នាក់ និងច្រកដូងមានចំនួន២៨៥៤នាក់ស្រី ១១៧១នាក់សរុបរួមខែតុលា ៣៣២៣ នាក់ស្រី ១៣៥៩ នាក់។ លោកបានបន្តទៀតថា ជារួមចាប់ពីខែកញ្ញា ដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ មានប្រជាពលរដ្ឋ និងពលករខ្មែរវិលត្រឡប់មកពីប្រទេសចំនួន៩៦៨៩នាក់ ស្រី៤៣៦០នាក់។

បើតាមលោក កត្តា អ៊ន គិតត្រឹមខែសីហាឆ្នាំ ២០២៣ កម្ពុជាមានពលករកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសចំនួន១៣៤២៩៦៣ នាក់ ស្រី ៥៤៦៩៨១ នាក់ក្នុងនោះនៅប្រទេសថៃមានចំនួន ១២៤៨២៤៥ នាក់ស្រី ៥០២២៥០នាក់។ អត្ថបទ៖ សំអឿន

# ឧត្តមសេនីយ៍ឯក សៀក សុជាតិ ដឹកនាំប្រជុំពង្រឹងការគ្រប់គ្រង និងសម្រួលដំណើរចេញ-ចូល ឆ្លងកាត់ព្រំដែនរបស់ពលករនៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ

https://freshnewsasia.com/index.php/en/localnews/313717-2023-10-12-01-38-18.html 2023-10-12 08:38am

**(បន្ទាយមានជ័យ)៖** *ដោយមានការយកចិត្តទុកដាក់ដ៏របស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា និងមានការណែនាំជាប្រចាំរបស់ឧបនាយករដ្ឋមន្ត្រី នេត សាវឿន ប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជា,ប្រធានក្រុមការងារនីមួយៗបានចាប់ផ្តើមដឹកនាំប្រជុំនិងចុះត្រួតពិនិត្យភ្លាមៗនៅតាមព្រំដែន។*

*ជាក់ស្តែងនាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ រដ្ឋលេខាធិការ ក្រសួងការពារជាតិ អនុប្រធានគណៈកម្មការចំពោះកិច្ច និងជាក្រុមការងារទី២ នៃគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែនកម្ពុជា ទទួលបន្ទុកខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ បានដឹកនាំក្រុមការងារពាក់ព័ន្ធ ដើម្បីពិតិត្យ និងពង្រឹងលើបញ្ហាការងារតាមព្រំដែន និងការធ្វើដំណើរចេញ-ចូល របស់កម្មករនៅតាមច្រកទ្វារព្រំដែន ព្រមទាំងទប់ស្កាត់បញ្ហាណាមួយដែលមនឹងកើតឡើងជាយថាហេតុ។*

*ក្នុងកិច្ចប្រជុំនេះដែរ លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ ក៏បានណែនាំឱ្យបង្កើតក្រុមការងារមួយដើម្បីប្រចាំការនៅតាមច្រកទ្វារព្រំដែន ដើម្បីប្រចាំការនៅតាមច្រកទ្វារព្រំដែន។ បន្ថែមពីនេះ ត្រូវបង្ហាញលេខទូរស័ព្ទ សម្រាប់ប្រជាពលរដ្ឋទាក់ទង ផ្តល់ព័ត៌មានផ្សេងៗជាដើម ដើម្បីជួយសម្រួល អន្តរាគមន៍ និងដោះស្រាយបញ្ហាជូនពួកគាត់ផងដែរ។* ***លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ ក៏បានស្នើសុំអភិបាលខេត្តទាំង៣ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តនូវការងារមួយចំនួន ដូចខាងក្រោម៖***

***ទី១៖*** *ត្រូវណែនាំដល់សមត្ថកិច្ចឈរជើងនៅតាមច្រកទ្វារព្រំដែនផ្លូវការ បង្កលក្ខណៈងាយស្រួល ដល់ដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែន ជាពិសេសនៅក្នុងរដូវភ្ជុំបិណ្ឌ។ ត្រូវបើកច្រកទ្វារព្រំដែនផ្លូវការទាំងអស់ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ពលករខ្មែរចេញ-ចូល បានឆាប់រហ័ស និងទាន់ពេលវេលា។*

***ទី២៖*** *ត្រូវចាត់វិធានការដើម្បីពង្រឹងការទទួលខុសត្រូវលើសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅតាមបណ្តាច្រកទ្វារព្រំដែន។*

**ទី៣៖** ត្រូវក្រើនរំលឹក និងណែនាំដល់សមត្ថកិច្ចឈរជើងនៅតាមបណ្តាច្រកទ្វារព្រំដែនទាំងអស់ឱ្យបញ្ឈប់ជាបន្ទាន់នូវការយកកម្រៃក្រៅផ្លូវការពីពលករ។

**ទី៤៖** ត្រូវចាត់តាំងថ្នាក់ដឹកនាំខេត្តសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ តាមដានជាប្រចាំអំពីស្ថានភាពនៃការធ្វើដំណើរចេញ-ចូលរបស់ពលករខ្មែរ និងរាយការណ៍មកក្រុមការងារត្រួតពិនិត្យដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែន នៅមុនម៉ោង១៦ និង៣០នាទី ជារៀងរាល់ថ្ងៃ។

**ទី៥៖** ត្រូវបិទច្រករបៀងខុសច្បាប់ទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីបញ្ចៀសពលករកុំឱ្យចាញ់បោកមេខ្យល់។

**ទី៦៖** ត្រូវគ្រប់គ្រងស្ថិតិ និងលំហូរពលករចេញ-ចូលឆ្លងកាត់ព្រំដែនឱ្យបានច្បាស់លាស់ ព្រមទាំងខិតខំដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើង។

**ទី៧៖** ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពមេខ្យល់ និងអ្នកសមគំនិត ដែលអូសទាញ ពលករឱ្យឆ្លងដែនខុសច្បាប់តាមគ្រប់រូបភាព។

**ទី៨៖** អាជ្ញាធរខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធនៅតាមច្រកទ្វារព្រំដែនត្រូវសហការសម្របសម្រួលជាមួយ អាជ្ញាធរថៃ ដើម្បីសម្រួលភាពងាយស្រួលដល់ដំណើរចេញ ចូលរបស់ពលករខ្មែរ។

**និងទី៩៖** ត្រូវផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមសហការ និងរាយការណ៍នូវរាល់ភាព មិនប្រក្រតីនានានៅតាមតំបន់ព្រំដែន និងតាមបណ្តាច្រកទ្វារព្រំដែន។

ដោយឡែកសម្រាប់ព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣នេះ លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ បានដឹកនាំក្រុមការងារបន្តចុះត្រួតពិនិត្យច្រកព្រំដែនម៉ាឡៃ, ច្រកបឹងត្រកួន និងពេលរសៀលត្រលប់មកជួបជុំគ្នានៅច្រកអន្តរជាតិប៉ោយប៉ែតដើម្បី ប្រជុំបូកសរុបលទ្ធផល (តាមពេលវេលាជាក់ស្តែង)៕

## អង្គការមនុស្សធម៌
## ជួយសង្គ្រោះជនរងគ្រោះម៉ាឡេស៊ីដែលធ្លាក់ខ្លួនចាញ់បោកក្រុមឆបោកនៅកម្ពុជា

https://www.khmertimeskh.com/501374138//?p=1374138 October 10, 2023

នៅក្នុងប្រតិបត្តិការមួយ អង្គការមនុស្សធម៌អន្តរជាតិម៉ាឡេស៊ី (MHO) បានផ្តល់ព័ត៌មានសំខាន់ៗដល់នគរបាលកម្ពុជា ដើម្បីជួយសង្គ្រោះជនរងគ្រោះម៉ាឡេស៊ី ដែលបានចាញ់បោកក្រុមផ្តល់ការងារក្លែងក្លាយ។ ក្នុងពេលជាមួយគ្នានេះ ពួកគេបានបំបែកទីតាំងក្រុមឆបោកមួយនៅក្រុងព្រះសីហនុ។ ជាងនេះទៅទៀត អាជ្ញាធរក្នុងស្រុកបានចាប់ខ្លួនជនជាតិចិន ៣នាក់ រួមទាំងមេខ្លោង និងបានរំដោះមនុស្សជាង ២០០នាក់ ដែលរងការបង្ខំឱ្យធ្វើការនៅក្នុងក្រុមហ៊ុនឆបោក។

នៅព្រឹកព្រលឹមថ្ងៃទី៧ ខែតុលា លោក Azirul Syafiq តំណាងអង្គការ MHO បានអមដំណើរជនរងគ្រោះជាជនជាតិម៉ាឡេស៊ី ក្នុងការធ្វើដំណើរត្រឡប់ទៅអាកាសយានដ្ឋានអន្តរជាតិ Kuala Lumpur ។ ក្នុងអំឡុងសន្និសីទសារព័ត៌មាន ដែលធ្វើឡើងនៅអាកាសយានដ្ឋាន លោក Syafiq បានបង្ហាញព័ត៌មានលម្អិតអំពីរបៀបដែលអង្គការ MHO បានទាក់ទងជាសម្ងាត់ជាមួយជនរងគ្រោះម៉ាឡេស៊ី ដោយប្រមូលព័ត៌មានអំពីប្រតិបត្តិការខុសច្បាប់របស់ក្រុមឆបោក។ នៅពេលនោះ លោក Syafiq ស្ថិតក្នុងប្រទេសថៃ ដោយមើលការខុសត្រូវលើបេសកកម្មជួយសង្គ្រោះមួយផ្សេងទៀតសម្រាប់ជនរងគ្រោះមកពី Sabah ដែលជាប់ក្នុងប្រទេសមីយ៉ាន់ម៉ា។

លោក Azirul បានទាក់ទងភ្លាមៗទៅតំណាងបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដែលជាអង្គការដែលមានអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយនគរបាលជាតិកម្ពុជា។ ទំនាក់ទំនងដ៏សំខាន់នេះបានបើកការបញ្ជូនបន្តព័ត៌មានសម្ងាត់ទៅកាន់អាជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់។ ដោយមានជំនួយសហការពីភ្នាក់ងារជាច្រើន និងមន្ត្រីនគរបាល ពួកគេបានជួយសង្គ្រោះជនរងគ្រោះចេញពីក្រុមហ៊ុនឆបោកមួយ ដែលកំពុងប្រតិបត្តិការនៅខេត្តព្រះសីហនុ។

លោក Syafiq បានរាយការណ៍ថា "នៅពេលទទួលបានព័ត៌មានសំខាន់នេះ នគរបាលរាជធានីភ្នំពេញបានចាត់វិធានការយ៉ាងរហ័សក្នុងរយៈពេល ២៤ម៉ោង ដោយបានរំដោះជនរងគ្រោះចេញពីកណ្តាប់ដៃរបស់ក្រុមហ៊ុន និងចាប់ខ្លួនជនជាតិចិនចំនួន៣នាក់ រួមទាំងមេក្លោង ដែលត្រូវបានចោទប្រកាន់នៅពីក្រោយប្រតិបត្តិការឆបោក"។

ជនរងគ្រោះជាជនជាតិម៉ាឡេស៊ី អាយុ ២៨ឆ្នាំ ត្រូវបានគេល្បួងដោយសន្យាថានឹងផ្តល់ការងារដែលមានប្រាក់ខែខ្ពស់ ដោយធ្វើជាអ្នកចែកបៀក្នុងកាស៊ីណូនៅកម្ពុជា ដោយទទួលបានប្រាក់ចំណូលប្រចាំខែចំនួន១៣៥០ដុល្លារអាមេរិក។ ក្នុងអំឡុងពេលនោះពួកគេទទួលរងការរំលោភបំពានលើរាងកាយរយៈពេលពីរខែ ការឆក់ខ្សែភ្លើង និងការបង្ខិតបង្ខំដោយក្រុមឆបោក ដើម្បីចូលរួមក្នុងប្រតិបត្តិការចាប់ជំរិតជនជាតិចិនដើម្បីបំពេញទៅតាមការងារដែលបានដាក់អោយ។ ដោយរំលឹកពីហេតុការណ៍ដែលនាំអោយខ្លួនធ្លាក់ទៅក្នុងអន្ទាក់របស់ក្រុមខិលខូច គាត់បានពន្យល់ថា កាលពីខែសីហា ឆ្នាំនេះ មិត្តភ័ក្តម្នាក់បានណែនាំគាត់ឱ្យធ្វើការងារជាអ្នកចែកបៀកាស៊ីណូនៅកម្ពុជា ដោយសន្យាថានឹងទទួលបានប្រាក់ខែប្រចាំខែចំនួន១៣៥០ដុល្លារអាមេរិក។

ជាក់ស្តែងបំណងរបស់គាត់ត្រូវអសារបង់ នៅពេលដែលគាត់ធ្លាក់ចូលអន្ទាក់ក្នុងបណ្តាញក្រុមឆបោក។ រហូតដល់ Azirul Syafiq មកពីអង្គការ MHO ធ្វើអន្តរាគមន៍ ទើបគាត់រកផ្លូវរត់គេចខ្លួនបាន។ Azirul បានរៀបរាប់លម្អិតថា ជនល្មើសរឹបអូសលិខិតឆ្លងដែនរបស់ជនរងគ្រោះ បន្ទាប់ពីមកដល់កម្ពុជា។ ក្រោយមកគាត់ត្រូវបានបង្ខំឱ្យឡើងរថយន្តទៅទីតាំងក្រុមហ៊ុនឆបោកនៅខេត្តព្រះសី

ហនុ។ សំណាងល្អ ជនរងគ្រោះអាចរក្សាបាននូវទូរស័ព្ទដៃរបស់គាត់ ដែលសមាជិកក្រុមឆបោកមិនបានរឹបអូស។ ខ្សែទូរស័ព្ទនេះបានអនុញ្ញាតឱ្យគាត់រក្សាទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់គាត់ និងជូនដំណឹងដល់អាជ្ញាធរអំពីភាពលំបាករបស់ខ្លួន។ នៅពេលបានទទួលពាក្យបណ្ដឹងពីគ្រួសាររបស់គាត់កាលពីបីសប្តាហ៍មុន អង្គការ MHO បានផ្តួចផ្តើមប្រតិបត្តិការសង្គ្រោះភ្លាមៗ។

លោក Syafiq បានបន្ថែមថា "ជនរងគ្រោះបានស៊ូទ្រាំនឹងការរំលោភលើរូបរាងកាយធ្ងន់ធ្ងរ និងការឆក់ខ្សែភ្លើង ភាគច្រើនដោយសារតែគាត់មិនអាចបំពេញតាមអ្វីដែលបានដាក់អោយ។ "ក្នុងចំណោមជនរងគ្រោះទាំងអស់ គាត់បានរងទុក្ខវេទនាធ្ងន់ធ្ងរជាងគេ"។ គាត់បានបញ្ជាក់បន្ថែមថា ក្រៅពីធ្វើការអោយក្រុមឆបោក ជនរងគ្រោះក៏ត្រូវបានបង្ខិតបង្ខំឲ្យចាប់ជំរិតបុគ្គលជនជាតិចិនដែលមានទ្រព្យសម្បត្តិផងដែរ។ បច្ចុប្បន្នក្រុមឆបោក កំពុងប្រើប្រាស់គ្រប់មធ្យោបាយដើម្បីបង្កើតប្រាក់ចំណូលខុសច្បាប់បន្ថែមទៀត។ គាត់បានបន្ថែមថា ទោះបីជាជនរងគ្រោះភាគច្រើនត្រូវបានបង្ខាំងក្នុងក្រុងព្រះសីហនុក៏ដោយ ផ្អែកលើព័ត៌មានដែលទទួលបានតាមរយៈ MHO និងកិច្ចសហការ IJM កម្ពុជាមិនមែនជាទីតាំងសំខាន់សម្រាប់បង្ខាំងមនុស្ស ជាពិសេសជនជាតិម៉ាឡេស៊ីនោះទេ។ លោក Azirul បាននិយាយថា "ប្រតិបត្តិការនេះជាសក្ខីភាពមួយចំពោះការប្តេជ្ញាចិត្តមិនរុញរារបស់យើងក្នុងការប្រយុទ្ធប្រឆាំងនឹងការឆបោក និងដោះស្រាយបញ្ហាធ្ងន់ធ្ងរនៃការជួញដូរមនុស្ស"។

## នគរបាលប៉េរូ បង្ក្រាបក្រុមជួញដូរមនុស្ស និងជួយសង្គ្រោះពលរដ្ឋអាស៊ី ៤៤នាក់

https://www.btv.com.kh/article/32265 2023/10/11 09:38:23 am

នគរបាលប៉េរូបានចាប់ខ្លួនក្រុមជួញដូរមនុស្សកាលពីថ្ងៃអាទិត្យ (៨ តុលា) ក្នុងទីក្រុងលីម៉ា ដោយចាប់បានមនុស្ស ៨នាក់ ដែលត្រូវបានចោទប្រកាន់ថា ជាសមាជិក នៃសមាគមឧក្រិដ្ឋជន និងបានជួយសង្គ្រោះពលរដ្ឋអាស៊ីចំនួន ៤៤នាក់ផងដែរ។

ក្រុមអាជ្ញាធរបាននិយាយថា ជនរងគ្រោះដែលភាគច្រើនជាជនជាតិម៉ាឡេស៊ី ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទក្នុងស្ថានភាពមនុស្សថ្នាក់ទាប ហើយត្រូវបានទាក់ទាញទៅប្រទេសប៉េរូក្រោមការក្លែងបន្លំ។ ក្រុមអាជ្ញាធរបានបង្ហាញថា អ្នកត្រូវបានសង្គ្រោះទាំងនោះរួមមានស្ត្រី ២៦នាក់ និងបុរស ១៧នាក់ មកពីប្រទេសម៉ាឡេស៊ី ដែលម្នាក់ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានគេរាយការណ៍ថា បានបាត់ខ្លួននៅក្នុងប្រទេសកំណើត ហើយក៏មានស្ត្រីមកពីកោះតៃវ៉ាន់ផងដែរ ត្រូវបានដោះលែងក្នុងអំឡុងពេលប្រតិបត្តិការ។

ក្រុមអាជ្ញាធរក្នុងតំបន់បានបញ្ជាឱ្យឃុំខ្លួនជនជាតិតៃវ៉ាន់ ៦នាក់ដែលចាប់ខ្លួនបាន បណ្ដោះអាសន្នរយៈពេលប្រាំពីរថ្ងៃកាលពីថ្ងៃច័ន្ទ (៩ តុលា) ដែលពួកគេទាំងនោះត្រូវបានចោទប្រកាន់ពីបទដឹកនាំក្រុមជួញដូរនោះ។ លំនៅឋានកម្ពស់បីជាន់ ដែលជនរងគ្រោះកំពុងស្នាក់នៅក្នុងទីក្រុងលីម៉ា

មានរបងអគ្គិសនី រនាំងបង្ហួច និងទ្វារចាក់សោរដោយប្រើប្រាស់ឈើព័ទ្ធពីក្រៅ ដើម្បីរារាំងជនរងគ្រោះពីការរត់គេចខ្លួន។ ករណីនេះត្រូវបានគេដឹង ដោយសារតែជនរងគ្រោះពីរនាក់ដែលបានរត់គេចខ្លួន បានរាយការណ៍ពីបទឧក្រិដ្ឋនេះទៅកាន់នគរបាល។

## អាជ្ញាធរកម្ពុជាស្ទាក់ចាប់ជនជាតិហ្វីលីពីនដែលកំពុងធ្វើដំណើរទៅទីតាំងក្រុមហ៊ុនឆបោក

https://www.khmertimeskh.com/501375371// Khmer Times October 12, 2023

ក្រសួងពលករចំណាកស្រុក (DMW) បានបញ្ជូនក្រុមការងារមកកម្ពុជា ដើម្បីជួយធ្វើមាតុភូមិនិវត្តន៍ជនជាតិហ្វីលីពីន ២៧ នាក់ ដែលជាជនរងគ្រោះ 9នៃអំពើឆបោកការងារខុសច្បាប់។ បុគ្គលទាំងនេះដំបូងឡើយបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាក្នុងនាមជាអ្នកទេសចរ ដោយរំពឹងថានឹងធ្វើការ ជាអ្នកជំនួយផ្នែកបច្ចេកវិទ្យា។ ជាក់ស្តែង ពួកគេត្រូវបានគេបោកបញ្ឆោត និងបង្ខំឱ្យធ្វើការខុសច្បាប់តាមប្រព័ន្ធអ៊ីនធឺណិតក្នុងស្រុកអូរស្មាច់ ជិតព្រំដែនថៃ។

យោងតាមអនុរដ្ឋលេខាធិការ Hans Leo Cacdac មន្ត្រីទទួលបន្ទុកនៃក្រសួងពលករចំណាកស្រុកជនរងគ្រោះត្រូវបានជួយសង្គ្រោះកាលពីថ្ងៃទី ២៦ ខែកញ្ញា ដោយមានជំនួយពីអគ្គស្នងការនគរបាលជាតិកម្ពុជា។ ជនជាតិហ្វីលីពីនទាំង ២៧នាក់ ត្រូវបានផ្ទេរពីស្រុកអូរស្មាច់ ទៅកាន់កន្លែងឆបោកមួយទៀតក្នុងក្រុងព្រះសីហនុ នៅពេលដែលអគ្គស្នងការនគរបាលជាតិកម្ពុជាបានស្ទាក់ចាប់រថយន្តរបស់ពួកគេ។

ក្រុមការងារដឹកនាំដោយជំនួយការរដ្ឋលេខាធិការ Francis Ron de Guzman បានមកកម្ពុជា ដើម្បីផ្តល់ជំនួយ និងជួយដល់ប្រជាជនហ្វីលីពីនដែលត្រូវបានជួយសង្គ្រោះ។ ក្រុមការងារនឹងផ្តល់ជំនួយផ្នែកច្បាប់ និងហិរញ្ញវត្ថុ និងផ្នែកផ្លូវចិត្ត។ ដោយសហការជាមួយក្រសួងការបរទេស និងស្ថានទូតហ្វីលីពីននៅទីក្រុងភ្នំពេញ DMW កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារបស់កម្ពុជា ដើម្បីចងក្រងឯកសារ និងដំណើរការសំណុំរឿងជនរងគ្រោះ ដើម្បីអាចបញ្ជូនពួកគេត្រឡប់ទៅហ្វីលីពីនវិញបានភ្លាមៗ។ ជាការឆ្លើយតប ស្ថានទូតហ្វីលីពីននៅទីក្រុងភ្នំពេញបានថ្លែងអំណរគុណចំពោះសហគមន៍ហ្វីលីពីននៅកម្ពុជា និង សហគមន៍Philippine Eagles chapter នៅរាជធានីភ្នំពេញ។ ពួកគេបានជួយ និងបរិច្ចាគរបស់របរចាំបាច់ដូចជាអាហារជួយដល់ជនរងគ្រោះ។

លោក Caccac បានសង្កត់ធ្ងន់ថាករណីនេះគឺ ជាផ្នែកមួយគម្រោងជ្រើសរើសពលករខុសច្បាប់ និងការជួញដូរមនុស្ស ដែលផ្តោតលើពលករហ្វីលីពីននៅក្រៅប្រទេសសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុខុសច្បាប់តាមអ៊ីនធឺណិត។ DMWបានក្រើនរំលឹកប្រជាជនហ្វីលីពីនអំពីករណីឆបោកនេះ ជាពិសេសការផ្តល់ការងារពីបណ្តាប្រទេសក្នុងតំបន់អាស៊ីអគ្នេយ៍។ លោកបានបន្តថា "ប្រសិនបើ

យើងប្រយុទ្ធប្រឆាំងនឹងការជ្រើសរើសពលករខុសច្បាប់ និងការពារពលករហ្វីលីពីននៅបរទេសរបស់យើងប្រកបដោយប្រសិទ្ធភាព យើងត្រូវបន្តលើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាំងនេះ និងជួយដល់អ្នកដែលបានធ្លាក់ខ្លួនជាជនរងគ្រោះ”។

# ថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០២៣

## ភាគីថៃ ឯកភាពជួយសម្រួល ការធ្វើដំណើររបស់ពលរដ្ឋខ្មែរតាមច្រកព្រំដែន នាឱកាសភ្ជុំបិណ្ឌ

https://www.kampucheathmey.com/local-news/595265 ថ្ងៃព្រហស្បតិ៍ ១២ តុលា ២០២៣ ដោយ Thoeun Vansong

អគ្គនាយកស្តីទីការិយាល័យអន្តោប្រវេសន៍ថៃ បានទទួលយកសំណើរបស់កម្ពុជា ដោយបានបញ្ជាឱ្យមន្ត្រីរបស់ខ្លួន ជួយសម្របសម្រួលដល់ការធ្វើដំណើរ របស់ប្រជាពលរដ្ឋកម្ពុជានៅតាមច្រកទ្វារព្រំដែនរវាងប្រទេសទាំងពីរ កម្ពុជា និងថៃ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។ ការឯកភាពរបស់ភាគីថៃនេះ បានធ្វើឡើងក្រោយពេលឧត្តមសេនីយ៍ឯក សុខ វាសនា អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានស្នើសុំកិច្ចសម្របសម្រួលពីការិយាល័យអន្តោប្រវេសន៍ថៃចំពោះការសម្របសម្រួលដល់ប្រជាពលរដ្ឋកម្ពុជា សម្រាប់ការធ្វើដំណើរចូល-ចេញ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះ។

ក្នុងជំនួបកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ លោកឧត្តមសេនីយ៍ឯក សុខ វាសនា បានប្រាប់លោកឧត្តមសេនីយ៍ត្រី ផាន់ថាន: នុជ្ជនាថ អគ្គនាយកស្តីទីការិយាល័យអន្តោប្រវេសន៍ នៃអគ្គស្នងការនគរបាលថៃ ថា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហការ និងសម្របសម្រួលនីតិវិធីអន្តោប្រវេសន៍ ដើម្បីជាប្រយោជន៍រួមសម្រាប់ប្រជាជាតិទាំងពីរ។ ក្នុងនោះ លោកអគ្គនាយកអន្តោប្រវេសន៍ បានស្នើសុំកិច្ចសម្របសម្រួលពីការិយាល័យអន្តោប្រវេសន៍ថៃចំពោះការសម្របសម្រួលដល់ប្រជាពលរដ្ឋកម្ពុជា ដែលស្នាក់នៅប្រទេសថៃ ពេលធ្វើដំណើរចូល-ចេញ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នាពេលខាងមុខនេះ។ បើតាមអគ្គនាយកអន្តោប្រវេសន៍រូបនេះ សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីការធ្វើដំណើររបស់ប្រជាពលរដ្ឋកម្ពុជា ដែលកំពុងបម្រើការងារនៅប្រទេសថៃ ដើម្បីអាចធ្វើដំណើរទៅមកដោយមានសុខសុវត្ថិភាព និងមានភាពងាយស្រួល។

ជាការឆ្លើយតប លោកឧត្តមសេនីយ៍ត្រី ផាន់ថាន: នុជ្ជនាថ អគ្គនាយកស្តីទីការិយាល័យអន្តោប្រវេសន៍ថៃ បានឯកភាពចំពោះសំណើនេះ និងសន្យាដាក់បញ្ជាទៅតាមច្រកទ្វារព្រំដែនអន្តរជាតិរបស់ខ្លួនជាមួយភាគីកម្ពុជា ឱ្យសម្របសម្រួលចំពោះការធ្វើដំណើររបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះ។ ឧត្តមសេនីយ៍ត្រីថៃរូបនេះ ក៏បានសម្តែងការអំណរគុណចំពោះអគ្គនាយក

ដ្ឋានអន្តោប្រវេសន៍កម្ពុជា ដែលបានបន្តកិច្ចសហប្រតិបត្តិការដ៏ល្អ កន្លងមក តាមរយៈការសម្របសម្រួលការងារសន្តិសុខ សណ្តាប់ធ្នាប់ និងការឆ្លើយតបចំពោះសភាពការណ៍ជាទូទៅនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ។

ទន្ទឹមនឹងការអរគុណនេះ លោកអគ្គនាយកស្តីទីការិយាល័យអន្តោប្រវេសន៍ថៃ បានស្នើសុំដល់លោកឧត្តមសេនីយ៍ឯក សុខ វាសនា ចំពោះការសម្របសម្រួលកិច្ចសហការផ្លាស់ប្តូរព័ត៌មានអន្តោប្រវេសន៍ ក្នុងរូបភាពទប់ស្កាត់បទល្មើសផ្សេងៗ ជាអាទិ៍ ការជួញដូរមនុស្ស ការក្លែងបន្លំឯកសារធ្វើដំណើរ និងការធ្វើដំណើររបស់ជនសង្ស័យដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗចូលមកកាន់កម្ពុជា ឬក្នុងប្រទេសថៃ។

តាមរយៈសំណើនេះ លោកឧត្តមសេនីយ៍ឯក សុខ វាសនា អគ្គនាយកអន្តោប្រវេសន៍ បានឯកភាព និងទទួលសំណើលើការផ្លាស់ប្តូរព័ត៌មាន ដើម្បីជាការធានាឱ្យបានក្នុងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់របស់ប្រទេសកម្ពុជា ក៏ដូចជាសម្រាប់ប្រទេសក្នុងតំបន់។ លោកអគ្គនាយក សង្ឃឹមថា អង្គភាពទាំងពីរ នឹងបន្តរឹតចំណងកិច្ចសហប្រតិបត្តិការឱ្យកាន់ តែប្រសើរឡើងថែមទៀត ក្នុងនាមជាអ្នកជិតខាងល្អ៕

## កម្ពុជា-ថៃបន្តបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ

https://www.kampucheathmey.com/local-news/595325 ថ្ងៃព្រហស្បតិ៍ ១២ តុលា ២០២៣

ដោយ deth leng

លោកនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិបានអនុញ្ញាតឱ្យអនុប្រធាននាយកដ្ឋានកណ្តាលអន្តោប្រវេសន៍ថៃ ឧត្តមសេនីយ៍ទោ PHANTHANA NUTCHANART ចូលជួបសម្តែងការគួរសម និងបន្តបង្កើនកិច្ចសហប្រតិបត្តិរវាងគ្នាឱ្យកាន់តែល្អប្រសើរ ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ។ កិច្ចជំនួបនេះ ធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ នារសៀលថ្ងៃព្រហស្បតិ៍ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

ជាកិច្ចចាប់ផ្តើម អនុប្រធាននាយកដ្ឋានកណ្តាលអន្តោប្រវេសន៍ថៃ ឧត្តមសេនីយ៍ទោ PHANTHANA NUTCHANART បានអបអរសាទរចំពោះឯកឧត្តម នាយឧត្តមសេនីយ៍ ស ថេតដែលបានត្រូវព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់តែងតាំងជាអគ្គស្នងការនគរបាលជាតិ និងស្នើសុំបន្តពង្រឹងកិច្ចសហប្រតិការរវាងភាគីទាំងពីរឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។ ឧត្តមសេនីយ៍ទោ PHANTHANA NUTCHANART បានបន្តទៀតថា ក្រោយកិច្ចសហប្រតិបត្តិយ៉ាងល្អរយៈ

ពេល២ឆ្នាំកន្លងទៅនេះ បទល្មើសឆ្លងដែនជាច្រើន ដូចជាបទល្មើសអនឡាញ បទល្មើសជួញដូរមនុស្ស បទល្មើសគ្រឿងញៀន និងបទល្មើសផ្សេងៗ ត្រូវបានទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា។

ជាការឆ្លើយតប នាយឧត្តមសេនីយ៍ ស ថេត ស្នើសុំឱ្យភាគីថៃបន្តផ្លាស់ប្តូព័ត៌មានទាក់ទងនឹងបទល្មើសឆ្លងដែនឱ្យទាន់ពេលវេលា និងមានភាពច្បាស់លាស់ ដើម្បីឈានទៅបង្ក្រាបបទល្មើសដែលកើតមានឡើងរវាងប្រទេសទាំងពីរឱ្យទទួលបានជោគជ័យបន្ថែមទៀត។ លោកអគ្គស្នងការនគរបាលជាតិ អរគុណភាគីថៃ ដែលបានសម្របសម្រួល និងផ្តល់កិច្ចសហការល្អនៅពេលមានការស្នើសុំតាមចាប់ខ្លួនជនល្មើស ដែលរត់ទៅលាក់ខ្លួននៅក្នុងប្រទេសថៃ ហើយបានចាប់បញ្ជូនមកកាត់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ។

លើសពីនេះ ភាគីកម្ពុជា ក៏ជំរុញឱ្យភាគីថៃបន្តយកចិត្តទុកដាក់ចំពោះពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ដែលបញ្ជូនត្រឡប់មកកម្ពុជាវិញ សូមបញ្ជូនមកវិញជាដំណាក់កាលៗ ដោយមានការយោគយល់ និងគោរពសិទ្ធិមនុស្ស។ អគ្គស្នងការដ្ឋាននគរបាលជាតិ និងនាយកដ្ឋានកណ្តាលអន្តោប្រវេសន៍ថៃ ក៏បានឯកភាពគ្នា ក្នុងការពិនិត្យឡើងវិញទៅលើខ្លឹមសារពាក់ព័ន្ធដូចមានចែងក្នុងកំណត់ហេតុធ្វើការងារ នៃកិច្ចប្រជុំលើកទី៣ រវាងកម្ពុជាថៃ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគីលើកទី៤។

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដឹកនាំក្រុមការងារចុះត្រួតពិនិត្យ និងដោះស្រាយការធ្វើដំណើរចេញ-ចូល របស់ភ្ញៀវទេសចរ និងពលករ នៅច្រកទ្វារតាមព្រំដែនក្នុងខេត្តប៉ៃលិន

https://freshnewsasia.com/index.php/en/localnews/313855-2023-10-13-06-19-44.html 2023-10-13 01:19pm

**(ប៉ៃលិន)៖** លោក សំរិទ្ធ ឌី រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារទី១ នៃគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែនកម្ពុជា បានអញ្ជើញដឹកនាំក្រុមការងារចុះពង្រឹង តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរតាមទ្វារព្រំដែននៅខេត្តប៉ៃលិន និងជួយសម្រួលដល់ដំណើរចេញ-ចូលរបស់ពលករទាំងអស់ សម្រួលកុំឱ្យមានការកកស្ទះនៅតាមច្រកព្រំដែន និងពង្រឹងសន្តិសុខនៅតាមច្រកទ្វារព្រំដែន។

សូមបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ ក្រោយពីទទួលបានភារកិច្ច និងការចាត់តាំងបញ្ជាផ្ទាល់ពីសម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា និងមានការណែនាំជាប្រចាំរបស់ឧបនាយករដ្ឋមន្ត្រី នេត សាវឿន ប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយដំណើរចេញ-ចូល របស់ពលករខ្មែរតាមព្រំដែនកម្ពុជា, លោក សំរិទ្ធ ឌី បានដឹកនាំបញ្ជាផ្ទាល់នៅតាមច្រក

ទ្វារព្រំដែនក្នុងខេត្តប៉ៃលិន ដើម្បីពិនិត្យមើលការចេញ-ចូលរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ ជាពិសេសពលករខ្មែរ ដែលសម្រុកមកស្រុកកំណើត ដើម្បីជួបជុំគ្រួសារក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។

នាឱកាសដឹកនាំក្រុមការងារចំពោះកិច្ចនាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ម្សិលមិញ លោក សំរិទ្ធ ឌី បានគ្រើនរំលឹកដល់ស្ថាប័នជំនាញច្រកទ្វារព្រំដែននៅខេត្តប៉ៃលិន ធ្វើយ៉ាងណា ដើម្បីជួយបង្កលក្ខណៈងាយស្រួល និងលើកទឹកចិត្តដល់ភ្ញៀវទេចរ ក៏ដូចជាពលករឆ្លងដែនអន្តរជាតិ ដើម្បីលើកស្ទួយនូវជីវភាពដំណើរចេញ-ចូលរបស់ពលករខ្មែរ។ បន្ថែមពីនេះ លោកក៏បានណែនាំជាប្រចាំឱ្យសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនជួយសម្រួលបែបបទ និងឯកសារនានាឱ្យមានប្រសិទ្ធភាព និងឆាប់រហ័សជូនដល់ពលករខ្មែរ។

## សង់ត្រាល់៖ ពលករខ្មែរជាង៤00នាក់ ត្រូវបានប៉ូលិសថៃចាប់ខ្លួនក្នុងថ្ងៃទី១២តុលា២0២៣

https://www.rfi.fr/km//20231013tm_medium=social&utm_campaign=telegram&utm_source=shorty

13/10/2023 - 09:18 ៨ នាទី ដោយ៖អោ ស្រីពេជ្រ

ផ្អែកតាមព័ត៌មានបឋមរបស់អង្គការសង់ត្រាល់ ឱ្យដឹងថា នៅថ្ងៃព្រហស្បតិ៍ទី១២តុលា ម្សិលមិញនេះ ពលករខ្មែរប្រមាណជាង ៤០០នាក់ ដែលកំពុងបម្រើការងារសំណង់ ក្នុងខេត្តអាយុធ្យា ប្រទេសថៃ ត្រូវបានប៉ូលិសថៃចាប់ខ្លួន ដោយសារគ្មានឯកសារស្របច្បាប់។ តាមរយៈវិទ្យុបារាំងអន្តរជាតិនៅថ្ងៃសុក្រនេះ លោក ឡឹង សុផុន មន្ត្រីតំណាងអង្គការសង់ត្រាល់ប្រចាំនៅប្រទេសថៃ លើកឡើងថា ក្នុងស្ថានភាពនេះ ពលករខ្មែរជាច្រើននាក់កំពុងប្រឈមនឹងការបញ្ជូនត្រលប់មកខ្មែរវិញ។

លោក ឡឹង សុផុន មន្ត្រីតំណាងអង្គការសង់ត្រាល់ប្រចាំនៅប្រទេសថៃបានលើកឡើងថា ការចាប់ខ្លួនពលករខ្មែរទាំងនោះគឺដោយសារតែប៉ូលិសថៃបានរកឃើញថា ពួកគេគ្មានឯកសារស្របច្បាប់ ហើយអ្នកខ្លះទៀតមានឯកសារអនុញ្ញាតឱ្យធ្វើការនៅប្រទេសថៃស្របច្បាប់ តែអស់សុពលភាព។ និងឱ្យដឹងទៀតថា ក្នុងស្ថានភាពនេះពលករខ្មែរជាច្រើននាក់ នឹងប្រឈមបញ្ជូនត្រលប់មកខ្មែរវិញ។ បញ្ជូនត្រលប់មកវិញ ក៏ព្រោះតែពួកគេទាំងនោះ នៅមិនទាន់មានការធានារ៉ាប់រងធ្វើឯកសារស្របច្បាប់ពីថៅកែថៃ។

គួរដឹងដែរថា រដ្ឋាភិបាលថៃកាលពីខែកក្កដា ឆ្នាំ២០២៣កន្លងមក បានយល់ព្រមបន្តពេលវេលាសម្រាប់ពលករបរទេស ដែលបានដាក់ស្នើបញ្ជីឈ្មោះអាចស្នាក់នៅ និងធ្វើការបានរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ និងពន្យាពេលសម្រាប់ពលករតាមប្រព័ន្ធ MOU ដែលបានបញ្ចប់កិច្ចសន្យា៤ឆ្នាំ អាចបន្តធ្វើការរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ជាមួយនឹងការបញ្ចុះតម្លៃវីសារពី

២០០០ មកត្រឹម៥០០បាត។ ហើយតម្លៃឯកសារស្នើសុំបន្តស្នាក់នៅប្រទេសថៃជាបណ្តោះអាសន្ន បន្ថយ ពី១៩០០បាត មកត្រឹម៥០០បាតផងដែរ៕

## មុខសញ្ញានាំមនុស្ស ឆ្លងដែនចេញក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានចៅក្រម ចេញដីកាឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ

https://cen.com.kh/archives/702917.html Posted ByPen Srey NeatOctober 14, 2023

កំពង់ស្ពឺ ៖ នៅថ្ងៃសៅរ៍ ទី១៤ ខែតុលា ឆ្នាំ២០២៣នេះ កំលាំងនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បានបញ្ជូនមុខសញ្ញា០៣នាក់ ស្រី០១នាក់ ទៅសាលាដំបូងខេត្តកំពង់ស្ពឺ ចំណាត់ការករណីនាំមនុស្សមិនស្របច្បាប់ចេញក្រៅព្រះរាជាណាចក្រកម្ពុជា ។

ដោយបានការចង្អុលណែនាំផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការ នគរបាលខេត្តកំពង់ស្ពឺ កំលាំងផែនការងារសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បានសហការជាមួយកំលាំងអធិការដ្ឋាន នគរបាលស្រុកសាមគ្គីមុនីជ័យ ស្រាវជ្រាវឃាត់ខ្លួនមុខសញ្ញាសង្ស័យ ០៣នាក់ ពាក់ព័ន្ធករណី « ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ក្រៅព្រះរាជាណាចក្រកម្ពុជា » ជនសង្ស័យ ០៣នាក់មាន ៖

១-វង់ សុខណាង ភេទប្រុស អាយុ ៤៣ឆ្នាំ ស្រុកកំណើតខេត្តត្បូងឃ្មុំ (ចេញ-ចូលក្រៅប្រទេស)។

២-ប៉ែន សារឿន ភេទប្រុស អាយុ ៦០ឆ្នាំ មុខរបរ ទីប្រឹក្សា សមាគមអ្នកអភិរក្សធនធានធម្មជាតិ បរិស្ថាន និងការពារសិទ្ធពលរដ្ឋនៅកម្ពុជា ស្រុកកំណើតខេត្តតាកែវ បច្ចុប្បន្នរស់នៅស្រុកឈូក ខេត្តកំពត។

៣-ខុន សុខុម ភេទស្រី អាយុ ៣៦ឆ្នាំ រស់នៅភូមិបឹងថ្នល់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។

បច្ចុប្បន្នមុខសញ្ញាខាងលើត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ស្ពឺ ៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## ខ្លួនក៏ឈឺ លុយត្រូវគេបោកទៀត! ពលរដ្ឋខ្មែរ១៨នាក់ ដេករង់ចាំការវះកាត់ដូរសរីរាង្គនៅឥណ្ឌារាប់ខែ ខណៈលុយជិត១លានដុល្លារ ត្រូវតំណាងមន្ទីរពហុព្យាបាលមេត្រូ ប្រមូលគេចខ្លួនបាត់

https://freshnewsasia.com/index.php/en/localnews/314107-2023-10-16-11-27-54.html?fbclid=IwAR3PvbQm6rar1w-hRvQXZjN2Qh7nUSsl95eo6WDAXXOR89ZET0F5BwER1Q4 2023-10-16 06:27pm

(ភ្នំពេញ)៖ ពិតជាគ្រោះជាន់លើគ្រោះមែន ខ្លួនក៏ឈឺ លុយបង់ថ្លៃសេវាព្យាបាលត្រូវគេប្រមូលគេចខ្លួនបាត់អស់ទៀត។ ប្រជាពលរដ្ឋខ្មែរ ១៨នាក់ ដែលមានបញ្ហាតម្រងនោម ដែលហៅទូទៅថាក្រលៀននោះ កំពុងផុងខ្លួនដេករង់ចាំសេវាដូរតម្រងនោមនៅប្រទេសឥណ្ឌាអស់រាប់ខែហើយ តែមិនទទួលបានសេវាដោយសារលុយបង់សម្រាប់ការព្យាបាលនោះ ត្រូវតំណាងមន្ទីរពហុព្យាបាលមេត្រូប្រមូលរត់គេចខ្លួនបាត់។

ពលរដ្ឋខ្មែរម្នាក់ក្នុងចំណោម១៨នាក់ កំពុងដេកទន្ទឹងរង់ចាំសេវាព្យាបាលនៅប្រទេសឥណ្ឌា បានប្រាប់បណ្ដាញព័ត៌មាន Fresh News តាមបណ្ដាញតេឡេក្រាម ពីប្រទេសឥណ្ឌានៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣នេះថា រូបគាត់មានជំងឺខូចតម្រងនោម ហើយបានទាក់ទងរកសេវាព្យាបាលជាមួយមន្ទីរពហុព្យាបាល មេត្រូ អអិលវី (Metro RLV Polyclinic) ដែលជាតំណាងរបស់មន្ទីរពេទ្យមេត្រូរបស់ប្រទេសឥណ្ឌា កាលពីខែមីនា ឆ្នាំ២០២៣។ ដើម្បីទទួលបានសេវាព្យាបាលដោយការដូរតម្រងនោមនៅប្រទេសឥណ្ឌា អ្នកជំងឺមកពីខេត្តបន្ទាយមានជ័យ ដែលសូមលាក់អត្តសញ្ញាណរូបនេះ បានបង់ប្រាក់ប្រមាណ ៩ម៉ឺនដុល្លារអាមេរិក ឱ្យទៅលោក ង៉ែត សំអូន ជាអគ្គនាយកមន្ទីរពហុព្យាបាលមេត្រូ អអិលវី នៅក្នុងរាជធានីភ្នំពេញ។

អ្នកជំងឺរូបនេះ បានបន្តរៀបរាប់ថា បន្ទាប់ពីបានលុយហើយនោះ រូបលោកត្រូវបានបញ្ជូនទៅកាន់ប្រទេសឥណ្ឌា ដើម្បីទទួលសេវាព្យាបាល។ ក្រោយពេលទៅដល់ប្រទេសឥណ្ឌា រូបលោក មិនទទួលបានសេវាដូរតម្រងនោម ដូចអ្វីដែលមន្ទីរពហុព្យាបាលមេត្រូ បានសន្យានោះឡើយ។ អ្នកជំងឺរូបនេះ បានដេករង់ចាំសេវាដូរតម្រងនោមនៅប្រទេសឥណ្ឌាអស់រយៈពេល៧ខែមកហើយ។ បើតាមអ្នកជំងឺរូបនេះបានឱ្យដឹងថា ការដែលរូបលោក មិនទទួលបានសេវាដូរតម្រងនោមនេះ ដោយសារតែលោក ង៉ែត សំអូន ដែលជាអគ្គនាយកមន្ទីរពហុព្យាបាលមេត្រូ នៅក្នុងរាជធានីភ្នំពេញ មិនបានបង់ប្រាក់ឱ្យទៅមន្ទីរពេទ្យមេត្រូវនៅក្នុងប្រទេសឥណ្ឌា។

នៅពេលសួរទៅតំណាងមន្ទីរពហុព្យាបាលមេត្រូនៅភ្នំពេញ គេបានអះអាងថា ក្រុមហ៊ុននៅភ្នំពេញក្ស័យធន មិនមានលុយបង់សម្រាប់ការព្យាបាលនេះឡើយ។ ក្រៅតែពីអ្នកជំងឺដែលបានផ្ដល់ព័ត៌មានខាងលើនេះ នៅមានអ្នកជំងឺជាពលរដ្ឋខ្មែរ ១៧នាក់ផ្សេងទៀត កំពុងដេករង់ចាំដំណោះ

ស្រាយ និងទទួលបានសេវាដូរតម្រងនោម។ ប៉ុន្តែការរង់ចាំបានអូសបន្លាយអស់ជាច្រើនខែ ដោយគ្មានពន្លឺដំណោះស្រាយ ហើយលោក ង៉ែត សំអូន ដែលជាអ្នកទទួលលុយនោះ បានគេចខ្លួនបាត់ហើយ។

បើតាមអ្នកជំងឺខាងលើនេះ បានអះអាងថា ទាំងរូបលោក និងអ្នកជំងឺ ១៧នាក់ទៀត សុទ្ធតែជាអ្នកត្រូវដូរតម្រងនោម ហើយបានបង់ថ្លៃសេវាដូរនេះរួចរាល់ហើយ។ មកដល់ពេលនេះ អ្នកជំងឺខ្លះដេករង់ចាំការដូរតម្រងនោម រយៈពេល៤ ខ្លះ៥ ខ្លះ៧ខែ ខ្លះ៨ខែ និងខ្លះទៀត ៩ខែហើយ។ ខណៈពន្លឺនៃការទទួលបានសេវាដូរតម្រងនោមមិនដឹងថា លទ្ធផលយ៉ាងណានោះ ពួកគាត់ក៏ត្រូវចំណាយថ្លៃលាងឈាម និងថ្លៃអាហារហូបចុកអស់ជាច្រើនទៀត។

ពលរដ្ឋខ្មែរកំពុងមានជំងឺតម្រងនោមទាំង១៨រូបនេះ និងកំពុងទន្ទឹងរង់ចាំឱកាសបន្តដង្ហើមជីវិតតាមរយៈការដូរតម្រងនោមបានអំពាវនាវសូមការជួយអន្តរាគមន៍ពីសម្តេចធិបតី ហ៊ុន ម៉ាណែត ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ខណៈពួកគេគ្មានក្តីសង្ឃឹមថា លោក ង៉ែត សំអូន អគ្គនាយកមន្ទីរពហុព្យាបាលមេត្រូ នៅរាជធានីភ្នំពេញ នឹងចេញមុខដោះស្រាយនោះឡើយ។

ពាក់ព័ន្ធនឹងករណីខាងលើ បណ្តាញព័ត៌មាន Fresh News មិនទាន់សុំការបំភ្លឺពីខាង ពហុព្យាបាលមេត្រូ នៅរាជធានីភ្នំពេញ បាននៅឡើយទេ,Fresh News រង់ចាំការបំភ្លឺពីខាងពហុព្យាបាលមេត្រូ ចំពោះការលើកឡើងខាងលើរបស់អ្នកជំងឺ ដែលកំពុងសម្រាកព្យាបាលនៅប្រទេសឥណ្ឌា៕

# ថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០២៣

## អ.ស.បសង្កត់ធ្ងន់ពីទំហំនៃវិស័យជួញដូរមនុស្សឱ្យប្រព្រឹត្តបទល្មើសអនឡាញនៅកម្ពុជា

https://khmer.voanews.com/a/un-spotlights-scale-of-cambodia-s-cyber-trafficking-industry/7308515.html ១៣ តុលា ២០២៣

វ៉ាស៊ីនតោន៖ អង្គការសហប្រជាជាតិបានសង្កត់ធ្ងន់លើវិស័យជួញដូរមនុស្ស ឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអនឡាញ ដែលបានរីកដុះដាលពាសពេញតំបន់អាស៊ីអាគ្នេយ៍ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយប៉ាន់ប្រមាណថា សកម្មភាពឧក្រិដ្ឋកម្មជួញដូរមនុស្សនេះ បានបណ្តាលឱ្យមានជនរងគ្រោះរហូតដល់ប្រមាណ ១០០.០០០នាក់ គ្រាន់តែនៅកម្ពុជាមួយ។

នៅក្នុងរបាយការណ៍ថ្មីមួយ ស្តីពីប្រតិបត្តិការបោកតាមប្រព័ន្ធអ៊ីនធឺណិត ឬហៅថា scam នៅក្នុងតំបន់ ការិយាល័យឧត្តមស្នងការជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្ទះស្ទែងផ្សព្វផ្សាយបញ្ហាបណ្តាញក្រុមឧក្រិដ្ឋជនជួញដូរមនុស្ស ឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត

នេះថាជាការគំរាមកំហែងសិទ្ធិមនុស្សអន្តរជាតិបន្ទាន់មួយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាល និងអង្គការគាំពារសិទ្ធិលើសាកលលោក។

របាយការណ៍អះអាងថា ពីព្រោះមនុស្ស ដែលត្រូវបានជួញដូរឱ្យពាក់ព័ន្ធនឹងប្រតិបត្តិការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយប្រើប្រាស់អ៊ីនធឺណិត និងបណ្ដាញសង្គមជាមធ្យោបាយ ដើម្បីប្រព្រឹត្តអំពើឆបោកប្រាក់ពីជនរងគ្រោះ ដែលមិនដឹងខ្លួននៅតាមបណ្ដាប្រទេសដទៃទៀត ជារឿយៗ ពួកគេត្រូវបានចាត់ទុកទាំងនៅប្រទេសកំណើត និងនៅប្រទេស ដែលពួកគេស្ថិតនៅនោះថា បានឃុបឃិតជាមួយបណ្ដាញក្រុមឧក្រិដ្ឋជនផងដែរ។ ប៉ុន្តែរបាយការណ៍ជំរុញឱ្យក្រុមមន្ត្រីចាត់ទុកពួកគេជា ជនរងគ្រោះផងដែរ។

របាយការណ៍អង្គការសហប្រជាជាតិរៀបរាប់ថា៖ «មនុស្សដែលត្រូវបានជួញដូរឱ្យប្រព្រឹត្តបទល្មើសតាមអ៊ីនធឺណិតប្រឈមនឹងការគំរាមកំហែងសិទ្ធិរស់រាន សេរីភាព និងសន្តិសុខបុគ្គល។ ពួកគេត្រូវរងការធ្វើទារុណកម្ម និងការប្រព្រឹត្តដាក់យ៉ាងឃោរឃៅ ហិង្សា និងអមនុស្សធម៌ ការឃុំខ្លួនដោយបំពាន អំពើហិង្សាផ្លូវភេទ ការបង្ខំឱ្យធ្វើការ និងការកេងប្រវ័ញ្ចពលកម្ម ក៏ដូចជា ការរំលោភបំពានសិទ្ធិមនុស្សក្នុងទម្រង់ដទៃទៀត»។

រដ្ឋាភិបាលនាយករដ្ឋមន្ត្រីលោក ហ៊ុន ម៉ាណែត បានធ្វើការការពារភ្លាមៗប្រឆាំងនឹងរបាយការណ៍ខាងលើនេះ ដោយបន្ទាបទំហំបញ្ហា។ ទាំងរបាយការណ៍ និងអ្នកជំនាញលើបញ្ហានេះនិយាយថា កម្ពុជាមិនទាន់បង្ហាញការប្ដេជ្ញាណាមួយនៅក្នុងការដោះស្រាយវិបត្តិ និងបង្ក្រាបបណ្ដាញក្រុមជួញដូរមនុស្សនោះទេ។

យោងតាមរបាយការណ៍ ហេតុផលមួយគឺថា មន្ត្រី និងអ្នកមានអំណាចនៅកម្ពុជាប្រហែលជាបែងចែកផលចំណេញយ៉ាងច្រើនពាក់ព័ន្ធនឹងបញ្ហានេះ។ មានការប៉ាន់ប្រមាណថា កន្លែងឆបោកដែលមានប្រតិបត្តិការនៅតំបន់អាស៊ីអាគ្នេយ៍បានផ្ដល់ជាប្រាក់ចំណូលរាប់ពាន់លានដុល្លារ។ របាយការណ៍ ដែលផ្ដោតលើការជួញដូរនៅមីយ៉ាន់ម៉ានិងឡាវ និងកន្លែងឆបោកដែលកំពុងដំណើរការនៅតាមបណ្ដាប្រទេសទាំងនេះ លើកឡើងថា៖ «អំពើពុករលួយបានធ្វើឱ្យប៉ះពាល់គណនេយ្យភាព និងគំរាមកំហែងនីតិរដ្ឋ។

ជារឿយៗ អំពើពុករលួយកើតឡើងនៅមុនពេលមានការរំលោភបំពានសិទ្ធិមនុស្ស ធ្វើឱ្យផលវិបាកអាក្រក់ជាងមុន និងជាឧបសគ្គចំពោះការទទួលបានយុត្តិធម៌ និងសំណង»។ របាយការណ៍បានបន្តថា៖ «របាយការណ៍នានាបានបង្ហាញថា មានកង្វះការស៊ើបអង្កេតពាក់ព័ន្ធនឹងការអះអាងអំពីការឃុបឃិតរវាងក្រុមឧក្រិដ្ឋជន ពីក្រោយប្រតិបត្តិការឆបោក និងមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល អ្នកនយោបាយ អាជ្ញាធរពង្រឹងច្បាប់ និងអ្នកជំនួញមានឥទ្ធិពល»។

សារព័ត៌មាន Al Jazeera ដែលបានបញ្ចេញរបាយការណ៍ព័ត៌មានស៊ើបអង្កេតមិនធ្លាប់មានពីមុនមួយពី «ទាសករតាមប្រព័ន្ធអ៊ីនធឺណិត» នៅកម្ពុជា កាលពីឆ្នាំ ២០២២ បានរកឃើញថា អ្នកជំនួញ ដែលជាម្ចាស់អគារដែលមានប្រតិបត្តិការឆបោក មានទំនាក់ទំនងជិតដិតជាមួយនឹងអតីតនាយករដ្ឋមន្ត្រីលោក ហ៊ុន សែន ដែលបានផ្ទេរអំណាចដល់កូនប្រុសរបស់លោក បន្ទាប់ពីការបោះឆ្នោតកាលពីខែកក្កដា។

របាយការណ៍ដដែល បានពណ៌នាពីការណ៍ដែលវិបត្តិជំងឺកូវីដ១៩ បានជំរុញការកើនឡើងប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។ ពលរដ្ឋវ័យក្មេងមួយចំនួននៅក្នុងតំបន់ពេលនោះជួបការលំបាកខ្លាំងក្នុងការស្វែងរកការងារ ហើយបានក្លាយជាគោលដៅចម្បងសម្រាប់ក្រុមឧក្រិដ្ឋជននាំចូលឱ្យធ្វើការងារក្លែងក្លាយតាមប្រព័ន្ធអ៊ីនធឺណិត ខណៈមនុស្សជុំវិញពិភពលោកពេលនោះតែងមានភាពអផ្សុក និងចំណាយពេលរាប់ម៉ោងប្រើប្រាស់អ៊ីនធឺណិតនៅលើទូរសព្ទ កុំព្យូទ័រ ឬឧបករណ៍ដទៃទៀត។ របាយការណ៍បកស្រាយថា វិបត្តិជំងឺកូវីដ១៩ បានបង្ខំឱ្យកាស៊ីណូទូទាំងទ្វីបអាស៊ីបិទទ្វារ ដោយជំរុញឱ្យអ្នកវិនិយោគចិនស្វែងរកឱកាសអាជីវកម្មថ្មីតាមប្រព័ន្ធអ៊ីនធឺណិតដែលជារឿយៗខុសច្បាប់ និងនៅតាមបណ្ដាប្រទេស ដែលមានច្បាប់មិនតឹងរ៉ឹង និងហានិភ័យរងការចោទប្រកាន់តាមផ្លូវច្បាប់មានកម្រិត ដូចជា កម្ពុជា មីយ៉ាន់ម៉ា និងឡាវ។

របាយការណ៍និយាយថា៖ «ដោយប្រឈមស្ថានភាពប្រតិបត្តិការថ្មី ក្រុមឧក្រិដ្ឋជនផ្ដោតគោលដៅទាក់ទាញអ្នកធ្វើការចំណាកស្រុក ដែលជាប់នៅតាមបណ្ដាប្រទេសទាំងនេះ ហើយបានបាត់បង់ការងារដោយសារការបិទព្រំដែន និងអាជីវកម្ម ឱ្យមកធ្វើការនៅកន្លែងឆបោក»។

ក្រសួងមហាផ្ទៃបានប្រកាសយុទ្ធនាការគំហុកមួយដើម្បីទប់ទល់នឹងការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត កាលពីខែសីហា ឆ្នាំ២០២២។ អ្នកស្រី ជូ ប៊ុនអេង បានបន្ថែមថា រដ្ឋាភិបាលបានរៀបចំការប្រជុំមួយរវាងក្រុមអ្នកជំនាញ ដើម្បីបញ្ជាក់ពីចំនួនប៉ាន់ប្រមាណប្រាកដប្រជាជាងមុន ហើយបញ្ជូនរបាយការណ៍ត្រឡប់ទៅកាន់អង្គការសហប្រជាជាតិវិញ។

បញ្ហាការជួញដូរឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានលើកឡើងអំឡុងពេលកិច្ចប្រជុំនៅក្រុងភ្នំពេញកាលពីខែកញ្ញារវាងនាយករដ្ឋមន្ត្រីថៃលោក Srettha Thavisin និងលោក ហ៊ុន ម៉ាណែត។ សារបង្ហោះលើបណ្ដាញសង្គមមួយ ពីសំណាក់ក្រសួងការបរទេសថៃ បានលើកឡើងថា មេដឹកនាំទាំងពីរបានពិភាក្សាពីបញ្ហាសន្តិសុខមួយចំនួន រួមមាន កិច្ចប្រតិបត្តិការជារួមដើម្បី «បង្ក្រាបឧក្រិដ្ឋកម្មឆបោកតាមប្រព័ន្ធអ៊ីនធឺណិត»។

លោក Jason Tower នាយកប្រចាំប្រទេសភូមានៃអង្គការវិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក (United States Institute of Peace) ដែលតាមដានការជួញដូរឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺ

ណិតនៅក្នុងតំបន់ បាននិយាយថា លោកមានមន្ទិលខ្លះចំពោះចំនួនមនុស្ស ១០០.០០០នាក់ត្រូវបាន ជួញដូរឱ្យធ្វើការដោយបង្ខំនៅក្នុងបណ្តាញក្រុមឆបោកនៅកម្ពុជា។ ប៉ុន្តែលោកលើកឡើងថា តួលេខ នេះអាចឆ្លុះបញ្ចាំងពីចំនួនសរុបនៃអ្នកពាក់ព័ន្ធនៅក្នុងវិស័យនេះក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។

យ៉ាងណាក្តីលោក Tower បាននិយាយថា៖«ការច្រានចោលដ៏ខ្លាំងក្លា» ពីសំណាក់រដ្ឋាភិបាល កម្ពុជាចំពោះរបាយការណ៍ខាងលើគឺជា «រឿងអកុសល» ទាំងសម្រាប់ក្រុមគាំពារសិទ្ធិ និងបណ្តា ប្រទេសអាស៊ីដទៃទៀត ដែលចង់បានការការពារប្រសើរជាងមុនចំពោះពលរដ្ឋរបស់ខ្លួននៅកម្ពុជា ក៏ដូចជា ការប្តេជ្ញាប្រសើរជាងមុន ដើម្បីដោះលែងអ្នករងការជាប់ឃុំដោយក្រុមឧក្រិដ្ឋជនជួញដូរមនុស្ស។ លោក Tower បានថ្លែងប្រាប់វីអូអេថា៖ «តាមការយល់ឃើញរបស់ខ្ញុំ គឺនៅមានជនរងគ្រោះច្រើន ហើយអាជ្ញាធរនៅតាមបណ្តាប្រទេសជិតខាង កំពុងបន្តដាក់សម្ពាធមកលើអាជ្ញាធរកម្ពុជាពាក់ព័ន្ធ នឹងជនរងគ្រោះ ដែលពួកគេព្យាយាមជួយសង្គ្រោះ និងថា មានការអូសបន្លាយពេល និងថា អ្វីៗនៅ មិនទាន់សភាពការណ៍គ្រប់គ្រាន់នោះទេ»។ លោកបានបន្តថា៖ «ដូច្នេះអ្នកដឹងហើយថា បញ្ហាច្បាស់ មិនទៅណានោះទេ ហើយខ្ញុំគិតថា កិច្ចការច្រើនទៀតអាចត្រូវធ្វើឡើង ដើម្បីបង្ហាញជាសារសំខាន់ មួយថា គឺមិនមានការទ្រាំទ្រណាមួយនោះទេនៅក្នុងប្រទេសនេះ ហើយខ្ញុំគិតថា យើងមិនទាន់ឈាន ដល់កម្រិតជោគជ័យនោះទេ»។

របាយការណ៍អង្គការសហប្រជាជាតិលើកឡើងថា មកទល់ខែកក្កដា ឆ្នាំ២០២៣ កន្លែង ឆបោកតាមប្រព័ន្ធអ៊ីនធឺណិតត្រូវបានរាយការណ៍ថា កំពុងមានដំណើរការនៅតាមបណ្តាខេត្ត និង ក្រុងយ៉ាងហោចណាស់ចំនួនប្រាំបីនៅកម្ពុជារួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តកោះកុង ក្រុងបាវិត ខេត្តព្រះសីហនុ ខេត្តឧត្តរមានជ័យ និងខេត្តស្វាយរៀង។

របាយការណ៍បានកំណត់ឈ្មោះតំបន់សេដ្ឋកិច្ចពិសេសចំនួនពីរ ដែលត្រូវបានជឿថា ផ្តល់ទី តាំងសម្រាប់កន្លែងឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ដែលមានដូចជា តំបន់សេដ្ឋកិច្ចពិសេសតាពាសាគរ និងតំបន់សេដ្ឋកិច្ចពិសេស Henge Thmorda។ ក្រុមហ៊ុនអភិវឌ្ឍន៍ចម្បងនៅតំបន់សេដ្ឋកិច្ចពិសេស តាពាសាគរគឺ ក្រុមហ៊ុន Union Development Group ដែលស្ថិតក្រោមការគ្រប់គ្រងដោយជនជាតិចិន។ តំបន់សេដ្ឋកិច្ចពិសេស Henge Thmorda ដែលតែងត្រូវបានហៅថា តំបន់សេដ្ឋកិច្ចពិសេស MDS Thmor Da ដែលពីមុនមក ត្រូវបានផ្សារភ្ជាប់នឹងការជួញដូរមនុស្ស និងស្ថិតក្រោមកម្មសិទ្ធិរបស់ លោកឧកញ៉ា ទ្រី ភាព។

លោក Jacob Sims នាយកប្រចាំតំបន់នៃអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំតំបន់អាស៊ី ប៉ាស៊ីហ្វិក បាននិយាយថា អង្គការបានឃើញមានការបោះជំហានទៅមុខ «គួរឱ្យកត់សម្គាល់» ពី សំណាក់រដ្ឋាភិបាលកម្ពុជានៅក្នុងការឆ្លើយតបទៅនឹងការជួញដូរឱ្យប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីន

ជីណិត។ លោកបានលើកឡើងថា នៅក្នុងចំណោមសញ្ញាបង្ហាញពីការបោះជំហានទៅមុខគឺ ការបើកឱ្យមានលេខទូរសព្ទទំនាក់ទំនងជាបន្ទាន់ ដើម្បីជួយជនរងគ្រោះដែលស្វែងរកជំនួយ ហើយធ្វើកិច្ចប្រឹងប្រែងប្រសើរជាងមុន ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ។ ហើយកន្លែងជំរំឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតនៅខេត្តព្រះសីហនុ និងក្រុងភ្នំពេញ ត្រូវបានបង្ក្រាប នៅក្នុងកម្រិតមួយ។

លោក Jacob Sims បានថ្លែងថា៖ «ប៉ុន្តែក៏មានភស្តុតាងសំខាន់បង្ហាញថា ទីតាំងទាំងនេះត្រូវបានរើផ្លាស់ទៅកាន់តំបន់ថ្មីនៅកម្ពុជាផងដែរ»។ លោកបន្តថា៖ «នៅកម្រិតខ្ពស់ ការទទួលខុសត្រូវពីសំណាក់ម្ចាស់ទីតាំង និងមេក្លោងក្រុមឧក្រិដ្ឋជនគឺជា កត្តាសំខាន់។ ទីតាំងមួយប្រហែលបិទទ្វារ ប៉ុន្តែទីតាំងមួយទៀតទំនងនឹងបើកទ្វារ ដរាបណាហានិភ័យចំពោះប្រតិបត្តិការ និងការសម្របសម្រួលលើផ្នែកឧក្រិដ្ឋកម្មនេះនៅមានទាប»។ លោក Sims បានលើកឡើងថា លោកគិតថា តួលេខជនរងគ្រោះ ១០០.០០០នាក់ «ហាក់ដូចជា គួរឱ្យជឿជាក់បាន» ដោយសាររបាយការណ៍សាធារណៈ សក្ខីកម្មពីសាក្សី និងទំហំនៃវិស័យល្បែងអនឡាញដ៏ទូលំទូលាយ»។

លោក Tower បានកត់សម្គាល់ថា ក៏មានការកើនឡើងនូវសម្ពាធផ្នែកហិរញ្ញវត្ថុមកលើកម្ពុជា ដើម្បីដោះស្រាយបញ្ហានេះផងដែរ។ ចិនបានពង្រឹងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការព្រមានដល់ពលរដ្ឋអំពីហានិភ័យ នៃការជួញដូរមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍ ដែលបាននាំឱ្យមានជាការផ្តល់ដំបូន្មានព្រមានហានិភ័យចំពោះការធ្វើដំណើរជាដើម និងថែមទាំងមានភាពយន្តល្បីឈ្មោះមួយអំពីជនជាតិចិន ដែលត្រូវបានបញ្ឆោះបញ្ឆូលឱ្យប្រព្រឹត្តអំពើឆបោកតាមរយៈការសន្យាផ្តល់ប្រាក់ខែខ្ពស់ផងដែរ។

លោក Sims បាននិយាយថា៖ «ផ្នែកនៃយុទ្ធសាស្ត្រនេះគឺ គ្រាន់តែបន្ទាចជនជាតិចិន ដើម្បីកុំឱ្យអ្នកណាម្នាក់ចង់ទៅតំបន់អាស៊ីអាគ្នេយ៍តែប៉ុណ្ណោះ»។ ការណ៍នេះបានបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់វិស័យទេសចរណ៍នៅកម្ពុជា ដែលផ្តោតភាគច្រើនលើអ្នកទេសចរណ៍ចិន ខណៈមិនទាន់បានងើបរើពេញលេញចេញពីវិបត្តិជំងឺកូវីដ១៩ នៅឡើយ។

លោក Tower បាននិយាយថា បណ្តាប្រទេសបស្ចិមលោកក៏បានយកចិត្តទុកដាក់លើបញ្ហានេះផងដែរ ដូចជា សហរដ្ឋអាមេរិក ដែលបានខាតបង់ប្រាក់រាប់ពាន់លានដុល្លារដោយសារការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាមានពលរដ្ឋត្រូវបាននាំចូលឱ្យធ្វើការឱ្យក្រុមបណ្តាញឧក្រិដ្ឋជនតាមប្រព័ន្ធអ៊ីនធឺណិត។ ទាំងលោក Sims និងលោក Tower សង្ឃឹមថា របាយការណ៍របស់អង្គការសហប្រជាជាតិនឹងជំរុញឱ្យមានការយកចិត្តទុកដាក់ខ្លាំងជាងមុន និងនាំយកធនធានផ្សេងៗ ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាញក្រុមជួញដូរមនុស្ស។ លោក Tower បាននិយាយថា៖ «ខ្ញុំគិតថា ការ

ដាក់បញ្ចូលការផ្តោតលើសិទ្ធិមនុស្សនឹងនាំឱ្យបណ្តាប្រទេសលោកខាងលិច កាន់តែច្រើនងាកមកមើលបញ្ហានេះ។ ហើយខ្ញុំគិតថា ការណ៍នេះនឹងផ្តល់ផ្នែកមួយបន្ថែមទៀតទៅដល់ការឆ្លើយតប»។

## គណៈកម្មការចំពោះកិច្ចដោះស្រាយដំណើរចេញចូលពលករឆ្លងដែន ចុះជួយសម្រួលដល់ដំណើរចេញចូលរបស់ពលករខ្មែរ តាមច្រកសំខាន់ៗ

https://www.information.gov.kh/articles/115954 AKPចេញផ្សាយ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២៣

ក្នុងនាមជាប្រធានទទួលបន្ទុកគោលដៅ អនុវត្តតាមមតិណែនាំខ្ពង់ខ្ពស់របស់ឯកឧត្តមសន្តិបណ្ឌិតប្រធានគណៈកម្មការ ឯកឧត្តម សំរិទ្ធ ឌី និងឯកឧត្តម សៀក សុជាតិ បានដឹកនាំក្រុមការងារចុះពិនិត្យស្ថានការណ៍ផ្ទាល់តាមច្រកនីមួយៗ ដើម្បីជួយសម្រួលដល់ដំណើរចេញចូលរបស់ពលករ ទប់ស្កាត់ការយកកម្រៃក្រៅផ្លូវការនានា និងជួយសម្រួលការកកស្ទះនៅតាមច្រកមុន និងក្រោយពេលបុណ្យភ្ជុំបិណ្ឌនេះ។

គណៈកម្មការមានយន្តការ ការងារយ៉ាងម៉ត់ចត់ ដើម្បីជួលដល់ពលករខ្មែរ ឲ្យបានចេញចូលប្រកបការងារដោយសុវត្ថិភាព និងកក់ក្តៅបំផុត តាមការគិតគូរយកចិត្តទុកដាក់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតីហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មការចំពោះកិច្ច ត្រួតពិនិត្យ និងដោះស្រាយដំណើរចេញចូលពលករឆ្លងដែន ក្រោយពីរាជរដ្ឋាភិបាលចេញសេចក្តីសម្រេចបង្កើតឡើង ដែលមានឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ជាប្រធានគណៈកម្មការ បានបំពេញកិច្ចការរបស់ខ្លួនយ៉ាងសកម្មតាមគោលដៅបណ្តាខេត្តនៅជាប់ព្រំដែនថៃ ក្នុងនោះមានខេត្តពោធិសាត់ ប៉ៃលិន បាត់ដំបង ដែលមានឯកឧត្តមសំរិទ្ធ ឌី រដ្ឋលេខាធិការក្រសួងមហាផ្ទៃជាប្រធាន។

ដោយឡែកខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ មានឯកឧត្តម សៀក សុជាតិ រដ្ឋលេខាធិការក្រសួងការពារជាតិជាប្រធាន។

## ក្រសួងសុខាភិបាល បិទគ្លីនិក មេត្រូ អអិលវី ក្រោយបោកអ្នកជំងឺរឿងវះកាត់ប្តូរសរីរាង្គ

https://www.kampucheathmey.com/local-news/597024 ថ្ងៃអង្គារ ១៧ តុលា ២០២៣

ដោយ Thoeun Vansong

ក្រសួងសុខាភិបាល បានសម្រេចបិទមន្ទីរពហុព្យាបាលឯកជនឈ្មោះ មេត្រូ អអិលវី ក្រោយមន្ទីរពហុព្យាបាលនេះ បានបោកអ្នកជំងឺ ដើម្បីរត់ការបញ្ជូនអ្នកជំងឺទៅវះកាត់ប្តូរសរីរាង្គដោយខុសច្បាប់នៅក្រៅប្រទេស។

សេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣នេះ បានសម្រេចបិទមន្ទីរពហុព្យាបាលឯកជនឈ្មោះ មេត្រូ អអិលវី ដែលមានទីតាំងនៅផ្ទះលេខ៦៨ ផ្លូវលេខ២៧១ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយមូលហេតុ មន្ទីរពហុព្យាបាលនេះបានប្រើប្រាស់សេវាពិគ្រោះបញ្ជូនអ្នកជំងឺទៅវះកាត់ប្តូរសរីរាង្គតម្រងនោមនៅប្រទេសឥណ្ឌា ដែលខុសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និង សរីរាង្គមនុស្ស។

គួរជម្រាបថា កន្លងទៅ មានពលរដ្ឋចំនួន១៨នាក់ បានអះអាងថា ពួកគាត់មានជំងឺខូចតម្រងនោម ហើយបានទាក់ទងរកសេវាព្យាបាលជាមួយមន្ទីរពហុព្យាបាល មេត្រូ អអិលវី (Metro RLV Polyclinic) ដែលជាតំណាងរបស់មន្ទីរពេទ្យមេត្រូ របស់ឥណ្ឌា កាលពីខែមីនា ឆ្នាំ២០២៣។ ប៉ុន្តែលទ្ធផលចុងក្រោយ មិនទទួលបានសេវាឡើយ ដោយសារលុយ បង់សម្រាប់ការព្យាបាលនោះ ត្រូវតំណាងមន្ទីរពហុព្យាបាលមេត្រូប្រមូលរត់គេចខ្លួនបាត់៕

# ថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០២៣

## ពលកររាប់រយនាក់ត្រឡប់ទៅរកការងារធ្វើនៅថៃវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្រោយមកជួបជុំសាច់ញាតិនាបុណ្យភ្ជុំ

https://kohsantepheapdaily.com.kh/article/1820267.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ១៨ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ០៩:០៤

ខេត្តបន្ទាយមានជ័យ ៖ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ម្សិលមិញនេះ ពលកររាប់រយនាក់បានត្រឡប់ទៅរកការងារធ្វើនៅប្រទេសថៃវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្រោយមកជួបជុំសាច់ញាតិក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។

នគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានប្រាប់ថា នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ដែលឈមច្រកខ្លងលឹក ខេត្តស្រះកែវ ប្រទេសថៃ ឃើញពលករខ្មែរបានត្រឡប់ទៅ

រកការងារធ្វើនៅប្រទេសថៃ១ថ្ងៃរាប់រយនាក់ ក្រោយត្រឡប់ជួបជុំក្រុមគ្រួសារក្នុងឱកាសបុណ្យភ្ជុំបិណ្ឌរួចរាល់។ នគរបាលច្រកទ្វាររូបនោះបានបញ្ជាក់ថា ពលករខ្មែរដែលត្រឡប់ទៅរកការងារធ្វើនៅប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត មានពលករទៅធ្វើការនៅទីក្រុងបាងកក និងតាមបណ្ដាខេត្ត និងចូលធ្វើការតាមបន្ទាត់ព្រំដែននៅផ្សាររុងក្លឿ ប្រទេសថៃ។

នគរបាលរូបនោះបានបញ្ជាក់ថា មុនថ្ងៃបុណ្យភ្ជុំបិណ្ឌ គេសង្កេតឃើញមានបងប្អូនពលករបានត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ១ថ្ងៃមានរាប់រយនាក់ ហើយជាការយកចិត្តទុកដាក់ ពីថ្នាក់ដឹកនាំកម្លាំងនគរបាលអន្តោប្រវេសន៍ ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានជូនក្រម៉ាម្នាក់មួយដល់ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ។ នគរបាលអន្តោប្រវេសន៍ច្រកទ្វាអន្តរជាតិប៉ោយប៉ែតបានបញ្ជាក់ថា នៅពេលពលករត្រឡប់ចូលមកកម្ពុជា ហើយត្រឡប់ទៅរកការងារធ្វើនៅប្រទេសថៃវិញ គឺមន្ត្រីជំនាញច្រកទ្វារបានសម្រួលបែបបទជូនអោយបានទាន់ពេលវេលាយ៉ាងល្អប្រសើរនិងឆាប់រហ័ស ៕

## ពលករថៃត្រូវថៅកែអ៊ីស្រាអែលបង្ខំឱ្យបន្តធ្វើការក្នុងតំបន់សង្គ្រាម

https://kohsantepheapdaily.com.kh/article/1820724.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ១៨ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ១៦:៥៤

អ៊ីស្រាអែល-ប៉ាឡេស្ទីន ៖ ពលករថៃអះអាងថា ថៅកែអ៊ីស្រាអែលរបស់ពួកគេបានបង្ខំឲ្យពួកគេធ្វើការក្នុងបណ្ដាតំបន់គ្រោះថ្នាក់នៅអ៊ីស្រាអែល ។ ខណៈចំនួនអ្នកស្លាប់ជាជនជាតិថៃនៅអ៊ីស្រាអែល ក្រោយការវាយប្រហាររបស់ក្រុមហាម៉ាស់ ពេលនេះកើនដល់៣០នាក់ បណ្ដាថៅកែអ៊ីស្រាអែល កំពុងត្រូវការកម្លាំងពលកម្មបរទេសច្រើន ហើយបង្ខំពលករថៃឲ្យធ្វើការក្នុងបណ្ដាតំបន់គ្រោះថ្នាក់ ។ ពលករថៃ២៨នាក់នៅអ៊ីស្រាអែលកំពុងស្នើដល់រដ្ឋាភិបាលឲ្យជួយធ្វើមាតុភូមិនិវត្តន៍ពួកគេក្រោយពីត្រូវថៅការបញ្ជូនទៅធ្វើការក្នុងតំបន់ក្រហម ។

ក្នុងការអំពាវនាវតាមវីដេអូមួយលើបណ្ដាញសង្គម ពលករថៃម្នាក់លោកពង្សសាកនអ៊ីនតាវន អាយុ៣១ឆ្នាំ មានដើមកំណើតនៅអ៊ូដុមថានី អះអាងថា រូបគេនិងពលករថៃ២៧នាក់ទៀត ត្រូវបានគេបង្ខំឲ្យទៅធ្វើការក្នុងចម្ការប៉េងប៉ោះមួយដែលបោះបង់ចោលនៅ YATED ជាទីក្រុងតូចមួយនាភាគខាងត្បូងអ៊ីស្រាអែល ចម្ងាយត្រឹមតែ១០គីឡូម៉ែត្រពីជ្រោយហ្គាហ្សា ។ មុននេះនិយោជកអ៊ីស្រាអែលរបស់ពួកគេបានជម្លៀសពលករថៃមកកាន់ទីក្រុងដាច់ស្រយាលមួយ ស្ថិតនៅចម្ងាយ២០០គីឡូម៉ែត្រពី YATED កាលពីថ្ងៃទី១០ តុលា ។ ប៉ុន្តែនាថ្ងៃទី១៥តុលាថៅកែបាននាំពួកគេមកកាន់កសិដ្ឋាន ហើយទុកពួកគេចោលនៅទីនោះ ។ ពលករថៃនៅទីនោះពិតជាមានការបារម្ភខ្លាំងណាស់ចំពោះសន្តិសុខ ។

មានពលករថៃប្រមាណជា ៣០.០០០នាក់ នៅអ៊ីស្រាអែលពេលជម្លោះផ្ទុះឡើងនាថ្ងៃទី៧ តុលា ។ មកទល់ពេលនេះតាមក្រសួងការងារថៃថា ពលករថៃប្រមាណជា៨១៦០នាក់នៅអ៊ីស្រាអែល បានបង្ហាញពីបំណងពួកគេវិលត្រឡប់មកស្រុកវិញ ៕

## សង្គមស៊ីវិលបារម្ភអំពីការចែករំលែករូបភាពអាសអាភាស និងសេវាកម្មផ្លូវភេទ យ៉ាងអនាធិបតេយ្យ តាមរយៈបណ្ដាញទំនាក់ទំនងសង្គម

ដោយសុជីវី 2023.10.18 https://www.rfa.org/khmer/news/social-economy/civil-society-concerned-about-sharing-pornography-and-sexual-services-through-social-media-10182023063429.html

មន្ត្រីសង្គមស៊ីវិលបារម្ភថា ការចែកចាយរូបភាពអាសអាភាស និងសេវាកម្មផ្លូវភេទ យ៉ាងអនាធិបតេយ្យនៅលើបណ្ដាញទំនាក់ទំនងសង្គម នឹងធ្វើឱ្យករណីរំលោភសេពសន្ថវៈកាន់តែមានចំនួនច្រើនឡើង ដែលធ្វើឱ្យប៉ះពាល់ដល់តម្លៃ និងសុវត្ថិភាពរបស់ស្ត្រី។ ពួកគាត់ស្នើឱ្យរដ្ឋាភិបាលមានចំណាត់ការលើបញ្ហានេះ ដើម្បីការពារស្ត្រី និងលើកកម្ពស់តម្លៃសីលធម៌សង្គមឡើងវិញ។ ការចែកចាយរូបភាពអាសអាភាស និងការលក់សេវាកម្មផ្លូវភេទ ក្នុងពេលបច្ចុប្បន្ន កំពុងមានភាពសកម្មនៅលើបណ្ដាញទំនាក់ទំនងសង្គម ប្រៀបបានទៅនឹងការដាក់លក់ទំនិញ ឬសេវាកម្មដទៃទៀតដូច្នោះដែរ។

អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រ នៃអង្គការខុមហ្វ្រែល (Comfrel) អ្នកស្រី សឹនកេត សិរីលក្ខណ៍ ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៦ តុលា ថា ក្មេងស្រី និងស្ត្រីជាច្រើន បានក្លាយជាជនរងគ្រោះ ដោយសារការរំលោភសេពសន្ថវៈមិនថានៅផ្ទះ នៅកន្លែងការងារ ឬទីសាធារណៈដទៃទៀត ដែលវាជាផលជះមួយផ្នែក បណ្ដាលមកពីការចែកចាយ មើលរូបភាពអាសអាភាស ដោយសេរីលើបណ្ដាញសង្គម។ អ្នកស្រីបន្តថា ភាពស្រើបស្រាលចេញពីរូបភាព ឬវីដេអូទាំងនោះ នឹងធ្វើឱ្យអ្នកមើល ជាពិសេសមនុស្សប្រុសមានចំណង់ផ្លូវភេទ ហើយចាប់ផ្ដើមប្រព្រឹត្តទង្វើមិនសមរម្យ ខណៈវាក៏បានធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ និងការសិក្សារបស់យុវវ័យផងដែរ។

អ្នកស្រី សឹនកេត សិរីលក្ខណ៍៖ «វាប៉ះពាល់ក្មេង ជាពិសេសក្មេងចាប់ពីអាយុ ៧-៨ឆ្នាំរហូតដល់អាយុក្រោម ១៨ឆ្នាំ ប៉ះពាល់ខ្លាំងណាស់! ប៉ះពាល់ដល់សតិអារម្មណ៍គាត់ ហើយក្នុងនាមបងជាម្ដាយ បងក៏បារម្ភខ្លាំង ចំពោះកូនយើងដែលប្រើប្រាស់ទូរស័ព្ទ ជាពិសេសបងក៏ឃើញកូនស្រីបងគាត់មើលនៅក្នុងយូធូប ហើយអូស (Scroll) មក វាទាក់ទង (Related) ទៅចេញរូបអាសអាភាសអីហ្នឹង យើងមានអារម្មណ៍ថាអត់ស្រួលក្នុងចិត្តទេ»។

ក្ដីបារម្ភនេះ កើតឡើងបន្ទាប់ពីមានការចែកចាយរូបភាពអាសអាភាស ភាគច្រើនធ្វើឡើងនៅតាមបណ្ដាញទំនាក់ទំនងសង្គម រួមមាន តេឡេក្រាម ហ្វេសប៊ុក និងគេហទំព័រមួយចំនួនទៀត ដែល

ត្រូវបានគេបង្កើតឡើងលក្ខណៈជាក្រុមៗ ចែកចាយឱ្យមើលដោយសេរី ឬលក់រូបភាព ឬវីដេអូទាំងនោះៗ ចំណែកនារីរកស៊ីផ្លូវភេទមួយចំនួន ក៏បានប្រើប្រាស់បណ្ដាញទាំងនោះ ដើម្បីរកអតិថិជនផងដែរ ដោយថតរូបភាពរបស់ខ្លួនដាក់ចូលទៅក្នុងក្រុម ដោយមានភ្ជាប់ជាមួយលេខទូរស័ព្ទ និងពាក្យសម្ដីស្រើបស្រាលផ្សេងៗ។ រីឯសមាជិកនៅក្នុងក្រុមចែកចាយរូបអាសអាភាសទាំងនោះ ភាគច្រើនជាបុរស មិនថាចាស់ ជំទង់ ឬក្មេងនោះឡើយ។ ពួកគេចូលរួមធ្វើជាសមាជិកក្នុងក្រុមទាំងនោះដោយសេរី និងគ្មានលក្ខខណ្ឌ។

ទាក់ទិនរឿងនេះ ប្រធានសមាគមនិស្សិតបញ្ញវន្តខ្មែរ លោក កើត សារ៉ាយ យល់ឃើញថា ភាពអនាធិបតេយ្យ នៃការចែករំលែករូបភាព ឬវីដេអូអាសអាភាស គឺជាផ្នែកមួយដែលធ្វើឱ្យករណីរំលោភសេពសន្ថវៈមានចំនួនកើនឡើង។ លោកបន្តថា រដ្ឋាភិបាលគួរបង្កើនការរឹតបន្តឹងលើការរកស៊ីផ្លូវភេទ និងសីលធម៌នៃការប្រើប្រាស់បណ្ដាញសង្គម ដើម្បីកុំឱ្យមានរូបភាពស្រើបស្រាលទាំងនោះចែកចាយ ដោយសេរី ហើយលេចធ្លាយទៅដល់ក្មេកយុវជន និងក្មេងជំទង់។

លោក កើត សារ៉ាយ៖ «ព្រោះយើងត្រូវការបណ្ដុះយុវជនធនជានមនុស្សល្អៗ ហើយដើម្បីជានាសុខសុវត្ថិភាព នៃសន្តិសុខសង្គមឱ្យល្អដែរ។ ដូច្នេះការដែលគ្រប់គ្រងឱ្យបាននូវការធ្វើឱ្យមានរូបភាពអាសអាភាស ជាសាធារណៈដែលអាចធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍យុវជនក្មេងៗអីជាដើមហ្នឹង ជារឿងមួយ ដែលត្រូវតែធ្វើការរឹតបន្តឹងៗ ហើយរឹតបន្តឹងនោះ ខ្ញុំជឿជាក់ថា សាមីក្រសួងជំនាញ គឺគាត់មានការយល់ដឹងជាងយើងទៅទៀត»។

កាលពីឆ្នាំ២០២១ និយតករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) បានចាត់វិធានការបិទខ្ទប់គេហទំព័រ និងយូអរិល (URL) ចំនួន៩ បន្ទាប់ពីរកឃើញថាគេហទំព័រនិងយូអរិលទាំងនេះ បានបង្ហោះរូបភាពនិងវីដេអូអាសអាភាសកុមារ តាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា។ តែទោះយ៉ាងណាក្ដី ការចាត់វិធានការនេះធ្វើឡើងតែមួយផ្នែកតូច ខណៈការចែកចាយរូបភាពអាសអាភាស និងការលក់សេវាកម្មផ្លូវភេទ កើតឡើងយ៉ាងគគ្រឹកគគ្រេង នៅក្នុងក្រុមតេឡេក្រាម។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទង ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា លោក សុខ នីត្យា និងអគ្គស្នងការនគរបាលជាតិ លោក ស ថេត ដើម្បីសុំការបកស្រាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី ១៧ តុលា។

យោងតាមវេបសាយ ដាតា រីផតថល (Data Reportal) បង្ហាញថា នៅក្នុងឆ្នាំ២០២៣ នេះ កម្ពុជាមានអ្នកប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គមចម្រុះចំនួនជិត ១១លាននាក់ (១០,៩៥) ឬស្មើនឹង ៦៥ភាគរយ នៃចំនួនប្រជាជនសរុប។ ក្នុងនោះអ្នកប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គមតេឡេ

ក្រាម (Telegram) ជាង ១០លាននាក់ ហ្វេសប៊ុក (Facebook) មានចំនួន ១០លាននាក់(១០,៤៥) អ៊ីនស្តាក្រាម (Instagram) ជាង ១លាននាក់ (១,៧៥) និងតិកតុក (Tik Tok) ជាង ៧លាននាក់ (៧,០៦)។

ជុំវិញរឿងនេះ ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក លោក នី សុខា លើកឡើងថា ការចែកចាយរូបភាពអាសអាភាសនៅលើបណ្តាញសង្គម គឺជាការប្រើប្រាស់សិទ្ធិហួសហេតុ ដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណីទំនៀមទម្លាប់ខ្មែរ។ លោកជំរុញឱ្យរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធមានវិធានការទប់ស្កាត់ទង្វើទាំងអស់នេះ ជាជាងការរាំងខ្ទប់ឬចាត់វិធានការលើសំឡេងលេងរិះគន់ និងការតស៊ូមតិផ្សេងៗ។ លោក នី សុខា៖ «ដូចខ្ញុំជម្រាប គឺថាវាមានផលប៉ះពាល់ធ្ងន់ធ្ងរណាស់ ហើយរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ក្នុងការមានវិធានការ។ ខ្ញុំគិតថា រដ្ឋាភិបាលមិនមែនអត់សមត្ថភាពក្នុងការចាត់វិធានការចំពោះបញ្ហាអ៊ីចឹងទេ ពីព្រោះថា ប្រសិនបើមានបុគ្គលណានិយាយប៉ះពាល់ដល់ថ្នាក់ដឹកនាំរដ្ឋាភិបាល ឬក៏ប៉ះពាល់ដល់កិត្តិយស ឬក៏មានបញ្ហានិយាយរិះគន់រដ្ឋាភិបាលអី រដ្ឋាភិបាលមានចំណាត់ការលឿនណាស់ មិនអាចគេចរួចទេ»។

ការចែកចាយរូបភាពអាសអាភាស និងការលក់សេវាកម្មផ្លូវភេទ មិនមែនមានតែនៅក្នុងបណ្តាញសង្គមប៉ុណ្ណោះទេ ដោយនៅតាមហាងកាហ្វេមួយចំនួន ក៏មានបង្កប់នូវសកម្មភាពទាំងនេះផងដែរ។ នៅក្នុងហាងកាហ្វេទាំងនោះមានសភាពងងឹតជាងហាងកាហ្វេធម្មតា ហើយតែងមានសិស្សនិស្សិត ឬមនុស្សវ័យកណ្តាលចេញចូលហូរហែ ប្រៀបបានទៅនឹងទីស្នាក់ការនៃការចែកចាយរូបភាព ឬសេវាកម្មផ្លូវភេទ និងការប្រព្រឹត្តអំពើអបាយមុខដទៃទៀតដែរ។

ជាលទ្ធផលនៃទិដ្ឋភាពទាំងនេះ ការចុះផ្សាយរបស់សារព័ត៌មានកន្លងមក បានបង្ហាញនូវករណីរំលោភសេពសន្ថវៈបានកើតឡើងទៅលើទារក កុមារ ទៅដល់មនុស្សពេញវ័យ រហូតដល់មានអ្នកស្លាប់ ឬបាត់បង់សតិ ខណៈជនល្មើសមួយចំនួនជាអនីតិជន ខ្លះជាឪពុកបង្កើត ឪពុកចុង ជីតា ឬសាច់ញាតិដទៃទៀតជាមួយជនរងគ្រោះ។

មន្ត្រីសង្គមស៊ីវិលយល់ឃើញថា ករណីទាំងនេះអាចនឹងកើតឡើងដោយសារជនល្មើសមើលរឿងអាសអាភាស ហើយមិនអាចគ្រប់គ្រងខ្លួនបាន។ ពួកគាត់បារម្ភថា ក្មេងស្រី និងស្ត្រី កាន់តែប្រឈមនឹងការរំលោភសេពសន្ថវៈកាន់តែខ្លាំងជាងនេះ ប្រសិនបើការចែកចាយរូបភាពអាសអាភាសនៅលើបណ្តាញសង្គម នៅតែបន្តដោយអនាធិបតេយ្យ គ្មានចំណាត់ការពីរដ្ឋាភិបាល៕

# ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២៣

## មន្ត្រីមហាផ្ទៃ
## ជំរុញឱ្យបន្តអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" នៅខេត្តកណ្ដាល

https://www.kampucheathmey.com/local-news/597671 *ថ្ងៃព្រហស្បតិ៍ ១៩ តុលា ២០២៣*

*ដោយ អុន ស្រីមាន*

*រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក អង មង្គល បានជំរុញឱ្យអភិបាលក្រុង-ស្រុកទាំងអស់នៅក្នុងខេត្តកណ្ដាល បន្តចុះពង្រឹង និងអនុវត្តនូវគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" ដល់ឃុំ-សង្កាត់ របស់ខ្លួនឱ្យបានជាប់ជាប្រចាំដើម្បីផ្ដល់សុខសុវត្ថិភាពបន្ថែមដល់ប្រជាជន។ លោក ជំរុញបែបនេះ នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" ប្រចាំខែតុលា ឆ្នាំ២០២៣ និងលើកទិសដៅអនុវត្តបន្តរបស់រដ្ឋបាលខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣។*

*លោករដ្ឋលេខាធិការ បានបញ្ជាក់ថា៖ "ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព របស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក ឃុំ-សង្កាត់ ធ្វើឱ្យរដ្ឋបាលខេត្ត ទប់ស្កាត់បាននូវបទល្មើសនានា ក្នុងមូលដ្ឋាន ដូចជាបទល្មើសគ្រឿងញៀន ចោរកម្ម ល្បែងស៊ីសង គ្រោះថ្នាក់ចរាចរណ៍ ការជួញដូរមនុស្ស ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ បទល្មើសសេដ្ឋកិច្ច បទល្មើសនានាតាមច្រកព្រំដែន និងច្រករបៀងនានា ត្រូវបានបង្ក្រាប ទប់ស្កាត់ បានទាន់ពេលវេលា និងមានវិធានការចុះអប់រំផ្សព្វផ្សាយជាប្រចាំផងដែរ"។ លោកក៏បានបន្ថែមថា នៅពេលដែលប្រទេសមានស្ថេរភាពគ្រប់គ្រាន់ នោះក៏ធ្វើឱ្យគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា មានការរីកចម្រើនដូចគ្នា។*

*រីឯ លោក គង់ សោភ័ណ្ឌ អភិបាលខេត្តកណ្ដាល បានលើកឡើងថា នៅខែតុលានេះ រដ្ឋបាលខេត្តកណ្ដាលបានយកចិត្តទុកដាក់ និងអន្តរាគមន៍ជូនប្រជាពលរដ្ឋភ្លាមៗចំពោះមានបញ្ហាអ្វីកើតឡើង ជាពិសេស ត្រួតពិនិត្យយ៉ាងដិតដល់លើសកម្មភាពអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ដោយសម្រេចបានលទ្ធផលជាច្រើនទាំងគុណភាព និងប្រសិទ្ធភាព។*

*នៅខេត្តកណ្ដាល នៅក្នុងខែតុលានេះ បទល្មើព្រហ្មទណ្ឌ កើតឡើងចំនួន ១៨/២៥ករណី ថយ៧លើក បានបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ១៥ករណី ស្មើនឹង៨៣% ចាប់ជនល្មើស ៣២នាក់។ បានបង្ក្រាបបទល្មើសគ្រឿងញៀនចំនួន ៤៧ករណី ចាប់ជនល្មើស ១០៩នាក់។ គ្រោះថ្នាក់ចរាចរណ៍កើតឡើង ១៤ / ៩លើក កើន ៥លើក បណ្ដាលឱ្យស្លាប់ ៧នាក់, របួស២៦នាក់ កើតឡើងដោយសារ បើកបរក្នុងស្ថានភាពស្រវឹង មិនគោរពសិទ្ធិអាទិភាព ប្រជែងគ្រោះថ្នាក់ បើកហួសល្បឿន*

កំណត់ និងមិនប្រកាន់ស្តាំ។ នេះបើតាមការគូសបញ្ជាក់របស់លោក គង់ សោភ័ណ្ឌ អភិបាលខេត្តកណ្ដាល៕

## តុលាការ នៅប្រទេសវៀតណាម កាត់ទោសស្ត្រី៦នាក់ ឱ្យជាប់ពន្ធនាគារ៣០ ឆ្នាំ ចំពោះការជួញដូរ និងលក់ស្ត្រី ឱ្យរៀបការ ជាមួយបុរសចិន

https://dap-news.com/international/2023/10/19/366467/ ByPH104Posted on October 19, 2023 2:19 pm VNEXPRESS

បរទេស ៖ តុលាការខេត្ត Bac Lieu ប្រទេសវៀតណាម បានកាត់ទោសស្ត្រីចំនួន៦នាក់ ឱ្យជាប់ពន្ធនាគាររយៈពេល ៣០ឆ្នាំ ចំពោះការជួញដូរ ដែលបានបោកបញ្ឆោត និងលក់ស្ត្រីទៅប្រទេសចិន ធ្វើជាប្រពន្ធគេ។

យោងតាមសារព័ត៌មាន VN Express ចេញផ្សាយកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ បានឱ្យដឹងថា ឈ្មោះ Luong Thi Hai អាយុ ៣១ឆ្នាំ មានស្រុកកំណើតនៅខេត្ត Nghe An ភាគកណ្ដាល ត្រូវបានគេកំណត់អត្តសញ្ញាណថាជាមេខ្លោង។ ឈ្មោះនេះត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនា ៣០ ឆ្នាំពីបទ "ជួញដូរមនុស្ស ទិញ និងលក់មនុស្សអាយុក្រោម ១៦ឆ្នាំ រៀបចំការចូលខុសច្បាប់សម្រាប់អ្នកដទៃ និងការរឹបអូសទ្រព្យសម្បត្តិ" នៅឯការកាត់ក្តីនៅខេត្តភាគខាងត្បូងកាលពីថ្ងៃអង្គារ។

ចំណែកមនុស្ស៥នាក់ផ្សេងទៀត រួមមាន ឈ្មោះ Pham Thi Tu, Huynh Mong Linh, Nguyen Thi Ngoc Ha, Thach Thi Thu Nga, និងឈ្មោះ Nguyen Thi Tuyen ត្រូវបានគេកាត់ទោសពី ៥ ទៅ ២៩ ឆ្នាំដោយចោទប្រកាន់ដូចគ្នា។ យោងតាមសាលក្រម ឈ្មោះ Hai បានទៅធ្វើការនៅប្រទេសចិនកាលពីឆ្នាំ ២០១៥ បន្ទាប់មកនាងបានរៀបការ និងតាំងទីលំនៅនៅក្នុងខេត្ត Henan ភាគកណ្ដាលរបស់ប្រទេសចិន ។ Hai បានដឹងថា មានបុរសជាច្រើននៅក្នុងប្រទេសចិន ចង់រៀបការជាមួយស្ត្រីវៀតណាម ដើម្បីមានកូន ដូច្នេះនាងនិងប្តីរបស់នាង ដែលមិនស្គាល់អត្តសញ្ញាណ និងអាសយដ្ឋានក៏សម្រេចចិត្តបោកបញ្ឆោត និងលក់ស្ត្រីវៀតណាម ឱ្យបុរសចិនទាំងនោះ៕ ប្រែសម្រួល: ណៃ តុលា

## គណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរព្រំដែនកម្ពុជាបើកកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយ និងពិភាក្សាពីរបៀបរបបការងាររបស់ក្រុមលេខាធិការដ្ឋានចេកវិលែក

https://www.tvk.gov.kh/?p=38042 ចេញផ្សាយ ថ្ងៃទី 19 ខែ តុលា ឆ្នាំ 2023

ភ្នំពេញ : ឯកឧត្តម សន្តិបណ្ឌិត គៀត ច័ន្ទថារិទ្ធ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម សន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជា

ប្រធានគណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរព្រំដែនកម្ពុជាបានបើកកិច្ចប្រជុំលេខាធិការដ្ឋានគណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូល របស់ពលករខ្មែរព្រំដែនកម្ពុជា ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចបង្កើតក្រុមលេខាធិការដ្ឋាន និងពិភាក្សាពីរបៀបរបបការងាររបស់ក្រុមលេខាធិការដ្ឋាន។

កិច្ចប្រជុំនេះបានធ្វើឡើងនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម ថោង សំអាត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមលេខាធិការដ្ឋានប្រចាំការនៃគណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរព្រំដែនកម្ពុជា លោក-លោកស្រីអនុប្រធាន និងសមាជិកដែលតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

ឯកឧត្តម សន្តិបណ្ឌិត គៀត ច័ន្ទថារិទ្ធ មានប្រសាសន៍ថា គោលបំណងនៃកិច្ចប្រជុំនេះគឺផ្តោតលើ ១.ផ្សព្វផ្សាយសេចក្តីសម្រេចបង្កើតក្រុមលេខាធិការដ្ឋាន នៃគណៈកម្មការចំពោះកិច្ច ២.ការផ្សព្វផ្សាយពីគម្រោងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Hotline 1244 ដើម្បីទទួលពាក្យបណ្តឹងពីពលករដែលធ្វើដំណើរចេញ-ចូលតាមព្រំដែន និង៣.ពិភាក្សាពីរបៀបរបបការងាររបស់ក្រុមលេខាធិការដ្ឋានប្រចាំការ។

ឯកឧត្តម សន្តិបណ្ឌិតក៏បានណែនាំពីភារកិច្ចរបស់គណៈកម្មការចំពោះកិច្ច ក៏ដូចជាផ្តល់អនុសាសន៍ពាក់ព័ន្ធក្រុមលេខាធិការដ្ឋាន គឺជាជំនួយការដល់គណៈកម្មការ និងកិច្ចការងាររដ្ឋបាល និងតួនាទីសំខាន់មួយទៀតគឺការងារក្រុមការងារ Call Center (1244)ដែលមានមន្ត្រីប្រចាំការ២៤ម៉ោងសម្រាប់ទទួលការទាក់ទងជាមួយដំណើរចេញចូល និងការប្តឹងផ្តល់ របស់ពលករខ្មែរតាមបណ្តាខេត្តជាប់ព្រំដែនឱ្យទាន់ហេតុការណ៍និងប្រសិទ្ធភាព។

ឯកឧត្តម សន្តិបណ្ឌិត គៀត ច័ន្ទថារិទ្ធ បានលើកឡើងបន្ថែមថា ចំពោះកិច្ចការដែលក្រុមការងារបានដោះស្រាយរួចគឺត្រូវតែផ្សព្វផ្សាយជាព័ត៌មានជូនប្រជាពលរដ្ឋតាមបណ្តាញស្ថានីយ៍វិទ្យុទូរទស្សន៍ ទីភ្នាក់ងារ ស្ថាប័នរដ្ឋ និងឯកជន ក៏ដូចជាតាមបណ្តាញសង្គម Social Media ផងដែរ។

ក្នុងឱកាសនោះដែរ ឯកឧត្តម ថោង សំអាត បានគូសបញ្ជាក់ពីបញ្ហាមួយចំនួនកន្លងមក ដែលភាគីកម្ពុជាយើងតែងតែជួបប្រទះ គឺបញ្ហាការកកស្ទះការឆ្លងចេញ-ចូលប្រចាំថ្ងៃរបស់ពលករ (ជាពិសេសគឺថ្ងៃបុណ្យទាន) ការចាប់បញ្ជូនពលករខុសច្បាប់កម្ពុជាពីប្រទេសថៃ មកប្រទេសកម្ពុជា និងការលួចចូលឆ្លងដែនតាមច្រកផ្សេងៗ ដោយខុសច្បាប់ ជាពិសេសនោះគឺពាក់ព័ន្ធការយកកម្រៃសេវាក្រៅពីសំណាក់អាជ្ញាធរមួយចំនួនរបស់កម្ពុជា អាជ្ញាធរថៃ និងមេខ្យល់រត់ការជាដើម ចំណុចទាំងអស់នេះ ។

ឯកឧត្តមប្រធានក្រុមលេខាធិការដ្ឋានប្រចាំការ នៃគណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរព្រំដែនកម្ពុជា បានសង្កត់ធ្ងន់ថា សម្រាប់ក្រុមលេខាធិការដ្ឋាននេះ គឺត្រូវសរុបរបាយការណ៍ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ហើយចំពោះរបាយការណ៍ ដែលសរុបនេះត្រូវបាន ផ្តល់ជូនពី ក្រុមទី១ និងក្រុមទី២ ដែលទទួលខុសត្រូវត្រួតពិនិត្យទាំង៧ ខេត្ត ជាប់ព្រំដែនថៃ រួមមាន៖ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ។

សូមជម្រាបជូនថា ប្រធានក្រុមលេខាធិការដ្ឋានប្រចាំការ នៃគណៈកម្មការចំពោះកិច្ចពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរព្រំដែនកម្ពុជា បានកំណត់គោលដៅមួយចំនួនសម្រាប់កិច្ចប្រជុំនោះគឺ ទី១. ដោះស្រាយរាល់បញ្ហាបំពានសិទ្ធិទៅលើពលករកម្ពុជាយើងនៅតាមព្រំដែន ទី២.ដោះស្រាយបញ្ចប់ការយកកម្រៃសេវាក្រៅផ្លូវការ ទី៣. ដោះស្រាយភាពមិនប្រក្រតីពីមន្រ្តីជួរមុខតាមព្រំដែន និងទី៤. សម្រួលការកកស្ទះពលករឆ្លងដែន៕

# ថ្ងៃទី២៣ ខែ តុលា ឆ្នាំ២០២៣

## អង្គការ APLE និងភាគបាទក្រហមកម្ពុជា បន្តរួមបញ្ជ្រាបការយល់ដឹងពីការបង្ការ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

https://freshnewsasia.com/index.php/en/localnews/314744-2023-10-20-04-25-44.html 2023-10-20 11:25am

**(ភ្នំពេញ)៖** អង្គការ APLE និងសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ បន្តរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង ពីកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដល់អាណាព្យាបាល៥៤នាក់ មកពីខណ្ឌចំនួន៣ ក្នុងរាជធានីភ្នំពេញ។ ពិធីនេះធ្វើឡើងនាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការឧបត្ថម្ភគាំទ្រពីមូលនិធិ World Childhood Foundation នៃប្រទេសស៊ុយអែត។

កម្មវិធីនេះមានការអញ្ជើញចូលរួមជាអធិបតីពីលោក ជិន ប៊ុនធឿន នាយកប្រតិបត្តិ នៃសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ និងលោក ណេង វណ្ណៈ តំណាងអង្គការ APLE។ កម្មវិធីនេះ មានគោលបំណងពង្រឹងចំណេះដឹង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ធ្វើការឆ្លុះបញ្ចាំងឈ្វេងយល់លើការប្រើប្រាស់អ៊ីនធឺណិត និងការទំនាក់ទំនងតាមបច្ចេកវិទ្យា

*របស់កុមារ និងយុវជននៅប្រទេសកម្ពុជា ឈ្វេងយល់ពីហានិភ័យនៃការប្រើប្រាស់អ៊ីធឺណិត និងទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងការឆ្លើយតបចំពោះបញ្ហានេះ។*

*បើតាមនាយកប្រតិបត្តិ នៃសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ បានថ្លែងថា* ***«ឪពុកម្ដាយ និងអាណាព្យាបាលនៅតែដើរតួនាទីសំខាន់ណាស់ក្នុងការរក្សាសុវត្ថិភាពកូនៗ និងកុមារដទៃទៀតក្នុងសហគមន៍ពីព្រោះពួកគាត់រស់នៅជិតស្និតជាមួយពួកគេ។ ហេតុដូច្នេះ ឪពុកម្ដាយ និងអាណាព្យាបាលត្រូវតែបន្តយកចិត្តទុកដាក់តាមដាន និងណែនាំកូនៗឱ្យយល់ដឹងពីហានិភ័យ និងការរក្សាសុវត្ថិភាពនៅពេលពួកគេប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ឬអនឡាញ»*** *។*

*តាមការសិក្សាស្រាវជ្រាវ បានឱ្យដឹងថាអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញបានក្លាយជាបញ្ហាសកល និងនៅក្នុងប្រទេសកម្ពុជា ហើយវាក៏បានក្លាយជាក្ដីបារម្ភថ្មីមួយទៀតដែលទាមទារឱ្យភាគីពាក់ព័ន្ធទាំងសាធារណជន អាណាព្យាបាល អាជ្ញាធរ សង្គមស៊ីវិល មន្ត្រីអនុវត្តច្បាប់ ចាំបាច់ធ្វើការរួមគ្នាដើម្បីទប់ស្កាត់ និងការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញនេះ។*

*តំណភ្ជាប់អ៊ីនធឺណិតនៅកម្ពុជា បានកើនឡើងជាលំដាប់ ហើយមនុស្សកាន់តែច្រើនឡើងៗ រួមទាំងកុមារមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ការសិក្សាថ្មីលើការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា* (Disruptiong Harm Study in Cambodia) *បានបង្ហាញថា កុមារ ជាង៨០% ដែលមានអាយុចន្លោះពី ១២ឆ្នាំ ទៅ ១៧ឆ្នាំ បានប្រើប្រាស់ និងភ្ជាប់អ៊ីនធឺណិតច្រើនជាងមនុស្សពេញវ័យ ខណៈដែលកុមារ និងក្មេងវ័យជំទង់ បានចំណាយពេលវេលាច្រើនលើការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ពួកគេភាគច្រើនមិនបានដឹងពីហានិភ័យ និងគ្រោះថ្នាក់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញនោះទេ។*

*សូមបញ្ជាក់ផងដែរថា យោងតាមរបាយការណ៍របស់អង្គការ* APLE *ក្នុងរយៈពេល៩ខែ ឆ្នាំ២០២៣ មានការរាយការណ៍ចំនួនជាង១៨០ករណី ដែលពាក់ព័ន្ធនឹងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ហើយមាន ១៣០ករណី ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៕*

# សភាកម្ពុជា-ឡាវ-វៀតណាម ជំរុញទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែននៅតំបន់ត្រីកោណ

https://www.information.gov.kh/articles/116158 ចេញផ្សាយ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២៣

*រដ្ឋសភានៃប្រទេសកម្ពុជា ឡាវ និងវៀតណាម បានជំរុញឱ្យមានការខិតខំទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់អភិវឌ្ឍន៍ជាប់ព្រំប្រទល់គ្នា ខណៈនៅតំបន់ត្រីកោណនេះ ទទួលបានគម្រោងអភិវឌ្ឍន៍ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី ការបើកច្រកទីផ្សារ ដែលលើកកម្ពស់ដល់ទំនាក់ទំនង និងជីវភាពរស់នៅរបស់ប្រជាជននៃ ប្រទេសទាំងបីនេះ។*

*ការជំរុញលើកិច្ចសហប្រតិបត្តិការរួមគ្នា ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែននេះ ធ្វើឡើងក្នុងពេលរដ្ឋសភានៃប្រទេសទាំងបី ជួបប្រជុំពិភាក្សាគ្នាក្នុងក្របខ័ណ្ឌគណៈកម្មការជំនាញ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃកិច្ចព្រមព្រៀង និងការអនុវត្តគម្រោងអភិវឌ្ឍន៍ក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណ ដែលអនុម័តដោយរដ្ឋាភិបាលនៃប្រទេសទាំងបីនាឆ្នាំកន្លងទៅមានដូចជា៖ ជំរុញកំណើនឧស្សាហកម្មដំណាំកៅស៊ូ វិស័យកសិកម្ម និងទេសចរណ៍ ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននិងអំពើជួញដូរគ្រឿងញៀន ការពន្លឿនគម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់ជាប់ព្រំដែន ពន្លឿនការកាត់បន្ថយភាពក្រីក្រ ជាដើម។*

*ឯកឧត្តម សួស យ៉ារ៉ា ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភាកម្ពុជា បានគូសបញ្ជាក់ពីសារៈសំខាន់លើការផ្សារស្រាវជ្រាវ និងអភិវឌ្ឍន៍តំបន់ត្រីកោណដូចជាយន្តការនៃការទូទាត់ប្រាក់ ដើម្បីជួយសម្រួលពាណិជ្ជកម្មឆ្លងដែនក្នុងតំបន់ត្រីកោណ, ការលើកទឹកចិត្តបង្កើតផ្សារនៅតាមព្រំដែនដើម្បីជំរុញពាណិជ្ជកម្ម, ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនឱ្យបានដាច់ខាត ខណៈគម្រោងវិនិយោគចំនួន២៧គម្រោងរបស់វៀតណាម នៅខេត្តក្នុងតំបន់ត្រីកោណ ទើបតែដំណើរការបានត្រឹម១០គម្រោងប៉ុណ្ណោះ ស្របពេលគម្រោងវិនិយោគវារីអគ្គិសនី សេសាន២ ក្នុងទំហំទឹកប្រាក់វិនិយោគរបស់ក្រុមហ៊ុនចិនចំនួន៨០០លានដុល្លារអាមេរិក ដែលមានសមត្ថភាពផលិតថាមពលអគ្គិសនីបានដល់៤០០មេហ្គាវ៉ាត់ ផ្គត់ផ្គង់ដល់រាជធានីភ្នំពេញ និងបញ្ជូនមួយភាគតូចទៅខេត្តរតនគិរី និងគម្រោងទឹកស្អាតដែលជាជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងទុនវិនិយោគ១៣លានដុល្លារ បាននិងកំពុងអនុវត្តតាមផែនការ។*

*ឯកឧត្តម វូ ហាយហា ប្រធានគណៈកម្មាធិការកិច្ចការបរទេស នៃរដ្ឋសភាវៀតណាម បានឯកភាពចំពោះការលើកឡើងរបស់តំណាងរដ្ឋសភាកម្ពុជា និងបានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការអភិវឌ្ឍមណ្ឌលសុខភាពក្នុងតំបន់ត្រីកោណ ព្រមទាំងការជំរុញឱ្យមានការអភិវឌ្ឍន៍កាន់តែខ្លាំងឡើង និងស្របគ្នាក្នុងប្រទេសទាំងបី។*

ចំណែក ឯកឧត្តម Linkham DOUANSAVANH ប្រធានគណៈកម្មការសេដ្ឋកិច្ច បច្ចេកវិទ្យា និងបរិស្ថាន និងជាប្រធានគណៈប្រតិភូឡាវ គាំទ្រឱ្យមានការវិនិយោគពីភាគីវៀតណាម ដោយឯកឧត្តមថ្លែងថា ភាគីឡាវ ក៏ដូចជាភាគីកម្ពុជា តែងតែបើកចំហ និងជួយសម្រួល ហើយគាំទ្រការវិនិយោគលើវិស័យកសិកម្ម នៅក្នុងតំបន់ត្រីកោណ។

គួររំឭកថា តំបន់ត្រីកោណអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ឡាវ វៀតណាម កាលពីឆ្នាំ១៩៩៩ ក្នុងគោលបំណងអភិវឌ្ឍន៍ផែនការមេស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម ធនធានសក្តានុពល ព្រមទាំងរចនាសម្ព័ន្ធរួម និងដោយឡែកនៅក្នុងខេត្តជាប់ព្រំដែននៃ ប្រទេសទាំងបី ដែលនៅកម្ពុជាមាន៖ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី។ ចំណែកឯប្រទេសឡាវ មានខេត្តចំប៉ាសាក់ អាតាពើ សេកុង សារ៉ាវ៉ាន់ និងប្រទេសវៀតណាមវិញ មានខេត្តកុនទុំ ចាឡៃ ប៊ិញភឿក ដាកឡាក់ និងដាកណង៕ អត្ថបទ៖ វ៉ាង កក្តី ផ្សាយដោយ៖ កន ចំណាន

## ពលករខ្មែរមួយចំនួនចូលធ្វើការវិញខណៈមួយចំនួនត្រៀមកវិញក្រោយថៃចាប់ខ្លួន

https://www.rfi.fr/km//20231020-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 20/10/2023 - 11:25

*សំណុំរឿងពលករខ្មែរជាង២០០នាក់ ដែលត្រូវបានចាប់ខ្លួន ដោយអាជ្ញាធរថៃ កាលពីពាក់កណ្តាលខែតុលានេះ មួយចំនួនត្រូវបានថៅកែថៃទទួលយកទៅធ្វើការវិញ និងមួយចំនួនត្រៀមបញ្ជូនមកកម្ពុជាក្នុងករណីគ្មានឯកសារស្របច្បាប់។*

លោក កត្តា អន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានគូសបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិ rfi នៅថ្ងៃទី២០ខែតុលាឆ្នាំ២០២៣ថា ពលករខ្មែរដែលត្រូវបានឃាត់ខ្លួនដោយអាជ្ញាធរមានចំនួនជាង២០០នាក់ ក្នុងចំណោមពលករបរទេសសរុបចំនួន៣៤៧នាក់។ អ្នកនាំពាក្យរូបនេះបន្ថែមថា ករណីចាប់ខ្លួនពលករខ្មែរ ផ្តើមចេញពីកិច្ចអន្តរាគមន៍របស់ប៉ូលីសថៃចំពោះករណីកាប់ចាក់គ្នាមានរបួសស្នាមក្នុងខេត្តអយុធ្យា ដែលពេលនោះប៉ូលីសថៃបានប្រមូលផ្តុំពលករទាំងអស់ ហើយត្រួតពិនិត្យក៏រកឃើញមានពលករមិនមានឯកសារត្រឹមត្រូវកំពុងធ្វើការនៅប្រទេសថៃ។

នៅចំពោះមុខរឿងនេះ រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារស្នើសុំអាជ្ញាធរពាក់ព័ន្ធសម្របសម្រួលដោះលែងពលករមានឯកសារស្របច្បាប់ និងពលករចុះឈ្មោះតាមប័ណ្ណស៊ីជម្ពូ ត្រឡប់មកធ្វើការតាមធម្មតាវិញ ហើយថៅកែថៃមួយចំនួនក៏បានទទួលពលករទាំងនោះមកវិញ

បន្ទាប់ពីរៀបចំឯកសារស្របច្បាប់រួចរាល់។ ករណីពលករមិនមានឯកសារផ្លូវច្បាប់ និងគ្មានប័ណ្ណការងារក្នុងប្រទេសថៃ នឹងត្រូវអនុវត្តតាមច្បាប់អន្តោប្រវេសន៍ថៃ គឺបញ្ជូនត្រឡប់មកកម្ពុជាវិញតាមខេត្តស្រះកែវ ហើយកម្ពុជាក៏បានណែនាំពលកររបស់ខ្លួនអំពីសារៈសំខាន់ នៃភាពស្របច្បាប់ដើម្បីធ្វើការងារនៅប្រទេសគេដោយមិនបារម្ភ។

ចំណែកលោក ឡឹង សុផុន មន្ត្រីអង្គការសង់ត្រាល់ប្រចាំនៅក្នុងប្រទេសថៃធ្លាប់ប្រាប់វិទ្យុបារាំងអន្តរជាតិ RFIថា ពលករខ្មែរជាង៤០០នាក់ ក្នុងចំណោមពលករបរទេសសរុបជាង១ពាន់នាក់ត្រូវបានអាជ្ញាធរចាប់ខ្លួន ដោយសារតែគ្មានឯកសារត្រឹមត្រូវតាមច្បាប់ការងាររបស់ថៃ។ បើតាមលោក ឡឹង សុផុន ការចាប់ខ្លួនធ្វើឡើងនៅកន្លែងធ្វើការ និងម្តុំកន្លែងស្នាក់នៅរបស់ពលករ។ បន្ទាប់ពីចាប់ខ្លួនទាំងពលករខ្មែរ និងពលករបរទេសត្រូវបានបញ្ជូនទៅឃុំខ្លួននៅកន្លែងរស់នៅរបស់ពួកគេ ហើយការឃុំខ្លួន ដើម្បីរង់ចាំថៅកែចូលខ្លួនដោះស្រាយជាមួយអាជ្ញាធរ។

ប៉ុន្តែយ៉ាងណាមិញលោក ឡឹង សុផុន បានគូសបញ្ជាក់ថា ថៅកែមួយចំនួនមិនចូលខ្លួនមកដោះស្រាយសំណុំរឿងទទួលពលករខុសច្បាប់ធ្វើការនោះទេ ព្រោះគេយល់ថា បើកាលណាចូលខ្លួនដោះស្រាយគេត្រូវរងការផាកពិន័យពីអាជ្ញាធរ។

## កងកម្លាំងប៉ូលិសអាស៊ាន ប្តេជ្ញារួមគ្នាបន្តប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/international/2023/10/20/366873/ BySS107Posted on October 20, 2023 9:48 pm

វៀងច័ន្ទ៖ ប្រភពពីទីភ្នាក់ងារ Xinhua បានផ្សព្វផ្សាយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ថា ប្រតិភូមកពីកងកម្លាំងប៉ូលិសអាស៊ាន បានជួបប្រជុំគ្នានៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយប្តេជ្ញាបន្តការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ក៏ដូចជាពង្រឹងទំនាក់ទំនងរវាងកងកម្លាំងប៉ូលិសអាស៊ាន ដៃគូសន្ទនា និងប្រទេសអ្នកសង្កេតការណ៍ផងដែរ ។ ចំពោះការសន្យានេះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់ប្រធានគណៈប្រតិភូប៉ូលិសអាស៊ាន និងដៃគូចរចា ដែលជាផ្នែកមួយនៃសន្និសីទហៅកាត់ថា ASEANAPOL លើកទី៤១ ដែលធ្វើឡើងនៅទីក្រុងវៀងច័ន្ទ កាលពីថ្ងៃអង្គារ ដែលដឹកនាំដោយអនុរដ្ឋមន្ត្រីសន្តិសុខសាធារណៈឡាវ លោក Khamking Phouilamanivong ។

កងកម្លាំងប៉ូលិសអាស៊ាន បាននឹងកំពុងស្វែងរកការពង្រឹងភាពជាដៃគូ ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព ក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការ ក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន ដូចជាការរត់ពន្ធគ្រឿងញៀន អំពើភេរវកម្ម ការជួញដូរមនុស្ស និងពាណិជ្ជកម្មអាវុធ ផងដែរ ។

ថ្ងៃផងនៅក្នុងសន្និសីទនេះ លោក Vilay Lakhamfong ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈឡាវ បានឲ្យដឹងថា "សន្និសីទ ASEANAPOL លើកទី៤១ ប្រព្រឹត្តទៅក្នុងបរិយាកាសមួយ ដែលមានទាំងសម្ភារៈបរិក្ខារ និងបញ្ហាប្រឈមជាច្រើន" ។ លោកបានថ្លែងថា "ដូច្នេះ សន្និសីទនេះមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ការបង្កើនកិច្ចសហប្រតិបត្តិការ ទាំងក្នុងកម្រិតតំបន់ និងពិភពលោក ក្នុងការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មផ្សេងៗ ដើម្បីជានាឱ្យតំបន់ និងសហគមន៍ជុំវិញពិភពលោកទទួលបានសន្តិភាព ភាពស្ងប់ស្ងាត់ និងស្ថិរភាព" ៕ ប្រែសម្រួលដោយ៖ ម៉ៅ បុប្ផាមករា

## លោក ខៀវ កាញារីទ្ធ សរសើរទូតខ្មែរនៅឡាវ ដែលប្រឹងប្រែងជួយនារីខ្មែរចាញ់ បោកមេខ្យល់នាំយកទៅធ្វើការនៅតំបន់ត្រីកោណមាស

https://dap-news.com/international/2023/10/21/366994/ BySS107Posted on October 21, 2023 2:30 pm

ភ្នំពេញ៖ បន្ទាប់ពីមានកិច្ចអន្តរាគមន៍ ពីសំណាក់ឯកអគ្គរាជទូតខ្មែរ ប្រចាំប្រទេសឡាវ ដែលបានជួយសង្គ្រោះក្មេងស្រីម្នាក់ ចាញ់បោកមេខ្យល់ នាំយកទៅធ្វើការនៅកាស៊ីណូមួយកន្លែង នៅតំបន់ស្រីកោណមាស បានដោយជោគជ័យនោះ លោក ខៀវ កាញារីទ្ធ អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន បានចាត់ទុកឯកអគ្គរាជទូតខ្មែរជាទូតឱជីថល និងកោតសរសើរពីស្នាដៃ ក្នុងការយកចិត្តទុកដាក់បំពេញភារកិច្ច ជាពិសេសសង្គ្រោះពលរដ្ឋ បានលឿនរហ័ស ។

លោក លោក ខៀវ កាញារីទ្ធ បានឲ្យដឹងថា កន្លងទៅ មានក្មេងស្រីម្នាក់ បានទាក់ទងមកលោក ដើម្បីស្វែងរកការសង្គ្រោះ បន្ទាប់ពីនារីរូបនេះ បានចាញ់បោកមេខ្យល់ នាំយកទៅធ្វើការនៅកាស៊ីណូមួយកន្លែង នៅតំបន់ត្រីកោណមាស ប្រទេសឡាវ ដែលតំបន់នេះ ត្រូវបានគេដឹងថា ជាតំបន់អនាធិបតេយ្យគ្រឿងញៀនមួយ ក្នុងចំណោមតំបន់សំបុកគ្រឿងញៀនដ៏ធំលើពិភពលោក ។

យោងតាមសារ ដែលបង្ហោះលើបណ្តាញសង្គមហ្វេសប៊ុក នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ នេះ លោក ខៀវ កាញារីទ្ធ បានសរសេរថា "សូមថ្លែងសរសើរ និងគោរពឯកឧត្តមឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងវៀងចន្ទដ៏ស្មោះ ! ប៉ុន្មានថ្ងៃមុន វេលាយប់ ខ្ញុំបានទទួលសាររបស់នារីកម្ពុជាម្នាក់ដែលត្រូវគេបោកយកទៅធ្វើការកន្លែងកាស៊ីណូមួយ នៅតំបន់ត្រីកោណមាស ។ ខ្ញុំក៏បង្ហោះសារនោះ ដើម្បីជូនទៅអាជ្ញាធរតែប៉ុន្មានម៉ោងក្រោយ ខ្ញុំត្រូវលុបចោល ដោយនារីសាមីខ្លួន មិនចង់អោយក្រុមគ្រួសារខ្លួនជ្រួលច្របល់ ។

ខ្ញុំគិតថានឹងបញ្ជូនសារនេះ ទៅក្រសួងការបរទេសយើង ដើម្បីធ្វើអន្តរាគមន៍ ។ ព្រឹកឡើងមិនទាន់ ខ្ញុំទទួលសារពីឯកឧត្តម ឯកអគ្គរាជទូតខ្មែរយើង ប្រចាំនៅក្រុងវៀងចន្ទ ប្រទេសឡាវ ដើម្បីសុំ

លម្អិតពីរឿងទាំងនេះ ហើយ នៅពេលនេះ នារីនេះបានរួចខ្លួនហើយ ។ នេះពិតជាការទូតឌីជីថលមែន ខ្ញុំលុបហើយក្តីតែឯកឧត្តម នៅឈ្មុសឈ្មុលតាមដោះស្រាយរឿងនេះ រហូតជួយនារីខ្មែរម្នាក់បាន” ។

ជាមួយគ្នានោះ លោក ខៀ កាញារីទ្ធ ក៏បានវាយតម្លៃខ្ពស់ និងកោតសរសើរ ដល់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ ក្នុងនាមជាសេនាធិការឲ្យរាជរដ្ឋាភិបាល បានខិតខំយកចិត្តទុកដាក់ ជួយដោះស្រាយទុក្ខលំបាក ជូនប្រពលរដ្ឋ ទាន់ពេលវេលា ។ ក្នុងនោះអតីតរដ្ឋមន្ត្រីរូបនេះ បានបញ្ជាក់ថា “សូមជូនពរឯកឧត្តមមានជោគជ័យក្នុងភារកិច្ច ក៏ដូចសូមកោតសរសើរ ដល់ថ្នាក់ដឹកនាំក្រសួងការបរទេស ដែលបណ្តុះបណ្តាល បានជួរមន្ត្រីរាជការដ៏សកម្មៗបែបនេះ”៕

# ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០២៣

## សមាជិកព្រឹទ្ធសភា ជំរុញឱ្យអាជ្ញាធរមូលដ្ឋានពង្រឹងការងារអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការបម្រើសេវាសាធារណជូនពលរដ្ឋឱ្យបានល្អ

https://freshnewsasia.com/index.php/en/localnews/314927-2023-10-21-05-54-51.html 2023-10-21 12:54pm

**(កំពង់ធំ)៖** លោកស្រី ឃួន ឃុនឌី សមាជិកព្រឹទ្ធសភា និងជាប្រធានក្រុមការងារចុះមូលដ្ឋានស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានជំរុញឱ្យអាជ្ញាធរមូលដ្ឋានបង្កើនការពង្រឹងការងារអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការបម្រើសេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យបានល្អ ស្របតាមគោលនយោបាយ ដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ព្រមទាំងពិនិត្យមើលបញ្ហាគ្រឿងញៀនបញ្ហាក្មេងទំនើង បញ្ហាគ្រោះថ្នាក់ចរាចរណ៍ បញ្ហាចោរលួច ឆក់ អំពើហិង្សា និងល្បែងខុសច្បាប់ជាដើម ព្រោះបញ្ហានេះបានធ្វើឱ្យពលរដ្ឋនៅមានការបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ដែលទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ចយកចិត្តទុកដាក់បន្ថែមទៀត។

ការជំរុញបែបនេះរបស់លោកស្រី ឃួន ឃុនឌី បានធ្វើឡើងក្នុងកិច្ចប្រជុំប្រចាំខែរបស់គណបក្សប្រជាជនកម្ពុជា ស្រុកកំពង់ស្វាយ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ នៅស្នាក់ការគណបក្សស្រុកកំពង់ស្វាយ។ លោកស្រីបានកោតសរសើរអាជ្ញាធរដែនដីក្នុងការយកចិត្តទុកដាក់ បម្រើការងារជូនប្រជាពលរដ្ឋយ៉ាងសកម្ម និងលើកទឹកចិត្តឱ្យបន្តខិតខំប្រឹងប្រែងបំពេញការងារបន្ថែមទៀត ដើម្បីរួមគ្នាធ្វើអំពើល្អបំម្រើភូមិ ឃុំរបស់ខ្លួន ក្រុមប្រឹក្សាឃុំសូមចូលរួមសហការគ្នាកសាង និងថែរក្សាសមិទ្ធផលនានា ដែលបានកសាងកន្លងមកអោយបានគង់វង្ស និងត្រូវបន្តពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បី

បំពេញនូវតម្រូវការការងារបច្ចុប្បន្នឱ្យមានភាពល្អប្រសើរបន្ថែមទៀត និងបន្តពង្រឹងទំនាក់ទំនងយ៉ាងជិតស្និតលើការងារផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាពខ្ពស់។

លោកស្រី ឃួន យុនឌី បានជំរុញឲ្យអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធនៅមូលដ្ឋានបង្កើនការពង្រឹងការងារអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការបម្រើសេវាសាធារណៈជូនបងប្អូនប្រជាពលរដ្ឋឱ្យបាន កាន់តែល្អទ្វេឡើង ស្របតាមគោល នយោបាយ ដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ព្រមទាំងពិនិត្យមើលបញ្ហាគ្រឿងញៀនបញ្ហាក្មេងទំនើង បញ្ហាគ្រោះថ្នាក់ចរាចរណ៍ បញ្ហាចោរលួចឆក់ អំពើហិង្សា និងល្បែងខុសច្បាប់ជាដើម ព្រោះបញ្ហានេះបានធ្វើឱ្យពលរដ្ឋនៅមានការបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ដែលទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ចយកចិត្តទុកដាក់បន្ថែមទៀត។

លោកស្រី ឃួន យុនឌី បានលើកទឹកចិត្តជំរុញ និងគាំទ្រគ្រប់រាល់សកម្មភាពទាំងអស់របស់ភូមិឃុំ ក្នុងឆន្ទៈចូលរួមកសាង និងអភិវឌ្ឍមូលដ្ឋានផ្ទាល់បម្រើសុខភាពសាធារណៈ ចូលរួមដោះស្រាយទុក្ខលំបាក កែលម្អកម្រិតជីវភាព និងអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែរីកចម្រើនថែមទៀត ព្រមទាំងផ្តាំផ្ញើឱ្យយកចិត្តទុកដាក់មើលថែរក្សាសុខភាពជូនប្រជាពលរដ្ឋពង្រឹងការងារសន្តិសុខ និងសុវត្ថិភាពមូលដ្ឋានឱ្យបានល្អប្រសើរ ក្រោមម្លប់សុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរបស់ប្រទេសជាតិ៕

## Amnesty International៖
## អាជ្ញាធរខ្មែរអាចជាប់ពាក់ព័ន្ធពីការទទួលសំណូកក្នុងបទល្មើសឆបោកអនឡាញ

https://www.rfi.fr/km//20231021-amnesty-international?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 21/10/2023 - 14:07

ក្នុងបទសម្ភាសជាមួយ Amnesty International អ្នករាយការណ៍ពិសេស UN និងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស OHCHR បានចោទប្រកាន់ថា អាជ្ញាធរកម្ពុជា អាចមានជាប់ពាក់ព័ន្ធនឹងការទទួលយកសំណូក ពីអ្នកឆបោកអនឡាញ និងម្ចាស់កាស៊ីណូ។ ជាការចោទប្រកាន់ នៅចំពោះមុខកំណើនគួរឲ្យកត់សម្គាល់ នៃបទល្មើសជួញដូរមនុស្សទាក់ទងនឹងអំពើឆបោកតាមអនឡាញ។ នេះបើតាម Amnesty International ខណៈអ្នករាយការណ៍ពិសេស UN ក៏បានអះអាងថា ជនរងគ្រោះពីការជួញដូរមនុស្សក្នុងក្រុងព្រះសីហនុតែមួយ អាចមានដល់ទៅ១០ម៉ឺននាក់។

ការកើនឡើងគួរឲ្យកត់សម្គាល់ នៃអំពើជួញដូរមនុស្សពាក់ព័ន្ធនឹងការឆបោកអនឡាញ និងប្រតិបត្តិការកាស៊ីណូ គឺជាក្តីបារម្ភមួយ ក្នុងចំណោមក្តីបារម្ភ ស្តីពីបញ្ហាសិទ្ធិមនុស្សមួយចំនួនទៀត ដែលអង្គការ Amnesty International ដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្លួន។ ជារបាយការណ៍

ត្រៀមដាក់ទៅក្រុមការងារពិនិត្យជាសលកតាមកាលកំណត់ (UPR) ដែលនឹងត្រូវពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជា នៅខែឧសភា ឆ្នាំ២០២៤ខាងមុខ។

ពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស របាយការណ៍របស់ Amnesty International គូសបញ្ជាក់ថា ក្នុងប្រទេសកម្ពុជា ទីតាំងប្រព្រឹត្តអំពើជួញដូរមនុស្សជាច្រើន នៅតែបើកដំណើរការ និងមិនត្រូវបានបិទពិតប្រាកដឡើយ បើទោះបីជនល្មើសរាប់រយនាក់ ត្រូវបានអាជ្ញាធរកម្ពុជារកឃើញ តាមរយៈការចុះបង្ក្រាបក្នុងក្រុងភ្នំពេញ និងព្រះសីហនុក្តី។ កាលពីខែកញ្ញា ឆ្នាំ២០២២ អ្នករាយការណ៍ពិសេស UN បានអះអាងពីការសរសេរទៅកាន់រដ្ឋាភិបាលកម្ពុជាដោយគូសបញ្ជាក់ថា ក្នុងក្រុងព្រះសីហនុតែឯង អាចមានជនរងគ្រោះពីការជួញដូរមនុស្សដល់ទៅ១០ម៉ឺននាក់ឯណោះ។ នៅចំពោះមុខកំណើនគួរឲ្យកត់សម្គាល់នេះហើយ ដែលអ្នករាយការណ៍ពិសេស UN រួមជាមួយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ចោទប្រកាន់ថា អាជ្ញាធរកម្ពុជាអាចមានជាប់ពាក់ព័ន្ធនឹងការទទួលយកសំណូកពីអ្នកឆបោកអនឡាញ និងម្ចាស់កាស៊ីណូ។

ក្រៅពីនេះតាម Amnesty International ដដែល ជនរងគ្រោះក្រោមអំពើអមនុស្សធម៌គ្រប់រូបភាព ក្រោយត្រូវបានជួយសង្គ្រោះដោយអាជ្ញាធរកម្ពុជា ពួកគេជាច្រើនក៏ត្រូវបានយកទៅដាក់នៅមជ្ឈមណ្ឌលឃុំឃាំងជនអន្តោប្រវេសន៍ ជាច្រើនខែ ដែលមានលក្ខណៈណែនតែនតាប់ ហើយគ្មានឱកាសទទួលបានការប្រឹក្សាផ្នែកជាដើម។ មិនតែប៉ុណ្ណោះ ពួកគេភាគច្រើន ក៏ត្រូវបានតម្រូវឲ្យបង់ថ្លៃអាហារផងដែរ។ បន្ទាប់ពីការកត់សម្គាល់ឃើញយ៉ាងដូច្នេះ Amnesty International បានផ្ដល់អនុសាសន៍ឲ្យរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ជនរងគ្រោះដោយការជួញដូរ និងធានាថា សិទ្ធិសេរីភាពរបស់ពួកគេមិនត្រូវបានដកហូត និងអាចទទួលបានការផ្ដល់ប្រឹក្សាផ្នែកច្បាប់តាមការចាំបាច់។ ទន្ទឹមនឹងនេះ ត្រូវផ្ដល់ការគាំទ្រដល់អ្នករួចផុតពីការជួញដូរ ដូចជាការគាំទ្រផ្នែកច្បាប់ និងការសម្របសម្រួលបញ្ជូនពួកគេទៅប្រទេសកំណើតវិញ នៅពេលមានការស្នើសុំ និងស្ថានភាពមានសុវត្ថិភាព ជាពិសេសចំពោះស្ត្រី កុមារ និងក្រុមមនុស្សងាយរងគ្រោះ។

សូមបញ្ជាក់ថា ក្រៅពីបទល្មើសជួញដូរមនុស្ស ក្ដីបារម្ភស្ដីពីបញ្ហាសិទ្ធិមនុស្សមួយចំនួនទៀត ដែលអង្គការ Amnesty International ដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្លួន មានដូចជា ការបណ្ដេញពលរដ្ឋដោយបង្ខំក្នុងតំបន់អង្គរ ការរំលោភបំពានលើជនរងគ្រោះពីការសេពគ្រឿងញៀន ការធ្វើទារុណកម្មនិងការឃុំខ្លួនតាមអំពើចិត្តក្នុងយុទ្ធនាការបោសសម្អាតគ្រឿងញៀន សិទ្ធិជនជាតិដើមភាគតិច និងការបាត់ខ្លួនរបស់សកម្មជននយោបាយថៃលោក Wanchalearm Satsaksit។

## ក្រសួងទូរគមនាគមន៍ឥណ្ឌូនេស៊ី
## រកឃើញម៉ាស៊ីនមេល្បែងស៊ីសងអនឡាញដែលដាក់នៅកម្ពុជានិងហ្វីលីពីន

https://www.khmertimeskh.com/501380054//?p=1380054 October 22, 2023

លោក Budi Arie Setiadi រដ្ឋមន្ត្រីក្រសួងទូរគមនាគមន៍ និងព័ត៌មានឥណ្ឌូណេស៊ី បានបញ្ជាក់ថា ម៉ាស៊ីនមេ (servers) នៃគេហទំព័រល្បែងស៊ីសងអនឡាញ ដែលកំពុងរីករាលដាលនៅក្នុងប្រទេស ត្រូវបានដាក់នៅក្នុងប្រទេសកម្ពុជា និងហ្វីលីពីន ដែលសកម្មភាពល្បែងស៊ីសងទាំងនេះ គឺខុសច្បាប់។ លោក Budi Arie បាននិយាយនៅក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការក្រសួងកណ្តាលទីក្រុងហ្សាកាតា កាលពីថ្ងៃសុក្រ ទី២០ ខែតុលា ឆ្នាំ២០២៣ ថា "ម៉ាស៊ីនមេមានទីតាំងនៅក្នុងប្រទេសកម្ពុជា និងហ្វីលីពីន"។ យ៉ាងណាមិញ ទោះបីជាទីតាំងត្រូវបានរកឃើញក៏ដោយ ក៏អ៊ីនធឺណិតប្រូតូកូល ឬអាសយដ្ឋាន IP នៅតែបន្តផ្លាស់ប្តូរ។ ដូច្នេះហើយក្រសួងទូរគមនាគមន៍ និងព័ត៌មានឥណ្ឌូនេស៊ី បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការទប់ស្កាត់គេហទំព័រដែលទាក់ទងនឹងល្បែងស៊ីសង។

វិធានការនានាដែលធ្វើឡើង ដើម្បីដោះស្រាយសកម្មភាពខុសច្បាប់នៅក្នុងប្រទេស រួមមានការទប់ស្កាត់ការផ្សព្វផ្សាយ ការផ្តាច់ការចូលទៅកាន់គេហទំព័រ និងការបិទគណនីធនាគារដែលភ្ជាប់ទៅនឹងល្បែងស៊ីសង។ ក្រសួងក៏បានសហការជាមួយប្រតិបត្តិករទូរស័ព្ទដើម្បីត្រួតពិនិត្យលេខដែលប្រើដើម្បីផ្សព្វផ្សាយល្បែងស៊ីសង។ លោក Budi Arie បាននិយាយថា "ពួកគេប្រើលេខបរទេស ប៉ុន្តែយើងកំពុងបន្តទប់ស្កាត់វា" ។

លោកបានថ្លែងថា ចាប់ពីថ្ងៃទី១៨ ខែកក្កដា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រសួងបានធ្វើការផ្តាច់ការចូលប្រើមាតិកាល្បែងស៊ីសងអនឡាញចំនួន ៤២៥,៥០៦ នៅលើវេទិកាផ្សេងៗ រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។ លោក Budi Arie ក៏បាននិយាយផងដែរថា ក្រសួងបានស្នើឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) និងប្រតិបត្តិករទូរស័ព្ទចល័តបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ការលេងល្បែងស៊ីសងអនឡាញ និងឱ្យតាមដានបន្ទាន់លើសំណើសុំបិទការចូលដំណើរការដែលយើងបានធ្វើ»។ *Tempo.co*

## ពលរដ្ឋខ្មែររងគ្រោះ ចំនួន ០៥នាក់ ត្រូវបានក្រុមហ៊ុនចិន ក្រុងបាវិត បោកបញ្ជូនមកធ្វើការនៅទីក្រុងឌូបៃ ដោយមិនទទួលបានប្រាក់ខែ និងត្រូវរងការចាប់បង្ខាំងទុក

https://cen.com.kh/archives/704781.html Posted ByPen Srey NeatOctober 22, 2023

ភ្នំពេញ ៖ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំរដ្ឋកូវ៉ែត នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ បានចេញផ្សាយព័ត៌មានថា ពលរដ្ឋខ្មែររងគ្រោះ ចំនួន ០៥នាក់ ដែលត្រូវបានក្រុមហ៊ុនចិន ក្រុងបាវិត បោកបញ្ជូនមកធ្វើការនៅទីក្រុងឌូបៃ ដោយមិនទទួលបានប្រាក់ខែ និងត្រូវរងការចាប់បង្ខាំងទុក

ព្រមទាំងជាប់បណ្តឹងហាមឃាត់ការធ្វើដំណើរត្រលប់មកកម្ពុជាវិញ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២៣ នេះ។

ពួកគាត់ត្រូវបានស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំរដ្ឋកូវ៉ែត ជួយដោះស្រាយ និងសម្រប សម្រួលជាមួយអាជ្ញាធរអេមីរ៉ាតអារ៉ាប់រួម ឱ្យអាចធ្វើដំណើរត្រលប់ទៅកម្ពុជាវិញ បានដោយសុវត្ថិភាពហើយ។ ចំណែកឯក្រុមហ៊ុនដែលមានទីតាំងក្នុងទីក្រុងឌូបៃនោះ កំពុងបិតក្នុងចំណាត់ការផ្លូវច្បាប់របស់រដ្ឋអាជ្ញាអេមីរ៉ាតអារ៉ាប់រួម៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## ជប៉ុនស្នើកម្ពុជារួមគ្នាបង្ក្រាបបទល្មើសឆបោកតាមអនឡាញ ខណៈបទល្មើសមួយនេះបាន ធ្វើឲ្យជនជាតិ ជប៉ុនបាត់បងលុយរាប់ពាន់លានដុល្លារ

https://btv.com.kh/article/32999 2023/10/22 08:53:46 pm

ភ្នំពេញ÷ លោក Yoshimi Ogata អគ្គនាយករងទទួលកិច្ចការបរទេស នៃទីភ្នាក់ងារជាតិនគរបាលជប៉ុន បានស្នើសុំដល់នគរបាលកម្ពុជារួមគ្នាទប់ស្កាត់ និងបង្ក្រាបបទល្មើសតាមអនឡាញឲ្យបានសកម្ម និងទាន់ពេលវេលាបន្ថែមទៀត ខណៈបច្ចុប្បន្ននេះជនជាតិជប៉ុនរបស់លោក បានបាត់បង់ថវិការាប់ពានលានដុល្លារអាមេរិក ដោយសារតែបទល្មើសបច្ចេកវិទ្យាដ៏ទំនើបមួយនេះ។ ការស្នើសុំកិច្ចសហការជាមួយនគរបាលកម្ពុជានេះ គឺបានធ្វើឡើងនៅក្នុងកិច្ចជំនួបទ្វេភាគីជាមួយ នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិកម្ពុជា កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ ២០២៣នេះ នៅប្រទេសឡាវ ខណៈដែលភាគីទាំងពីរអញ្ជើញទៅចូលរួមសន្និសីទអាស៊ានណាប៉ូលលើកទី៤១ ដែលប្រ ទេសឡាវធ្វើជាម្ចាស់ផ្ទះ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣នេះ ស្តីពីលទ្ធផល នៃការចូលរួមសន្និសីទអាស៊ានណាប៉ូលលើកទី៤១ រដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានបញ្ជាក់ថា នៅក្នុងកិច្ចជំនួបនោះ Yoshimi Ogata បានថ្លែងនូវអំណរគុណនិងកោតសរសើរចំពោះនគរបាលជាតិកម្ពុជា និងបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃការអនុវត្តច្បាប់ ដោយបានចាត់ទុកឆ្នាំ២០២២-២០២៣នេះ គឺជាឆ្នាំនៃសមិទ្ធផលកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងទីភ្នាក់ងារនគរបាលជាតិជប៉ុន។

លោក Yoshimi Ogata បានលើកឡើងទៀតជាមួយនឹងសមិទ្ធផលដែលភាគីទាំងពីរសម្រេចបាន នោះលោក ក៏បានលើកឡើងករណីបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ដែលកំពុងមានការកើនឡើងគួរឲ្យកត់សម្គាល់ទាំងក្នុងសកលលោក ក្នុងតំបន់និងក្នុងប្រទេសជប៉ុន ដែលបាននិងកំពុងធ្វើឲ្យប្រជាពលរដ្ឋជប៉ុន ជាច្រើននាក់រងគ្រោះបាត់បង់ទ្រព្យសម្បត្តិរាប់ពាន់លានដុល្លាអាមេរិក។ ជាមួយនឹងការផ្តល់កិច្ចសហការពីសំណាក់នគរបាលជាតិកម្ពុជា ដែលបានបង្ក្រាបមុខសញ្ញាមក

សម្ងំលាក់ខ្លួនលួចលាក់ប្រព្រឹត្តបទល្មើសឆបោកឆ្លងដែនជាច្រើនករណីធំៗ តាងនាមឲ្យអគ្គស្នងការនៃទីភ្នាក់ងារនគរបាលជាតិជប៉ុន បានគោរពស្នើសុំនគរបាលជាតិកម្ពុជា បន្តផ្តល់កិច្ចសហការឲ្យបានជិតស្និទ្ធ និងរឹងមាំថែមទៀត ដើម្បីរួមគ្នាទប់ស្កាត់ និងបង្រ្កាបបទល្មើសបច្ចេកវិទ្យាទំនើបនេះទាន់ពេលវេលា។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ នាយឧត្តមសេនីយ៍ ស ថេត ក៏បានបញ្ជាក់ប្រាប់ដល់ភ្នាក់ងារនគរបាលជាតិជប៉ុន អំពីគោលជំហររបស់នគរបាលជាតិកម្ពុជាចំនួនផងដែរ ដោយក្នុងនោះនាយឧត្តម សេនីយ៍ បានបញ្ជាក់ថា អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា មិនត្រឹមតែប្តេជ្ញាបន្តថែរក្សានូវទំនាក់ទំនងដែលមានពីមុនជាមួយទីភ្នាក់ងារនគរបាលជាតិជប៉ុនប៉ុណ្ណោះទេ ក៏ប៉ុន្តែនឹងបន្តធ្វើការពូនជ្រុំសមិទ្ធផល នៃកិច្ចសហប្រតិបត្តិការដែលកំពុងមានស្រាប់នេះ ឲ្យកាន់តែទូលំទូលាយ រឹងមាំជិតស្និទ្ធ និងស៊ីជម្រៅប្រកបដោយវឌ្ឍនភាព។ ឆ្លើយតបទៅនឹងជំនួយឧបត្ថម្ភគាំទ្រផ្តល់ដោយទីភ្នាក់ងារនគរបាលជាតិជប៉ុន ជាមធ្យោបាយ ឧបករណ៍ សម្ភារបច្ចេកទេស ជូនដល់កងកម្លាំងនគរបាលជាតិកម្ពុជារយៈកាលកន្លងទៅ អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីផ្តល់កិច្ចសហការតាមការស្នើសុំស្របតាមគោលការណ៍ច្បាប់ និងបទដ្ឋានក្រោមច្បាប់ដែលពាក់ព័ន្ធ។ និងរាល់សំណើសុំកិច្ចសហការ អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជានឹងផ្តល់ជូនភ្លាមៗនៅពេលទទួលបានព័ត៌មានច្បាស់លាស់និងមានភស្តុតាងឯកសារគ្រប់គ្រាន់ដែលជាមូលដ្ឋាននៃការបើកកិច្ចប្រតិបត្តិការ។

នៅក្នុងកិច្ចជំនួបនោះដែរ នាយឧត្តមសេនីយ៍ ស ថេត ក៏បានស្នើភាគីជប៉ុន ពិនិត្យលទ្ធភាពក្នុងការជួយអន្តរាគមន៍ចំពោះពលរដ្ឋកម្ពុជា ដែលមានបញ្ហាផ្លូវច្បាប់អន្តោប្រវេសន៍ក្នុងពេលរស់នៅបម្រើការងារ ក្នុងប្រទេសជប៉ុន ឆាប់បានបញ្ជូនត្រឡប់មកកម្ពុជាវិញ និងបានស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការលើការងារបណ្តុះបណ្តាល កសាងធនធានមន្ត្រីអនុវត្តច្បាប់លើជំនាញប្រឆាំងបទល្មើសបច្ចេកវិទ្យាផងដែរ ខណៈសំណើរខាងលើនេះត្រូវបានភាគីជប៉ុនទទួលយកទៅពិចារណា និងអន្តរាគមន៍ផងដែរ៕ អត្ថបទ ៖ បាន ចក់

## នគរបាលអូស្ត្រាលី
## ចាត់ទុកនគរបាលកម្ពុជា ជាដៃគូនាំមុខក្នុងតំបន់ ដើម្បីទប់ស្កាត់រាល់បទល្មើសគ្រប់ប្រភេទ

https://www.btv.com.kh/article/33005 2023/10/23 09:45:38 am

លោកស្រី Lesa Jane GALE អគ្គស្នងការរងទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ នៃនគរបាលសហព័ន្ធអូស្ត្រាលី បានថ្លែងថា នគរបាលអូស្ត្រាលី បានចាត់ទុកអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា គឺជាដៃគូនាំមុខគេក្នុងតំបន់ លើកិច្ចសហប្រតិបត្តិការ ដើម្បីទប់ស្កាត់រាល់បទល្មើសគ្រប់ប្រភេទជាពិសេសឧក្រិដ្ឋកម្មឆ្លងដែនតែម្តង។ ការអះអាងរបស់លោកស្រី Lesa Jane GALE នេះគឺបានធ្វើ

ឡើង នៅក្នុងកិច្ចជំនួបទ្វេភាគីជាមួយ នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការនគរបាលជាតិកម្ពុជា កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣នេះ នៅប្រទេសឡាវ ខណៈដែលភាគីទាំងពីរអញ្ជើញទៅចូលរួមសន្និសីទអាស៊ានណាប៉ូល លើកទី៤១ ដែលប្រ ទេសឡាវធ្វើជាម្ចាស់ផ្ទះ។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣នេះ ស្ដីពីលទ្ធផលនៃការចូលរួមសន្និសីទអាស៊ានណាប៉ូលលើកទី៤១រដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានបញ្ជាក់ថា នៅក្នុងកិច្ចជំនួបនោះ អ្នកស្រី Lesa Jane GALEបាន កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការរវាងនគរបាលសហព័ន្ធអូស្ត្រាលី និងនគរបាលជាតិ កម្ពុជា។ លោកស្រី«សូមចាត់ទុកនគរបាលជាតិកម្ពុជាគឺជាដៃគូសហប្រតិបត្តិការនាំមុខក្នុងតំបន់ ក្នុងកិច្ចប្រតិបត្តិការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទ ជាពិសេសបទល្មើសឆ្លងដែនមានអង្គការចាត់តាំង ដូចជា បទល្មើសគ្រឿងញៀន បទល្មើសបច្ចេកវិទ្យា បទល្មើសសំអាតប្រាក់....ក៏ដូចជាបទល្មើសផ្លូវភេទកុមារជាដើម»។

នៅចំពោះមុខអគ្គស្នងការនគរបាលជាតិកម្ពុជា លោកស្រី Lesa Jane GALE ក៏បានអះអាងផងដែរថា ក្នុងនាមឯកឧត្ដមអគ្គស្នងការនគរបាលសហព័ន្ធអូស្ត្រាលី និងក្នុងនាមជាថ្នាក់ដឹកនាំទទួលកិច្ចការទំនាក់ទំនងអន្តរជាតិ លោកស្រី ប្ដេជ្ញារក្សាទំនាក់ទំនងជាមួយនគរបាលកម្ពុជាឲ្យកាន់តែមានវិសាលភាពទូលំទូលាយបន្ថែមទៀតនាពេលអនាគត។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ នាយឧត្តមសេនីយ៍ ស ថេត បានថ្លែងថា នគរបាលជាតិកម្ពុជារីករាយស្វាគមន៍ និងបើកទ្វារទទួលយករាល់កិច្ចសហការគ្រប់ពេលវេលា ដោយប្ដេជ្ញារួមគ្នាបន្តអនុវត្តយន្តការដែលមានស្រាប់ ធ្វើការផ្លាស់ប្ដូរព័ត៌មានបើកការស្រាវជ្រាវ ស៊ើបអង្កេត ឈានទៅបោសសំអាតក្រុមឧក្រិដ្ឋជនមានការចាត់តាំងគ្រប់ប្រភេទដែលរត់គេចខ្លួន ឬសម្ងំលាក់ខ្លួនប្រព្រឹត្តបទល្មើស ឬបង្កអស្ថិរភាពសន្តិសុខដល់ប្រទេសទាំងពីរ។

នាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិកម្ពុជា ក៏បានថ្លែងនូវអំណរគុណចំពោះនគរបាលសហព័ន្ធអូស្ត្រាលី ដែលបានរួមចំណែកជួយជ្រោមជ្រែងដល់អាជ្ញាធរកម្ពុជា ក្នុងការប្រឹងប្រែងអនុវត្តបានជោគជ័យស្របតាមអនុសាសន៍របស់ក្រុមការងារប្រតិបត្តិការហិរញ្ញវត្ថុFATF ដែលធ្វើឲ្យប្រទេសកម្ពុជា បានចេញផុតពីបញ្ជីប្រផេះ នៃការសម្អាតប្រាក់។ ជាមួយនិងជោគជ័យដ៏ត្រចះត្រចង់នេះ នគរបាលជាតិកម្ពុជានឹងបន្តខិតខំប្រឹងប្រែងអនុវត្តកិច្ចការនេះឲ្យបានជាប់ជាប្រចាំ ដើម្បីជំរុញចំណាត់ថ្នាក់កម្ពុជាឲ្យកាន់តែល្អក្នុងការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់នេះ។

នៅក្នុងកិច្ចជំនួបនោះដែរ នាយឧត្តមសេនីយ៍ ស ថេត ក៏បានស្នើសុំនគរបាលសហព័ន្ធអូស្ត្រាលីបន្តពិនិត្យលទ្ធភាពរៀបចំវគ្គបណ្តុះបណ្តាល បង្កើនសមត្ថភាពមន្ត្រីជំនាញ ដើម្បីទទួល

បានទូវចំណេះដឹងថ្មីៗឆ្លើយតបបានទាន់ពេលវេលា ចំពោះបទល្មើសប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដែលកំពុងមានកំណើន និងគំរាមកំហែងដល់សន្តិសុខ និងសុវត្ថិភាពដល់ប្រជាពលរដ្ឋទាំងក្នុងតំបន់ និងសកលលោកផងដែរ។ អត្ថបទបាន ចក់

# ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០២៣

## អាជ្ញាធរថៃសម្រេចឃុំខ្លួនពលករខ្មែរ ជាង២រយនាក់ដោយសារគ្មានឯកសារធ្វើការស្របច្បាប់

[https://www.rfa.org/khmer/news/human-rights/more-than-200-cambodian-workers-in-thailand-were-detained-in-jail-10222023125302.html](https://www.rfa.org/khmer/news/human-rights/more-than-200-cambodian-workers-in-thailand-were-detained-in-jail-10222023125302.html) ដោយ ជាតិ ចំណាន2023.10.22

អាជ្ញាធរថៃសម្រេចឃុំខ្លួនពលករខ្មែរ ដែលគ្មានឯកសារធ្វើការងារស្របច្បាប់ ជាង២រយនាក់ នៅខេត្តអយុធ្យា។ដោយឡែកពលករខ្មែរឆ្លងដែនខុសច្បាប់ជាង៣០នាក់ផ្សេងទៀតត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅស្រុកអារញ្ញប្រាថេត (Aranyaprathet) នៅជាប់ព្រំដែនកម្ពុជា កាលពីថ្ងៃទី១៩ តុលា ។

មន្ត្រីសង្គមស៊ីវិលអំពាវនាវឱ្យរដ្ឋាភិបាលខ្មែរប្រញាប់ជួយអន្តរាគមន៍ទៅអាជ្ញាធរថៃ ឲ្យដោះលែងពួកគេឱ្យបានឆាប់ ព្រមទាំងសម្រួលធ្វើឯកសារស្របច្បាប់ ដើម្បីអាចធ្វើការងាររកប្រាក់ចំណូលដោះស្រាយជីវភាព។ មន្ត្រីសង្គមស៊ីវិលមើលឃើញថា មន្ត្រីស្ថានទូតខ្មែរ ដែលសន្យាជួយដោះស្រាយរឿងប៉ូលិសថៃចាប់ពលករខ្មែរកាលពីពេលថ្មីៗនេះ ហាក់គ្មានលទ្ធផលវិជ្ជមានណាមួយនៅឡើយមកដល់ពេលនេះ ពីព្រោះកម្មករជាង ២រយនាក់ កំពុងជាប់គុកនៅខេត្តអយុធ្យា កំពុងប្រឈមនឹងប៉ូលិសថៃបញ្ជូនត្រឡប់ទៅកម្ពុជាវិញ។

មន្ត្រីគម្រោង នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សរបស់អង្គការសង់ត្រាល់ (CENTRAL) លោក លឹង សុផុន ប្រាប់វិទ្យុអាស៊ីសេរីថា តាមច្បាប់ការងាររបស់ថៃពលករដែលគ្មានសំបុត្រស្នាមធ្វើការងារស្របច្បាប់ប្រឈមជាប់ពន្ធនាគារនៅក្នុងប្រទេសនេះរយៈពេល៤៥ថ្ងៃ មុនបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ។ លោកបារម្ភថា អំឡុងពេលជាប់ឃុំនេះធ្វើឱ្យពលករខ្មែរជួបទុក្ខលំបាកក្នុងការទំនាក់ទំនងអំពីសុខទុក្ខជាមួយសាច់ញាតិ ការហូបចុក និងការបាត់បង់សិទ្ធិជាដើមដែលរដ្ឋាភិបាល ឬមន្ត្រីស្ថានទូតខ្មែរគួរតែជួយអន្តរាគមន៍ទៅអាជ្ញាធរថៃ ជាពិសេសជំរុញទៅថៅកែពួកគេចេញមុខដោះស្រាយដោយធានាធ្វើឯកសារស្របច្បាប់ឱ្យបានឆាប់។លោក លឹង សុផុន ៖ «ពួកគាត់នៅតែរង់ចាំថៅកែ ប៉ុន្តែថ្មីៗនេះគាត់មិនទាន់ឃើញថៅកែចេញមកធានារ៉ាប់រងប្រហែលធ្វើឱ្យគាត់អស់សង្ឃឹមថាគេ (អាជ្ញាធរថៃ) នឹងបញ្ជូនគាត់ទៅព្រំដែន ឬបញ្ជូនទៅប្រទេសកំណើតវិញ

អ៊ីចឹង។ កន្លងមកខ្ញុំឃើញច្រើនណាស់ពេលពួកគាត់នៅក្នុងពន្ធនាគារនោះយើងដឹងស្រាប់ហើយថា ពួកគាត់មិនអាចទំនាក់ទំនងទៅសាច់ញាតិបានទេ មិនមានសិទ្ធិសេរីភាព មិនអាចធ្វើអ្វីតាមចិត្តរបស់គាត់បាន មានការហាមឃាត់ការចេញចូលកន្លែងហ្នឹងដែលនាំការទំនាក់ទំនាក់ទៅពួកគាត់ក៏ជួបការលំបាកដែរ»។

កាលពីថ្ងៃទី១២ ខែតុលា អាជ្ញាធរថៃបានព័ទ្ធចាប់ខ្លួនពលករចំណាកស្រុកខុសច្បាប់ជាង ១ ពាន់នាក់ ដែលធ្វើការជាកម្មករសំណង់នៅខេត្តអយុធ្យា (Ayuthaya) ក្នុងប្រទេសថៃ (Thailand)។ ក្នុងនោះរួមមានពលករខ្មែរជាង៤រយនាក់ ព្រមទាំងពលករភូមា និងវៀតណាមផងដែរ។ ប៉ុន្តែករណីនេះអាជ្ញាធរថៃបានដោះលែងពលរដ្ឋខ្មែរខ្លះឱ្យវិលត្រឡប់ទៅកន្លែងការងារវិញ ក្រោយពេលថៅកែជានាដោយសន្យាធ្វើសំបុត្រស្នាមស្របច្បាប់ជូនពួកគេ។

ស្រដៀងគ្នានេះដែរ បញ្ជាការកងទ័ពជើងគោកថៃ ប្រចាំតំបន់នៅស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ កាលថ្ងៃទី១៩ ខែតុលា បានចាប់ពលករខ្មែរចំណាកស្រុកខុសច្បាប់ជាង៣០នាក់ (៣៣នាក់)។ ពលរដ្ឋខ្មែរចូលប្រទេសថៃ នោះគ្មានឯកសារសម្រាប់ធ្វើដំណើរ និងបង់ប្រាក់ឱ្យមេខ្យល់នាំលួចឆ្លងដែនផ្លូវកាត់ដោយខុសច្បាប់។ បច្ចុប្បន្នកម្មករទាំងនោះត្រូវបានបញ្ជូនទៅឱ្យប៉ូលិសខ្លងណាំសៃ(Khlong Nam Sai Police Station) ដើម្បីចាត់ការតាមច្បាប់។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងមន្ត្រីអនុព័ន្ធការងារអមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃលោក ឈឹម វិបុល និងអ្នកនាំពាក្យក្រសួងការងារលោក កត្តា អ៊ន ដើម្បីបញ្ជាក់ជុំវិញរឿងនេះបានទេ នៅថ្ងៃទី២១ ខែតុលា។

ជុំវិញរឿងនេះលោក លឹង សុផុន មើលឃើញថា បញ្ហាពលរដ្ឋខ្មែរចំណាកខុសច្បាប់ស្រុកធ្វើការងារនៅប្រទេសថៃកើតឡើងដដែលៗ ដោយរដ្ឋាភិបាលកម្ពុជាមិនទាន់មានដំណោះស្រាយនៅឡើយមកដល់ពេលនេះ ។ លោកបន្តថា ពលករដែលអាជ្ញាធរថៃចាប់ខ្លួនដោយសារឆ្លងដែនខុសច្បាប់ និងធ្វើការងារខុសច្បាប់កន្លងមកតែងតែជាប់គុក និងបញ្ជូនទៅកម្ពុជាវិញជាបន្តបន្ទាប់ ប៉ុន្តែលោកមិនសូវឃើញរដ្ឋាភិបាលជួយសម្របសម្រួលជាមួយភាគីថៃ ចំពោះបញ្ហានេះឱ្យមានលទ្ធផលប្រសើរសម្រាប់កម្មករនោះទេ។ លោក លឹង សុផុន៖ «សម្រាប់ខ្ញុំចង់ឱ្យអាជ្ញាធរកម្ពុជាជួយផ្សព្វផ្សាយឱ្យបានជាក់លាក់ថា ករណីពួកគាត់អាចដោះស្រាយបាន ឬដោះស្រាយមិនបានប៉ុណ្ណាសូមប្រាប់មកពលករមក ពេលខ្លះទៅពលករសង្ឃឹមទៅលើអាជ្ញាធរ ស្ថានទូតកម្ពុជាដែលជាតំណាងឱ្យប្រទេសធ្វើការនៅប្រទេសថៃមកជួយដោះស្រាយ តែមិនឃើញមកដោះស្រាយ ហើយមិនមានលទ្ធផលអ្វីក្រៅពីចាប់បញ្ជូនទៅវិញ ហាក់ដូចជាមិនដោះស្រាយឱ្យដែរហ្នឹង»។

មន្ត្រីសង្គមស៊ីវិលលើកឡើងថា ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលគួរតែបង្កើតការងារក្នុងស្រុកឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ និងបំណុលធនាគារជាដើម។ បន្ថែមពីនេះរដ្ឋាភិបាលត្រូវកាត់បន្ថយការចំណាយរបស់កម្មករឱ្យទាបទៅលើតម្លៃធ្វើលិខិតឆ្លងដែន និងការធ្វើប័ណ្ណការងារនានា។ ដោយឡែក ប្រសិនបើរដ្ឋាភិបាលនៅតែមិនដោះស្រាយបញ្ហានេះទេនោះប្រជាពលរដ្ឋនឹងនៅតែធ្វើចំណាកស្រុកខុសច្បាប់និងរងគ្រោះកាន់តែច្រើន៕

## កម្ពុជា និងវៀតណាម រួមគ្នាប្រឆាំងការចេញ-ចូលឆ្លងដែនដោយខុសច្បាប់

https://www.khmertimeskh.com/501380975// October 24, 2023

កាលពីថ្ងៃទី២៣ ខែតុលានៅទីក្រុងហាណូយនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងនគរបាលវៀតណាម និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃកម្ពុជាបានរៀបចំកិច្ចប្រជុំពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ស្តីពីការគ្រប់គ្រងជនអន្តោប្រវេសន៍។

ថ្ងៃងមតិក្នុងជំនួបនេះ លោកឧត្តមសេនីយ៍ត្រី Pham Dang Khoa ប្រធាននាយកដ្ឋានអន្តោប្រវេសន៍បាននិយាយថា ក្រសួងទាំងពីរកំពុងសម្របសម្រួលយ៉ាងជិតស្និទ្ធ ដើម្បីធានាបាននូវសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។ ភាគីទាំងពីរបានផ្លាស់ប្តូរព័ត៌មានជាប្រចាំ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ទាក់ទិននឹងការចេញ-ចូលដោយខុសច្បាប់។ ភាគីទាំងពីរក៏បានបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរក្នុងការឆ្លងកាត់ព្រំដែន និងជំរុញសកម្មភាពវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍។

ក្នុងជំនួបនេះ តំណាងភាគីទាំងពីរ បានពិភាក្សាអំពីរចនាសម្ព័ន្ធរៀបចំថ្មី របស់នាយកដ្ឋានអន្តោប្រវេសន៍ គោលនយោបាយ និងបទប្បញ្ញត្តិថ្មីក្នុងការគ្រប់គ្រងអន្តោប្រវេសន៍ ការធ្វើដំណើរឆ្លងដែន និងការស្នាក់នៅរបស់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរក្នុងទឹកដីនៃភាគីទាំងពីរ រួមទាំងស្ថានភាពនៃអន្តោប្រវេសន៍/ការធ្វើចំណាកស្រុកខុសច្បាប់ កិច្ចសហប្រតិបត្តិការទទួលប្រជាពលរដ្ឋមកវិញ និងការសម្របសម្រួលក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។ ភាគីទាំងពីរបានឯកភាពបន្តអនុវត្តការងារសំខាន់ៗ រួមមានការពង្រឹងការត្រួតពិនិត្យ និងបើកការបង្ក្រាបលើគ្រឹះស្ថានដែលជួលកម្មករខុសច្បាប់។ កងកម្លាំងនគរបាលនៃប្រទេសទាំងពីរ ជាពិសេសអ្នកដែលធ្វើការនៅតាមតំបន់ព្រំដែន នឹងរឹតបន្តឹងកិច្ចសហប្រតិបត្តិការ និងបង្កើនការផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់ និងការដោះស្រាយការចេញ-ចូលដោយខុសច្បាប់។

ភាគីទាំងពីរក៏នឹងពង្រឹងសកម្មភាពទំនាក់ទំនង ដើម្បីជួយប្រជាជនឱ្យយល់កាន់តែច្បាស់អំពីគោលនយោបាយ និងបទប្បញ្ញត្តិរបស់ប្រទេសទាំងពីរ។ ក្រសួង ស្ថាប័ននានានៃប្រទេសកម្ពុជា និងវៀតណាមនឹងធ្វើការរួមគ្នាជំរុញការចរចាសម្រាប់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីច្រកទ្វារ

ព្រំដែន និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងច្រកព្រំដែនគោកវៀតណាម-កម្ពុជា ដើម្បីជំនួសកិច្ចព្រមព្រៀងឆ្នាំ ១៩៨៣។ កិច្ចព្រមព្រៀងថ្មីនេះត្រូវបានគេរំពឹងថានឹងបង្កើតមូលដ្ឋានច្បាប់សម្រាប់ការគ្រប់គ្រងជនអន្តោប្រវេសន៍ប្រកបដោយប្រសិទ្ធភាពជាងមុន។ VNA

## អន្តោភាពជំនាញកម្ពុជា-វៀតណាម ឯកភាពបន្តកិច្ចសហការរួមគ្នាទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន

https://www.kampucheathmey.com/local-news/600944 ថ្ងៃអង្គារ ២៤ តុលា ២០២៣ដោយ Thoeun Vansong

ក្នុងនាមជាប្រទេសជាប់ព្រំដែនជាមួយគ្នា អគ្គនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា និងនាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែនវៀតណាម បានឯកភាពបន្តកិច្ចសហការរួមគ្នាលើការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនតាមគ្រប់រូបភាពរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម។ ការឯកភាពរវាងភាគីទាំងពីរនេះ បានលើកឡើងនៅក្នុងកិច្ចប្រជុំពិភាក្សាប្រចាំឆ្នាំ រវាងអគ្គនាយកអន្តោប្រវេសន៍កម្ពុជា និងនាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែនវៀតណាម កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ នាទីក្រុងហាណូយ។ នៅក្នុងកិច្ចពិភាក្សានេះ ភាគីកម្ពុជា ដឹកនាំដោយឧត្តមសេនីយ៍ឯក សុខ វាសនា អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងភាគីវៀតណាម ដឹកនាំដោយឧត្តមសេនីយ៍ត្រី ផាម ដាំង ខ្វា ប្រធាននាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែន។

កិច្ចប្រជុំនេះ ភាគីទាំងពីរ បានពិភាក្សា ផ្លាស់ប្តូរបទពិសោធរវាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃនៃកម្ពុជា និងនាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែន នៃក្រសួងនគរបាលវៀតណាម ជុំវិញស្ថានភាពប្រជាជននៃប្រទេសទាំងពីរចេញ-ចូលឆ្លងដែន និងស្នាក់នៅប្រទេសទាំងពីរ ក៏ដូចជាបន្តសម្របសម្រួលជូនប្រជាពលរដ្ឋទាំងសងខាង ក្នុងនាមជាអ្នកជិតខាងល្អ។ ក្នុងនោះ ភាគីទាំងពីរ បានលើកឡើងការបន្តសហការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធលើការទប់ស្កាត់ បទឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព និងបានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីបន្តជានាទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនរវាងកម្ពុជា-វៀតណាម។

ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ឯក សុខ វាសនា ក៏បានថ្លែងអំណរគុណដល់នាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែនវៀតណាម ដែលបានផ្តល់នូវវគ្គបណ្តុះបណ្តាលដល់មន្ត្រីរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន២០រូបលើវគ្គគ្រប់គ្រងការចេញ-ចូលឆ្លងដែន។ តាមរយៈកិច្ចសហប្រតិបត្តិការល្អនេះ លោកឧត្តមសេនីយ៍ឯក សុខ វាសនា បានស្នើ សុំភាគីវៀតណាមបន្តផ្តល់

ការបណ្ដុះបណ្ដាលដល់អគ្គនាយកដ្ឋានអន្តោប្រវេសន៍បន្ថែមទៀត ដើម្បីបន្តពង្រឹកសមត្ថភាពរបស់មន្ត្រីអគ្គនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា។

ជាកិច្ចបញ្ចប់នៃកិច្ចប្រជុំ ឧត្តមសេនីយ៍ឯក អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃកម្ពុជា និងឧត្តមសេនីយ៍ត្រី ប្រធាននាយកដ្ឋានគ្រប់គ្រងការចេញ-ចូលឆ្លងដែននៃប្រទេសវៀតណាម បានឯកភាពគ្នារឹតចំណងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែប្រសើរឡើងថែមទៀតផងដែរ។

## ឃាត់ខ្លួនជនបរទេសជាច្រើននាក់ បន្ទាប់ពីមានការបែកធ្លាយវីដេអូរឿង អាសអាភាស នៅលើបណ្ដាញសង្គមហ្វេសប៊ុក និងTikTok

https://cen.com.kh/archives/705467.html Posted ByPen Srey NeatOctober 25, 2023

ភ្នំពេញ ៖ កម្លាំងនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ចុះឆែកឆេរអាគារមួយកន្លែង ឃាត់ខ្លួនជនបរទេសបានជាច្រើននាក់ បន្ទាប់ពីមានការបែកធ្លាយវីដេអូរឿង អាសអាភាស នៅលើបណ្ដាញសង្គមហ្វេសប៊ុក និងTikTokមួយចំនួន ។ ហេតុការណ៍ ខាងលើនេះដែរបង្កឲ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង ៨និង៣០នាទីយប់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្ថិតនៅលើផ្លូវ ៣១០ សង្កាត់បឹងកេងកង ទី១ ខណ្ឌ បឹងកេងកង។

បើយោងតាមប្រភពពីបុរសជាសន្តិសុខម្នាក់ ដែលបានឃើញហេតុការណ៍ខាងលើ បានបង្ហើបឲ្យដឹងថា នៅមុនកើតហេតុដោយរូបគាត់បានឃើញ ខាងកម្លាំងនាយកដ្ឋាននគបាលព្រហ្មទណ្ឌ បានចុះមកឆែកឆេរ និងឡោមព័ទ្ធនៅទីតាំងអាគារកើតហេតុខាងលើ ក្រោយមកក៏មានការឃាត់ជនបរទេសជាច្រើននាក់ផងដែរ ។

គួរបញ្ជាក់ផងដែរថា នៅក្នុងករណីចុះឃាត់ខ្លួនជនបរទេសខាងលើនេះ ដោយស្ត្រីរងគ្រោះពីរនាក់ បានស្ម័គ្រចិត្តថតនៅរឿងអាសអាភាសជាមួយនិងជនបរទេសនៅលើអាគារ កើតហេតុខាងលើ ក្រោយមកក៏ឃើញមានការបែកធ្លាយនូវវីដេអូរឿងអាសអាភាស របស់ខ្លួន ដែលថតជាមួយនិងជនបរទេស នៅលើបណ្ដោយសង្គមតេឡេក្រាម និងមានការចែកចាយជាច្រើនផងដែរ ទើបនារីរងគ្រោះទាំង២នាក់នោះ បាននាំគ្នាទៅដាក់ពាក្យបណ្ដឹង នៅនាយកដ្ឋាននគបាលព្រហ្មទណ្ឌ ដើម្បីឲ្យជួយទៅលើរូបនាង។

ក្រោយពីខាងកម្លាំងនាយកដ្ឋានព្រហ្មទណ្ឌ ទទួលបានពាក្យបណ្ដឹងពីនារីរងគ្រោះទាំងពីររួចក៏បានចុះមកអាគារខាងលើ និងឃាត់ខ្លួនទៅលើបុរសជនបរទេសបានជាច្រើននាក់ រួមមានសម្ភារៈផលិតរឿងមួយចំនួនថែមទៀត ដឹកយកទៅនាយកដ្ឋានព្រហ្មទណ្ឌ ដើម្បីសួរនាំបន្តនិងចាត់ការទៅតាមនិតិវិធីផ្លូវច្បាប់។រក្សាសិទ្ធដោយ ៖ សាមេត

# លោក ទូច សុខៈ ការបង្រ្កាបករណីសង្ស័យផលិតរឿងអាសអាភាសនៅខណ្ឌបឹងកេងកង ជាការអនុវត្តទិសដៅ២ចំណោមទិសដៅទាំង៦របស់ក្រសួងមហាផ្ទៃ

https://www.kampucheathmey.com/security/601518 ថ្ងៃពុធ ២៥ តុលា ២០២៣ ដោយ Sokhom Khon

ការចុះបង្រ្កាបទីតាំងខុនដូ ដែលសង្ស័យផលិតរឿងអាសអាភាស កាលពីយប់ថ្ងៃទី២៤ ខែតុលា នៅក្នុងមូលដ្ឋានខណ្ឌបឹងកេងកង គឺជាការអនុវត្តទិសដៅ២រួមគ្នា ក្នុងចំណោមទិសដៅទាំង៦ របស់ក្រសួងមហាផ្ទៃ ដែលដាក់ចេញដោយឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នេះជាការបញ្ជាក់របស់លោក ទូច សុខៈ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី២៥ ខែតុលា បន្ទាប់ពីកម្លាំងចម្រុះរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ចុះបង្រ្កាបនិងឃាត់ខ្លួនមនុស្សជាង៥០នាក់។

លោក ទូច សុខៈ បញ្ជាក់ថា ទិសដៅទាំងពីរដែលប្រតិបត្តិការជាមួយគ្នាកាលពីយប់ថ្ងៃទី២៤ តុលានេះរួមមាន ជាការបង្រ្កាបបទល្មើសព្រហ្មទណ្ឌទូទៅផង និងបទល្មើសក្នុងវង្វង់អំពើជួញដូរមនុស្សផង។ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ បន្ថែមថា ឯទិសដៅទាំង៦ ដែលដាក់ចេញដោយឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ក្នុងអាណត្តិទី៧នេះ រួមមាន «១-បញ្ហាគ្រឿងញៀន។ ២-បញ្ហាចរាចរណ៍។ ៣-ករណីចោរកម្ម និងបទល្មើសព្រហ្មទណ្ឌផ្សេងៗ។ ៤-ការបង្រ្កាបអំពើជួញដូរមនុស្សគ្រប់ប្រភេទ។ ៥-ការគ្រប់គ្រងក្រុមក្មេងទំនើង និង៦-បញ្ហាតាមព្រំដែនទាំងគោកនិងទឹកជាប់ជាមួយប្រទេសជិតខាង។

គួររំលឹកថា កាលពីវេលាម៉ោង៨យប់ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ កម្លាំងនគរបាលព្រហ្មទណ្ឌក្រសួងមហាផ្ទៃ បានចុះឡោមព័ទ្ធខុនដូមួយកន្លែងពាក់ព័ន្ធករណីថតរឿង និងចែកចាយវីដេអូអាសអាភាស ដោយឃាត់ខ្លួនជនបរទេស និងនារីជាជនជាតិខ្មែរបានសរុបជាង៥០នាក់។ ប្រតិបត្តិការនេះបានធ្វើឡើងនៅចំណុចខុនដូ(វ៉ាវ ណាវ)(WOW NOW) ជាន់ទី៩ តាមបណ្ដោយផ្លូវលេខ ៣១០ ក្នុងសង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការនេះ កម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សប្រុសស្រីជាជនជាតិបរទេស និងនារីជនជាតិខ្មែរសរុបជាង៥០នាក់ យកទៅសួរនាំនៅក្រសួងមហាផ្ទៃ។

បើតាមមន្ត្រីជំនាញ មុនឈានដល់ការបង្រ្កាបនេះ គឺបន្ទាប់ពីបែកធ្លាយខ្សែភាពយន្តខ្លីបែបក្ដៅសាច់រវាងនារីខ្មែរ និងជនបរទេសនៅលើបណ្ដាញសង្គម។

# រាជរដ្ឋាភិបាលថៃ
# នឹងបញ្ចុះតម្លៃការធ្វើទិដ្ឋាការការងារដល់កម្មករខ្មែរពី១៩០០បាត មកត្រឹម ៥០០បាត

https://www.btv.com.kh/article/33219 2023/10/25 02:39:19 pm

កំពង់ចាម៖ ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា រាជរដ្ឋាភិបាលនៃប្រទេសថៃ បានសម្រេចបញ្ចុះតម្លៃ នៃការធ្វើទិដ្ឋាការ (VISA) ការងារ ដល់កម្មករ និយោជិតខ្មែរ ដែលទៅធ្វើការនៅប្រទេសថៃ ពីតម្លៃ១៩០០ (ប្រមាណ៥០ដុល្លា) មកត្រឹម ៥០០បាត (ជិត១៥ដុល្លារ) ។

ក្នុងពិធីសំណេះសំណាលកម្មករនិយោជិតជាង ១ម៉ឺន ២ពាន់នាក់ នៅខេត្តកំពង់ចាម ក្រោមអធិបតីភាពសម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម ហេង សួរ មានប្រសាសន៍ថា កាលពីជំនួបទ្វេភាគីរបស់សម្តេចធិបតី បានស្នើទៅកាន់នាយករដ្ឋមន្ត្រីថៃ ជួយកាត់បន្ថយនូវបន្ទុកចំណាយផ្សេងៗ របស់ពលករខ្មែរ ដែលទៅធ្វើការងារនៅប្រទេសថៃ ជាការឆ្លើយតប ទើបរាជរដ្ឋាភិបាលថៃ បានសម្រេចបញ្ចុះនូវតម្លៃធ្វើទិដ្ឋាការ ដែលត្រូវអនុវត្តចាប់ពីខែធ្នូ ឆ្នាំ២០២៣តទៅ ។

គួរបញ្ជាក់ថា ឯកឧត្តម សេដ្ឋា ថាវីស៊ីន នាយករដ្ឋមន្ត្រី នៃប្រទេសថៃ បានធ្វើដំណើរទស្សនកិច្ចនៅក្រៅប្រទេសលើកដំបូង ក្នុងតំណែងជានាយករដ្ឋមន្ត្រី មកកាន់ប្រទេសកម្ពុជា កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ មានជំនួបទ្វេភាគី និងពិភាក្សាការងារជាមួយសម្តេចធិបតី លើការងារមួយចំនួន ។ ក្នុងជំនួបនោះ ភាគីទាំងពីរ បានសន្យាបន្តពង្រឹងនូវកិច្ចសហប្រតិបត្តិការលើវិស័យមួយចំនួន ដូចជា ការផ្សារភ្ជាប់វិស័យសេដ្ឋកិច្ចឌីជីថល និងសេដ្ឋកិច្ចបៃតង វិស័យទេសចរណ៍ វិស័យអប់រំ វិស័យការងារ វិស័យការពារជាតិ រួមទាំងវិស័យសំខាន់ៗមួយចំនួនទៀត ដើម្បីបម្រើដល់ផលប្រយោជន៍ប្រជាជន នៃប្រទេសទាំងពីរ ដែលជាប់ព្រំដែននឹងគ្នា ។

ជាមួយគ្នានោះ តបតាមសំណើរបស់សម្តេចធិបតី នាយករដ្ឋមន្ត្រីថៃ នឹងពិចារណាដោយយកចិត្តទុកដាក់បំផុត ចំពោះសំណើរឲ្យមាននីតិវិធីអន្តោប្រវេសន៍ និងការសម្រួលនៅតាមព្រំដែនប្រសើរជាងមុន ព្រមទាំងពន្លឿននីតិវិធីបង្កើតអគ្គកុងស៊ុលកម្ពុជា នៅក្នុងខេត្តសុងក្លា ដើម្បីពង្រីកសេវាកុងស៊ុលជួយប្រជាពលរដ្ឋកម្ពុជា ដែលធ្វើការ និងស្នាក់នៅក្នុងភាគខាងត្បូង នៃប្រទេសថៃផងដែរ ៕ អត្ថបទ បាន សុខរិទ្ធិ

# ក្រសួងកិច្ចការនារីរៀបចំវគ្គបណ្តុះ បណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់ការរំលោភបំពានផ្លូវ ភេទលើស្រ្តី និងក្មេងស្រី

https://www.information.gov.kh/articles/116545 ចេញផ្សាយ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២៣

នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០២៣ ក្រសួងកិច្ចការនារី បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្រ្តី និងក្មេងស្រី" ជូនដល់សិក្ខាកាម ដែលជាគ្រូបង្គោលមកពីរាជធានី ខេត្តចំនួន៩ គឺ ខេត្តកំពង់ចាម ព្រះសីហនុ កោះកុង កំពង់ស្ពឺ តាកែវ បាត់ដំបង មណ្ឌលគីរី ស្វាយរៀង និងខេត្តកែប ដែលមានសិក្ខាកាមចូលរួម ៤២នាក់។ វគ្គបណ្តុះបណ្តាលនេះ បានប្រារព្ធឡើងក្រោមអធិបតីភាព លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួង កិច្ចការនារី លោកស្រី គឹម ចន្ទី អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិត សោម ពិសិដ្ឋ អភិបាលនៃគណៈអភិបាលខេត្ត។

លោកស្រី គឹម ចន្ទី អភិបាលរង ខេត្តកែប បានបញ្ជាក់ថា៖ ខេត្តកែប មានបទល្មើសព្រហ្មទណ្ឌ ៧ករណី បទឧក្រិដ្ឋ ៥ករណី ចំពោះបទ ល្មើសការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ពុំមានឡើយ។ កន្លងមកមន្ទីរកិច្ចការនារីខេត្ត បើកវគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទស្រ្តី និងក្មេងស្រី ទប់ស្កាត់ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ទប់ស្កាត់ការជួញ ដូរមនុស្ស អាជីវកម្មផ្លូវភេទ ទប់ ស្កាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ចំនួន ៣លើក ជូនដល់មន្ត្រីបង្គោលយេនឌ័រតាមមន្ទីរវិស័យ ក្រុង ស្រុក គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់, បានបញ្ជ្រាបការយល់ដឹងអំពីការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទលើស្រ្តី និងកុមារ ក្នុងកិច្ច ប្រជុំ សិក្ខាសាលា ទិវានារីអន្តរជាតិ ៨មីនា។ លោកស្រីបានបន្តថា ឆ្នាំ២០២២ កន្លងទៅ ខេត្តកែបបានកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងខេត្តកែប ពី១៦,៤៩% នៅឆ្នាំ២០២១ មកត្រឹម២,៦១% នៅឆ្នាំ២០២៣នេះ។

មានប្រសាសន៍ បើកវគ្គបណ្តុះ បណ្តាលក្នុងឱកាសនោះ លោក ជំទាវ ហ៊ូ សាមិត្ត បញ្ជាក់ថា៖ អំពើរំលោភបំពានផ្លូវភេទ រួមមាន ការ រំលោភសេពសន្ថវៈ អំពើប្រទូស្តកេរខ្មាស់ អំពើបង្ហាញកេរភេទ អំពើរុកគួនខាងផ្លូវភេទ អំពើអាសអាភាសប្រឆាំនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ រូបភាព និងសម្ភារៈអាសអាភាសផ្សេងៗ គឺជាអំពើខុសច្បាប់ ហើយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជនរងគ្រោះ និងការអភិវឌ្ឍធនធានមនុស្ស។ លោកជំទាវបញ្ជាក់ថា យោងតាមទិន្នន័យដែលទទួលបាននៅក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០២៣ មន្ទីរកិច្ចការនារីរាជធានី ខេត្ត ទាំង២៥ បានផ្តល់សេវាជូនជនរងគ្រោះចំនួន ២៧៤ករណី និងមានករណីរំលោភ ២៥៩ករណី ក្នុងនោះជនល្មើសជាប់ពន្ធនាគារចំនួន ២២៩នាក់ រត់គេចខ្លួន ៦៤នាក់ និងបញ្ជូនទៅតុលាការចំនួន ២២៩ ករណី ។ ចំពោះករណី

រំលោភបំពានស្ត្រី និងកុមារ ក្នុងឆ្នាំ២០២២ មានចំនួន ៣០៧ករណី ក្នុងនោះមានរំលោភ២៨២ករណី ស្លាប់៣ករណី ជនល្មើសជាប់ពន្ធនាគារ ២៥៨នាក់ រត់គេចខ្លួន ៥១នាក់ និងបញ្ជូនទៅតុលាការ២៥៨ករណី។

ក្នុងវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ លោជំទាវក្រើនរំលឹក គ្រូបង្គោលមកពីខេត្តទាំង៩ ឲ្យយកចិត្តទុកដាក់ តាមដានរាល់បទបង្ហាញរបស់គ្រូឧទ្ទេស ដើម្បីយកចំណេះដឹងទៅបន្តអនុវត្តការងារ និងជួយដល់ជនរងគ្រោះ ឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះ បានលើកឡើងនូវប្រធានបទរួមមានការយល់ដឹងអំពីការរំលោភបំពានផ្លូវភេទ, ដំណោះស្រាយនានាពាក់ព័ន្ធ នឹងអំពើរំលោភបំពានផ្លូវភេទ, ចំណុចសំខាន់ៗមួយចំនួនដែលត្រូវអនុវត្ត ដើម្បីឈានទៅរកដំណោះស្រាយផ្លូវច្បាប់, សុខភាពផ្លូវចិត្ត និងបញ្ហាចិត្តសង្គម, ការលើកកម្ពស់សីលធម៌សង្គម, ការការពារខ្លួន និងស្វែងរកជំនួយ, កិច្ចប្រជុំពិភាក្សាផ្សព្វផ្សាយនៅសហគមន៍៕

# ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០២៣

## ក្រសួងការពារជាតិ ដឹកនាំប្រជុំគណៈកម្មការចំពោះកិច្ច ពិភាក្សាពង្រឹងវិធានការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងបន្តចុះត្រួតពិនិត្យការអនុវត្តការងាររបស់សមត្ថកិច្ចតាមច្រកទ្វារព្រំដែនខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ

https://freshnewsasia.com/index.php/en/localnews/315376-2023-10-25-09-02-49.html 2023-10-25 04:02pm

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរតាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ក្រុមការងារទី២ បានបើកកិច្ចប្រជុំ នៅទីស្តីការក្រសួងការពារជាតិ ដើម្បីពិភាក្សាពង្រឹងវិធានការរបស់រាជរដ្ឋាភិបាលទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងបន្តចុះត្រួតពិនិត្យការអនុវត្តការងាររបស់សមត្ថកិច្ចពាក់ព័ន្ធតាមច្រកទ្វារព្រំដែន ខេត្តព្រះវិហារ និង ខេត្តឧត្តរមានជ័យ។

កិច្ចប្រជុំនេះ បានប្រព្រឹត្តិទៅក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាអនុប្រធានគណៈកម្មាការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរ តាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានក្រុមការងារទី២ និងមានការចូលរួមពីអនុប្រធាន និងសមាជិក ក្រុមការងារទី២ នៃគណៈកម្មការចំពោះកិច្ចជាច្រើនរូបទៀត។

ថ្លែងបើកកិច្ចប្រជុំ ឧត្តមសេនីយ៍ឯក សៀក សុជាតិ បានបញ្ជាក់ថា «**គោលបំណង នៃកិច្ចប្រជុំ គឺដើម្បីពិភាក្សាស្វែងរកដំណោះស្រាយ ជួយសម្រួលដល់ការឆ្លងកាត់ព្រំដែន របស់ប្រជាពលករ ជានាឱ្យបាននូវភាពស្របច្បាប់ ប្រកបដោយសុវត្ថិភាព និងដាក់ទិសដៅបន្តចុះត្រួតពិនិត្យតាម បណ្តាច្រកទ្វារព្រំដែនស្ថិតក្នុងខេត្តព្រះវិហារ និងខេត្តឧត្តមានជ័យ តាមការអនុវត្តតាមអនុសាសន៍ របស់សន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មការចំពោះកិច្ច**»។ ជាមួយគ្នានេះ កិច្ចប្រជុំក៏បានដាក់ចេញនូវទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីជួយសម្របសម្រួលដល់ពលករ ក្នុងការឆ្លងដែនប្រកបដោយសុវត្ថិភាព និងភាពស្របច្បាប់ផងដែរ។

## រដ្ឋាភិបាលថៃបញ្ចុះថ្លៃទិដ្ឋាការពលករខ្មែរពីជាង $៥០ មកជាង $១០

https://www.postkhmer.com/national/2023-10-26-0905-255497.html ជា សុខនី। Publication date 26 October 2023 । 09:05 ICT

**ភ្នំពេញ:** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ បានថ្លែងឱ្យដឹងថា រដ្ឋាភិបាលនៃប្រទេសថៃ បានសម្រេចបញ្ចុះតម្លៃទិដ្ឋាការការងារសម្រាប់ពលករ កម្ពុជាពី ១៩០០បាត ដែលប្រហែល ៥២ដុល្លារអាមេរិក មកត្រឹម ៥០០ បាត ឬប្រមាណ ១៤ ដុល្លារអាមេរិក។ លោក ហេង សួរ បានបញ្ជាក់ដូចនេះ នាថ្ងៃទី ២៥ ខែតុលា ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករនិយោជិតជាង ១ ម៉ឺននាក់ នៅខេត្តកំពង់ចាម ក្រោមអធិបតីភាពលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត។

លោកថ្លែងថា៖ «ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមគោរពជម្រាបជូនថា តាមរយៈលទ្ធផលនៃជំនួបទ្វេភាគី សម្តេចធិបតី ជាមួយឯកឧត្តមនាយករដ្ឋមន្ត្រីថៃ មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាកាលពីចុងខែកញ្ញា កន្លងទៅនេះ រដ្ឋាភិបាលថៃ ទើបបានឯកភាពតាមសំណើ និងការលើកឡើងរបស់សម្តេចធិបតីស្នើឱ្យភាគីថៃសម្របសម្រួល និងបន្ទុកចំណាយផ្សេងៗ។ ឥឡូវនេះរាជរដ្ឋាភិបាលថៃសម្រេចបញ្ចុះតម្លៃទិដ្ឋាការការងារដល់ បងប្អូនកម្មករនិយោជិតកម្ពុជាដែលពីមុនមានពី ១៩០០ បាតមកត្រឹម ៥០០ បាតប៉ុណ្ណោះ»។ លោកថា អត្រាថ្មីនេះ នឹងចាប់ផ្តើមអនុវត្តនៅក្នុងខែធ្នូខាងមុខ។ «ក្នុងនាមបងប្អូនពលករដែលធ្វើការនៅក្រៅប្រទេស ខ្ញុំសូមអរគុណសម្តេចធិបតី ដែលតែងតែលើកឡើងនូវសំណើនានាជូនទៅដល់ភាគីមិត្តម្ចាស់ផ្ទះទទួលពលករយើងឱ្យជួយសម្របសម្រួល និងថែទាំពលករយើងយ៉ាងកក់ក្តៅ»។

លោក មឿន តុលា ប្រធានអង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ថ្លែងថា ប្រសិនជាភាគីថៃបានឯកភាពលើការបញ្ចុះតម្លៃវីសាសម្រាប់ពលករកម្ពុជាពិតមែន ពិត

ជាល្អណាស់ ព្រោះពលករខ្មែរដែលធ្វើចំណាកស្រុក ភាគច្រើនជាអ្នកដែលមិនមានការងារធ្វើ អត់មានមុខរបរឬក៏ជាអ្នកដែលជំពាក់បំណុលគេ។ លោកបន្តថា ដូច្នេះលទ្ធភាពរបស់ពលករ គឺមិនមានលុយក្នុងការចំណាយសម្រាប់ទៅស្នើសុំការស្នាក់នៅ និងការធ្វើឯកសារផ្សេងៗបានដោយខ្លួនឯងទេ គឺពួកគាត់ត្រូវការខ្ចីលុយពីគេ ដើម្បីបានធ្វើឯកសារទាំងអស់នោះ។

លោកបញ្ជាក់ថា៖ «អ៊ីចឹង! ការកំណត់ទិដ្ឋាការ ឬវីសា ធ្លាក់មកដល់ត្រឹមជាង ១០ ដុល្លារនេះ វាគ្រាន់តែជួយបន្ថយបន្ទុកសម្រាប់ការចំណាយរបស់ពលករ ក្នុងការចុះឈ្មោះជាមួយក្រុមហ៊ុនជ្រើសរើសពលករ ប៉ុន្តែការចំណាយផ្សេងៗវានៅខ្ពស់ដដែលដូចជា ចំណាយការធ្វើលិខិតឆ្លងដែនពីខ្មែរយើងទៅនិងការពិនិត្យសុខភាពជាដើម»។

លោកថា ដើម្បីជួយទៅដល់ពលករខ្មែរ ក្នុងការកាត់បន្ថយការចំណាយ ភាគីកម្ពុជាត្រូវពិចារណាទៅលើតម្លៃការធ្វើលិខិតឆ្លងដែន តម្លៃពិនិត្យសុខភាពនិងតម្លៃឯកសារផ្សេងៗដែលផ្លូវច្បាប់មួយចំនួន តម្រូវ គួរតែធ្វើការបញ្ចុះដូចទៅនឹងភាគីថៃផងដែរ ពីព្រោះហេតុផល ដែលលោកចង់ឱ្យកម្ពុជាធ្វើការបញ្ចុះរាល់ការធ្វើឯកសារទាំងនោះគឺ ដើម្បីឱ្យពលករខ្មែរដែលឆ្លងដែនទៅធ្វើការនៅប្រទេសថៃមានឯកសារត្រឹមត្រូវ និងលិខិតឆ្លងដែនបានគ្រប់ៗគ្នា។ លោក មឿន តុលា បន្ថែមថា៖ «ប្រសិនការចំណាយហ្នឹងកាន់តែតិច ហើយមានពេលវេលារង់ចាំច្បាស់លាស់ គឺអាហ្នឹងវាអាចកាត់បន្ថយការចំណាកស្រុកដោយប្រថុយប្រថានរបស់ពលករយើងបានផងដែរ»។

ចំណែកលោក ម៉ាន់ សេងហាក់ ប្រធានសហព័ន្ធសហជីពឥទ្ធិពលការងារ បានថ្លែងថា ការបញ្ចុះតម្លៃទិដ្ឋាការរបស់ថៃ មកនៅត្រឹមជាង ១០ ដុល្លារនេះបានចូលរួមកាត់បន្ថយការចំណាយរបស់ពលករខ្មែរដែលទៅធ្វើចំណាកស្រុក ឬធ្វើការនៅប្រទេសថៃ។ លោកថ្លែងថា៖ «ការបញ្ចុះតម្លៃនេះ វាបង្ហាញថា ពលករខ្មែរយើងហ្នឹងមានច្រើន ហើយការងារដែលនៅប្រទេសថៃហ្នឹង ក៏មានច្រើនផងដែរ។ អ៊ីចឹង ថៃគឺខ្វះពលករដើម្បីបម្រើការងារនៅក្នុងប្រទេសរបស់ខ្លួន ខណៈដែលកម្ពុជាយើង គឺមានកម្លាំងពលករច្រើន។ ដូច្នេះខ្ញុំយល់ថា វាជាការប្រសើរណាស់ ពីព្រោះវាកាត់បន្ថយការចំណាយច្រើនរបស់ពលករយើង»។ លោកថា ក្រៅពីនេះ វាក៏កាត់បន្ថយការទៅធ្វើចំណាកស្រុកដោយខុសច្បាប់ដែរព្រោះការឆ្លងដែនដោយខុសច្បាប់គឺធ្វើឱ្យពលករខ្មែរត្រូវប្រឈមនឹងអាជ្ញាធរថៃចាប់ដាក់គុកនិងការកេងប្រវ័ញ្ចកម្លាំងពលកម្ម៕

# កម្ពុជា និងថៃ ពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗ ជាពិសេសនីតិវិធីអន្តោប្រវេសន៍ដើម្បីសម្រួលដល់ពលករខ្មែរទៅធ្វើការនៅប្រទេសថៃ

https://www.information.gov.kh/articles/116597 AKP ភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣

នៅក្នុងជំនួបពិភាក្សារវាងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម សេដ្ឋា ថាវីស៊ីន នាយករដ្ឋមន្ត្រីថៃ បានផ្តោតសំខាន់ទៅលើការពង្រឹងទំនាក់ទំនង នៃកិច្ចសហប្រតិបត្តិការទ្វេភាគី ទៅលើវិស័យគន្លឹះ ដោយរាប់ចាប់ពីវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ កិច្ចការទូត ទំនាក់ទំនងធុរកិច្ច ទំនាក់ទំនងប្រជាជន និងប្រជាជន ការតភ្ជាប់រវាងប្រទេសទាំងពីរតាមផ្លូវអាកាស ផ្លូវរថភ្លើង និងផ្លូវថ្នល់ សេដ្ឋកិច្ចឌីជីថល និងសេដ្ឋកិច្ចបៃតង កិច្ចការពាក់ព័ន្ធនឹងអន្តោប្រវេសន៍ រហូតដល់វិស័យសន្តិសុខឆ្លងដែន និងសន្តិសុខអនឡាញ ជាពិសេសនីតិវិធីអន្តោប្រវេសន៍ និងការសម្រួលនៅតាមព្រំដែនសម្រាប់ពលករកម្ពុជាដែលទៅធ្វើការងារនៅក្នុងប្រទេសថៃ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឱ្យដឹងថា នៅក្នុងជំនួបនោះ ឯកឧត្តម សេដ្ឋា ថាវីស៊ីន បានមានប្រសាសន៍ថា «ពលករកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសថៃ។ ដូច្នេះ រាជរដ្ឋាភិបាលថៃនឹងយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់ពួកគាត់»។ សេចក្តីប្រកាសព័ត៌មានដដែល បានបញ្ជាក់ថា «តបតាមសំណើរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាយករដ្ឋមន្ត្រីថៃនឹងពិចារណាដោយយកចិត្តទុកបំផុត ចំពោះសំណើឱ្យមាននីតិវិធីអន្តោប្រវេសន៍ និងការសម្រួលនៅតាមព្រំដែនប្រសើរឱ្យមានភាពប្រសើរជាងមុន ព្រមទាំងពន្លឿននីតិវិធីបង្កើតអគ្គកុងស៊ុលកម្ពុជានៅក្នុងខេត្តសុងក្លា ដើម្បីពង្រីកសេវាកុងស៊ុលជូនប្រជាពលរដ្ឋកម្ពុជា ដែលធ្វើការងារ និងស្នាក់នៅក្នុងភាគខាងត្បូងនៃប្រទេសថៃ»។

មួយវិញទៀត ដោយយោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា បច្ចុប្បន្ននេះ មានពលករកម្ពុជាចំនួន ១,២លាននាក់ កំពុងស្នាក់នៅ និងធ្វើការងារនៅក្នុងប្រទេសថៃ។ នៅក្នុងបណ្តាញតេឡេក្រាម (Telegram) សម្តេចធិបតី បានបញ្ជាក់ថា នៅក្នុងជំនួបទ្វេភាគីនោះ ប្រមុខរាជរដ្ឋាភិបាលទាំងពីរបានពិភាក្សាគ្នាដោយយកចិត្តទុកដាក់ និងដោយភាពស្និទ្ធស្នាល អំពីវិស័យនៃកិច្ចសហការទ្វេភាគីកម្ពុជា-ថៃ ដែលមានភាពសម្បូរបែប និងទូលំទូលាយ។ ថ្នាក់ដឹកនាំទាំងពីរក៏បានណែនាំដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ឱ្យបន្តពិភាក្សា និង សហការគ្នាដើម្បីឱ្យកិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ ទទួលបានផ្លែផ្កាសម្រាប់ជាឧត្តមប្រយោជន៍

*ទាំងសងខាង។ ថ្នាក់ដឹកនាំទាំងពីរបានវាយតម្លៃខ្ពស់ទៅវិញទៅមក និងមានជំនឿដ៏មុតមាំថា កិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ នឹងកាន់តែរីកចម្រើន និងរឹងមាំថែមទៀត។*

*ដោយឡែក ទាក់ទងទៅនឹងកិច្ចការងារតាមព្រំដែននោះ គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរតាមព្រំដែននៃប្រទេសកម្ពុជា បានបើកកិច្ចប្រជុំមួយនៅទីស្តីការក្រសួងការពារជាតិ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៣ ម្សិលមិញនេះ ដើម្បីពង្រឹងវិធានការរបស់រាជរដ្ឋាភិបាលទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងបន្តចុះត្រួតពិនិត្យការអនុវត្តការងាររបស់សមត្ថកិច្ចពាក់ព័ន្ធតាមច្រកទ្វារព្រំដែននៃខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។*

*កិច្ចប្រជុំនោះមានគោលបំណងពិភាក្សាស្វែងរកដំណោះស្រាយជួយសម្រួលដល់ការឆ្លងកាត់ព្រំដែនរបស់ប្រជាពលករកម្ពុជា ធានាឱ្យបាននូវភាពស្របច្បាប់ប្រកបដោយសុវត្ថិភាព និងដាក់ទិសដៅបន្តចុះត្រួតពិនិត្យតាមបណ្តាច្រកទ្វារព្រំដែនស្ថិតក្នុងខេត្តទាំង ២នេះ។ ដោយ៖ ខន្តី, ផ្សាយដោយ៖ កន ចំណាន*

## មន្ត្រីជាន់ខ្ពស់ក្រសួងការពារជាតិ ស្នើអភិបាលខេត្តជាប់ព្រំដែនពង្រឹងកិច្ចសហការដោះស្រាយបញ្ហាពលករ

https://www.kampucheathmey.com/local-news/602000 *ថ្ងៃព្រហស្បតិ៍ ២៦ តុលា ២០២៣ដោយ* Thoeun Vansong

*លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ មន្ត្រីជាន់ខ្ពស់ក្រសួងការពារជាតិ បានទទូចឱ្យអភិបាលខេត្តជាប់ព្រំដែនទាំងអស់ ត្រូវបន្តពង្រឹងកិច្ចសហការជាមួយភាគីប្រទេសដែលជាប់ព្រំដែនជាមួយកម្ពុជាឱ្យបានល្អ ដើម្បីដោះស្រាយបញ្ហាឆ្លងដែនរបស់ពលករខ្មែរ។*

*នៅក្នុងឱកាសដឹកនាំកិច្ចប្រជុំគណៈកម្មាការចំពោះកិច្ច សំដៅពង្រឹងវិធានការរបស់រាជរដ្ឋាភិបាលទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ នាថ្ងៃទី២៥ ខែតុលា លោក សៀក សុជាតិ រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាអនុប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរតាមព្រំដែន បានថ្លែងឱ្យដឹងថា កិច្ចប្រជុំនេះ បានពិភាក្សាគ្នាលើការស្វែងរកដំណោះស្រាយជួយសម្របសម្រួលដល់ការឆ្លងដែនរបស់ពលករ ដោយធានាយ៉ាងណាឱ្យបាននូវភាពស្របច្បាប់ប្រកបដោយសុវត្ថិភាព។*

*បើតាមលោក សៀក សុជាតិ កិច្ចប្រជុំនេះ ក៏នឹងកំណត់ការដាក់ទិសដៅបន្តចុះត្រួតពិនិត្យតាមបណ្តាច្រកទ្វារព្រំដែន ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដោយអនុវត្តតាមការណែនាំរបស់លោក នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការចំពោះកិច្ច ក៏ដូចជាលោកនាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។*

មន្ត្រីជាន់ខ្ពស់ក្រសួងការពារជាតិរូបនេះ បានបញ្ជាក់ថា ជាទិសដៅបន្ត គឺការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីជួយសម្របសម្រួលដល់ពលករក្នុងការធ្វើដំណើរឆ្លងដែនប្រកបដោយសុវត្ថិភាព ក៏ដូចជាចូលរួមជានាថៃរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ឱ្យបានល្អប្រសើរនៅតាមច្រកទ្វារព្រំដែន។ លោក បន្ថែមថា កម្ពុជា នឹងបន្តពិភាក្សាជាមួយភាគីថៃបន្តទៀត ដើម្បីកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេសរវាងខេត្ត និងខេត្តដែលនៅជាប់ព្រំដែន។

ក្នុងនាមជាអនុប្រធានគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែន លោក សៀក សុជាតិ បានស្នើសុំដល់អភិបាលខេត្តជាប់ព្រំដែនទាំងអស់ ត្រូវពង្រឹងយន្តការសហការជាមួយភាគីប្រទេសជិតខាងឱ្យបានល្អ ជៀសវាងកុំអោយមានបញ្ហា ឬហានិភ័យដល់ពលករកម្ពុជា។ ក្នុងនោះ អាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ច កងកម្លាំងប្រដាប់អាវុធតាមព្រំដែន ក៏ដូចជាស្ថាប័នឈរជើងតាមបណ្ដាច្រកទ្វារអន្តរជាតិ ក៏ត្រូវចូលរួមឱ្យបានសកម្មថែមទៀត ដើម្បីជួយសម្របសម្រួលការងារនេះកុំឱ្យកកស្ទះ សំដៅធ្វើយ៉ាណាបម្រើសេវាជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។

## ពលរដ្ឋឃុំសាគ្រាមខេត្តកំពង់ធំ
## ប្រមាណ៧០ភាគរយធ្វើចំណាកស្រុកដើម្បីរកប្រាក់ដោះបំណុល

https://www.rfa.org/khmer/news/economy/about-70-percentage-of-people-in-a-commune-in-kampong-thom-province-migrate-to-find-job-to-pay-off-debts-10262023100316.html ដោយ ឡេង ម៉ាលី2023.10.26

ក្រោយចប់រដូវបុណ្យភ្ជុំបិណ្ឌ ប្រជាពលរដ្ឋរស់នៅឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ប្រមាណជាង ៧០ភាគរយនៅក្នុងឃុំ បាននាំគ្នាចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដោយសារពួកគេមិនអាចរកការងារធ្វើនៅក្នុងស្រុក និងគ្មានប្រាក់សងបំណុលធនាគារ។ មន្ត្រីសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋានបារម្ភខ្លាចពលរដ្ឋទាំងនោះទៅធ្វើការងារឆ្លងដែន ចាញ់បោកមេខ្យល់ ដោយសារពលរដ្ឋមួយចំនួនមិនមានឯកសារត្រឹមត្រូវ។

ប្រជាពលរដ្ឋនៅក្នុងឃុំសាគ្រាមអះអាងថា ពលរដ្ឋនៅក្នុងឃុំប្រមាណជាង៧០ភាគរយ បាននាំគ្នាទៅធ្វើការនៅប្រទេសថៃ ដោយសារពួកគេគិតថា នៅទីនោះស្រួលរកលុយចិញ្ចឹមគ្រួសារជាងនៅកម្ពុជា។ ក្រៅពីនោះពួកគេថា ការងារនៅក្នុងស្រុក មិនអាចរកប្រាក់ដោះបំណុលបាននោះទេ ។ អ្នកភូមិបន្ថែមថា អ្នកទាំងនោះភាគច្រើននាំគ្នាទៅស៊ីឈ្នួល ធ្វើការងារសំណង់ ដោយបានប្រាក់ឈ្នួលក្នុងមួយថ្ងៃ ចន្លោះពី១០ដុល្លារ ទៅ១៥ដុល្លារ ច្រើនជាងក្នុងស្រុកដែលពួកគេរកបានតែ៣ម៉ឺនរៀល ទៅ៥ម៉ឺនរៀល។

ប្រជាពលរដ្ឋរស់នៅឃុំសាគ្រាម លោក ង៉ោ បូរ៉ា បានរៀបរាប់ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៥ ខែតុលាថា ក្រោយចប់បុណ្យភ្ជុំបិណ្ឌភ្លាម ពលរដ្ឋនៅក្នុងឃុំ នាំគ្នាសម្រុកទៅធ្វើការងារនៅប្រទេសថៃច្រើនជាងសព្វមួយដង ដោយសារពួកគេធ្វើការងារនៅក្នុងស្រុកមិនអាចរកប្រាក់បានដោះបំណុលធនាគារ។ លោកបន្ថែមថា នៅក្នុងភូមិមានភាពស្ងប់ស្ងាត់ និងមានតែមនុស្សចាស់ជរានៅមើលថែចៅតែប៉ុណ្ណោះ រីឯគ្រួសារខ្លះទៀត បានបង្ខំឲ្យកូនឈប់រៀនទៅធ្វើការងារដែរ។ លោក ង៉ោ បូរ៉ា៖ «គាត់ចំណាកទីមួយគាត់ទៅថៃ ទៅថៃច្រើន គាត់ទៅភ្នំពេញ ភាគច្រើនគឺទៅថៃ ពលរដ្ឋពេញកម្លាំង៧០ភាគរយ ៨០ភាគរយ គាត់ចំណាកស្រុក គាត់មិនសូវនៅធ្វើស្រែធ្វើចម្ការទេ»។

ពលរដ្ឋម្នាក់ទៀតនៅឃុំសាគ្រាម គឺ កញ្ញា លី រ៉ាក់សា កត់សម្គាល់ថា ពលរដ្ឋនៅក្នុងឃុំរបស់កញ្ញា ធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ដែលមានការកើនឡើង ក្នុងអំឡុងពេល២ឆ្នាំចុងក្រោយនេះ ។ កញ្ញាបន្ថែមថា ពលរដ្ឋទាំងអស់នោះភាគច្រើននាំគ្នាទៅធ្វើការជាកម្មករសំណង់ រីឯអ្នកខ្លះទៀតបង្ខំចិត្តទៅធ្វើការនៅទីនោះ ដោយសារតែមុខរបរកសិកម្ម របស់ពួកគេ ដូចជា ដំឡូងស្វាយចន្ទី និងស្វាយ មានការខាតបង់និងមិនអាចរកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារបាន។ កញ្ញា លី រ៉ាក់សា៖ «គាត់ធ្វើស្រែចម្ការមិនសូវបានផល ដូចជាធ្វើដំឡូងជួនកាលទឹកលិចអ៊ីចឹងគាត់ខាត ធ្វើដំឡូងដោយសារគាត់យកលុយធនាគារធ្វើ ដល់ពេលដំឡូងខូចក៏គាត់កប់លុយអ៊ីចឹងឯងគាត់អត់មានអ្វីបង់ ជួនកាលក៏គាត់រត់ទៅប្រទេសថៃ ធ្លាប់សួរគាត់អ៊ីចឹង គាត់នៅយកចៅ[មើល]កូនគាត់ធ្វើការចំណាកស្រុក ដើម្បីយកលុយមកបង់ធនាគារ»។

ជុំវិញរឿងនេះ មេឃុំសាគ្រាម លោក ចាន់ សុផល ទទួលស្គាល់ថា មានប្រជាពលរដ្ឋក្នុងឃុំធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃពិតមែន ប៉ុន្តែលោកថា មានប្រមាណតែ៣០ភាគរយ ទៅ៤០ភាគរយប៉ុណ្ណោះ ដែលបាននាំគ្នាធ្វើការចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃ និងមួយចំនួនទៀត ទៅធ្វើការនៅទីក្រុងភ្នំពេញ ដោយសារពលរដ្ឋទាំងអស់នោះភាគច្រើន ជំពាក់បំណុលធនាគារ។ លោកមានការព្រួយបារម្ភចំពោះពលរដ្ឋ ដែលបានទៅធ្វើការឆ្លងដែននៅប្រទេសថៃ មិនមានឯកសារត្រឹមត្រូវ ប៉ុន្តែលោកថា កន្ទងទៅអាជ្ញាធរឃុំ និងអង្គការសង់ត្រាល់ (CENTRAL) បានផ្សព្វផ្សាយអប់រំអំពីផ្លូវច្បាប់ និងការធ្វើចំណាកស្រុក ដោយស្របច្បាប់និងឲ្យបានត្រឹមត្រូវជាបន្តបន្ទាប់មកហើយដែរ។

លោក ចាន់ សុផល៖ «និយាយរួមទៅតំបន់ខ្ញុំនេះច្រើនតែយកលុយធនាគារ គាត់យកលុយពីធនាគារទៅដល់គាត់ដោះការប្រាក់មិនទាន់ទៅគាត់ត្រូវការធ្វើចំណាកស្រុក។ ជីវភាពនៅតំបន់របស់ខ្ញុំរបរកសិកម្មវាអស់ហើយ ស្រែ ចម្ការ ស្វាយចន្ទី ប៉ុណ្ណោះឯងទេ ដល់ផុតដំណាំសម្រាប់ជីវភាពរបស់គាត់ទាន់ចិត្តគាត់ត្រូវធ្វើការចំណាកស្រុក។ និយាយរួមទៅជំពាក់ធនាគារច្រើន»។

របាយការណ៍របស់សាលាឃុំសាគ្រាម បង្ហាញថា ឃុំនេះមានពលរដ្ឋជាង២ពាន់គ្រួសារ (២១២៣គ្រួសារ) ស្មើនឹង ជាង១ម៉ឺន នាក់(១០១២៨នាក់) ដែលជាអ្នករស់នៅពឹងផ្អែកទៅលើមុខរបរកសិកម្ម។ អាជ្ញាធរឃុំក៏ បានកំណត់ ភូមិចំនួន៣ ដែលជាភូមិមានបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ និងលំបាកខ្លាំងក្នុងការពិបាករកប្រាក់សងទៅម្ចាស់បំណុល មានដូចជា ភូមិព្រិច ភូមិស្រែវាល និងភូមិគន្ធាក។

ទាក់ទិននឹបញ្ហានេះ មន្ត្រីជាន់ខ្ពស់ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (ហៅកាត់សង់ត្រាល់) លោក ឌី ថេហូយ៉ា យល់ឃើញថា ពលករចំណាកស្រុក ទទួលបានផលប្រយោជន៍តិចតួច គឺអាចរកប្រាក់បានចិញ្ចឹមជីវិតនិងអាចសងបំណុលគេបាន ប៉ុន្តែក៏មានផលប៉ះពាល់ច្រើនផងដែរ ជាពិសេសពលរដ្ឋធ្វើចំណាកស្រុកដោយខុសច្បាប់។ លោកថា ការធ្វើការចំណាកស្រុកដោយខុសច្បាប់ប្រឈមនឹងការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ព្រមទាំងសមត្ថកិច្ចថៃចាប់ខ្លួនថែមទៀតផង។ លោក ឌី ថេហូយ៉ា៖ «កាលណាទៅមិនស្របច្បាប់ បញ្ហាប្រឈមរបស់គាត់គឺប្រឈមពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម ការរងគ្រោះថ្នាក់ផ្សេងៗជាដើម ដោយមិនមានការការពារសិទ្ធិរបស់ពួកគាត់ នៅពេលអត់មានការការពារទាំងអស់ហ្នឹងអត់មានបានការគោរពសិទ្ធិគឺគាត់ទៅធ្វើការងារមួយ ដែលគេហៅថាទាសភាពទាសម័យទំនើប (Modern slavery) មានន័យថាធ្វើការដោយបង្ខំ ធ្វើការដោយគ្មានសេរីភាព ដោយសារតែគាត់ជាប់ដោយបំណុលជាដើមហ្នឹង»។

បើទោះបីយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាលអាណត្តិទី៧នេះ បានកំណត់យកការពង្រឹងសេដ្ឋកិច្ច និងបង្កើតការងារឱ្យពលរដ្ឋរកប្រាក់ចំណូលជារឿងសំខាន់ក៏ដោយ នៅរយៈពេលជាង២ខែបន្ទាប់ពីបង្កើតបានរដ្ឋាភិបាលថ្មីមក ពលរដ្ឋនៅគ្រប់កន្លែងតែងតែលើកឡើងអំពីបញ្ហាលំបាក បាត់បង់ការងារធ្វើ បាត់បង់ប្រាក់ចំណូល ព្រមទាំងរងសម្ពាធយ៉ាងធ្ងន់ធ្ងរពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រជាពលរដ្ឋនៅក្នុងឃុំសាគ្រាម បានត្អូញត្អែរថា ពួកគេមានបញ្ហាខ្វះថវិកាទិញម្ហូបអាហារ ទិញថ្នាំព្យាបាលជំងឺ ជាពិសេសខ្វះលុយបង់ធនាគារ និងភ័យខ្លាចមានការរឹបអូសទ្រព្យសម្បត្តិ ដោយសារគ្មានលទ្ធភាពសងបំណុល៕

# ថ្ងៃទី៣០ ខែ តុលា ឆ្នាំ២០២៣

## ក្រសួងព័ត៌មាន រៀបចំសិក្ខាសាលា ស្ដីពីការពង្រឹងអក្ខរាវិរុទ្ធ ក្រមសីលធម៌លើវេទិកា ឬផ្សាយផ្ទាល់ និងឈ្វេងយល់ពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងគ្រឿងញៀន

https://www.information.gov.kh/articles/116703 AKP ភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

ក្រសួងព័ត៌មាន រៀបចំសិក្ខាសាលា ស្ដីពីការពង្រឹងអក្ខរាវិរុទ្ធ ក្រមសីលធម៌លើវេទិកា ឬផ្សាយផ្ទាល់ និងឈ្វេងយល់ពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងគ្រឿងញៀន ដោយមានការអញ្ជើញចូលរួមធ្វើជាវាគ្មិនពីលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ឯកឧត្តម ជុំ កុសល រដ្ឋលេខាធិការក្រសួងព័ត៌មាន និងឯកឧត្តម សាម៉ន បណ្ឌិត្យ រដ្ឋលេខាធិការក្រសួងព័ត៌មាន ដែលមានកិច្ចសហការរៀបចំពី គ.ជ.ប.ជ និងអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន (អ.ជ.ប.អ.ញ) នាព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នៅក្រសួងព័ត៌មាន រាជធានីភ្នំពេញ។ សួស សាវី

## អាជ្ញាធរសមត្ថកិច្ច នៅខេត្តជាប់ព្រំដែន ត្រូវឈប់ឱ្យយកលុយពីប្រជាពលរដ្ឋ ឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/article/1825436.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៧ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ១៨:៤៨

ភ្នំពេញ៖ ក្នុងសារជាសំឡេង ជូនអាជ្ញាធរសមត្ថកិច្ចខេត្តជាប់ព្រំដែន និងមេបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នេះ លោកឧបនាយករដ្ឋមន្ត្រី នេត សាវឿន បានណែនាំដល់អាជ្ញាធរសមត្ថកិច្ចខេត្តជាប់ព្រំដែន ឈប់ឱ្យយកលុយពីប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់។ បទបញ្ជាផ្ទាល់មាត់របស់លោកឧបនាយករដ្ឋមន្ត្រី នេត សាវឿន ខាងលើនេះ បានធ្វើឡើង ក្រោយពីលោកបានរាយការណ៍ជូនសម្ដេចធិបតី នាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ដោយលើកឡើងថា «បន្ទាប់ពីទទួលបានព័ត៌មានពីប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងករណីនគរបាលប៉ុស្តិ៍៤០០ ស្រុកសំឡូត ខេត្តបាត់ដំបង យកលុយពីប្រជាពលរដ្ឋ ពេលឆ្លងដែនទៅធ្វើការនៅប្រទេសថៃ លោកបានចាត់ឲ្យកម្លាំងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានចុះធ្វើការស្រាវជ្រាវជាបន្ទាន់ ក្នុងនោះទទួលបានលទ្ធផល ដូចខាងក្រោម៖

ពិតជាមានករណី មន្ត្រីនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនតំបន់៤០០ ស្រុកសំឡូត ចំនួន ២ នាក់ បានយកប្រាក់ពីពលខ្មែរយើង ៥ នាក់ ក្នុង ១ នាក់ ចំនួន ២ម៉ឺនរៀល ដោយពួកគាត់ទាំង៥ នោះ បានពឹងពាក់ឲ្យជួយសម្រួលទាំងខាងខ្មែរ និង ថៃ ដោយសារពួកគាត់ ពុំមានឯកសារគ្រប់គ្រាន់

ដើម្បីឆ្លងដែន។ បច្ចុប្បន្ន ស្នងការដ្ឋាននគរបាលខេត្ត បានឲ្យមន្ត្រីនគរបាលទាំង ២រូប ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពខុសច្បាប់របស់ខ្លួន»។

លោកឧបនាយករដ្ឋមន្ត្រី នេត សាវឿន បានជម្រាបជូនសម្ដេចធិបតី ដោយយកករណីនេះជាបទពិសោធ ណែនាំដល់ប៉ុស្ដិ៍ព្រំដែនទាំងអស់ ដើម្បីឲ្យមន្ត្រីតាមប៉ុស្ដិ៍យើង បញ្ឈប់សកម្មភាពយកប្រាក់ពីប្រជាពលរដ្ឋឆ្លងកាត់តាមព្រំដែន៕

## ជនជាតិចិន
## និងខ្មែរដែលសង្ស័យថតរឿងអាសអាភាសបានបញ្ជូនខ្លួនទៅតុលាការហើយ

https://www.rfi.fr/km//20231027-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 27/10/2023 - 13:20

ជនជាតិចិន និងខ្មែរប្រមាណ ១០នាក់ ក្នុងចំណោម៤៥នាក់ ដែលនគរបាលព្រហ្មទណ្ឌក្រសួងមហាផ្ទៃឃាត់ខ្លួនបានកាលថ្ងៃទី២៤តុលា ត្រូវបានបញ្ជូនខ្លួនទៅតុលាការ ដើម្បីចាត់ការទៅតាមផ្លូវច្បាប់ហើយ។ ពួកគេត្រូវបានចាប់និងឃាត់ខ្លួន ក្រោយសង្ស័យថា លួចថតរឿងវីដេអូអាសអាភាសដែលបានបង្ហោះតាមបណ្ដាញសង្គម។

ក្នុងចំណោម ៤៥នាក់ដែលបានចាប់ និងឃាត់ខ្លួនបាន ក្នុងនោះមេក្លោង និងបក្ខពួកសរុបចំនួន ១០នាក់ ភាគច្រើនជាជនជាតិចិន ព្រមទាំងវត្ថុតាងផ្សេងៗ ត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការទៅតាមផ្លូវច្បាប់ នៅរសៀលថ្ងៃទី២៧ ខែតុលានេះ។

លោក ឆាយ គឹមខឿន អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិ បានបញ្ជាក់ថា ការចាប់និងឃាត់ខ្លួនជនជាតិចិន និងខ្មែរ ៤៥នាក់នេះ បន្ទាប់ពីទទួលបានបណ្ដឹងពីជនរងគ្រោះ នៅថ្ងៃទី១០ ខែតុលា ពាក់ព័ន្ធករណីឆបោក សញ្ចារកម្ម ផលិតចែកចាយរូបភាពវីដេអូអាសអាភាសមកអគ្គស្នងការដ្ឋាននគរបាលជាតិ។

បើតាមលោក ឆាយ គឹមខឿន ក្រោយទទួលបានពាក្យបណ្ដឹងពីជនរងគ្រោះ សមត្ថកិច្ចបានបើកការស្រាវជ្រាវស៊ើបអង្កេត ដោយមានការសម្របសម្រួលនីតិវិធីពី លោក គឹម ហុងសាន ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ទើបនៅថ្ងៃទី២៤តុលា សមត្ថកិច្ចបានឆែកឆេរ ពិនិត្យនៅចំណុចអគារ Wow Now នៅសង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ហើយឈានដល់នាំខ្លួនជនសង្ស័យចំនួន៤៥នាក់ ដកហូតសម្ភារៈ និងឧបករណ៍អេឡិចត្រូនិចមួយចំនួន។

អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិរូបនេះ បញ្ជាក់ថា ក្នុងចំណោមជនសង្ស័យចំនួន ៤៥នាក់នេះ ក្នុងនោះមានជនជាតិចិន ៣៧នាក់ (ស្រី៣នាក់) និងខ្មែរចំនួន ៨នាក់ (ស្រី៣នាក់)។

ចំណែកគ្រឿងឧបករណ៍សម្ភារៈដែលចាប់បានមានកុំព្យូទ័រលើតុសម្រាប់កាត់តវិដេអូមួយចំនួន ឧបករណ៍ស៊ិច សម្ភារៈបម្រើថតស៊ិច និងស្រោមអនាម័យជាដើម។

ក្រោយពីធ្វើការសាកសួររួចមក ឃើញថាមានជនសង្ស័យពាក់ព័ន្ធចំនួន ១០នាក់ជាជនជាតិចិន ត្រូវបានឲ្យឃាត់ខ្លួនបណ្ដោះអាសន្នពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយជនសង្ស័យទាំង ១០នាក់ រួមទាំងវត្ថុតាង ត្រូវបានបញ្ជូនទៅតុលាការដើម្បីចាត់ការបន្តតាមនីតិវិធីនៅថ្ងៃទី២៧តុលានេះ។ នេះបើតាមលោក ឆាយ គីមខឿន។ ដោយឡែកអ្នកដទៃផ្សេងទៀតដែលមិនជាប់ពាក់ព័ន្ធចំនួន ៣៥នាក់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅវិញ៕

## អនុញ្ញាតឱ្យទីស្នាក់ការត្រួតច្រកទ្វារចំនួន៣ អាចទទួលនិងប្រគល់ឯកសារប័ណ្ណព្រំដែនកម្ពុជា-ថៃ

https://kohsantepheapdaily.com.kh/article/1825055.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ ២៧ ខែ តុលា ឆ្នាំ ២០២៣ ម៉ោង ១០:០២

ខេត្តបន្ទាយមានជ័យ ៖ លោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពីការអនុញ្ញាតឱ្យទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់បឹងត្រកួន, ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ម៉ាឡៃ និងការិយាល័យច្រកចេញ-ចូលតែមួយនៃរដ្ឋបាលស្រុក ទទួលនិងប្រគល់ឯកសារប័ណ្ណព្រំដែនកម្ពុជា-ថៃ ។

កិច្ចប្រជុំនេះ ក៏មានការចូលរួមពីលោក ជា សេងអាន នាយករងរដ្ឋបាលសាលាខេត្ត លោក ឈិន សូរិយា ប្រធានអង្គភាពច្រកចេញ-ចូលតែមួយខេត្ត លោក-លោកស្រី អភិបាលរងស្រុក ប្រធានការិយាល័យច្រកចេញ-ចូលតែមួយស្រុកចំនួន៧ ធ្វើឡើងនៅរសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០២៣ នាសាលប្រជុំច្រកចេញ-ចូលតែមួយ ខេត្តបន្ទាយមានជ័យ។

លោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា៖ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពលរដ្ឋរដ្ឋបាលខេត្តបន្ទាយមានជ័យ បានពង្រីកសេវាការធ្វើប័ណ្ណព្រំដែន ទៅការិយាល័យច្រកចេញ-ចូលតែមួយស្រុកចំនួន៧បន្ថែមទៀត ដើម្បីបង្ខិតសេវាឱ្យទៅដល់គៀកនិងបងប្អូនប្រជាពលរដ្ឋ មិនចាំបាច់ចំណាយពេលមកធ្វើនៅច្រកចេញ-ចូលតែមួយនៃរដ្ឋបាលខេត្ត ។

លោក ឈិន សូរិយា ប្រធានអង្គភាពច្រកចេញ-ចូលតែមួយខេត្ត បានបញ្ជាក់ឱ្យដឹងថា៖ យោងតាមសេចក្ដីជូនដំណឹងរបស់រដ្ឋបាលខេត្ត ស្ដីពីការបន្ថែមទីតាំងទទួល-ប្រគល់ឯកសារសេវាផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ការធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ ប័ណ្ណ១ តម្លៃ២ម៉ឺនរៀល រយៈពេលអតិបរិមាផ្តល់សេវាចំនួន៥ថ្ងៃ ដែលមានសុពលភាព២ឆ្នាំ ដោយឡែក

ចំពោះការបន្តសុពលភាពប័ណ្ណព្រំដែនកម្ពុជា-ថៃ ប័ណ្ណ១ តម្លៃ១ម៉ឺនរៀល រយៈពេលអតិបរិមាផ្តល់សេវាចំនួន៣ថ្ងៃ ដែលមានសុពលភាព២ឆ្នាំ។

លោកបន្តថា ចំពោះការប្រើប្រាស់ប័ណ្ណព្រំដែន បងប្អូនពលរដ្ឋអាចស្នាក់នៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃរយៈពេល០៧ថ្ងៃ ក្នុងពេលចូលម្តង ចំពោះការស្នាក់នៅរយៈពេលយូរ ប៉ុន្តែមិនលើសពី១៥ថ្ងៃ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីថៃ។ ប្រជាពលរដ្ឋខ្មែរកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ដែលបានបំពេញលក្ខខណ្ឌ និងនីតិវិធីផ្ទៃក្នុងពាក់ព័ន្ធការងារប្រចាំថ្ងៃ ការងារតាមរដូវកាលត្រូវបានអនុញ្ញាតឱ្យស្នាក់នៅចំនួន ៣០ថ្ងៃ នៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃ ។

## ភូមាចាប់ខ្លួនអ្នកឆបោកអនឡាញបាន៩៥នាក់

https://www.rfi.fr/km//20231028-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 28/10/2023 - 16:49

នៅសប្តាហ៍នេះ ប៉ូលិសភូមាចាប់ខ្លួនមនុស្សបាន៩៥នាក់ នៅក្រុងរ៉ង់ហ្គូន ពីបទជាប់សង្ស័យរកស៊ីឆបោកតាមបណ្តាញអ៊ីនធ័រនែត។ នេះបើតាមការជូនដំណឹងរបស់អាជ្ញាធរភូមានៅល្ងាចថ្ងៃសុក្រទី ២៧តុលា២០២៣។ ជាសរុបអាជ្ញាធរភូមាចាប់ខ្លួនមនុស្សបាន៩៥នាក់ កាលពីថ្ងៃព្រហស្បតិ៍ទី ២៦តុលា ភាគច្រើនជាជនជាតិភូមា ក្នុងទីតាំងបីកន្លែងផ្សេងគ្នា នៅក្រុងរ៉ង់ហ្គូន។ ក្នុងពេលចុះឆែកឆេរនោះ ប៉ូលិសក៏រឹបអូសបាននូវឡានមួយគ្រឿង កុំព្យូទ័រ ទូរស័ព្ទដៃជាច្រើនគ្រឿង ព្រមទាំងសម្ភារៈជាច្រើនផ្សេងទៀត ប៉ុន្តែជនសង្ស័យជាអ្នកទទួលខុសត្រូវ នៃបណ្តាញឆបោកនេះ បានគេចខ្លួនរួច ពេលប៉ូលិសទៅដល់ផ្ទះ។ នេះបើតាមសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសឹកភូមាចេញផ្សាយនៅព្រលប់ថ្ងៃសុក្រទី ២៧តុលា។

នេះជាលើកទីមួយហើយ ដែលអាជ្ញាធរភូមា បានប្រកាសចាប់ខ្លួនមនុស្សបានក្នុងទ្រង់ទ្រាយធំនៅក្រុងរ៉ង់ហ្គូនអតីតរដ្ឋធានីនៃប្រទេស ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការរកស៊ីឆបោកតាមអនឡាញ។ ប្រតិបត្តិការចាប់ខ្លួនមុនៗដៅធ្វើតែនៅតាមព្រំដែនភាគខាងជើងជាប់ប្រទេសចិនតែប៉ុណ្ណោះ ព្រោះចិនជាសម្ព័ន្ធមិត្តបានដាក់សម្ពាធលើភូមាឱ្យបិទបញ្ចប់ការឆបោកតាមអ៊ីនធ័រនែតដៅលើពលរដ្ឋចិន។

នៅភូមា បណ្តាញឧក្រិដ្ឋជនជាប់ចោទជាអ្នកចាប់ជំរិតបរទេស ឬទាក់ជនបរទេសឱ្យចូលមកតំបន់គ្មានច្បាប់នៅតាមបណ្តោយព្រំដែនភាគខាងជើងនិងខាងកើតភូមា រួចចាប់បង្ខំឱ្យពួកគេ

ឆបោកតទាក់ជនរួមជាតិ តាមបណ្ដាញអ៊ីនធឺណែត។ បណ្តាញឧក្រិដ្ឋនេះ ទំនងទាក់ទាញ ចាប់ និងបង្ខំមនុស្សរាប់ពាន់នាក់ឱ្យរកស៊ីឆបោកតាមអនឡាញ។

បើតាមភ្នាក់ងារអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន និងឧក្រិដ្ឋកម្ម ការជួញដូរមនុស្សក្នុងកាស៊ីណូ និងប្រតិបត្តិការឆបោកអនឡាញបានកើនឡើងយ៉ាងខ្លាំងនៅនៅពេញតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅតាមបណ្ដាប្រទេសតាមបណ្ដោយទន្លេមេគង្គ និងបានផលចំណេញយ៉ាងខ្លាំងមិនធ្លាប់មានពីមុនមកទេ។ ផលចំណេញពីរបរឆបោកមានទំហំដល់រាប់ពាន់លានដុល្លារ ស្ទើរស្មើនឹងផលិតផលដុលនៃប្រទេសខ្លះនៅក្នុងតំបន់ផង។

ជនរងគ្រោះបានអះអាងបានធ្វើដំណើរទៅប្រទេសភូមា កម្ពុជា ថៃនិងឡាវ ដោយលង់ជឿនឹងពាក្យសន្យាក្លែងក្លាយ បានការងារធ្វើមានប្រាក់ខែខ្ពស់ ឬ បានជួបគូស្នេហ៍។ តែពេលទៅដល់ត្រូវជាប់ការបង្ខាំងនិងរងការបង្ខំឱ្យធ្វើការឆបោក ទាក់ជនរួមជាតិឯងបន្តតាមអនឡាញ។ អ្នកនាំពាក្យក្រសួងការបរទេសថៃបានប្រកាសនៅថ្ងៃសុក្រម្សិលមិញថា មានពលរដ្ឋខ្លួនរងគ្រោះជាប់ក្នុងបណ្ដាញឆបោកនៅរដ្ឋShanភាគខាងជើងភូមាចំនួន២១៩នាក់ និងសង្គ្រោះបាន១៥៣នាក់៕

# ថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០២៣

## ចោទប្រកាន់ជាផ្លូវការ
## លើជនជាតិចិន10នាក់ ដែលជាមេក្លោង ជតរឿងអាសអាភាសក្នុងសណ្ឋាគារមួយ

https://www.kampucheathmey.com/security/604122 ថ្ងៃចន្ទ ៣០ តុលា ២០២៣ដោយ Kang Tola

ភ្នំពេញ ៖ នៅល្ងាច ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ តំណាងអយ្យការ បានស៊ើបសួរ លើជនជាតិចិនចំនួន១០ នាក់ ដែលជាក្លោង ជតរឿងក្ដៅសាច់ នៅក្នុងសណ្ឋាគារ Wow Now រួចចោទប្រកាន់ជាផ្លូវការ។

លោក ប្ញង់ សុផល ព្រះ ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យអមសាលាដំបូងរាជធានីភ្នំពេញនាល្ងាចថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២៣ បានប្រាប់ឲ្យដឹងថា សំណុំរឿងខាងលើនេះ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ ស្ពានទម្ងន់ទោស នៃសញ្ញកម្ម ការដឹកនាំពេស្យាចារ និងរូបភាព និងសម្ភារ:អាសអាភាស តាមមាត្រា ២៧ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ពួកគេត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅ

តុលាការ ពាក់ព័ន្ធពីបទសញ្ចារកម្ម ការដឹកនាំពេស្យាចារ និងផលិតចែក ចាយរូបភាពវីដេអូអាសអាភាស តាមពាក្យបណ្ដឹងរបស់នារីរង គ្រោះ២ នាក់។

សូមបញ្ជាក់ថា នាយកដ្ឋាននគរបាលព្រហ្មទណ្ឌក្រសួងមហាផ្ទៃ បានដាក់កម្លាំងចុះឡោមព័ទ្ធទីតាំង អគារមួយកន្លែង និងបានឃាត់ខ្លួនជនបរទេសជាច្រើននាក់ ដោយសង្ស័យពាក់ព័ន្ធករណីផលិតរឿងបែប(អាសអាភាស)បង្កឱ្យមានការភ្ញាក់ផ្អើល កាលពីវេលាម៉ោង៨ យប់ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២៣ នៅលើកំណាត់ ផ្លូវលេខ៣១០ សង្កាត់បឹងកេងកង១ ក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

តាមប្រភពព័ត៌មានបឋមបានឲ្យដឹងថា មុនកើត ហេតុមាននារីខ្មែរ២ នាក់ ជាជនរងគ្រោះបានទៅដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ ដោយចោទប្រកាន់ជនជាតិចិន១ ក្រុមនោះថា យកពួកនាងទៅថត និង ផលិតរឿងជាវីដេអូក្ដៅសាច់ បែបអាសអាភាស នៅក្នុងបន្ទប់ជាន់ទី៩ នៃអគារកើតហេតុខាងលើ។ ក្រោយពីទទួលបានព័ត៌មាននោះភ្លាម កម្លាំងសមត្ថកិច្ចនាយកដ្ឋាននគរបាលព្រហ្មទណ្ឌក្រសួងមហាផ្ទៃដឹកនាំផ្ទាល់ដោយលោកឧត្តមសេនីយ៍ឯក ង៉េង ជួ ប្រធាននាយកដ្ឋានក្រោមការចង្អុល បង្ហាញពីនាយឧត្តមសេនីយ៍ ស ថេត អគ្គស្នង ការ នគរបាលជាតិ និងមានការសម្របសម្រួលពីស្ថាប័នអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានដាក់កម្លាំងជាច្រើននាក់រួមមាន ឯកសណ្ឋានអាវក្រោះ និងកាំភ្លើងវែងខ្លីស្ទើរគ្រប់ដៃ បានចុះទៅឡោមព័ទ្ធទីតាំងអគារមួយកន្លែងនោះ ព្រមទាំងបានធ្វើការឃាត់ខ្លួនជនបរទេសប្រមាណជិត៩០នាក់ ដោយសង្ស័យជាប់ពាក់ព័ន្ធករណីថត និងផលិតរឿងវីដេអូ បែបអាសអាភាស។ បច្ចុប្បន្ន ក្រុមជនត្រូវចោទកំពុងស្ថិតក្នុងដំណាក់កាលចៅក្រមស៊ើបសួរនៅឡើយ៕

## មន្ត្រីសង្គមស៊ីវិលថា ករណីជនបរទេស ផលិតវីដេអូអាសអាភាសជាការរំលោភសិទ្ធិមនុស្ស និងធ្វើឱ្យអាប់ឱនមុខមាត់ជាតិធ្ងន់ធ្ងរ

https://www.rfa.org/khmer/news/human-rights/csos-say-the-case-of-foreigners-producing-pornographic-videos-is-a-violation-of-human-rights-and-a-serious-disgrace-to-the-nation-10272023103533.html ដោយ សេក បណ្ឌិត2023.10.27

មន្ត្រីសិទ្ធិមនុស្សលើកឡើងថា ជនបរទេសដែលយកស្ត្រីខ្មែរ និងស្ត្រីបរទេសផ្សេងទៀត ដើម្បីផលិតវីដេអូអាសអាភាសបានធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពស្ត្រីខ្មែរ និងធ្វើឱ្យអាប់ឱនដល់វប្បធម៌ជាតិធ្ងន់ធ្ងរ។ ពួកគាត់បារម្ភថា ករណីផលិតវីដេអូ (Video) អាសអាអាភាស ដោយជនបរទេសនេះនឹងបន្តកើតមាន ប្រសិនបើអាជ្ញាធរពុំមានការចុះបង្ក្រាបឱ្យបានខ្លាំងក្លាទេនោះ។

បទល្មើស ដែលប្រព្រឹត្តដោយជនបរទេសរស់នៅកម្ពុជា ជាពិសេសគឺជនជាតិចិន និងវៀតណាមបន្តកើតឡើងជារៀងរាល់ថ្ងៃ ធ្វើឱ្យពលរដ្ឋមានការបារម្ភ បើទោះជាមានការបង្ក្រាបជាហូរហែរបស់សមត្ថកិច្ចកម្ពុជាក្តី ប៉ុន្តែជនល្មើសទាំងនោះហាក់កាន់តែច្រើន។ ពួកគេមួយចំនួនហ៊ានប្រព្រឹត្តបទល្មើសគ្រប់បែបយ៉ាង ជាពិសេសពាក់ព័ន្ធករណីជួញដូរផ្លូវភេទ និងផលិតវីដេអូអាសអាភាសតាមទំនើងចិត្ត ដោយពុំខ្លាចញញើតចំពោះការបង្ក្រាបរបស់សមត្ថកិច្ច និងច្បាប់របស់កម្ពុជាឡើយ។

ប្រធានអង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា ច្រាក់ (CHRAC) លោក រស់ សុដ្ឋា ចាត់ទុកទង្វើក្រុមជនបរទេស ដែលផលិតខ្សែវីដេអូអាសអាភាសទាំងនោះថា ធ្វើឱ្យប៉ះពាល់កិត្តិយសជាតិធ្ងន់ធ្ងរ។ លោកថា កម្ពុជាជាប្រទេសមានវប្បធម៌ទំនៀមទម្លាប់ប្រពៃណីល្អ និងមិនគួរក្លាយជាទីកន្លែងសម្រាប់ក្រុមជនជាតិចិន និងវៀតណាមមកធ្វើអាជីវកម្មខុសច្បាប់នាំស្ត្រីខ្មែរផលិតរឿងដែលនាំឱ្យមានភាពអាម៉ាស់ដល់សង្គមឡើយ។

លោក រស់ សុដ្ឋា៖ «កម្ពុជាគឺជាប្រទេស ដែលមានអរិយធម៌ រក្សានូវសេចក្តីសុខផ្លូវចិត្តភាពស្ងប់ស្ងាត់ ពោលគឺមិនឱ្យមានចិត្តពុះកញ្ជ្រោលទៅលើលោភៈ ទោសៈ មោហៈ និយាយឱ្យចំតណ្ហាផ្លូវភេទនេះឯង។ ការថតវីដេអូសិច (Sex) នេះអាចជំរុញមនុស្សឱ្យមានចំណង់ជ្រុលទៅលើផ្លូវភេទ ហើយអាចថា មានចិត្តទៅលើការប្រព្រឹត្តនូវអំពើខុសឆ្គងផ្នែកផ្លូវភេទ ដូចជាការរំលោភកូន ប្រពន្ធគេអ្នកដទៃ ដែលមិនមានការព្រមព្រៀង ជាការរំលោភផ្នែកសីលធម៌ខ្មែរ ក៏ដូចជាច្បាប់ជាតិផងដែរ។ ខ្ញុំជឿជាក់ថា ឥស្លាមសាសនា ឬក៏គ្រិស្តសាសនា ក៏គេមិនគាំទ្រដែរនូវអំពើថតវីដេអូដែលជាសកម្មភាពមួយក្នុងការលើកកម្ពស់ចំណង់ផ្លូវភេទនេះ»។

ប្រតិកម្មរបស់មន្ត្រីសង្គមស៊ីវិលបែបនេះ ធ្វើឡើងបន្ទាប់ពីសមត្ថកិច្ចរាជធានីភ្នំពេញកាលពីយប់ថ្ងៃទី២៤ ខែតុលា បានចុះបង្ក្រាបជនសង្ស័យជាង ៣០នាក់ ក្នុងនោះរួមមានជនជាតិចិន វៀតណាម និងស្ត្រីខ្មែរផង ដែលសមត្ថកិច្ចចោទថា ពួកគេលួចផលិតខ្សែវីដេអូអាសអាភាសនៅអគារខុនដូរ (Condo) មួយស្ថិតនៅខណ្ឌបឹងកេងកង។

វិទ្យុអាស៊ីសេរីមិនទាន់អាចទាក់ទងអ្នកនាំពាក្យអគ្គស្នងការដ្ឋាន នគរបាលជាតិលោក ឆាយ គីមខឿន និងអ្នកនាំពាក្យក្រសួងមហាផ្ទៃលោក ខៀវ សុភ័គ ដើម្បីបញ្ជាក់បន្ថែមជុំវិញរឿងនេះបានទេ នៅថ្ងៃទី២៦ ខែតុលា។ ប៉ុន្តែ លោក ឆាយ គីមខឿន បញ្ជាក់ប្រាប់កាសែតក្នុងស្រុក កាលពីថ្ងៃទី២៥ ខែតុលាថា សមត្ថកិច្ចកំពុងសាកសួរជនសង្ស័យ ប្រសិនបើរកឃើញថា ពួកគេមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសសមត្ថកិច្ចនឹងបញ្ជូនពួកគេទៅតុលាការ។

ខ្សែវីដេអូអាសអាភាសនោះមានជនជាតិចិន ស្ត្រីជនជាតិចិន និងខ្មែរ គឺពួកគេប្រើប្រាស់ភាសាជាតិរៀងខ្លួន ដើម្បីសម្តែង និងធ្វើសកម្មភាពស្រើបស្រាល។ ក្រោយការបែកធ្លាយវីដេអូ

អាសអាភាសនោះ យុវជនខ្មែរមួយចំនួនដែលនិយមប្រើប្រាស់បណ្ដាញសង្គម ដោយអ្នកខ្លះចូលបញ្ចេញមតិរិះគន់ និងអ្នកខ្លះទៀតបញ្ចេញមតិបែបបញ្ចើចបញ្ចើ និងចែករំលែកយ៉ាងផុលផុស។

មន្ត្រីសង្គមស៊ីវិល សង្កេតឃើញថា សីលធម៌សង្គមខ្មែរកំពុងធ្លាក់ចុះជាបន្តបន្ទាប់ ខណៈយុវជនខ្មែរជាច្រើនបានទទួលរងឥទ្ធិពលពីខ្សែវីដេអូអាសអាភាសដែលផ្សព្វផ្សាយលើបណ្ដាញសង្គម ខណៈសមត្ថកិច្ចមិនទាន់ចាត់វិធានការទប់ស្កាត់ឱ្យមានប្រសិទ្ធភាពឡើយ។ មន្ត្រីសិទ្ធិមនុស្សអំពាវនាវយុវជនខ្មែរគ្រប់ស្រទាប់វណ្ណៈថា គួរចំណាយពេលសម្រាប់សិក្សាពីសង្គមជាតិដែលកំពុងជួបបញ្ហា និងពុំគួរបន្តចែករំលែកវីដេអូអាសអាភាសលើបណ្ដាញសង្គមនោះទេ ព្រោះវាគ្មានចំណេញអ្វីក្រៅពីនាំភាពអាម៉ាស់ដល់សង្គមជាតិឡើយ។

ទាក់ទងនឹងរឿងនេះដែរ កាលពីខែសីហា កន្លងទៅក៏មានស្ត្រីខ្មែរម្នាក់បានបង្ហោះវីដេអូតាមបណ្ដាញសង្គមដោយអះអាងថា សណ្ឋាគារមួយកន្លែងឈ្មោះ ហ្វឹងហ្សូវ ស្ថិតនៅខេត្តព្រះសីហនុ មានក្រុមជនជាតិចិនប្រើប្រាស់គ្រឿងញៀន និងល្បួងនារីខ្មែរ ដើម្បីថតអាក្រាតកាយ ដើម្បីផលិតខ្សែវីដេអូអាសអាភាសធ្វើអាជីវកម្ម។ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ១៩ ចែងថា ជនណាជួញដូរអ្នកដទៃក្នុងគោលដៅស្វែងរកប្រយោជន៍ បំពានផ្លូវភេទ និងផលិតរូបភាពអាសអាភាស ជាដើម អាចប្រឈមត្រូវផ្តន្ទាទោសរយៈពេល ២០ឆ្នាំ។

ប្រធានអង្គការសម្ពន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា លោក រស់ សុដ្ឋា ស្នើដល់អាជ្ញាធរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ជនបរទេសដែលជួញដូរមនុស្ស ជាពិសេសស្ត្រីខ្មែរក្នុងទម្រង់ផ្សេងៗយកទៅផលិតរូបភាពអាសអាភាស ដែលធ្វើឱ្យប៉ះពាល់កិត្តិយសជាតិ និងនាំឱ្យសីលធម៌សង្គមធ្លាក់ចុះ៕

## ហ្វីលីពីនឃុំខ្លួនមនុស្សជិត ៦០០ នាក់
## ចម្រុះជាតិសាសន៍ក្នុងប្រតិបត្តិការបង្ក្រាបការជួញដូរមនុស្ស

https://www.postkhmer.com/national/2023-10-30-1051-255578.html ហួន ឌីណា | Publication date 29 October 2023 | 10:55 ICT

អាជ្ញាធរហ្វីលីពីន បាននិយាយកាលពីថ្ងៃសៅរ៍ ទី ២៨ ខែតុលាថា ប៉ូលិសហ្វីលីពីនបានឃុំខ្លួនមនុស្សជិត ៦០០ នាក់ ក្នុងប្រតិបត្តិការឆ្មក់ចូលទីតាំងសង្ស័យ ក្រោមប្រតិបត្តិការជួញដូរមនុស្ស និងឆបោកតាមអ៊ិនធឺណិតនៅទីក្រុងម៉ានីល។ នេះបើតាមការចុះផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មាន AFP។

គណៈកម្មាធិការប្រឆាំងឧក្រិដ្ឋកម្ម (PAOCC) របស់ហ្វីលីពីន បាននិយាយក្នុងសេចក្តីថ្លែងការណ៍មួយថា ជនជាតិចិន កូរ៉េ វៀតណាម និងហ្វីលីពីន ស្ថិតក្នុងចំណោមមនុស្ស ដែលក្រុម

ប៉ូលិសរកឃើញនៅខាងក្នុងបរិវេណអំឡុងពេលប្រតិបត្តិការឆ្មក់ចូលកាលពីយប់ថ្ងៃសុក្រ។ លេខាធិការក្រសួងយុត្តិធម៌ លោក Crispin Remulla បានប្រាប់អ្នកយកព័ត៌មានថា អាជ្ញាធរកំពុងសម្ភាសអ្នកជាប់ឃុំចំនួន ៥៩៨ នាក់ ដើម្បីកំណត់ថា អ្នកណាជាជនរងគ្រោះ ឬអ្នកណាជាជនសង្ស័យ។

បើតាមការចុះផ្សាយរបស់ AFP ស្ថានទូតចិនទទួលបា នការស្នើសុំឱ្យជួយកំណត់អត្តសញ្ញាណមនុស្ស ៩ នាក់ ដែលសង្ស័យថា បានដំណើរការអាជីវកម្មពាក់ព័ន្ធ ដែលទទួលបានអាជ្ញាបណ្ណថាជាក្រុមហ៊ុនហ្គេមអ៊ីនធឺណិត។ ការបង្រ្កាបរបស់ប៉ូលិសហ្វីលីពីននានេះ ធ្វើឡើងចំពេលមានកំណើន នៃការព្រួយបារម្ភជាអន្តរជាតិជុំវិញការបោកប្រាស់តាមអ៊ិនធឺណិតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលជារឿយៗប្រើជនរងគ្រោះនៃការជួញដូរមនុស្សដោយបង្ខំឱ្យធ្វើការបោកបញ្ឆោត ឬផ្សព្វផ្សាយការវិនិយោគគ្រីបតូក្លែងក្លាយ។ លោក Remullaបាននិយាយថា អាជ្ញាធរហ្វីលីពីន កំពុងដាក់ពាក្យសុំដីកា ដើម្បីចូលឆែកកុំព្យូទ័រដែលបានរកឃើញនៅខាងក្នុងបរិវេណបង្រ្កាប។

ចំណែកឯ PAOCC វិញ បាននិយាយថា ក្នុងអំឡុងនៃការវាយឆ្មក់នោះ ជនជាតិចិន២នាក់បាននិយាយថា ពួកគេត្រូវបានគេឃុំខ្លួន ហើយមានស្នាមគេធ្វើទារុណកម្មលើដងខ្លួនរបស់ពួកគេ។ បុរសម្នាក់ក្នុងចំណោមនោះ អះអាងថា គេចាប់ជំរិត ហើយលក់លោកក្នុងតម្លៃ ៨ ៨០០ ដុល្លារអាមេរិក ខណៈម្នាក់ទៀតបាននិយាយថាលោកជាប់ឃុំអស់រយៈពេល១ឆ្នាំ ហើយបង្ខំឱ្យធ្វើការរហូតដល់ ១៥ ម៉ោងក្នុងមួយថ្ងៃ។

កាលពីខែមិថុនាកន្លងទៅ មនុស្សជាង ២៧០០ នាក់ ត្រូវបានប៉ូលិសចាប់ឃុំខ្លួនអំឡុងពេលវាយឆ្មក់លើអគារជាច្រើនកន្លែងក្នុងទីក្រុងម៉ានីល ជាកន្លែងដែលជនរងគ្រោះនៃការជួញដូរមនុស្សត្រូវបានគេបង្ខំធ្វើការរកលុយ ដោយស្វែងរកអ្នកលេងហ្គេមតាមអ៊ិនធឺណិត៕